ឯកសារបណ្តុះបណ្តាល

# លើកកម្ពស់សមធម៌នៅសហគមន៍មូលដ្ឋាន ក្នុងបរិបទវិស័យព្រៃឈើ និងការប្រែប្រួលអាកាសធាតុ




USAID FROM THE AMERICAN PEOPLE

Norad

RECOFTC THE CENTER FOR PEOPLE AND FORESTS

ឯកសារបណ្តុះបណ្តាលៈ លើកកម្ពស់សមធម៌នៅសហគមន៍មូលដ្ឋានក្នុងបរិបទវិស័យព្រៃឈើ និងការប្រែប្រួលអាកាសធាតុ

រក្សាសិទ្ធិ © RECOFTC – មជ្ឈមណ្ឌលសម្រាប់មនុស្ស និងព្រៃឈើ

ការផលិតឯកសារនេះឡើងវិញ សម្រាប់អប់រំ ឬ សម្រាប់គោលបំណងដទៃទៀតក្រៅពីការធ្វើពាណិជ្ជកម្ម អាចធ្វើទៅបានដោយពុំចាំបាច់សុំការអនុញ្ញាតជាលាយលក្ខអក្សរជាមុនពីម្ចាស់រក្សាសិទ្ធិឡើយ ក្នុងករណីដែលមានការធ្វើសេចក្តីយោងពេញលេញ។ ហាមឃាត់ការផលិតឡើងវិញសម្រាប់លក់ ឬ គោលបំណងពាណិជ្ជកម្មដទៃទៀត ដោយគ្មានការអនុញ្ញាតជាលាយលក្ខអក្សរជាមុនពីម្ចាស់រក្សាសិទ្ធិ។។

ISBN: 978-616-91154-7-2

ទស្សនៈនានាដែលរំលេចនៅក្នុងឯកសារនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ និងពុំមែនសុទ្ធតែឆ្លុះបញ្ចាំងពីទស្សនៈរបស់ RECOFTC ទីភ្នាក់ងារន័រវេសសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងទីភ្នាក់ងារសហរដ្ឋអាមេរិក សម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) នោះឡើយ។

អ្នកនិពន្ធៈ Karen Edwards, Ronnakorn Triraganon, Rejani Kunjappan

សម្រង់អត្ថបទៈ

RECOFTC. 2014. ឯកសារបណ្តុះបណ្តាលៈ លើកកម្ពស់សមធម៌នៅសហគមន៍មូលដ្ឋានក្នុងបរិបទវិស័យព្រៃឈើ និង ការប្រែប្រួលអាកាសធាតុ ក្រុងបាងកក RECOFTC – មជ្ឈមណ្ឌលសម្រាប់មនុស្ស និងព្រៃឈើ។

ឯកសារបណ្តុះបណ្តាល

# លើកកម្ពស់សមធម៌នៅសហគមន៍មូលដ្ឋាន ក្នុងបរិបទវិស័យព្រៃឈើ និងការប្រែប្រួលអាកាសធាតុ

RECOFTC – មជ្ឈមណ្ឌលសម្រាប់មនុស្ស និងព្រៃឈើ
បាងកក ឆ្នាំ 2014

USAID FROM THE AMERICAN PEOPLE

Norad

RECOFTC THE CENTER FOR PEOPLE AND FORESTS

# មាតិកា


បុព្វកថា ៥

សេចក្តីថ្លែងអំណរគុណ ៧

តារាងពាក្យបំព្រួញ ៩

សេចក្តីផ្តើម 10

**ក្រុមមេរៀនទី ១**
**គោលការណ៍គ្រឹះនៃសមធម៌ និងការចូលរួមក្នុងបរិបទព្រៃឈើ និងការប្រែប្រួលអាកាសធាតុ ២៥**

ក. របកគំហើញដោយខ្លួនឯងតាមរយៈការគិតដែលផ្អែកលើសម្បត្តិ (ភាពវិជ្ជមាន) ២៦

ខ. ការបង្ហាញជូនអំពីវគ្គបណ្តុះបណ្តាល ៣៧

គ. តើសមធម៌ជាអ្វី? ៤៣

ឃ. អ្នកណាពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន? ៥៧

ង. ហេតុអ្វីសមធម៌ជារឿងសំខាន់ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលផ្អែកលើព្រៃឈើ រួមទាំង REDD+ ៦៤

ច. ផ្សារភ្ជាប់ការចូលរួមនិងសមធម៌ ៧៧

ឆ. តថភាពនៃការប្រើប្រាស់ក្របខ័ណ្ឌសមធម៌ ៨៥

**ក្រុមមេរៀនទី ២**
**តួនាទី និងជំនាញរបស់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន ដើម្បីលើកកម្ពស់សមធម៌នៅថ្នាក់មូលដ្ឋាន ៩៦**

ក. ការពង្រឹងជំនាញរបស់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានជួយលើកកម្ពស់សមធម៌នៅសហគមន៍មូលដ្ឋាន ៩៧

ខ. តួនាទីរបស់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានសម្រាប់លើកកម្ពស់សមធម៌នៅសហគមន៍មូលដ្ឋាន ១០២

គ. អនុវត្តជំនាញចោទសួរ ១០៧

ឃ. ការនិទានរឿង ១១៦

ង. អនុវត្តជំនាញបង្កើតរូបភាព ១២៥

ច. អនុវត្តជំនាញពន្យល់ ១៣៥

ឆ. ការបង្កើតជំនាញដឹកនាំ-យេនឌ័រ ១៤៤

# មាតិកា

**ក្រុមមេរៀនទី ៣**
**ការរៀបចំនិងតាមដានដំណើរការចូលរួមដោយប្រសិទ្ធភាព នៅថ្នាក់មូលដ្ឋាន ដើម្បីលើកកម្ពស់សមធម៌** **១៤៨**

ក. តើពាក់ព័ន្ធដោយប្រសិទ្ធភាពគឺជាអ្វី? ១៤៩
ខ. ការពន្យល់អំពីសមធម៌ និងការពាក់ព័ន្ធ ១៥៩
គ. អំណាច និងការពាក់ព័ន្ធ ១៦៣
ឃ. ការបើកចំហប្រអប់ឧបករណ៍សម្រាប់បង្កើតការពាក់ព័ន្ធ ១៧៦
ង. ការរៀបចំដំណើរការនៃការពាក់ព័ន្ធមួយឱ្យមានប្រសិទ្ធភាព ១៧៩
ច. ការតាមដានសមធម៌បែបនីតិវិធី ១៩៦

**ក្រុមមេរៀនទី ៤**
**ពង្រឹងការរៀនសូត្រនៅក្នុងវគ្គបណ្តុះបណ្តាលរបស់អ្នក** (ជម្រើស) **២០០**

ក. សមធម៌ ធៀបនឹងសមភាព (រំលឹកឡើងវិញអំពីការរៀនសូត្រ) ២០១
ខ. តើអ្នកសម្របសម្រួលថ្នាក់មូលដ្ឋានអាចដោះស្រាយសមធម៌ដោយរបៀបណា? (ការរំលឹកឡើងវិញអំពីការរៀនសូត្រ) ២០៤
គ. តើអ្នកឃើញ មានអារម្មណ៍ ឮ និងរៀនសូត្រអ្វីខ្លះសម្រាប់លើកកម្ពស់សមធម៌? ២០៧
ឃ. ការជំរុញឱ្យមានភាពច្នៃប្រឌិត និងកែសម្រួលរចនាបថនៃដំណើរការ ២១០

**ឧបសម្ព័ន្ធ ១៖ សេណារីយ៉ូនៃការរៀបចំវគ្គបណ្តុះបណ្តាលទៅតាមមេរៀន** **២១៣**
**ឧបសម្ព័ន្ធ ២៖ ឯកសារយោង និងឯកសារអំណានបន្ថែម** **២១៧**

# បុព្វកថា

សារៈសំខាន់នៃការគ្រប់គ្រងព្រៃឈើ សម្រាប់ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ បានការទទួលស្គាល់កាន់តែច្រើនឡើងជាបន្តបន្ទាប់នៅក្នុងទសវត្សរ៍កន្លងទៅនេះ និងបានឈានចូលក្នុងសម័យកាលមួយនៃវេទិកានយោបាយ និងសន្និសីទជាច្រើន ដែលរួមទាំងអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (United Nations Framework Convention on Climate Change - UNFCCC) ជាពិសេស តាមរយៈការបង្កើតយន្តការការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងការរេចរឹលព្រៃឈើ (រេដបូក) (Reducing Emissions from Deforestation and Forest Degradation-REDD+) ។ ជាលទ្ធផល កិច្ចការនានាដែលទាក់ទងនឹងការរួមបញ្ចូល (ឬការមិនបានរួមបញ្ចូល) សហគមន៍ព្រៃឈើ នៅក្នុងរចនាបថ និងការអនុវត្តយន្តការទាំងនេះក៏បានលេចឡើងយ៉ាងឆាប់រហ័សផងដែរ។ ដើម្បីទទួលបានសមធម៌ និងនវានុវត្តភាព រាល់គម្រោងប្រែប្រួលអាកាសធាតុទាក់ទងទៅនឹងវិស័យព្រៃឈើត្រូវផ្តោតការយកចិត្តទុកដាក់លើអភិបាលកិច្ចល្អ កម្មសិទ្ធ ច្បាស់លាស់ ការទទួលសិទ្ធិប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ប្រកបដោយយុត្តិធម៌។

បច្ចុប្បន្ននេះ "សមធម៌" បានក្លាយជាប្រធានបទនៃកង្វល់កាន់តែច្រើនឡើង នៅក្នុងការជជែកវែកញែកជាអន្តរជាតិ អំពីការកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលផ្អែកលើព្រៃឈើ។ ទោះជាយ៉ាងណាក៏ដោយ ចំពោះអ្នកពាក់ព័ន្ធភាគច្រើន គោលគំនិតអំពី "សមធម៌" នៅតែប្រឈមនឹងការលំបាកក្នុងការបង្ហាញឱ្យឃើញ និងដាក់ឱ្យអនុវត្ត ដោយនៅពុំទាន់និយាយដល់ការកែលម្អ និងជានាសុវត្ថិភាពនៅឡើយផង។ ហានិភ័យជាប្រចាំនៃការធ្វើឱ្យសហគមន៍ព្រៃឈើធ្លាក់ក្នុងស្ថានភាពទន់ខ្សោយ នៅក្នុងការរៀបចំផែនការ និងការអនុវត្តគោលនយោបាយ និងប្រតិបត្តិការនានា ដែលទាក់ទងនឹងព្រៃឈើ និងការប្រែប្រួលអាកាសធាតុ គឺជាសភាពដែលកើតមានជាក់ស្តែង។ ហានិភ័យនេះ កាន់តែធ្ងន់ធ្ងរថែមទៀត ដោយសារតែអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានអាចនៅពុំទាន់មានជំនាញច្បាស់លាស់ និងឱកាសដើម្បីបញ្ចេញទស្សនៈ និងកង្វល់របស់ខ្លួនដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងសាធារណជននៅឡើយ។ ការពិនិត្យមួយដែលផ្តោតលើការលើកកម្ពស់គោលគំនិត និងគោលការណ៍នៃ "សមធម៌នៅសហគមន៍មូលដ្ឋាន" នៅក្នុងកិច្ចផ្តួចផ្តើមប្រែប្រួលអាកាសធាតុ ដែលផ្អែកលើព្រៃឈើ ដែលរួមទាំង REDD+ មានការពាក់ព័ន្ធ និងជាប្រការចាំបាច់។

ភាគច្រើននៃឯកសារបណ្តុះបណ្តាលផ្សេងៗនាពេលបច្ចុប្បន្នដែលទាក់ទងនឹង REDD+ ផ្តោតលើទ្រឹស្តីនៃគោលគំនិតនៅជុំវិញព្រៃឈើ ការប្រែប្រួលអាកាសធាតុ និង REDD+ និងនៅក្នុងករណីខ្លះឯកសារទាំងនោះបានទទួលជោគជ័យ ក្នុងការធ្វើឱ្យងាយស្រួលយល់នូវគោលគំនិតទាំងនេះសម្រាប់អ្នកពាក់ព័ន្ធនានានៅថ្នាក់មូលដ្ឋាន និងសហគមន៍ព្រៃឈើ។ ទោះជាយ៉ាងណាក៏ដោយ គេនៅពុំទាន់មានភាពច្បាស់លាស់នៅឡើយទេថា តើសម្ភារៈទាំងនោះមានឥទ្ធិពលបែបណាមកលើឱកាសដែលមានសម្រាប់ប្រជាជននៅមូលដ្ឋាន ដើម្បីសំដែងយោបល់ គំនិត និងកង្វល់របស់ពួកគាត់ឡើយ។

RECOFTC - មជ្ឈមណ្ឌលសម្រាប់មនុស្ស និងព្រៃឈើ បានរៀបរៀងឯកសារបណ្តុះបណ្តាលនេះឡើងសម្រាប់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន សំដៅបង្កើនការយល់ដឹងរបស់ពួកគាត់អំពី ដំណើរការ និងទិដ្ឋភាពខុសៗគ្នានៅក្នុងវិស័យព្រៃឈើនិងការប្រែប្រួលអាកាសធាតុព្រមទាំងបង្កើនជំនាញជាក់លាក់សំដៅប្រែក្លាយការរៀនសូត្រទៅជាការអនុវត្តជាក់ស្តែង។ តាមរយៈកំណើនសមត្ថភាព ភ្នាក់ងារទាំងនេះនឹងអាចសម្រួលឱ្យមានការពិភាក្សានៅថ្នាក់មូលដ្ឋាន ដែលអាចបញ្ចេញយោបល់ និងជំហរដ៏មានតម្លៃអំពីសមធម៌នៅក្នុងវិស័យព្រៃឈើ និងការប្រែប្រួលអាកាសធាតុ ដែលបន្ទាប់មកអាចបញ្ជូនទៅអ្នកធ្វើសេចក្តីសម្រេចពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធដទៃទៀត។

ឯកសារបណ្តុះបណ្តាលនេះ ដែលមានចំណងជើងថា លើកកម្ពស់សមធម៌នៅសហគមន៍មូលដ្ឋានក្នុងបរិបទវិស័យព្រៃឈើ និងការប្រែប្រួលអាកាសធាតុ ត្រូវបានរៀបរៀងឡើងដោយមានការគាំទ្រពីគម្រោងចំនួនពីរនៅថ្នាក់តំបន់៖ កម្មវិធី "សមធម៌ និងការពង្រឹងបណ្តាញនៅថ្នាក់មូលដ្ឋានក្នុងតំបន់ទន្លេមេគង្គ (GREEN Mekong) ដែលទទួលមូលនិធិពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (United Stated Agencies for International Development-USAID) និងគម្រោង "ការកសាងសមត្ថភាពនៅថ្នាក់មូលដ្ឋានសម្រាប់ REDD+ នៅអាស៊ី" ដែលទទួលមូលនិធិពី ទីភ្នាក់ងារន័រវេសសម្រាប់សហប្រត្តិការអភិវឌ្ឍន៍ (Norwagian Agency for Development Cooperation-NORAD)។

ខ្ញុំរំពឹងថា ឯកសារបណ្តុះបណ្តាលនេះនឹងបំពេញភាពខ្វះខាត ដោយឆ្លើយតបនឹងតម្រូវការកសាងសមត្ថភាពរបស់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន តាមរយៈការលើកកម្ពស់ចំណេះដឹង និងជំនាញរបស់ពួកគាត់ អំពីរបៀបបង្កើត និងសម្របសម្រួលដំណើរការធ្វើឱ្យមានការចូលរួមប្រកបដោយអត្ថន័យ និងបរិយាប័ន្ន ដែលពាក់ព័ន្ធនឹងប្រជាជននៅក្នុងមូលដ្ឋាន។ ក្រៅពីពន្យល់អំពីគោលគំនិតគោលការណ៍នានានៃសមធម៌ និងការបង្ហាញជូនអំពីជាតុផ្សំសំខាន់ៗ ឯកសារបណ្តុះបណ្តាលនេះក៏លើកស្នើឧបករណ៍ជាក់ស្តែង និងវិធីសាស្ត្រនានាសម្រាប់លើកកម្ពស់ និងកែលម្អវេទិកានៃការចូលរួមរបស់អ្នកពាក់ព័ន្ធនានាផងដែរ ដែលរួមទាំងអ្នកមូលដ្ឋាន។ ឧបករណ៍ និងវិធីទាំងនេះ ក៏នឹងជួយអ្នកសម្របសម្រួលដើម្បីប្រមូលយកទស្សនៈ និងកង្វល់នានារបស់អ្នកពាក់ព័ន្ធនៅមូលដ្ឋាន ដែលទាក់ទងនឹងវិស័យព្រៃឈើ និងការប្រែប្រួលអាកាសធាតុ និងការប្រាស្រ័យទាក់ទងទស្សនៈ និងកង្វល់ទាំងនេះជាមួយអ្នកកសាងគោលនយោបាយ និងអ្នកអនុវត្តគម្រោងផងដែរ។

ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះស្ម័គ្រចំពោះអ្នកនិពន្ធ និងអ្នកដែលបានរួមចំណែកក្នុងការរៀបរៀងឯកសារបណ្តុះបណ្តាលដ៏មានសារៈសំខាន់នេះប្រកបដោយជោគជ័យ។

បណ្ឌិត **Tint Lwin Thaung**
នាយកប្រតិបត្តិ
RECOFTC- មជ្ឈមណ្ឌលសម្រាប់មនុស្ស និងព្រៃឈើ

# សេចក្តីថ្លែងអំណរគុណ

ឯកសារបណ្តុះបណ្តាលនេះត្រូវបានរៀបរៀងឡើងតាមរយៈការប្រមូលគំនិតពីប្រភព និងឯកសារយោងខុសៗគ្នាពីផ្នែកជាច្រើន គេហទំព័រ ប្លក់ឯកទេស និងបទពិសោធន៍ផ្ទាល់ខ្លួន។

ក្របខ័ណ្ឌសម្រាប់ការស្វែងយល់ពីទិដ្ឋភាពនានានៃសមធម៌ និងយុត្តិធម៌សង្គម នៅក្នុងវិស័យព្រៃឈើ ដែលជាមូលដ្ឋានគ្រឹះនៃឯកសារបណ្តុះបណ្តាលនេះ ត្រូវបានស្រង់ចេញពី Defining equity: a framework for evaluating equity in the context of ecosystem services ដោយ Melanie McDermott, Sango Mahanty និង Kate Schreckenberg។ លក្ខណៈងាយៗនៃក្របខ័ណ្ឌទាំងនោះសម្រាប់ការប្រើប្រាស់គោលគំនិតសាំញ៉ាំនៅក្នុងបរិបទខុសៗគ្នា មានភាពសមស្របបំផុត សម្រាប់សម្ភារៈបណ្តុះបណ្តាល និងការរៀនសូត្រ ដែលស្វែងយល់អំពីស្ថានភាពខុសៗគ្នា ទន្ទឹមនឹងជំរុញឱ្យមានការគិតគូរស៊ីជម្រៅអំពីសមធម៌។ ក្នុងឯកសារនេះ អ្នកនិពន្ធបានពិនិត្យមើលប៉ារ៉ាម៉ែត្រចំនួនបួននៃសមធម៌ដែលគួរតែពិចារណានៅក្នុងការរៀបចំផែនការវាយតម្លៃគោលនយោបាយ កម្មវិធី ឬ គម្រោង៖ i) គោលបំណងដែលទាក់ទងនឹងសមធម៌ ii) គោលដៅ និងតុល្យភាពនៃសមធម៌ iii) ខ្លឹមសារនៃសមធម៌ (ការបែងចែក នីតិវិធី និងបរិបទនៃសមធម៌) និង iv) ដំណើរការនៃការកំណត់ប៉ារ៉ាម៉ែត្រទាំងនេះ។ ប៉ារ៉ាម៉ែត្រទាំងបួននេះគាំទ្រដល់មេរៀនជាច្រើនស្តីពីសមធម៌ ដែលមានក្នុងឯកសារនេះ។

គោលគំនិតអំពីការរៀនសូត្រថ្មីៗ និងការសម្របសម្រួល ព្រមទាំងឧបករណ៍នានាសម្រាប់ការចូលរួម ដែលមានបង្ហាញនៅក្នុងឯកសារណែនាំនេះ បានមកពីប្រភពខុសៗគ្នាជាច្រើន ដែលរួមទាំង Gamestorming: a Playbook for Innovators, Rulebreakers and Changemakers ដោយ Dave Gray, Sunni Brown និង James Macanufo និង Change the Way You See Everything through Asset Based Thinking ដោយ Kathryn D. Cramer និង Hank Wasiak។ The Power of Appreciative Inquiry ដោយ Diana Whitney និង Amanda Trosten-Bioom ក៏បានពិចារណាផងដែរ នៅក្នុងការរៀបចំមេរៀនមួយចំនួន និងរបៀបប្រើប្រាស់ពាក្យនៅក្នុងឯកសារនេះ។ ទិដ្ឋភាពថ្មីៗនៃការសម្របសម្រួល និងការចូលរួមដែលណែនាំនៅក្នុងឯកសារនេះបានទទួលការលើកទឹកចិត្តតាមរយៈការសម្របសម្រួល និងការច្នៃប្រឌិតនៃប្រតិបត្តិករអន្តរជាតិ ដែលបានងាកចេញពីការចូលរួមតាមបែបធម្មតាមករកគំរូនៃកិច្ចសហការបែបច្នៃប្រឌិត ជាពិសេសពាក់ព័ន្ធសម្រាប់ការប្រើប្រាស់នៅថ្នាក់មូលដ្ឋាន។

ក្រុមការងារ RECOFTC - មជ្ឈមណ្ឌលសម្រាប់មនុស្ស និងព្រៃឈើ សូមថ្លែងអំណរគុណជាទីបំផុតចំពោះ Karen Edwards ដែលបានផ្តល់គោលគំនិត និងចូលរួមនិពន្ធឯកសារនេះ។ សូមថ្លែងអំណរគុណជាពិសេស ចំពោះប្រតិបត្តិករខាងការបង្កើតគំនិត តាមរយៈរូបភាពមកពីប្រទេសឥណ្ឌូនេស៊ីជាអាទិ៍ Bjeou Nayaka និង Deni Rodendo ដែលបានផ្តល់គំនិតល្អៗសម្រាប់មេរៀននានាស្តីពីការនិទានរឿង និងការបង្កើតរូបភាព នៅក្នុងវគ្គបណ្តុះបណ្តាលសហការគ្នាមួយ រវាង RECOFTC និងទីភ្នាក់ងារដទៃទៀត។

ក្រុមការងារក៏សូមថ្លែងអំណរគុណផងដែរ ចំពោះសិក្ខាកាមនៅក្នុងវគ្គបណ្តុះបណ្តាលដោយ RECOFTC មកពីតំបន់អាស៊ីអាគ្នេយ៍ ដែលបានផ្តល់យោបល់អំពីដំណើរការបណ្តុះបណ្តាលនៅក្នុងអំឡុងពេលសាកល្បងកំណែមុនៗនៃឯកសារនេះ។ យើងសូមថ្លែងអំណរគុណចំពោះ Ronnakorn Triraganon, Rejani Kunjappan និង Bishnu Poudyal គ្រូបង្គោត់មកពី RECOFTC ដែលបានចូលរួមក្នុងការផ្តល់វគ្គបណ្តុះបណ្តាលសាកល្បងយ៉ាងហោចណាស់ចំនួនពីរ លើកដោយប្រើប្រាស់ឯកសារនេះ ព្រមទាំងបានផ្តល់គំនិតជារួម និងប្រាជ្ញាស្មារតី យោបល់ប្រកបដោយការស្តាបនា និងភាពអំណត់នៅក្នុងពេលរៀបរៀងឯកសារនេះ។ លើសពីនេះទៀត ក្រុមការងារសូមថ្លែងអំណរគុណចំពោះ Chandra Silori និង Etienne Delattre ក៏ដូចជា បុគ្គលិកផ្នែកទំនាក់ទំនងនៃ RECOFTC ជាពិសេស Ann Jyothis ដែលបានផ្តល់ការគាំទ្រជារួមនៅក្នុងការផលិតឯកសារនេះ។

នៅទីបញ្ចប់ក្រុមការងារRECOFTC សូមថ្លែងអំណរគុណចំពោះទីភ្នាក់ងារន័រវេសសម្រាប់សហប្រត្តិការអភិវឌ្ឍន៍ និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ ដែលបានផ្តល់ការគាំទ្រហិរញ្ញវត្ថុសម្រាប់ការរៀបរៀងឯកសារនេះ។

**ក្រុមការងារ RECOFTC**
បាងកក ឆ្នាំ ២០១៤

# តារាងពាក្យបំព្រួញ

| | | |
|---|---|---|
| **ABT** | Asset Based Thinking | ការគិតដែលផ្អែកលើសម្បត្តិ( ភាពវិជ្ជមាន ) |
| **CFMC** | Community Forestry Management Committee | គណៈកម្មាធិការគ្រប់គ្រងសហគមន៍ព្រៃឈើ |
| **CONAFOR** | National Forest Commission | គណៈកម្មការព្រៃឈើជាតិ |
| **FEICOM CAMEROUN** | The Special Support Fund for Mutual Assistance | មូលនិធិគាំទ្រពិសេសសម្រាប់ជួយគ្នាទៅវិញទៅមក |
| **LIDAR** | Light detection and ranging | ឧបករណ៍វាស់ពន្លឺ និងវង្វាស់ចម្ងាយ |
| **MRV SYSTEM** | Monitoring, Reporting and Verification system | ប្រព័ន្ធតាមដាន រាយការណ៍ និងការផ្ទៀងផ្ទាត់ |
| **NFA** | National  Forestry Authority | អាជ្ញាធរព្រៃឈើជាតិ |
| **NGO** | Non-Governmental Organization | អង្គការមិនមែនរដ្ឋាភិបាល |
| **NORAD** | Norwegian Agency for Development Cooperation | ទីភ្នាក់ងារន័រវេសសម្រាប់សហប្រត្តិការអភិវឌ្ឍន៍ |
| **PES** | Payment for Environmental | ការបង់ថ្លៃសម្រាប់សេវាកម្មបរិស្ថាន |
| **PSAH** | National Programme for Hydro-logical  Environmental Services | កម្មវិធីជាតិសម្រាប់សេវាកម្មបរិស្ថានជលសាស្ត្រ |
| **REDD** | Reduced Emissions from Deforestation and Degradation | កាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងការរេចរឹលព្រៃឈើ |
| **REDD +** | Reduced Emissions from Deforestation and Degradation and the role of conservation, sustainable management of forests and enhancement of carbon stocks | កាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងការរេចរឹលព្រៃឈើ និងតួនាទីនៃការអភិរក្ស ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព  និងការបង្កើនសន្និធិកាបូន |
| **UNFCCC** | United Nations Framework Convention on Climate Change | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| **UN-REDD** | United Nations Programme on Reducing Emissions from Deforestation and Forest Degradation | កម្មវិធីសហប្រជាជាតិដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ និងការរេចរឹលព្រៃឈើ |
| **USAID** | United States Agency for United States Agency for International | ទីភ្នាក់ងារសហរដ្ឋអាមេរិក សម្រាប់អភិវឌ្ឍន៍អន្តរជាតិ |

# សេចក្តីផ្តើម




វិធីសាស្ត្រកាត់បន្ថយការប្រែប្រួលអាកាសធាតុដោយផ្អែកលើព្រៃឈើ មានគោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយសារសកម្មភាពមនុស្ស និងដើម្បីបង្កើនកម្រិតកាបូនដែលរក្សាទុក និងស្រូបយកនៅក្នុងអាងស្តុកកាបូន។ ការធានាថា ព្រៃឈើលើពិភពលោកស្ថិតនៅដោយគ្មានការខូចខាត បានគ្រប់គ្រងដោយនិរន្តរភាព និងបានបង្កើនផ្ទៃដី ឥឡូវនេះបានការទទួលស្គាល់ជាទូទៅថា ជាវិធីជាក់ស្តែងមួយប្រកបដោយប្រសិទ្ធភាពខ្ពស់ខាងការចំណាយ សម្រាប់កាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

យន្តការនានាសម្រាប់កាត់បន្ថយការប្រែប្រួលអាកាសធាតុ ដែលរួមទាំង កាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ព្រៃឈើនិងការរេចរឹលព្រៃឈើ និងការអភិរក្សដែលពាក់ព័ន្ធ ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព និងការបង្កើនស្តុកកាបូនព្រៃឈើ (REDD+) មានសក្តានុពលក្នុងការផ្តល់ផលយ៉ាងសំខាន់ខាងសេដ្ឋកិច្ច ក៏ដូចជាអត្ថប្រយោជន៍បន្ថែមខាងសង្គម និងបរិស្ថានផងដែរ។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការធ្វើបែបនេះ យន្តការទាំងនេះក៏បង្ហាញពីហានិភ័យធ្ងន់ធ្ងរ និងការប្រឈមផងដែរដែលមានការប៉ះពាល់ជាពិសេសមកលើជនជាតិដើមភាគតិច សហគមន៍មូលដ្ឋាន ស្ត្រី និងក្រុមអ្នកទន់ខ្សោយ(Marginalised group)ដទៃទៀត ដែលពឹងផ្អែកយ៉ាងខ្លាំងលើព្រៃឈើសម្រាប់ការចិញ្ចឹមជីវិតរបស់ពួកគាត់ ដោយសារការរស់នៅ និងអនាគតរបស់ពួកគាត់ ស្ថិតក្រោមឥទ្ធិពលនៃសេចក្តីសម្រេចចិត្តនានា ដែលបង្កការប៉ះពាល់មកលើព្រៃឈើទាំងនោះ។

កត្តាសំខាន់ក្នុងចំណោមការប្រឈមនានាចំពោះជោគជ័យនៃកិច្ចប្រឹងប្រែងកាត់បន្ថយនេះគឺ ភាពមិនច្បាស់លាស់នៃកម្មសិទ្ធិដីធ្លី ភាពទន់ខ្សោយខាងអភិបាលកិច្ច និងយន្តការមិនច្បាស់លាស់សម្រាប់

ការបែងចែកផលប្រយោជន៍។ ការមិនយកចិត្តទុកដាក់ជាទូទៅ និងការមិនរួមបញ្ចូលអ្នកពាក់ព័ន្ធនានា នៅក្នុងសហគមន៍ និងនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងពិភពលោក ធ្វើឱ្យការប្រឈមនេះកាន់តែធ្ងន់ធ្ងរ។ អ្នកពាក់ព័ន្ធនានាដែលត្រូវបានចាត់ទុកថា មានអំណាចតិចតួច ឬគ្មានអំណាច ធៀបនឹងបុគ្គលក្រុម និង ស្ថាប័នដទៃទៀត ត្រូវបានគេផាត់ចេញពីដំណើរការនានាដែលមានឥទ្ធិពលមកលើពួកគាត់។

ការមិនរាប់បញ្ចូលសមាជិកសហគមន៍មួយចំនួនក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា សម្រាប់កិច្ចប្រឹងប្រែងកាត់បន្ថយ និងបញ្ហាដទៃទៀតនៃការប្រែប្រួលអាកាសធាតុគឺជាបញ្ហាដែលត្រូវប្រឈម។ ការផ្លាស់ប្តូរដ៏ចាំបាច់នូវទម្លាប់នេះ អាចទាក់ទងជាមួយការធ្វើឱ្យអ្នកពាក់ព័ន្ធទាំងអស់ចូលរួមនៅក្នុងរាល់ការជជែកពិភាក្សាអំពីព្រៃឈើ និងការប្រែប្រួលអាកាសធាតុ និងការបែងចែកកាន់តែមានសមធម៌ជាងមុននូវផលប្រយោជន៍ពីអន្តរាគមន៍នានា។

ឯកសារបណ្តុះបណ្តាលនេះផ្តល់ជាការណែនាំសម្រាប់បណ្តុះបណ្តាលអ្នកសម្របសម្រួល នៅថ្នាក់មូលដ្ឋាន ដើម្បីធ្វើឱ្យអ្នកពាក់ព័ន្ធនានាបានចូលរួមកាន់តែប្រសើរជាងមុន និងលើកស្ទួយសមធម៌ក្នុងប្រតិបត្តិការ និងអន្តរាគមន៍លើការប្រែប្រួលអាកាសធាតុដែលផ្អែកលើព្រៃឈើ និងការគ្រប់គ្រងព្រៃឈើ។ មូលដ្ឋានគ្រឹះសំខាន់នៃឯកសារនេះគឺពង្រីកប្រតិបត្តិការ និងដំណើរការនៃការចូលរួមយ៉ាងសកម្ម ឆ្ពោះទៅរកការធ្វើឱ្យមានការពាក់ព័ន្ធយ៉ាងសកម្មដែលជាមូលដ្ឋានសម្រាប់ពង្រឹងសមធម៌។
បញ្ហាសមធម៌ដែលគូសបញ្ជាក់នៅក្នុងឯកសារនេះ រួមមាន៖

- ការទទួលស្គាល់ច្បាស់លាស់ និងរឹងមាំជាងមុនអំពីសិទ្ធិ ដែលអាចឱ្យអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានចូលរួមយ៉ាងសកម្ម នៅក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើព្រៃឈើ និងសកម្មភាពគ្រប់គ្រងព្រៃឈើ និងទទួលផលពីសកម្មភាពទាំងនេះ
- អភិបាលកិច្ចល្អ ដែលលើកកម្ពស់នីតិរដ្ឋ តម្លាភាព គណនេយ្យភាព និងការចូលរួមប្រកបដោយអត្ថន័យពីអ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់មូលដ្ឋាន នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និង
- ការបែងចែកផលប្រយោជន៍ត្រឹមត្រូវពីការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើព្រៃឈើ និងសកម្មភាពគ្រប់គ្រងព្រៃឈើ សម្រាប់អ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់មូលដ្ឋាន។

ដើម្បីកែលម្អលក្ខខណ្ឌសមធម៌ នៅក្នុងដំណើរការណាមួយប្រការសំខាន់គឺ ត្រូវយល់ដឹងអំពីថាមវន្តនៃអំណាចទាំងនៅថ្នាក់មូលដ្ឋាន និងពិភពលោក។ កិច្ចការនេះ មានការពាក់ព័ន្ធជាពិសេសនៅក្នុងគ្រប់ REDD+ ឬយន្តការ ឬកិច្ចផ្តួចផ្តើមដទៃទៀតនៃការកាត់បន្ថយការប្រែប្រួលអាកាសធាតុដោយផ្អែកលើព្រៃឈើ ដែលមានប៉ារ៉ាម៉ែត្រ និងគោលការណ៍នានាត្រូវបានកំណត់នៅកម្រិតពិភពលោក ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ប៉ុន្តែត្រូវបានអនុវត្តដោយសហគមន៍ ដែលមានឱកាសក្នុងកម្រិតកំណត់ ដើម្បី បង្ហាញពីទស្សនៈរបស់ពួកគាត់នៅលំដាប់ថ្នាក់ខុសៗគ្នា ដូច្នេះជាការកំហិតលើឥទ្ធិពលរបស់ពួកគាត់នៅក្នុងការជជែកពិភាក្សាដំណើរការ ឬ អន្តរាគមន៍នានា។

## តើឯកសារនេះមានគោលដៅអ្វីខ្លះ?

ឯកសារបណ្តុះបណ្តាលនេះ មានគោលដៅអភិវឌ្ឍចំណេះដឹង និងសមត្ថភាពដែលត្រូវការចាំបាច់ សម្រាប់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ដើម្បីអនុវត្តដំណើរការចូលរួមពិតប្រាកដ សម្រាប់លើកកម្ពស់សមធម៌នៅសហគមន៍មូលដ្ឋាន ក្នុងក្របខ័ណ្ឌ យន្តការ និងកិច្ចផ្តួចផ្តើមគោលនយោបាយ ប្រែប្រួលអាកាសធាតុ ដោយផ្អែកលើព្រៃឈើ។ ឯកសារនេះផ្អែកលើគោលការណ៍ដែលធានាថាអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន ត្រូវតែបានចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនានា សម្រាប់កំណត់គោលនយោបាយជាតិ ដើម្បីបង្កើត និងរៀបចំផែនការកម្មវិធីនានា។ ដើម្បីសម្រេចបានលទ្ធផលដែលកាន់តែមានសមធម៌ជាងមុន អ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានត្រូវតែមានឱកាសប្រកបដោយខ្លឹមសារដើម្បីចូលរួម ហើយរាល់សេចក្តីថ្លែងការណ៍នានាអំពីព្រៃឈើ និងការប្រែប្រួលអាកាសធាតុ ត្រូវតែបានរួមបញ្ចូលទស្សនៈរបស់ពួកគាត់។

ឯកសារបណ្តុះបណ្តាលនេះជំរុញការពិភាក្សាអំពីសមធម៌ មិនត្រឹមតែតាមរយៈគោលការណ៍ "មិនធ្វើឱ្យមានគ្រោះថ្នាក់"[១] ដែលបច្ចុប្បន្ននេះត្រូវបានអនុវត្តដោយអង្គការអន្តរជាតិជាច្រើន (ដូចជា UN-REDD និងកម្មវិធីកាបូនព្រៃឈើ ទីផ្សារនិងសហគមន៍) ប៉ុណ្ណោះទេ។ ឯកសារនេះបានជំរុញហួសគោលគំនិតអំពី "ប្រព័ន្ធការពារសុវត្ថិភាពសង្គម" និងផ្តល់វិធាននានាសម្រាប់រួមបញ្ចូលក្រុមអ្នកទន់ខ្សោយនានានៅថ្នាក់មូលដ្ឋាន ដែលអាចរួមបញ្ចូលទៅក្នុងដំណើរការជាក់ស្តែង នៅតាមទីតាំងភូមិសាស្ត្រ ដូចជាកិច្ចផ្តួចផ្តើមសម្រាប់ការឯកភាពដោយគ្មានការបង្ខិតបង្ខំ និងដោយមានព័ត៌មានជាមុន ឬសម្រាប់ការបញ្ជ្រាបយេនឌ័រ។ ចំណុចគន្លឹះ គឺត្រូវធ្វើការកាន់តែបើកចំហជាងមុន នៅក្នុងការធ្វើឱ្យក្រុមអ្នកទន់ខ្សោយបានចូលរួមនៅ ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលមានឥទ្ធិពលមកលើពួកគាត់។

ឯកសារបណ្តុះបណ្តាលនេះ ពុំមានគោលដៅផ្តល់ចំណេះដឹងបច្ចេកទេសអំពីវិទ្យាសាស្ត្រ ព្រៃឈើ និងការប្រែប្រួលអាកាសធាតុ ឬ ជំនាញបច្ចេកទេសចាំបាច់ សម្រាប់យន្តការជាក់លាក់ សម្រាប់កាត់បន្ថយការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើព្រៃឈើ ដូចជា REDD+ នោះឡើយ។ ផ្ទុយទៅវិញ ឯកសារនេះប្រើប្រាស់ក្របខ័ណ្ឌងាយមួយ ដើម្បីពន្យល់បញ្ហាសមធម៌ក្នុងបរិបទជាក់លាក់។ បន្ទាប់មកឯកសារនេះបានពិចារណាអំពីចំណុចចាប់ផ្តើម ដើម្បីមានឥទ្ធិពលលើបញ្ហាសមធម៌ដោយស្វែងយល់អំពីនិតិវិធីនៃសមធម៌ (ដែលដោះស្រាយដំណើរការនានាដែលជំរុញ ឬមិនជំរុញសមធម៌) និងរបៀបកែលម្អការចូលរួមរបស់អ្នកពាក់ព័ន្ធនានាពីថ្នាក់មូលដ្ឋាននៅក្នុងដំណើរការតាមបែបចូលរួម និងឱកាសផ្សេងទៀត។

---

១ កម្មវិធី ឬ គម្រោង REDD ត្រូវតែបានបង្កើតឡើង និងអនុវត្តតាមរបៀបដែលអាចបញ្ចៀស បន្ធូរបន្ថយ ឬកាត់បន្ថយរាល់ផលប៉ះពាល់អវិជ្ជមានសង្គម ឬបរិស្ថានដែលអាចកើតមាន។

## តើហេតុអ្វីត្រូវលើកកម្ពស់សមធម៌នៅសហគមន៍មូលដ្ឋាន?

បញ្ហាសមធម៌ ស្តែងឡើងយ៉ាងច្បាស់នៅក្នុងសេចក្តីថ្លែងការណ៍ស្តីពីព្រៃឈើ និងការប្រែប្រួលអាកាសធាតុ។ ប៉ុន្តែការផ្តោតលើសមធម៌មានភាពខ្លាំងក្លានៅកម្រិត អន្តរជាតិជាងនៅថ្នាក់មូលដ្ឋាន ជាកន្លែងដែលផលប៉ះពាល់ភាគច្រើនពីកិច្ចផ្តួចផ្តើម ឬគោលនយោបាយបានកើតឡើង។ ទោះបីការចូលរួមគឺជាគោលគំនិតមួយដែលបានបញ្ជ្រាបក្នុងសហគមន៍ព្រៃឈើហើយក៏ដោយ ជាការច្បាស់ណាស់ដែលថាវាពាក់ព័ន្ធនឹងការកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលផ្អែកលើព្រៃឈើ (ភាគច្រើនផ្សំដោយយន្តការដែលជំរុញដោយកត្តាពីខាងក្រៅ) គុណតម្លៃស្នូលជាច្រើនបាន ប្រើប្រាស់ប្រចាំសប្តាហ៍ ឬក្នុងករណីខ្លះបានបោះបង់ចោលទាំងស្រុង។ ប្រការនេះបន្សល់ទុកឱកាសតិចតួច ឬគ្មានឱកាសពិតប្រាកដសម្រាប់ការចូលរួមនៅថ្នាក់មូលដ្ឋានឡើយ។

ទោះបីសម្ភារៈ និងឯកសារជាច្រើនមានចែងអំពីគោលគំនិតនៃសមធម៌ និងយុត្តិធម៌សង្គមក៏ដោយ មានតែឯកសារមួយចំនួនតូចប៉ុណ្ណោះ ដែលចងក្រងបទពិសោធន៍ សម្រាប់ផ្តល់ជាចំណេះដឹង ជំនាញ និងឧបករណ៍ ដើម្បីជួយអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន អភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួនជាបន្ថែមទៀតដើម្បីផ្តោតលើបញ្ហាជាក់លាក់នៃសមធម៌សង្គម។ ឯកសារនេះ បានផ្អែកលើឯកសារបណ្តុះបណ្តាលនានាដែលបានពិសោធន៍ និងសាកល្បងពីមុនមក ស្តីពីការសម្របសម្រួលដែលរៀបរៀងឡើងដោយ RECOFTC ស្របជាមួយវិធានថ្មីៗ ដើម្បីធ្វើឱ្យអ្នកពាក់ព័ន្ធនានាបានចូលរួម។

ឯកសារនេះ បានរៀបរៀងឡើងដោយផ្អែកលើការសន្មតថា ប្រតិបត្តិករកាត់បន្ថយការប្រែប្រួលអាកាសធាតុអាចពុំធ្លាប់បានចូលរួមនៅក្នុងសហគមន៍ព្រៃឈើឡើយ។ នៅក្នុងការពិចារណានេះផងដែរគឺប្រតិបត្តិករជំនាន់ថ្មីដែលធ្វើការកាត់បន្ថយការប្រែប្រួលអាកាសធាតុដោយផ្អែកលើព្រៃឈើ គឺជាអ្នកដែលមានសាវតាខុសៗគ្នា និងអាចទទួលផលពីការបណ្តុះបណ្តាលនេះ ដើម្បីបង្កើនជំនាញសម្របសម្រួលរបស់ពួកគាត់ផងដែរ ជាពិសេស នៅពេលពួកគាត់ធ្វើការនៅសហគមន៍មូលដ្ឋាន។

ប្រការសំខាន់ដូចគ្នានេះដែរគឺដំណើរការបែបចូលរួមបច្ចុប្បន្ននេះនៅក្នុងវិស័យព្រៃឈើនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុជួបប្រឈមជាប្រចាំជាមួយបញ្ហាសមធម៌ នៅក្នុងការធានាថាដំណើរការទាំងនោះឆ្លុះបញ្ចាំងពីគុណតម្លៃស្នូល ដែលពួកគាត់ព្យាយាមជំរុញ។ ដូច្នេះ ឯកសារនេះ ក៏មានគោលដៅឈានហួសលក្ខខណ្ឌងាយស្រួលរបស់ប្រតិបត្តិការខាងការចូលរួមផងដែរ និងលើកទឹកចិត្តពួកគាត់ឱ្យធ្វើការវាយតម្លៃឡើងវិញ និងគិតគូរឡើងវិញ អំពីគុណភាពនៃដំណើរការចូលរួមរបស់ពួកគាត់។

ការដោះស្រាយបញ្ហាសមភាពយេនឌ័រ តាមរយៈការបង្កើត និងប្រើប្រាស់ដំណើរ ការនៃការចូលរួមត្រឹមត្រូវ និងដោយតម្លាភាពគឺជាតួនាទីសំខាន់មួយរបស់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន។ ឯកសារនេះបានរៀបរៀងឡើង ដើម្បីជួយកសាង ឬបង្កើតជំនាញរបស់អ្នកសម្របសម្រួល ដែលទាក់ទងនឹងសមធម៌យេនឌ័រ ក្នុងឋានៈជាគោលដៅចុងក្រោយមួយនៃការលើកកម្ពស់សមធម៌ នៅក្នុងយន្តការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើព្រៃឈើ និងការគ្រប់គ្រងព្រៃឈើ។ ឯកសារនេះមាន

គោលដៅជេញដោល និងរំលឹកឡើងវិញនូវការសន្ទតរបស់ប្រតិបត្តិករដែលមានបទពិសោធន៍អំពីកិច្ចផ្តើមដែលមានបច្ចុប្បន្នលើការបញ្ជាបយេនឌ័រ និងដើម្បីកំណត់ការពាក់ព័ន្ធសម្រាប់អ្នកសម្របសម្រួលនៅមូលដ្ឋាន។ នៅទីបំផុតដើម្បីលើកកម្ពស់សមធម៌អ្នកសម្របសម្រួលនៅមូលដ្ឋានត្រូវតែបង្ហាញអំពីភាពជាអ្នកដឹកនាំក្នុងការលើកកម្ពស់សមភាពយេនឌ័រ។

## តើអ្នកណាខ្លះអាចទទួលផលប្រយោជន៍ពីឯកសារនេះ?

ឯកសារនេះបានរៀបរៀងឡើង សម្រាប់គ្រូបង្ហាត់ដែលចង់ទទួលបានគំនិតថ្មីៗ និងការរៀនសូត្រ បន្ថែម ដែលអាចឱ្យអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ទាក់ទាញការចូលរួមរបស់អ្នកកាន់កាប់សិទ្ធិនៅថ្នាក់មូលដ្ឋាន នៅក្នុងបរិបទនៃការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដែលទាក់ទងនឹងព្រៃឈើ ដែលរួមទាំង REDD+។

ឯកសារនេះបានរៀបរៀងឡើង សម្រាប់បណ្តុះបណ្តាលអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ទោះជាយ៉ាងណាក៏ដោយគេអាចកែសម្រួលសម្រាប់បណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាល នៅមូលដ្ឋាន និងមេដឹកនាំសហគមន៍ អំពីសមធម៌ និងការកែលម្អដំណើរការជំរុញការចូលរួមផងដែរ។ ឯកសារនេះក៏ពាក់ព័ន្ធសម្រាប់ អ្នកគ្រប់គ្រង ឬអ្នកសិក្សាស្រាវជ្រាវ ដែលធ្វើការលើគម្រោងកាត់បន្ថយការប្រែប្រួលអាកាសធាតុដោយផ្អែកលើព្រៃឈើផងដែរ ដែលចង់វាយតម្លៃតម្រូវការសមត្ថភាពរបស់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន សម្រាប់កែលម្អលក្ខខណ្ឌសមធម៌នៅក្នុងបរិបទនៃគម្រោង។



ឯកសារនេះបានរៀបរៀងឡើងសម្រាប់គ្រូបង្ហាត់ដែលមានលក្ខណៈវិនិច្ឆ័យដូចតទៅ៖

- មានបទពិសោធន៍ខ្លះៗលើការងារជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន ក្នុងការគ្រប់គ្រងធនធានធម្មជាតិតាមបែបចូលរួម
- មានការយល់ដឹងអំពីទំនាក់ទំនងរវាងព្រៃឈើ ការប្រែប្រួលអាកាសធាតុ និងយុត្តិធម៌សង្គម ព្រមទាំងបទពិសោធន៍ខ្លះៗខាងការងារ នៅតាមមូលដ្ឋានលើការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើព្រៃឈើ (ដូចជា REDD+) និង/ឬគម្រោងគ្រប់គ្រងព្រៃឈើ
- មានចំណេះដឹង និងការយល់ដឹងជាមូលដ្ឋានអំពីគោលការណ៍នៃការរៀនសូត្ររបស់មនុស្សពេញវ័យ និងបច្ចេកទេសបណ្តុះបណ្តាលដោយមានការចូលរួម និង
- ជំនាញសម្របសម្រួលពីកម្រិតកណ្តាលទៅកម្រិតខ្ពស់។

ប្រសិនបើពុំមានគ្រូបង្ហាត់ណាម្នាក់ដែលមានគុណវុឌ្ឍិចាំបាច់ទេនោះ គេគួរតែប្រមូលផ្តុំគ្រូបង្ហាត់មួយក្រុមដែលមានលក្ខណៈសមស្របនឹងលក្ខណៈវិនិច្ឆ័យតាមការចង់បាន។

សម្ភារៈដែលរួមបញ្ចូលនៅក្នុងឯកសារនេះ តម្រូវឱ្យគ្រូបង្ហាត់ធ្វើការសាកល្បងលើការសន្ទតមួយចំនួនអំពីសិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាល ដែលអាចមានបទពិសោធន៍នៅក្នុងវិស័យនេះ និងដែលអាចលំបាកក្នុងការចោទសួរខ្លួនឯងអំពីទស្សនៈ និងការអនុវត្តរបស់ខ្លួន។ នៅក្នុងបរិបទនេះ បទពិសោធន៍នៅតាមមូលដ្ឋានរបស់គ្រូបង្ហាត់មានសារៈសំខាន់ណាស់ នៅពេលធ្វើការបណ្តុះបណ្តាលអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ដោយសារការធ្វើបែបនេះនឹងជួយធានាថា អ្នកទាំងនោះអាចប្រើប្រាស់ឧទាហរណ៍ជាក់ស្តែងនានា និងអាចជម្រះមន្ទិលសង្ស័យអំពីការសន្ទតនានាប្រកបដោយទំនុកចិត្តថែមទៀតផង។

## តើត្រូវប្រើប្រាស់ឯកសារនេះដោយរបៀបណា?

ឯកសារនេះបានរៀបរៀងឡើងដើម្បីឱ្យងាយស្រួលក្នុងការប្រើប្រាស់។ គ្រូបង្ហាត់អាចជ្រើសរើសយកសម្ភារៈនានា អាស្រ័យតាមគោលបំណង ក្រុមគោលដៅ និងពេលវេលាដែលបានគ្រោងសម្រាប់ការបណ្តុះបណ្តាលនោះ។

កិច្ចតែងការមេរៀននីមួយៗ ចែងអំពីដំណើរការនៃការរៀនសូត្រ ដែលផ្សំដោយជំហាន និងសកម្មភាពជាក់លាក់ ទៅតាមពេលវេលាច្បាស់លាស់ ជាមួយគោលបំណងដែលបានកំណត់ច្បាស់លាស់។ កិច្ចតែងការមេរៀននីមួយៗ រួមមានសេចក្តីពិស្តារ អំពីសកម្មភាពបណ្តុះបណ្តាល និងឯកសារអំណានដែលផ្តល់ទិដ្ឋភាពរួម អំពីចំណុចសំខាន់ៗនៃការរៀនសូត្រ។ ឯកសារអំណានមិនមានគោលដៅជាឯកសារយោងពេញលេញសម្រាប់ប្រធានបទនីមួយៗឡើយ ផ្ទុយទៅវិញវាគ្រាន់តែជាការធានាថាគ្រូបង្ហាត់ដែលគ្មាន ឬមានបទពិសោធន៍ ក្នុងកម្រិតកំណត់អាចធ្វើសេចក្តីសង្ខេបបានត្រឹមត្រូវអំពីខ្លឹមសារបច្ចេកទេសដែលមាននៅក្នុងមេរៀននីមួយៗ។ គ្រូបង្ហាត់មិនត្រូវចែកចាយឯកសារអំណានដល់សិក្ខាកាមជាមុនឡើយ ដោយហេតុថាការធ្វើបែបនេះអាចជាការរំខានដល់ដំណើរការរៀនសូត្រ។ គេគួរផ្តល់ឯកសារអំណានដល់សិក្ខាកាមនៅចុងនៃមេរៀននីមួយៗឬនៅពេលចប់មេរៀនប្រចាំថ្ងៃ។

ប្រការសំខាន់គឺគ្រូបង្ហាត់ត្រូវស្វែងយល់ពីកិច្ចតែងការមេរៀននីមួយៗ និងឯកសារអំណាននៅមុនធ្វើការបណ្តុះបណ្តាលផ្ទាល់។ ការធ្វើបែបនេះនឹងជួយនៅក្នុងការគ្រោងសម្រាប់វគ្គនីមួយៗ។

មេរៀននីមួយៗអាចកែសម្រួលបានដោយងាយស្រួល ដើម្បីឱ្យស្របតាមតម្រូវការនៃវគ្គបណ្តុះបណ្តាល និងសិក្ខាកាម។ ទោះជាយ៉ាងណាក៏ដោយ គេត្រូវដឹងថា ជំហាននីមួយៗនៃដំណើរការនេះមានហេតុផលច្បាស់លាស់សម្រាប់ការរួមបញ្ចូល និងត្រូវបានរៀបចំឡើងដើម្បីពង្រឹងដំណើរការនៃការរៀនសូត្របែប ដកស្រង់ពិសោធន៍។ នៅពេលធ្វើការកែសម្រួលមេរៀននីមួយៗ គេមិនត្រូវកាត់បន្ថយចំនួនម៉ោងសម្រាប់ការឆ្លុះបញ្ចាំងឡើយ។ ដំណើរការឆ្លុះបញ្ចាំងច្រើនតែទាមទារពេលជាច្រើន ហើយវាក៏ជាដំណើរការដែលចាំបាច់សម្រាប់ការរៀនសូត្រពីបទពិសោធន៍ផងដែរ។

## តើឯកសារនេះត្រូវបានរៀបចំឡើងដោយរបៀបណា?



ឯកសារនេះ បានរៀបចំឡើងជា "ក្រុមមេរៀន" ចំនួនបីធំៗ ដែលមានក្រុមមេរៀនចំនួនបួនបន្ថែមទៀត សម្រាប់ផ្តល់មេរៀនជ្រើសនានា ដែលជាការលើកទឹកចិត្តបន្ថែម នៅក្នុងការពង្រឹងដំណើរការរៀនសូត្រក្នុងចំណោមសិក្ខាកាម។

ក្រុមមេរៀនទាំងនេះ ក៏មានគោលដៅសម្រាប់ការរៀបចំចេញជាម៉ូឌុលផងដែរឬប្រើប្រាស់ជាលំដាប់លំដោយជាក់លាក់។ អ្នកអាចជ្រើសយកមេរៀននានាក្នុងក្រុមនីមួយៗ និងផ្គុំបញ្ចូលគ្នាតាមវិធីខុសៗគ្នា សម្រាប់បង្កើតជាវគ្គបណ្តុះបណ្តាលមួយសមស្រប។ អ្វីដែលប្រើប្រាស់ត្រូវកំណត់ដោយគោលបំណងនៃការបណ្តុះបណ្តាល និងរយៈពេលបណ្តុះបណ្តាល។ ទោះជាយ៉ាងណាក៏ដោយ ទម្រង់មេរៀនដែលមានប្រសិទ្ធភាពបំផុតត្រូវមានការពាក់ព័ន្ធជាមួយមេរៀននានា មកពីក្រុមមេរៀនទាំងបី។ ឧទាហរណ៍ អំពីការរៀបចំវគ្គបណ្តុះបណ្តាលត្រូវបានរួមបញ្ចូលនៅក្នុងសេណារីយ៉ូបណ្តុះបណ្តាល នៅក្នុងឧបសម្ព័ន្ធ ១។

**ក្រុមមេរៀនទី ១៖** គោលការណ៍គ្រឹះនៃសមធម៌ និងការចូលរួមនៅក្នុងបរិបទព្រៃឈើ និងការប្រែប្រួលអាកាសធាតុ

ក្រុមមេរៀនទីមួយ ផ្តល់មូលដ្ឋានគ្រឹះសម្រាប់ការយល់ដឹងអំពីគោលគំនិតបឋមនៅក្នុងវគ្គបណ្តុះបណ្តាល និងជួយសិក្ខាកាមឱ្យយល់អំពីទំនាក់ទំនងរវាងសមធម៌ និងការចូលរួម។ មេរៀនសំខាន់មួយបង្ហាញពីក្របខ័ណ្ឌងាយមួយសម្រាប់ការពន្យល់នូវគោលគំនិតអំពីសមធម៌ ដែលអាចយកទៅប្រើប្រាស់នៅក្នុងគ្រប់បរិបទ។ ក្រុមមេរៀននេះក៏ផ្តល់ជាកិច្ចតែងការមេរៀន សម្រាប់ជួយណែនាំអំពីគោលបំណងនៃការបណ្តុះបណ្តាល និងទំនាក់ទំនងរវាងពាក្យ"ថ្នាក់មូលដ្ឋាន" ជាមួយបទពិសោធន៍ការងាររបស់សិក្ខាកាមផងដែរ។ កិច្ចតែងការមេរៀននេះដែលរៀបតាមលំដាប់លំដោយ អាចជួយបកស្រាយអំពីការសន្មតរបស់សិក្ខាកាម និងលើកទឹកចិត្តពួកគាត់ឱ្យពិនិត្យឡើងវិញនូវការយល់ដឹង និងបទពិសោធន៍របស់ខ្លួនអំពីសមធម៌នៅក្នុងបរិបទនៃវិស័យព្រៃឈើ និងការប្រែប្រួលអាកាសធាតុ។

**ក្រុមមេរៀនទី ២៖** តួនាទី និងជំនាញរបស់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានសម្រាប់លើកកម្ពស់សមធម៌នៅថ្នាក់មូលដ្ឋាន

ក្រុមមេរៀននេះផ្តល់សម្ភារៈនានា ដែលអាចជួយកំណត់អំពីតួនាទី និងជំនាញរបស់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ជាពិសេសផ្តោតលើការជួយក្រុមអ្នកទន់ខ្សោយឱ្យបានចូលរួម។ ប្រការនេះត្រូវបានចាត់ទុកថាជាការលំបាកជាងគេ នៅក្នុងការងាររបស់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន។ ជំនាញទាំងនេះក៏អាចយកទៅប្រើប្រាស់បានផងដែរ នៅពេលសម្របសម្រួលសម្រាប់ការចូលរួមនៃក្រុមអ្នកពាក់ព័ន្ធខុសៗគ្នាជាច្រើននៅមូលដ្ឋាន។ សម្ភារៈនៅក្នុងក្រុមមេរៀននេះ ទាក់ទងជិតស្និទ្ធជាមួយ

មេរៀនដំបូងៗ និងមានបំណងជម្រះមន្ទិលសង្ស័យរបស់សិក្ខាកាម អំពីចំណងទាក់ទងរវាងការសម្របសម្រួល និងការចូលរួម។ ក្រុមមេរៀននេះរួមបញ្ចូលកិច្ចតែងការមេរៀនមួយចំនួនអំពីជំនាញជាក់លាក់ ដែលជំនាញខ្លះត្រូវបានដកស្រង់ និងកែសម្រួលឡើងវិញ ដោយប្រើប្រាស់សម្ភារៈពីមុនៗមករបស់ RECOFTC[២] ហើយសម្ភារៈខ្លះ បន្ថែមគំនិតថ្មីៗ តាមរយៈការចូលរួមយ៉ាងមានប្រសិទ្ធភាព។ ទិដ្ឋភាពថ្មីៗទាំងនោះរួមមានមេរៀននានាស្តីពីការនិទានរឿងការបង្កើតរូបភាពទំនាក់ទំនងយេនឌ័រ និងសមភាព និងជំនាញក្នុងការពន្យល់។

**ក្រុមមេរៀនទី ៣៖** ការរៀបចំ និងតាមដានដំណើរការចូលរួមប្រកបដោយប្រសិទ្ធភាព នៅថ្នាក់មូលដ្ឋានដើម្បីលើកកម្ពស់សមធម៌

ក្រុមមេរៀននេះជួយសិក្ខាកាមនៅក្នុងការជម្រះមន្ទិលសង្ស័យអំពីភាពខុសគ្នារវាងការចូលរួម និងការពាក់ព័ន្ធ ព្រមទាំងឈានមួយជំហានបន្ថែមទៀតទៅក្នុងការអនុវត្តអ្វីដែលពួកគាត់បានរៀនក្នុងមេរៀនមុនៗ។ មេរៀនមុនៗជួយសិក្ខាកាមធ្វើការឆ្លុះបញ្ចាំងជាដំបូង អំពីការពាក់ព័ន្ធយ៉ាងមានប្រសិទ្ធភាពនៅថ្នាក់មូលដ្ឋាន និងបន្ទាប់មកបង្កើតដំណើរការនៃការពាក់ព័ន្ធ ដែលនឹងលើកកម្ពស់សមធម៌នៅក្នុងបរិបទរបស់ពួកគេ។

សម្រាប់គ្រូបង្គាត់ ភាពប្រឈមនៅក្នុងការប្រើប្រាស់សម្ភារៈនានា នៅក្នុងក្រុមមេរៀននេះគឺជួយសិក្ខាកាមឱ្យយល់ពីទំនាក់ទំនងនៃគោលគំនិតអំពីសមធម៌ និងជំនាញនានាដែលត្រូវការ ដើម្បីលើកកម្ពស់គោលគំនិតនេះ តាមរយៈការពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព ទន្ទឹមនឹងតម្រូវការ ដើម្បីជានាថាទម្រង់ និងការអនុវត្តដំណើរការនៃការពាក់ព័ន្ធផ្ទាល់មានប្រសិទ្ធភាព។ ប្រសិនបើគ្រូបង្គាត់ណាម្នាក់ធ្វើការនៅក្នុងបរិបទណាមួយ កិច្ចការសម្រាប់បង្កើតដំណើរការមួយអាចផ្សារភ្ជាប់ជាមួយទីតាំងជាក់លាក់ដែលធ្វើឱ្យការបណ្តុះបណ្តាលកាន់តែអាចទុកចិត្តបាន និងពាក់ព័ន្ធផងដែរ។

ក្រុមមេរៀននេះ ក៏មានមេរៀនមួយស្តីពីការពាក់ព័ន្ធ ដើម្បីកែលម្អនីតិវិធីនៃសមធម៌ផងដែរ ដែលផ្តល់ចំណងទាក់ទងយ៉ាងសំខាន់រវាងសម្ភារៈនានា នៅក្នុងក្រុមមេរៀននេះ និងមេរៀនក្នុងក្រុម ១ ។

**ក្រុមមេរៀន ៤៖** ពង្រឹងការរៀនសូត្រនៅក្នុងវគ្គបណ្តុះបណ្តាលរបស់អ្នក (ជម្រើស)

មេរៀននានាក្នុងក្រុមនេះ បានរៀបចំឡើង ដើម្បីជួយគ្រូបង្គាត់ធ្វើការបូកសរុបទស្សនវិស័យដែលបានពីក្រុមមេរៀនបីខាងដើម តាមវិធីច្នៃប្រឌិត និងសម្រួលឱ្យមានការឆ្លុះបញ្ចាំងកាន់តែស៊ីជម្រៅក្នុងចំណោមសិក្ខាកាម។ មេរៀនទាំងនេះនឹងជួយគ្រូបង្គាត់ និងសិក្ខាកាមធ្វើការពិចារណាអំពីអ្វីដែលបានពិភាក្សា និងតាមវិធីដែលផ្តល់ភាពសប្បាយរីករាយ និងការពាក់ព័ន្ធ នៅក្នុងការគូសបញ្ជាក់រាល់ចំណុចរៀនសូត្រ ដែលអាចពុំមានភាពច្បាស់លាស់ ឬ មានការយល់ខុស។

---

២ សម្ភារៈដែលរៀបចំឡើងដោយ RECOFTC រួមមាន៖ សិល្បៈនៃការកសាងសមត្ថភាពសម្របសម្រួល សិល្បៈនៃការកសាងសមត្ថភាពបណ្តុះបណ្តាល បង្កើតឲ្យមានការឯកភាពដោយគ្មានការបង្ខិតបង្ខំ និងការទទួលបានព័ត៌មានជាមុន ទៅក្នុងការអនុវត្តក្នុងកិច្ចផ្តួចផ្តើម REDD+។

## តើធ្វើរបៀបណាដើម្បីពង្រីកដំណើរការរៀនសូត្រ?



សម្ភារៈទាំងនេះ បានសាកល្បងជាមួយសិក្ខាកាម នៅទូទាំងអាស៊ីអាគ្នេយ៍ តាមរយៈវគ្គបណ្តុះបណ្តាលខុសៗគ្នារបស់ RECOFTC។ មេរៀន និងគន្លឹះមួយចំនួន ដែលកើតចេញពីបទពិសោធន៍នានាបានគូសបញ្ជាក់នៅទូទាំងឯកសារបណ្តុះបណ្តាលនេះទាំងមូល។ កំណត់សំគាល់សម្រាប់គ្រូបង្ហាត់ផ្តល់ជាការណែនាំសំខាន់ៗ សម្រាប់ការប្រើប្រាស់សម្ភារៈនានាទាំងនេះ។

## ជម្រះមន្ទិលសង្ស័យនៃការយល់ឃើញ និងជំរុញការកែប្រែរបស់ខ្លួន

ឯកសារបណ្តុះបណ្តាលនេះផ្តោតលើរបៀបកែលម្អសមធម៌ ក៏ដូចជាគុណភាព និងទម្លាប់អនុវត្តបច្ចុប្បន្ននៃដំណើរការចូលរួមផងដែរ។ ប្រការសំខាន់គឺ គ្រូបង្ហាត់ត្រូវដឹងថាសម្ភារៈរៀនសូត្រទាំងនេះមានឥទ្ធិពលនៅកម្រិតនៃការកែប្រែបុគ្គល និងគុណតម្លៃសម្រាប់សិក្ខាកាម។ សិក្ខាកាមជាច្រើននឹងមានបទពិសោធន៍ និងទស្សនៈទូលំទូលាយជាងមុន អំពីរបៀបដោះស្រាយបញ្ហាសមធម៌ តាមរយៈដំណើរការ "ផ្សព្វផ្សាយ" ទាំងតាមវិធីធម្មតា និងមិនធម្មតា។ សិក្ខាកាមខ្លះទៀតនឹងមានបទពិសោធន៍ខ្លះៗក្នុងការកៀរគរឱ្យមានចលនានៅថ្នាក់មូលដ្ឋានសម្រាប់ការកែប្រែ និងការបញ្ជូនសារពីថ្នាក់មូលដ្ឋាន ទៅកម្រិតគោលនយោបាយ។ បទពិសោធន៍ខុសៗគ្នារបស់សិក្ខាកាម ក៏ត្រូវតែយកមកពិចារណានៅក្នុងដំណាក់កាលដំបូងនៃវគ្គបណ្តុះបណ្តាលផងដែរ ដើម្បីគ្រូបង្ហាត់អាចរៀបចំផ្តល់ការបំភ្លឺចំពោះការយល់ឃើញជាប្រចាំកន្លងមកអំពីក្រុមអ្នកទន់ខ្សោយ និងបញ្ហាពាក់ព័ន្ធនានា។

ឥឡូវពាក្យថា "ការកសាងសមត្ថភាព" ត្រូវបានប្រើប្រាស់នៅក្នុងអន្តរាគមន៍ខុសៗគ្នាជាច្រើននៅថ្នាក់មូលដ្ឋានដែលអាច ឬមិនអាចស្របគ្នាជាមួយគុណតម្លៃដែលកំពុងស្ថិតក្នុងការជំរុញសម្រាប់បង្កើនការចូលរួម និងសមធម៌។ ការប្រឈមនៅក្នុងដំណើរការនៃការចូលរួមពិតប្រាកដ គឺការជំរុញអ្នកសម្របសម្រួលឱ្យឃ្លាតចាកឆ្ងាយពីវិធីណែនាំឬការបង្រៀនទៅរកគំរូនៃការសម្របសម្រួល និងការចូលរួមដែលតាមរយៈគំរូនេះ គេអាចឃើញ ចម្រាញ់យក និងប្រាស្រ័យទាក់ទងយោបល់របស់ពលរដ្ឋនៅថ្នាក់មូលដ្ឋានដល់អ្នកដទៃតាមវិធីដែលមានប្រសិទ្ធភាព។ និយាយដោយខ្លីអ្នកសម្របសម្រួលនៅមូលដ្ឋានពុំគួរបង្គាប់បញ្ជា ឬបង្រៀនអំពីអ្វីដែលពួកគាត់គិតថា ប្រជាជននៅមូលដ្ឋានគួរធ្វើនោះឡើយ។

## សម្របសម្រួលការឆ្លុះបញ្ចាំង

គ្រប់វគ្គមេរៀននៅក្នុងឯកសារបណ្តុះបណ្តានេះ បានផ្អែកទៅលើវដ្តនៃការរៀនសូត្របែបដកស្រង់ពិសោធន៍ដែលក្នុងនោះ ការឆ្លុះបញ្ចាំងគឺជាជំហានដំបូង។ សំណួរឆ្លុះបញ្ចាំងមានគូសបញ្ជាក់ជា អក្សរទ្រេត និងដាក់តាមលំដាប់លំដោយជាក់លាក់។ គ្រូបង្ហាត់ប្រហែលពុំចាំបាច់ប្រើប្រាស់គ្រប់សំណួរ

ដែលមាននៅទីនេះឡើយ។ ពាក់ព័ន្ធនឹងការគ្រប់គ្រងពេលវេលា រាល់សកម្មភាពរៀនសូត្រដែលជាផ្នែកមួយនៃជំហានឆ្លុះបញ្ចាំងនៅក្នុងមេរៀននីមួយៗ ត្រូវតែជាអាទិភាព។ គឺនៅក្នុងដំណាក់កាលនោះហើយដែលសិក្ខាកាមចូលរួមនៅក្នុងការរៀនសូត្រ និងចាប់ផ្តើមមើលឃើញរឿងរ៉ាវនីមួយៗខុសៗពីគ្នា។ គេអាចបង្កើតសំណួរថ្មីៗបន្ថែមទៀត ប៉ុន្តែត្រូវតែដាក់តាមលំដាប់លំដោយនៃការរៀនសូត្រតាមបទពិសោធន៍ ដូចដែលមានដកស្រង់នៅក្នុងរូបទី ១។

## រូបទី ១: វដ្តនៃការរៀនសូត្របែបដកស្រង់ពិសោធន៍




សំណួរឆ្លុះបញ្ចាំងនានានៅក្នុងវគ្គនីមួយៗត្រូវបានបង្កើតឡើង ដោយគោរពតាមលំដាប់លំដោយនៃដំណើរការរៀនសូត្ររបស់សិក្ខាកាម។ ឧទាហរណ៍៖

- សិក្ខាកាមម្នាក់អាចជួបប្រទះសកម្មភាពមួយ ឬគោលគំនិតខុសពីអ្នកដទៃ។ បុគ្គលម្នាក់ៗគួរតែវិភាគអំពីអ្វីដែលខ្លួនបានជួបប្រទះនៅក្នុងសកម្មភាពនីមួយៗ ឬនៅពេលដែលពិភាក្សាគោលគំនិតនានា។ ដូច្នេះសំណួរដែលគ្រូបង្គាត់សួរអាចរាប់បញ្ចូល៖ "តើអ្នកមានគំនិតនិងអារម្មណ៍បែបណាដែរ នៅពេលដែលអ្នកកំពុងអនុវត្តសកម្មភាពនោះ?" ឬ "តើអ្វីដែលធ្វើឱ្យអ្នកគិត និងមានអារម្មណ៍បែបនោះ?" ឬ "តើអ្នកដទៃមានប្រតិកម្មបែបណាចំពោះអ្នក និងហេតុអ្វី?" ឬ "តើអ្នកធ្វើអ្វីមុន បន្ទាប់មកមានអ្វីកើតឡើង?"
- នៅពេលពិចារណារួចហើយលើការសង្កេតងាយៗ និងអារម្មណ៍ដែលបានពីបទពិសោធន៍ដំបូងសិក្ខាកាមអាចស្វែងយល់ពីទស្សនៈដទៃទៀត ដោយផ្អែកលើគោលបំណងនានានៃមេរៀននេះ និងផ្សារភ្ជាប់ប្រតិកម្មរបស់ពួកគាត់ជាមួយបទពិសោធន៍កន្លងមក ឬ ជាមួយ

ទស្សនៈ និងគំនិតរបស់សិក្ខាកាមដទៃ។ ការឆ្លុះបញ្ចាំងបែបនេះអាចធ្វើបានតាមរយៈសំណួរ ដូចជា៖ "តើរឿងនោះប្រហែលគ្នាឬខុសគ្នាពីអ្វីដែលអ្នកអាចនឹងធ្វើឬទេ?" បន្ទាប់មកសួរថា "តើអ្នកធ្វើបែបណាដើម្បីកែប្រែអ្វីដែលបានកើតឡើង ដោយផ្អែកលើបទពិសោធន៍កន្លងមករបស់អ្នក? ហេតុអ្វីអ្នកធ្វើកែប្រែបែបនោះ?"

- នៅពេលសិក្សាស្វែងយល់ពីទស្សនៈថ្មីមួយ ដែលបានពីបទពិសោធន៍របស់សិក្ខាកាមណាម្នាក់ ដំណើរការនេះអាចឈានចេញពីការឆ្លុះបញ្ចាំង ទៅជាការបូកសរុបជាមួយសំណួរខ្លះៗ ដូចជា៖ តើកិច្ចការនោះទាក់ទងបែបណាជាមួយសមធម៌ និងភាពជាក់ស្តែងនៃដំណើរការបែបចូលរួម?" ឬ " តើរឿងនេះ ធ្លាប់កើតមានចំពោះអ្នកដែរ ឬទេ ឬ កើតនៅពេលណា និងដោយរបៀបណា?
- ដំណាក់កាលចុងក្រោយគួរតែនាំទៅរកការកែប្រែទម្លាប់អនុវត្តរបស់សិក្ខាកាម ឬឥរិយាបថដែលផ្សារភ្ជាប់ជាមួយគោលបំណងនៃមេរៀននេះ។ សំណួរនានាសម្រាប់ជំរុញការកែប្រែនេះមានជាអាទិ៍៖ "តើរឿងនោះមានអត្ថន័យបែបណាចំពោះអ្នកទៅអនាគតក្នុងឋានៈជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន និងហេតុអ្វី?" ឬ "តើអ្នកគិតថា លើកក្រោយអ្នកត្រូវធ្វើអ្វីខ្លះខុសប្លែកពីមុន?"

គ្រូបង្គាត់ដែលប្រើប្រាស់សម្ភារៈទាំងនេះត្រូវតែចងចាំថា ការរៀនសូត្រគឺជាដំណើរការមួយដែលក្នុងនោះបុគ្គលម្នាក់បានឆ្លងកាត់បទពិសោធន៍ខ្លះៗដោយផ្ទាល់ និងបន្ទាប់មកឆ្លុះបញ្ចាំងពីបទពិសោធន៍នោះ ដូចជាអ្វីមួយថ្មី ឬខុសគ្នា នៅក្នុងការប្រៀបធៀបជាមួយបទពិសោធន៍ដទៃទៀត។ គ្រូបង្គាត់ម្នាក់ៗត្រូវប្រើប្រាស់ការរៀនសូត្រនេះជាចំណុចចាប់ផ្តើម ដើម្បីសម្រួលឱ្យមានការកែប្រែចំណេះដឹង សកម្មភាព និងឥរិយាបថ។ នៅក្នុងស្ថានភាពខ្លះ គ្រូបង្គាត់គ្រាន់តែសម្រួលឃ្លោងឃ្លាឡើងវិញអំពីចំណេះដឹង និងបទពិសោធន៍នានារបស់សិក្ខាកាម ទៅតាមវិធីមួយ ដោយធ្វើការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន។

គ្រូបង្គាត់ម្នាក់ៗអាចពង្រឹងដំណើរការរៀនសូត្រដោយយល់ពីជំហាននានា និងបានបញ្ចូលជាក់ស្តែងនូវសំណួរឆ្លុះបញ្ចាំងទៅក្នុងមេរៀននីមួយៗព្រមទាំងធានាថា ជំហាននានាមិនត្រូវបានកាត់បន្ថយឡើយ។ ការសម្រួលឱ្យមានការឆ្លុះបញ្ចាំងអាចជាការលំបាក ដោយសារគ្រូបង្គាត់មិនអាចគ្រាន់តែ "ប្រមូល"ចម្លើយពីសិក្ខាកាមប៉ុណ្ណោះទេ។ ពួកគាត់ត្រូវតែប្រើប្រាស់ក្រុមនេះ ដើម្បីជម្រះមន្ទិលសង្ស័យនៃការយល់ឃើញរបស់គ្នាទៅវិញទៅមក។ ជាការមានប្រយោជន៍ ប្រសិនបើការជជែកទាំងនេះបានផ្អែកលើការសង្កេតនានា ដែលបានធ្វើឡើងជាពិសេស នៅក្នុងសកម្មភាពរៀនសូត្រ។

ទោះជាលំបាកក៏ដោយ ដំណើរការរៀនសូត្រកាន់តែមានប្រសិទ្ធភាព នៅពេលដែលគ្រូបង្គាត់ធ្វើការសម្របសម្រួលប្រកបដោយទំនុកចិត្តនូវការឆ្លុះបញ្ចាំងរបស់សិក្ខាកាមជាលក្ខណៈបុគ្គល និងជាក្រុម ជាជាងសិក្ខាកាមគ្រាន់តែស្តាប់ការសន្និដ្ឋាន និងការយល់ឃើញផ្ទាល់ខ្លួនរបស់គ្រូបង្គាត់។

## សមភាពយេនឌ័រ និងតួនាទីភាពជាអ្នកដឹកនាំរបស់គ្រូបង្គោល

ការគ្រោងទុកជាមុននៅក្នុងការធ្វើឱ្យមានសមភាពយេនឌ័រតាមរយៈដំណើរការរៀនសូត្រនេះ និងនៅក្នុងការប្រើប្រាស់សម្ភារៈរៀនសូត្រនានាមានសារៈសំខាន់ណាស់ ដូចដែលបង្ហាញតាមរយៈដំណើរការនានាដែលពាក់ព័ន្ធជាមួយការលើកកម្ពស់សមធម៌ផងដែរ។ ឧទាហរណ៍អំពីបញ្ហាយេនឌ័រនៅក្នុងសមធម៌ត្រូវបានរួមបញ្ចូលនៅក្នុងឯកសារនេះ។ ទោះជាយ៉ាងណាក៏ដោយ គ្រូបង្គាត់ត្រូវត្រៀមផ្តល់ ឧទាហរណ៍ច្បាស់លាស់អំពីនិយាមយេនឌ័រទៅតាមបរិបទមូលដ្ឋានទាក់ទងនឹងការលើកកម្ពស់សមធម៌។ គ្រូបង្គាត់ត្រូវធានាឱ្យមានឱកាសស្មើគ្នា និងត្រឹមត្រូវសម្រាប់ការចូលរួមរបស់សិក្ខាកាមជាបុរស និងស្ត្រី ដើម្បីធានាបង្កើតលទ្ធផលនៃការរៀនសូត្រដោយសមធម៌។ ប្រការសំខាន់គឺថា គ្រូបង្គាត់ត្រូវលើកស្ទួយសមភាពយេនឌ័រ ដែលនេះគឺជាការទទួលខុសត្រូវរបស់បុរសនិងស្ត្រីជាគ្រូបង្គាត់ ប្រកបដោយបទពិសោធន៍នៅគ្រប់លំដាប់ថ្នាក់ និងមិនត្រឹមតែអ្នកឯកទេសយេនឌ័រប៉ុណ្ណោះទេ។

នេះគឺជាតួនាទីរបស់គ្រូបង្គាត់ ក្នុងការជួយសិក្ខាកាមឱ្យបានដឹងអំពីឥរិយាបថផ្ទាល់ខ្លួនរបស់ពួកគាត់នៅក្នុងក្រុម និងដើម្បីជម្រះមន្ទិលសង្ស័យនៃផ្នត់គំនិតខាងយេនឌ័រ ឬលើកទឹកចិត្តឱ្យមានឥរិយាបថដែលយកចិត្តទុកដាក់ខាងយេនឌ័រ ក្នុងចំណោមសិក្ខាកាមទាំងនេះ។ ប្រការសំខាន់ផងដែរគឺ ត្រូវញែកភាពខុសគ្នារវាងការទទួលខុសត្រូវរួមសម្រាប់ការងារជាក្រុម និងការផ្តល់ឱកាសដូចគ្នាសម្រាប់សិក្ខាកាមជានារី និងបុរស ដើម្បីចូលរួមនៅក្នុងសកម្មភាពនានា។ ជាការប្រសើរគឺត្រូវត្រៀមខ្លួន ដើម្បីសម្រួលឱ្យមានការសន្ទនាប្រកបដោយការស្តាបនាអំពីឥរិយាបថដែលទាក់ទងនឹងយេនឌ័រ ដែលអាចជាការរំខានចំពោះដំណើរការនៃការរៀនសូត្រ។

## បង្កើតផ្ទៃជញ្ជាំងដែលមានរូបភាពសម្រាប់ការរៀនសូត្រ និងសម្រាប់ផ្សារភ្ជាប់គំនិតនានា

ទោះបីសម្ភារៈនានាដែលផ្តល់ឱ្យមានគោលដៅធ្វើឱ្យបញ្ហាស្មុគស្មាញនានានៃសមធម៌និងការចូលរួមកាន់តែមានលក្ខណៈងាយស្រួលយល់ក៏ដោយមេរៀននានានឹងពុំមានប្រសិទ្ធភាពឡើយ ប្រសិនបើគ្រូបង្គាត់ពុំផ្សារភ្ជាប់បញ្ហាទាំងនេះជាមួយមេរៀននីមួយៗជាបន្តបន្ទាប់។ វិធីសាស្ត្រមួយដែលមានប្រសិទ្ធភាពបំផុតសម្រាប់បង្កើតចំណងទាក់ទងដែលត្រូវការជាចាំបាច់គឺ "បង្កើតរូបភាព" អំពីដំណើរការនេះនៅលើ ផ្ទៃជញ្ជាំងណាមួយក្នុងបន្ទប់រៀន ឬសាលប្រជុំ និងបង្កើតមូលដ្ឋាននៃចំណេះដឹងជាជំហានៗទន្ទឹមនឹងដាក់វាជាលំដាប់លំដោយ (បិទផ្ទាំងរូបភាពដ្យាក្រាម ដែលបានពិភាក្សាជាមួយសិក្ខាកាមនៅទូទាំងវគ្គបណ្តុះបណ្តាលនេះលើជញ្ជាំង និងរក្សាទុកនៅទីនោះ ក្នុងអំឡុងពេលនៃវគ្គបណ្តុះបណ្តាល)។ ការប្រើប្រាស់ត្រឹមតែស្លាយ PowerPoint សម្រាប់បទបង្ហាញនានា នឹងពុំអាចជួយនៅក្នុងការតាមដានអំពីជំហ៊ានកន្លងមកបានឡើយ។ ការបន្សល់ទុកលើជញ្ជាំងនូវរូបភាព ដែលអាចមើលឃើញនៅក្នុងដំណើរការនេះនឹងជួយសម្រួលដល់ការចងចាំ។

សម្ភារៈនៅក្នុងឯកសារនេះមានជាអាទិ៍ រូបភាពនានាដែលអាចមើលឃើញ អាចជួយកែលម្អ និង ពង្រឹងចំណងទាក់ទងរវាងមេរៀននានា ដូចជា ក្របខ័ណ្ឌសមធម៌ កម្រិតនៃការពាក់ព័ន្ធ ផ្ទះជំនាញ ជំរុញការចូលរួមដោយច្នៃប្រឌិត និងការបង្កើត និងតាមដានដំណើរការនៃការចូលរួមដោយប្រសិទ្ធភាព។ ការបង្កើតកិច្ចការទាំងអស់នេះជាជំហានៗ និងយោងជាប្រចាំទៅលទ្ធផលទាំងនោះពីមេរៀនមួយទៅមេរៀនមួយទៀត ពិតជាមានសារៈសំខាន់ណាស់។




## គ្រប់គ្រងការពិភាក្សាក្នុងក្រុមរួម

នៅពេលប្រើប្រាស់សម្ភារៈនានា ដែលមាននៅក្នុងមេរៀននេះ ប្រការសំខាន់គឺត្រូវបង្កើតទម្លាប់ល្អ នៅក្នុងការសម្រួលឱ្យមានការចូលរួម ដែលជាគោលដៅចម្បង សម្រាប់ការបណ្តុះបណ្តាលនេះ។ សិក្ខាកាមទាំងអស់ត្រូវមានឱកាសដូចគ្នា ដើម្បីចូលរួម និងពាក់ព័ន្ធនៅក្នុងដំណើរការរៀនសូត្រនេះ។ សម្ភារៈត្រូវបានបង្កើតឡើង ដើម្បីបង្កើនការរៀនសូត្ររបស់សិក្ខាកាម។ ប្រសិនបើត្រូវពិភាក្សាជារួមការពិភាក្សានោះត្រូវតែផ្តោតឱ្យចំគោលដៅ និងខ្លី។ ការពិភាក្សារួមអាចទាមទារពេលច្រើន និងអាចនាំឱ្យសិក្ខាកាមខ្លះដកខ្លួនថយចេញពីដំណើរការនេះ។ លើសពីនេះ ជំនួសឱ្យការពិភាក្សារួមយ៉ាងវែងដែលក្នុងនោះមាន តែសិក្ខាកាមមួយចំនួនតូចជាអ្នកនិយាយ ជាការល្អគឺត្រូវជំរុញឱ្យមានស្វ័យសិក្សា។ ការពិភាក្សាបែបនេះនឹងលើកទឹកចិត្តឱ្យមានការកែប្រែ ដែលក្នុងនោះសិក្ខាកាមទទួលខុសត្រូវលើការរៀនសូត្ររបស់ខ្លួន ដោយខ្លួនឯង ជាងពឹងផ្អែកលើការណែនាំជាប្រចាំ។

## តើត្រូវចាត់ចែងការបណ្តុះបណ្តាលរបៀបណា?

ដូចដែលបានពន្យល់ គេអាចយកសម្ភារៈនានានៅក្នុងឯកសារនេះ ទៅប្រើប្រាស់ដើម្បីរៀបចំការបណ្តុះបណ្តាលស្របជាមួយបរិបទ និងភាពជាក់ស្តែងនៅតាមទីតាំងជាក់លាក់ សម្រាប់ក្រុមគោលដៅជាក់លាក់ និង/ឬសម្រាប់គោលដៅ និងគោលបំណងជាក់លាក់នានា។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីចាត់ចែងការបណ្តុះបណ្តាលបែបនេះ ប្រការចាំបាច់គឺ ជាដំបូងត្រូវកំណត់គោលបំណងនានា ដែលត្រូវសម្រេចឱ្យបាននៅចុងវគ្គបណ្តុះបណ្តាលនេះ។ ជាមួយគោលបំណងច្បាស់លាស់ គេអាចជ្រើសរើសមេរៀនជាក់លាក់ ដោយផ្អែកលើកាលវេលាកំណត់។ សេណារីយ៉ូនៃវគ្គបណ្តុះបណ្តាលមួយចំនួនត្រូវបានរួមបញ្ចូលនៅផ្នែកខាងចុងឯកសារនេះសម្រាប់ជាឧទាហរណ៍។ តារាងទី១ បង្ហាញសេចក្តីសង្ខេបអំពីផែនការបណ្តុះបណ្តាលពិស្តារដែលផ្អែកលើមេរៀន ដូចមានក្នុងឧបសម្ព័ន្ធ ១។

## តារាងទី ១: ផែនការបណ្តុះបណ្តាលតាមមេរៀននីមួយៗ

| | សេណារីយ៉ូនៃវគ្គបណ្តុះបណ្តាល | ក្រុមគោលដៅ | រយៈពេល | គោលបំណងនៃការរៀនសូត្រ |
|---|---|---|---|---|
| ១ | វគ្គបណ្តុះបណ្តាលតែមួយលើកសម្រាប់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន<br><br>(សម្រាប់ក្រុមមេរៀនទាំងអស់) | អ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន និងបុគ្គលិកផ្សព្វផ្សាយរបស់រដ្ឋាភិបាល | ៥ ថ្ងៃ | នៅចុងវគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមៈ<br>• អាចពន្យល់គោលការណ៍ងាយៗនៃសមធម៌ និងគូសបញ្ជាក់អំពីភាពពាក់ព័ន្ធនឹងសិទ្ធិ អភិបាលកិច្ច និងអត្ថប្រយោជន៍នៃព្រៃឈើ ការប្រែប្រួលអាកាសធាតុ និងបរិបទសមធម៌<br>• អាចកំណត់ឃើញឱកាសសម្រាប់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន ដើម្បីដោះស្រាយបញ្ហាសមធម៌ នៅក្នុងដំណើរការពាក់ព័ន្ធជាមួយ REDD+<br>• នឹងបានអនុវត្តសាកល្បងជំនាញជាក់លាក់ ដែលមានសារៈសំខាន់សម្រាប់បង្កើត និងអនុវត្តដំណើរការពាក់ព័ន្ធដែលមានប្រសិទ្ធភាព និង<br>• មានឱកាសដើម្បីធ្វើការឆ្លុះបញ្ចាំង ដើម្បីលើកកម្ពស់សមធម៌ក្នុងបរិបទ ឬទីកន្លែងរបស់ពួកគាត់ផ្ទាល់ និងបានរៀបចំផែនការមួយសម្រាប់ការចូលរួម។ |
| ២ | សិក្ខាសាលាបណ្តុះបណ្តាលតែមួយលើកសម្រាប់អ្នកធ្វើសេចក្តីសម្រេចចិត្ត<br><br>(សម្រាប់ក្រុមមេរៀនទី ១ និងទី ៣) | មន្ត្រីជាន់ខ្ពស់មកពីរដ្ឋាភិបាល និងអ្នកគ្រប់គ្រងគម្រោងព្រមទាំងអ្នកគ្រប់គ្រងក្នុងវិស័យឯកជន | ១ ថ្ងៃ | នៅចុងវគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមៈ<br>• អាចពន្យល់គោលការណ៍ងាយៗនៃសមធម៌ និងគូសបញ្ជាក់អំពីភាពពាក់ព័ន្ធនឹងសិទ្ធិ អភិបាលកិច្ច និងអត្ថប្រយោជន៍នៃព្រៃឈើ ការប្រែប្រួលអាកាសធាតុ និងបរិបទសមធម៌<br>• នឹងបានកំណត់ឃើញឧបសគ្គសម្រាប់អ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានក្នុងការចូលរួមនៅក្នុងកិច្ចផ្តួចផ្តើម និងការពិភាក្សាអំពីព្រៃឈើ និងការប្រែប្រួលអាកាសធាតុ និង<br>• កំណត់បានអត្ថប្រយោជន៍ និងគុណតម្លៃរបស់គ្នាទៅវិញទៅមកដែលបានពីការចូលរួមប្រសើរជាងមុន និងការពាក់ព័ន្ធសម្រាប់អ្នកគ្រប់គ្រង។ |
| ៣ | សិក្ខាសាលាបណ្តុះបណ្តាលតែម្តងដែលផ្តោតលើការងារនៅមូលដ្ឋាន<br><br>(សម្រាប់គ្រប់ក្រុមមេរៀន) | អ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន និងមេដឹកនាំសហគមន៍ | ៣ ថ្ងៃ ដែលរួមទាំងទស្សនកិច្ចតាមមូលដ្ឋាន ១ថ្ងៃ | នៅចុងវគ្គបណ្តុះបណ្តាល សិក្ខាកាមអាចៈ<br>• អាចពន្យល់គោលការណ៍ងាយៗនៃសមធម៌ និងគូសបញ្ជាក់អំពីភាពពាក់ព័ន្ធនឹងសិទ្ធិ អភិបាលកិច្ច និងអត្ថប្រយោជន៍នៃព្រៃឈើ ការប្រែប្រួលអាកាសធាតុ និងបរិបទសមធម៌<br>• អាចកំណត់ឃើញឱកាសសម្រាប់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន ដើម្បីដោះស្រាយបញ្ហាសមធម៌ នៅក្នុងទីតាំងព្រៃឈើ និង<br>• បង្កើតបានដំណើរការចូលរួមយ៉ាងមានប្រសិទ្ធភាពដែលផ្អែកលើការវិភាគស្ថានភាពនៃបញ្ហាសមធម៌។ |
| ៤ | សិក្ខាសាលាថ្នាក់សហគមន៍តែមួយលើក<br><br>(សម្រាប់ក្រុមមេរៀនទី ១ និងទី ២) | មេដឹកនាំសហគមន៍និងអ្នកពាក់ព័ន្ធដទៃទៀតដែលធ្វើការជាមួយសហគមន៍មូលដ្ឋាន (អ្នកតភ្ជាប់) | ២ ថ្ងៃ | នៅចុងវគ្គបណ្តុះបណ្តាល សិក្ខាកាមអាចៈ<br>• អាចពន្យល់គោលការណ៍ងាយៗនៃសមធម៌ និងគូសបញ្ជាក់អំពីភាពពាក់ព័ន្ធនឹងសិទ្ធិ អភិបាលកិច្ច និងអត្ថប្រយោជន៍នៃព្រៃឈើ ការប្រែប្រួលអាកាសធាតុ និងបរិបទសមធម៌ និង<br>• អាចកំណត់ឃើញឱកាស និងតួនាទីរបស់សម្រាប់មេដឹកនាំសហគមន៍ និងអ្នកតភ្ជាប់ដើម្បីដោះស្រាយបញ្ហាសមធម៌ក្នុងព្រៃឈើតាមមូលដ្ឋាន។ |
| ៥ | សិក្ខាសាលាដែលមានទស្សនកិច្ចនៅចន្លោះកណ្តាល<br>(សម្រាប់ក្រុមមេរៀនទី១ និងទី ៣) | អ្នកសម្របសម្រួលថ្នាក់មូលដ្ឋាននិងបុគ្គលិកផ្សព្វផ្សាយនៃរដ្ឋាភិបាលមកពីមូលដ្ឋានជាក់លាក់ | ៤ ថ្ងៃ (មេរៀន២ថ្ងៃដំបូងនិង២ថ្ងៃចុងក្រោយ ជាមួយការចុះអនុវត្តតាមមូលដ្ឋាន រយៈពេល២សប្តាហ៍នៅចន្លោះពេលកណ្តាលវគ្គ) | នៅចុងវគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមៈ<br>• អាចពន្យល់គោលការណ៍ងាយៗនៃសមធម៌ និងគូសបញ្ជាក់អំពីភាពពាក់ព័ន្ធនឹងសិទ្ធិ អភិបាលកិច្ច និងអត្ថប្រយោជន៍នៃព្រៃឈើ ការប្រែប្រួលអាកាសធាតុ និងបរិបទសមធម៌<br>• អាចកំណត់ឃើញឱកាស និងតួនាទីសម្រាប់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន ដើម្បីដោះស្រាយបញ្ហាសមធម៌ នៅក្នុងដំណើរការពាក់ព័ន្ធជាមួយ REDD+ ដែលរួមទាំង ឧបសគ្គនានាចំពោះការចូលរួមសម្រាប់ក្រុមជាក់លាក់ និង<br>• បានអនុវត្តជំនាញជាក់លាក់ចាំបាច់សម្រាប់រៀបចំ និងអនុវត្តដំណើរការចូលរួមយ៉ាងមានប្រសិទ្ធភាព ។ |

មេរៀនទី ១



# គោលការណ៍គ្រឹះនៃសមធម៌
# និងការចូលរួមក្នុងបរិបទព្រៃឈើ
# និងការប្រែប្រួលអាកាសធាតុ

# ក. របកគំហើញដោយខ្លួនឯងតាមរយៈការគិតដែលផ្អែកលើសម្បត្តិ ( ភាពវិជ្ជមាន ) (Asset Based Thinking-ABT)

**គោលបំណងនៃការរៀនសូត្រ**

នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមអាចៈ

- រំលឹកឡើងវិញឈ្មោះនិង តំណែងរបស់គ្នាទៅវិញទៅមក
- រៀបរាប់រឿងរ៉ាវដែលជាព្រឹត្តិការណ៍មោទនភាពបំផុតចំនួនបួនដែលទទួលបានក្នុងរយៈពេលបីឆ្នាំកន្លងមក
- អធិប្បាយភាពខ្លាំងផ្ទាល់ខ្លួនរបស់អ្នកដោយផ្អែកលើព្រឹត្តិការណ៍ដែលខ្លួនមានមោទនភាព




- នឹងបានប្រៀបធៀបវិធីចំនួនពីរ សម្រាប់ការណែនាំនៅក្នុងក្រុមនីមួយៗនិង
- ពន្យល់អំពីរបៀបដែលការសម្របសម្រួល ដើម្បីបង្កើតការជាប់ចិត្តនឹងគ្នា និងការប្រើប្រាស់វិធីគិត ដែលផ្អែកលើសម្បត្តិដើម្បីពង្រឹងឱកាសសម្រាប់ការពាក់ព័ន្ធ។

**សម្ភារៈ**

ក្រដាសផ្ទាំងធំ ហ្វឺត ក្រដាស Post-it ស្កុត ម៉ាស៊ីនថតឌីជីតាល់ កងចក្រ (ចូរប្រើក្រដាសពណ៌ច្បាស់ និងត្រៀមខ្លួនសម្រាប់វគ្គនេះដោយចែករង្វង់ជាបួនផ្នែក) និងឯកសារអំណាន។






**រយៈពេល**

៩០ នាទី

## ជំហានអនុវត្ត

១. ចាប់ផ្តើមដោយពន្យល់ថា មេរៀននេះនឹងជួយសិក្ខាកាមឱ្យស្គាល់គ្នាទៅវិញទៅមក ហើយទន្ទឹមនឹងនោះពួកគាត់នឹងអនុវត្តវិធីនៃការបង្ហាញភាពខ្លាំងរៀងៗខ្លួន។ វិធីនេះក៏អាចប្រើប្រាស់ដោយអ្នកសម្របសម្រួលថ្នាក់មូលដ្ឋានផងដែរក្នុងពេលធ្វើការជាមួយក្រុមខុសៗគ្នា។

២. សុំឱ្យសិក្ខាកាមឈរជារង្វង់ នៅកណ្តាលបន្ទប់រៀន។

៣. នៅក្នុងរង្វង់នេះ សុំឱ្យសិក្ខាកាមម្នាក់ៗប្រាប់ឈ្មោះរបស់ខ្លួនតំណែងក្នុងអាជីព និងកិច្ចការសំខាន់មួយដែលពួកគាត់សង្ឃឹមថានឹងអាចដោះស្រាយបាននៅក្នុងវគ្គបណ្តុះបណ្តាលនេះ។ ចូរសង្កត់ធ្ងន់ថា ពួកគាត់ម្នាក់ៗមានពេលមិនលើសពីមួយនាទីឡើយ (រយៈពេលនេះអាចកែប្រែបានអាស្រ័យលើចំនួនសិក្ខាកាម)។

៤. ក្រោយពេលដែលសិក្ខាកាមបាននិយាយគ្រប់គ្នាហើយ ត្រូវឱ្យប្រាកដថាពួកគាត់មានស្លាកឈ្មោះជំល្មម និងសរសេរលើនោះឱ្យបានច្បាស់លាស់នូវឈ្មោះក្រៅ ដែលពួកគាត់ចង់ឱ្យហៅនៅក្នុងវគ្គបណ្តុះបណ្តាលនេះ។

៥. សូមឱ្យសិក្ខាកាមដើរជាជុំម្តងម្នាក់ៗ និងផ្តល់ស្លាកលេខមួយទៅសិក្ខាកាមម្នាក់ៗ ដើម្បីពួកគាត់អាចបែងចែកទៅជាក្រុមតូចៗដែលក្នុងក្រុមនីមួយៗ មានគ្នាពីបួនទៅប្រាំនាក់ (សមាជិកក្រុមគួរតែខុសគ្នាពីក្រុមដែលពួកគាត់បានចូលជាមួយគ្នា ពេលពួកគាត់ចូលមកក្នុងបន្ទប់នេះជាលើកដំបូង)។

៦. សុំឱ្យសិក្ខាកាមអង្គុយចុះនៅតាមតុក្នុងក្រុមរបស់ពួកគាត់។

**រូបទី ២: កងចក្រផ្ទាល់ខ្លួនអំពីការពាក់ព័ន្ធដោយប្រសិទ្ធភាព**



៧. ផ្តល់ក្រដាសពណ៌ឱ្យសិក្ខាកាមគ្រប់រូប (រូបទី២) ដែលចែកចេញជា បួនផ្នែក។ សូមពន្យល់ថា សិក្ខាកាមម្នាក់ៗ គួរគិតអំពីព្រឹត្តិការណ៍ដែលខ្លួនមានមោទភាពបំផុត ក្នុងជីវិតរបស់ខ្លួនកាលពីបីឆ្នាំកន្លងទៅ (ក្នុងអាជីព ឬជីវិតឯកជនរបស់ខ្លួនផ្ទាល់) និងគូររូបអំពីឱកាស ដែលមានមោទនភាពនីមួយៗ នៅក្នុងជ្រុងនីមួយៗនៃក្រដាស។ ចូរគូសបញ្ជាក់ថា សិក្ខាកាមម្នាក់ៗ អាចគិតពីរូបអ្វីមួយរៀងៗខ្លួន ដើម្បីឆ្លុះបញ្ចាំងព្រឹត្តិការណ៍នីមួយៗ សូម្បីតែរូបគំនូរងាយឬនិមិត្តសញ្ញាផ្សេងៗ អាស្រ័យតាមសាច់រឿងនោះ។ សូមពន្យល់ថា ពួកគាត់មិនអាចប្រើពាក្យ ឬ ប្រយោគ ដើម្បីបកស្រាយពីព្រឹត្តិការណ៍នីមួយៗឡើយ។ សូមលើកទឹកចិត្តពួកគាត់ឱ្យក្លាហានក្នុងការពន្យល់ដោយខ្លួនឯង និងបំពេញនៅកន្លែងចន្លោះចំហ។ សូមទុកពេល ១០-១៥ នាទីសម្រាប់លំហាត់នេះ។

៨. ក្រោយពួកគាត់បានបំពេញទិន្នន័យផ្ទាល់ខ្លួនរួចហើយ សូមឱ្យពួកគាត់ចែករំលែករំលែកសាច់រឿងរបស់ខ្លួនដោយប្រើប្រាស់រូបភាពដែលពួកគាត់គូរ និងពន្យល់កងចក្ររបស់ពួកគាត់ទៅសិក្ខាកាមដទៃទៀតនៅតាមតុជាមួយគ្នា។



៩. ត្រូវប្រាកដថាសិក្ខាកាមម្នាក់ៗនៅតាមតុនីមួយៗ មានឱកាសនិទានរឿងរបស់ខ្លួនដោយរំលឹកពួកគាត់ពីពេលវេលា និងតាមរយៈការតាមដានវេននីមួយៗ និងការរីកចម្រើននៃក្រុមខុសៗគ្នា។ សូមទុកពេល២០នាទី ដើម្បីពួកគាត់អនុវត្តជំហាននេះ។ ក្រោយពួកគាត់បានបញ្ចប់សូមឱ្យពួកគេពិនិត្យមើលរឿងរ៉ាវរបស់បុគ្គលម្នាក់ៗឡើងវិញ ដើម្បីជួយបុគ្គលនោះក្នុងការកំណត់រកភាពខ្លាំងផ្ទាល់ខ្លួនដែលវាជាមូលហេតុនៃព្រឹត្តិការណ៍ដែលមានមោទនភាពនោះ។ សូមពន្យល់ថានៅចុងលំហាត់នេះបុគ្គលម្នាក់ៗគួរតែមានតារាងស្ដីពីភាពខ្លាំងផ្ទាល់ខ្លួន ដែលពួកគាត់អាចសរសេរនៅលើកងចក្ររបស់ខ្លួន (ឬបន្ថែមក្រដាស Post-it ប្រសិនបើសរសេរពុំអស់)។ សូមទុកពេល២០នាទី សម្រាប់ជំហាននេះ។ អ្នកអាចផ្ដល់ឧទាហរណ៍ជាក់លាក់ ដូចជា ៖ "ខ្ញុំមានមោទនភាពជាខ្លាំងនៅពេលបានជួយក្រុមស្ត្រីនៅមូលដ្ឋានមួយ ឱ្យចូលរួមក្នុងកិច្ចប្រជុំក្រុមការងារ REDD+ ថ្នាក់ជាតិ។ ភាពខ្លាំងផ្ទាល់ខ្លួនរបស់ខ្ញុំគឺខ្ញុំបានព្យាយាមការពារឱកាសសម្រាប់ពួកគាត់ និងមានការច្នៃប្រឌិតក្នុងការជួយពួកគាត់បានសំដែងមតិផ្ទាល់ខ្លួន។"

១០. ក្រោយពេលដែលក្រុមទាំងអស់បានបញ្ចប់ហើយ សូមទុកពេល ៥នាទី ដើម្បីពួកគាត់ពិភាក្សាអំពីគំនិតមួយ ដើម្បីថតរូបក្រុមនេះដែលតំណាងឱ្យភាពខ្លាំងខុសៗគ្នារបស់ពួកគាត់។ នៅក្នុងក្រុមពួកគាត់ម្នាក់ៗសំដែងកាយវិការពីមុខម៉ាស៊ីនថត តាមរបៀបដែលតំណាងឱ្យភាពខ្លាំងរបស់ខ្លួន។ សូមបញ្ជាក់ថា គំនិតនោះមិនមែនបង្ហាញពីរូបភាពដែលឆ្លុះបញ្ចាំងពីភាពខ្លាំងរួមតែមួយប៉ុណ្ណោះទេ ប៉ុន្តែជាការបង្ហាញពីភាពប្លែកៗគ្នារបស់បុគ្គលម្នាក់ៗអំពីភាពខ្លាំងនៃក្រុមនោះផងដែរ។ សូមលើកទឹកចិត្តឱ្យប្រើប្រាស់គ្រឿងតុបតែង ប៉ុន្តែសង្កត់ធ្ងន់ថា ពួកគាត់មិនអាចចលតែឡើយ ដើម្បីបង្ហាញភាពខ្លាំងរបស់ខ្លួនសម្រាប់ថតដោយសារតែនេះជារូបភាពគ្មានចលនា។

១១. ស្នើក្រុមនីមួយៗឈានចេញមកខាងមុខ ដើម្បីត្រៀមថត។ អ្នកអាចរាប់ដល់បី ដើម្បីឱ្យគ្រប់គ្នាយល់ច្បាស់ពីជំហរចុងក្រោយមុននឹងថត។ សូមឱ្យក្រុមដទៃទៀតទាយពីភាពខ្លាំងខុសៗគ្នារបស់ពួកគេ។ ត្រូវទុកពេលឱ្យក្រុមនេះរក្សាជំហរក្នុងស្ថានភាពប្រុងថតឱ្យបានយូរគ្រប់គ្រាន់ ដើម្បីឱ្យក្រុមដទៃទៀតទាយពីភាពខ្លាំងរៀងៗខ្លួន ដែលពួកគាត់បានឃើញ។ សិក្ខាកាមដទៃទៀតអាចនិយាយអំពីអ្វីដែលពួកគាត់មើលឃើញថា ជាភាពខ្លាំងដែលបង្ហាញនៅក្នុងជំហរនោះ។ ចូរថតរូបក្រុមនីមួយៗ នៅដំណាក់កាលចុងក្រោយរបស់ពួកគាត់ដែលអ្នកអាចប្រើប្រាស់នៅក្នុងវគ្គបណ្ដុះបណ្ដាលនេះ ឬបោះពុម្ព និងបង្ហាញរួមជាមួយកងចក្ររបស់ពួកគាត់។

១២. ក្រោយពេលដែលក្រុមទាំងអស់បានបង្ហាញពីជំហររបស់ខ្លួនសំរាប់ការថតហើយនោះ សូមអញ្ជើញក្រុមទាំងមូលធ្វើការឆ្លុះបញ្ចាំងដោយប្រើប្រាស់សំណួរដូចតទៅ៖

- *តើអ្នកមានអារម្មណ៍ផ្ទាល់ខ្លួនបែបណាក្នុងពេលអនុវត្តលំហាត់នេះ?*
- *តើមានអ្វីកើតឡើងដែលធ្វើឱ្យអ្នកមានអារម្មណ៍បែបនោះ?*
- *តើអ្នកមានអារម្មណ៍បែបណានៅពេលកំណត់រកភាពខ្លាំងរបស់អ្នក?*
- *តើអ្នកណាយល់ថាងាយស្រួលក្នុងការកំណត់រក និងចែករំលែករំលែកភាពខ្លាំងរបស់ខ្លួន ឬទេ? តើអ្នកណាយល់ថាលំបាក និងហេតុអ្វី?*
- *តើអ្នកគិតថា ហេតុអ្វីយើងប្រើលំហាត់នេះ នៅដំណាក់កាលដំបូងក្នុងវគ្គបណ្តុះបណ្តាលនេះ ឬក្នុងការបង្កើតក្រុម?*
- *តើមានអ្វីខ្លះខុសគ្នារវាងលំហាត់ទីមួយ និងទីពីរ នៅក្នុងការចាប់ផ្តើមនេះ៖ ការណែនាំខ្លួនម្នាក់ៗដោយខ្លួនឯងផ្ទាល់ ធៀបនឹងការណែនាំខ្លួនជាក្រុម?*
- *តើអ្នកមានអារម្មណ៍ និងការយល់ឃើញបែបណាអំពីអ្នកដទៃនៅក្នុងក្រុមដែលប្រែប្រួលជា បន្តបន្ទាប់ក្នុងពេលអនុវត្តលំហាត់នេះ? តើហេតុអ្វីបានជាប្រែប្រួលបែបនេះ?*
- *តើអ្នកមានអារម្មណ៍មិនសូវស្រួលមែនទេ? នៅពេលណា និងហេតុអ្វី?*
- *តើអ្វីបានជួយឱ្យអារម្មណ៍របស់អ្នកស្ងប់ និងចូលរួមចែករំលែក និងហេតុអ្វីបានជាវាជួយបែបនោះ?*
- *តើក្រុមនេះមានការចូលរួមកម្រិតណា?*
- *តើក្រុមនេះមានអារម្មណ៍ផ្សារភ្ជាប់គ្នាបែបណា? ហេតុអ្វីបានជាមានអារម្មណ៍ផ្សារភ្ជាប់គ្នាបែបនេះ ឬ ហេតុអ្វីគ្មានអារម្មណ៍ផ្សារភ្ជាប់គ្នា?*
- *តើលទ្ធផលអាចខុសពីនេះដែរឬទេ ប្រសិនបើខ្ញុំសូមឱ្យអ្នកផ្តោតលើការចែករំលែកបញ្ហាក្នុងជីវិតរបស់អ្នក? ហេតុអ្វី?*
- *តើការពិភាក្សារបស់អ្នកនៅក្នុងមេរៀននេះផ្សារភ្ជាប់នឹងមេរៀននេះបែបណា?*

១៣. សូមពន្យល់ថា គោលការណ៍ដែលលើកកម្ពស់ប្រសិទ្ធភាពនៃការចូលរួមបានមកពីវិធាននៃ ″ការគិតដោយផ្អែកលើសម្បត្តិ″។ សូមសួរសិក្ខាកាមថា តើពួកគាត់យល់បែបណាអំពីលំហាត់ដែលពួកគាត់ទើបបានអនុវត្ត ទាក់ទងនឹងវិធាន ផ្អែកលើសម្បត្តិ (ដូចជា ចែករំលែកព្រឹត្តិការណ៍នៃមោទនភាព ការផ្សារភ្ជាប់អារម្មណ៍វិជ្ជមាន ចែករំលែកការច្នៃប្រឌិតដោយផ្អែកលើភាពខ្លាំង)។

១៤. សូមពន្យល់ដល់សិក្ខាកាមអំពីថា តើការគិតដោយផ្អែកលើសម្បត្តិ គឺជាអ្វី (សូមអានឯកសារអំណាន)។ សូមបញ្ជាក់ឱ្យច្បាស់ថា ការគិតដែលផ្អែកលើសម្បត្តិ មិនត្រឹមតែជាការគិតបែបវិជ្ជមានប៉ុណ្ណោះទេ ប៉ុន្តែវាចាប់ផ្តើមជាមួយការកែប្រែវិធី ដែលមនុស្សម្នាក់មើលមកខ្លួនឯង។

សូមគូសបញ្ជាក់ថា ក្នុងនាមជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ដែលធ្វើការខាងកិច្ចការសមធម៌ និងលើកកម្ពស់ការចូលរួម និងការពាក់ព័ន្ធប្រការសំខាន់ គឺពួកគាត់ត្រូវទទួលស្គាល់សម្បត្តិខ្លួនឯង (ភាពខ្លាំង) ជាបឋម បន្ទាប់មកត្រូវកំណត់រក និងកសាងសម្បត្តិរបស់អ្នកដទៃ។ សូមពន្យល់ថា អ្នកនឹងពន្យល់បន្ថែមអំពីវិធានដែលផ្អែកលើសម្បត្តិជាបន្តទៀត នៅពេលក្រោយក្នុងវគ្គបណ្តុះបណ្តាលនេះ។

**១៥.** បូកសរុបដោយពន្យល់ថា មេរៀននេះត្រូវបានរៀបចំឡើង ដើម្បីផ្សារភ្ជាប់សិក្ខាកាមនៅកម្រិតស្មារតី និងបុគ្គល។ សូមគូសបញ្ជាក់ថា វិធានដូចគ្នានេះក៏អាចប្រើប្រាស់ក្នុងបរិបទខុសគ្នាផងដែរ ដើម្បីបង្កើតឱកាសសម្រាប់ការចូលរួមជាវិជ្ជមាន និងដើម្បីពង្រឹងស្មារតីនៃការបើកចំហនៅក្នុងដំណើរការជាបន្ត។ វិធាននេះក៏អាចរួមបញ្ចូលទៅក្នុងរចនាបថនៃដំណើរ[៣]ការ សម្រាប់ការចូលរួមផងដែរ (ពោល គឺដំណើរការនៃការពាក់ព័ន្ធដោយប្រសិទ្ធភាពដែលជំរុញការចូលរួម) ភាសាដែលប្រើប្រាស់សំណួរ និងបរិយាកាសទូទៅដែលបានបង្កើតឡើង នៅក្នុងដំណើរការនៃការចូល រួម។

**១៦.** ត្រូវប្រាកដថា កងចក្រផ្ទាល់ខ្លួន និងកំណត់ត្រាអំពីភាពខ្លាំងត្រូវបានបិទភ្ជាប់លើជញ្ជាំង (សូមអាន ផ្នែកស្តីពីការបង្កើតផ្ទៃជញ្ជាំងដែលមានរូបភាព សម្រាប់ការរៀនសូត្រ នៅក្នុងសេចក្តីផ្តើមនៃឯកសារនេះ) និងពន្យល់ថា នៅក្នុងវគ្គបណ្តុះបណ្តាលនេះ អ្នកនឹងប្រើប្រាស់វិធានបច្ចេកទេស និងឧបករណ៍នៃការសម្របសម្រួលខ្លះដែលសិក្ខាកាមក៏អាចប្រើប្រាស់នៅថ្នាក់ មូលដ្ឋានផងដែរ។




**១៧.** សូមពន្យល់ថា ក្នុងនាមជាគុណតម្លៃដែលជាប់ជាមួយ និងសេចក្តីណែនាំអ្នកអាចចង់ប្រើប្រាស់ប្រយោគនេះ៖ **“មនុស្សគ្រប់រូបមានលក្ខណៈដោយឡែកពីគ្នា និងគួរតែមានអ្នកដទៃយកចិត្តទុកដាក់ស្តាប់”**។ ត្រូវផ្សារភ្ជាប់ប្រយោគនេះទៅនឹងសេចក្តីពន្យល់ពីខាងដើមអំពីការគិតដែលផ្អែកលើសម្បត្តិ។ បិទប្រយោគនេះលើជញ្ជាំងនៅត្រង់កន្លែងងាយមើលឃើញ។

## កំណត់សំគាល់សម្រាប់គ្រូបង្គោល

ត្រូវដឹងថា សិក្ខាកាមនឹង “មានការប្រុងប្រយ័ត្ន” នៅពេលនេះ ដែលនេះជារឿងធម្មតាក្នុងចំណោមសិក្ខាកាម។ នេះមានន័យថា ពួកគាត់អាចមិនសំដែងអំពីអារម្មណ៍ពិតប្រាកដ ឬ អ្វីដែលពួកគាត់បានឆ្លង

៣. ការបង្កើតដំណើរការសម្រាប់ការពាក់ព័ន្ធគឺជាការអនុវត្តដោយដឹងជាមុន ដែលពាក់ព័ន្ធជាមួយការជ្រើសរើសឧបករណ៍ និងដំណើរការ ដែលជួយរៀបចំយុទ្ធសាស្ត្រដើម្បីសម្រេចគោលបំណងមួយឈុត និងដែលអាចឲ្យអ្នកពាក់ព័ន្ធទាំងអស់យល់បាន។ វាមិនត្រឹមតែជាផែនការ ឬ របៀបវារៈមួយនោះឡើយ។

កាត់ឡើយ។ ឬពួកគាត់ផ្តល់ជាចម្លើយដែលជាការរំពឹងទុកទៅវិញ ដោយសារតែស្ថិតក្រោមឥទ្ធិពលនៃនិយាមសង្គម ឬវប្បធម៌ និងថាមវន្តនៃក្រុមរបស់ខ្លួន។

មេរៀននេះត្រូវបានប្រើប្រាស់ជាការណែនាំដើម្បីឱ្យស្គាល់គ្នា។ មេរៀននេះបង្ហាញពីធាតុផ្សំខ្លះៗនៃខ្លឹមសារក្នុងវគ្គបណ្តុះបណ្តាលដូចជា សមធម៌ ការចូលរួម និងការពាក់ព័ន្ធ។ មេរៀននេះ ត្រូវការពេលវេលាសម្រាប់ឆ្លុះបញ្ចាំង និងពិចារណាព័ត៌មាននេះ។ ដោយសារនេះជាដំណាក់កាលដើមនៃវគ្គបណ្តុះបណ្តាល សិក្ខាកាមខ្លះអាចមិនយល់ពីមូលហេតុដែលអ្នកធ្វើការឆ្លុះបញ្ចាំងអំពីវិធីនេះ ក៏ដូចជាអ្វីដែលពួកគាត់បានជួបប្រទះ នៅក្នុងដំណាក់កាលនេះ។ អ្នកគួរតែបញ្ជាក់ឱ្យច្បាស់ថា មេរៀននេះមានបំណងពង្រឹងការគិតដែលផ្អែកលើសម្បត្តិដែលសិក្ខាកាមអាចទទួលស្គាល់អំពីភាពខ្លាំង និងលក្ខណៈដោយឡែករបស់ខ្លួន ហើយនេះជាមូលដ្ឋានដែលបន្ទាប់មកពួកគាត់អាចប្រើប្រាស់ ដើម្បីជួយអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានទទួលស្គាល់ភាពខ្លាំង និងលក្ខណៈដោយឡែកផ្ទាល់ខ្លួនរបស់ពួកគាត់ជាសហគមន៍មួយ។ គេអាចប្រើប្រាស់មេរៀននេះជាចំណុចចាប់ផ្តើមដើម្បីបង្កើនការចូលរួមរបស់ពួកគាត់ នៅក្នុងដំណើរការនានា ដែលមានការប៉ះពាល់មកលើពួកគាត់ និងដើម្បីឱ្យមានការយកចិត្តទុកដាក់ស្តាប់សំដីរបស់ពួកគាត់នៅក្នុងដំណើរការទាំងនេះ។

ប្រសិនបើអ្នកមានឧបករណ៍សម្រាប់ការបញ្ចាំងវីដេអូ អ្នកអាចបញ្ចាំងវីដេអូអំពីថាតើ "ពាក្យសំដីអាចបង្កើតពិភពលោក" ដោយរបៀបណា ដើម្បីពង្រឹងការរៀនសូត្រដូចដែលបានកត់សំគាល់ក្នុងជំហានទី ១៦៖ www.youtube.com/watch?v=Hzgzim5m7oU&feature=youtu.be.

# កងចក្រផ្ទាល់ខ្លួន អំពីការចូលរួមយ៉ាងមានប្រសិទ្ធភាព

លំហាត់នេះប្រើប្រាស់កងចក្រនេះ ដើម្បីពង្រឹងការគិតដែលផ្អែកលើសម្បត្តិ(ភាពវិជ្ជមាន)។

- គូររូបរង្វង់មួយដែលតំណាងឱ្យព្រឹត្តិការណ៍មោទនភាពចំនួនបួនកាលពីបីឆ្នាំមុន នៅក្នុងជ្រុងនីមួយៗនៃរង្វង់នេះ។
- កំណត់រកភាពខ្លាំងផ្ទាល់ខ្លួន ដែលបានរួមចំណែកទៅក្នុងអារម្មណ៍អំពីជោគជ័យ នៅក្នុងព្រឹត្តិការណ៍ នៃមោទនភាពនោះ និងសរសេរភាពខ្លាំងទាំងនោះនៅលើកងចក្រនេះ ឬប្រើសន្លឹក Post-it។
- តែងលម្អកងចក្រនេះ ដើម្បីឱ្យមានលក្ខណៈជាបុគ្គលអ្នកផ្ទាល់ ដើម្បីឆ្លុះបញ្ចាំងអំពីភាពខ្លាំង និងថាតើសិក្ខាកាមមើលឃើញខ្លួនឯងបែបណា។
- សរសេរឈ្មោះដែលសិក្ខាកាម ចង់ឱ្យគេហៅជាឈ្មោះក្រៅ នៅក្នុងវគ្គបណ្តុះបណ្តាលនេះ នៅជ្រុងណាមួយលើកងចក្រនេះ។
- គួរតែបិទភ្ជាប់កងចក្រទាំងនេះ នៅលើជញ្ជាំងបន្ទប់បណ្តុះបណ្តាលសម្រាប់អំឡុងពេលទាំងមូលនៃវគ្គនេះ។



# របកគំហើញផ្ទាល់ខ្លួន និងការគិតដែលផ្អែកលើសម្បត្តិ( ភាពវិជ្ជមាន ) ក្នុងនាមជាអ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន

## តើការគិតដែលផ្អែកលើសម្បត្តិ( ភាពវិជ្ជមាន )ជាអ្វី ?[៤]

ចូរស្រមៃថា តើអាចមានអ្វីកើតឡើង ប្រសិនបើមនុស្សផ្តោតការយកចិត្តទុកដាក់លើៈ

- ឱកាសជាងលើបញ្ហា
- ភាពខ្លាំងជាងលើភាពទន់ខ្សោយ
- តើអ្វីអាចធ្វើទៅបានជំនួសឱ្យអ្វីដែលមិនអាចធ្វើបាននោះ។




មានភស្តុតាងដែលបង្ហាញថា នៅពេលអ្នកកាត់បន្ថយការគិតរបស់អ្នកអំពីអ្វីដែលមិនអាចធ្វើបាន ( ការគិតដែលផ្អែកលើឱនភាព ) និងបង្កើនការយកចិត្តទុកដាក់របស់អ្នកលើអ្វីដែលដំណើរការទៅបាន ( ការគិតដែលផ្អែកលើសម្បត្តិ ឬភាពវិជ្ជមាន ) មានន័យថា អ្នកបង្កើតកម្លាំងចិត្ត និងថាមពលពង្រឹងទំនាក់ទំនងនានា និងធ្វើឱ្យមនុស្សរំជួលចិត្ត និងផលិតភាពទៅរកលំដាប់បន្តបន្ទាប់នៃអន្តរកម្មប្រកបដោយការស្ថាបនា។

> "នៅពេលអ្នកកែប្រែរបៀបដែលអ្នកមើលរបស់អ្វីម៉្យាង របស់ដែលអ្នកឃើញនោះប្រែប្រួល។"
> **អនាមិក**

នេះមិនមានន័យថា ការគិតដែលផ្អែកលើសម្បត្តិ គឺជាមោទនភាពងងឹតងងល់ ឬ វាមិនផ្តល់ដំណោះស្រាយឆាប់រហ័ស ឬ មានការប្តេជ្ញាខ្ពស់ហួសហេតុ ឬ លទ្ធផលរំពឹងទុកឡើយ។ ការគិតដែលផ្អែកលើសម្បត្តិ អាចត្រូវការនូវការគិតគូរវិជ្ជមាននៅកម្រិតថ្មីមួយនៃការពាក់ព័ន្ធដោយសារវាទាមទារឱ្យមានសកម្មភាពវិជ្ជមាន និងមូលដ្ឋានរឹងមាំក្នុងខណៈបច្ចុប្បន្ននេះ។

## តើការគិតដែលផ្អែកលើសម្បត្តិ ខុសគ្នាបែបណាពីការគិតដែលផ្អែកលើឱនភាព ?

យើងត្រូវបានផ្សារភ្ជាប់ ដើម្បីក្លាយជាអ្នកគិតបែបឱនភាព។ នេះមានន័យថា យើងប្រមូលផ្តុំលើភាពខ្វះចន្លោះ ភាពទន់ខ្សោយ ឧបសគ្គ និងដែនកំណត់របស់បុគ្គល។ នេះក៏ដោយសារ ក្នុងនាមជាមនុស្ស

---

៤. គោលគំនិតជាច្រើននៅក្នុងឯកសារអំណាននេះត្រូវបានស្រង់ចេញពី Cramer and Wasiak ( 2006 ).

ប្រព័ន្ធការគិតរបស់យើងកាន់តែមានភាពផុយស្រួយ ចំពោះសញ្ញានានានៃគ្រោះថ្នាក់ដែលមិនទាន់កើត ជាងចំពោះសញ្ញាវិជ្ជមាននៃឱកាសច្បាស់លាស់ទៅទៀត។

តារាងខាងក្រោមនេះ បង្ហាញពីឧទាហរណ៍មួយចំនួនតូចនៃភាសាដែលយើងប្រើប្រាស់តាមវិធីខុសៗគ្នា ដើម្បីពង្រឹងការពិភាក្សាបែបស្ថាបនា និងវិធីនានានៃការគិត។

### តារាងទី ២: ឧទាហរណ៍អំពីពាក្យសំដីដែលផ្អែកលើឱនភាព និងសម្បត្តិ

| **ការគិតដែលផ្អែកលើឱនភាព** | **ការគិតដែលផ្អែកលើសម្បត្តិ (ភាពវិជ្ជមាន)** |
|---|---|
| កុំធ្វើអញ្ចឹងទៀត... | យ៉ាងហោចណាស់ ខ្ញុំដឹងថាត្រូវដោះស្រាយរឿងនេះបែបណា... |
| ប្រយ័ត្ន... | ប្រឹងប្រែងឡើង... |
| ហេតុអ្វីអ្នកមិន... | តើមានអ្វីរារាំងអ្នក? |
| វាមិនអាចអញ្ចឹងទេ... | តើអ្វីខ្លះដែលអាចធ្វើបាន? |
| គាត់ឆ្កួតហើយ... | តើអ្វីខ្លះដែលធ្វើឱ្យគាត់មានទំនុកចិត្ត? |
| បញ្ហានេះមិនអាចកែប្រែបានទេ... | តើខ្ញុំអាចជៀសវាងវាដោយរបៀបណា? |

### តើការគិតដែលផ្អែកលើសម្បត្តិមានន័យបែបណាចំពោះអ្នកនៅថ្នាក់មូលដ្ឋាន?

ការគិតដែលផ្អែកលើសម្បត្តិ តម្រូវឱ្យមានការផ្លាស់ប្តូរតិចតួចនូវ វិធីដែលយើងទទួលបាន យល់ឃើញ ចម្រាញ់យក និងបកស្រាយពិភពលោកនៅជុំវិញយើង និងទំនាក់ទំនងរបស់យើងជាមួយពិភពលោកនោះ។ នេះមានន័យថា ជាបឋមយើងត្រូវតែកែប្រែវិធីដែលយើងមើលមកខ្លួនយើង និងបន្ទាប់មកមានអារម្មណ៍ស្រឡាញ់វិជ្ជមាន និងមានបំណងជាជាងការប្រតិកម្មតប។ និយាយម្យ៉ាងទៀតថា ក្នុងនាមជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន អ្នកអាចផ្តោតលើការធ្វើឱ្យអ្វីដែលវិជ្ជមានកើតឡើងជំនួសឱ្យការរារាំងការកែប្រែ ឬ កែតម្រូវរឿងមិនល្អ មិនឱ្យកើតឡើង។ ការធ្វើបែបនេះពាក់ព័ន្ធជាមួយការកែប្រែវិធីដែលអ្នកមើលមកខ្លួនឯង អ្នកដទៃ និងស្ថានភាពនានាដែលរូបអ្នក និង/ឬអ្នកដទៃស្ថិតនៅក្នុងនោះ។ នេះមានន័យថា នៅពេលអ្នកបង្កើតដំណើរការសំណួរលំហាត់ជាក្រុម ឬគ្រប់គ្រងការពិភាក្សាក្នុងនាមជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន អ្នកត្រូវធ្វើការពិចារណាជាប់ជានិច្ច និងប្រើប្រាស់ការគិតដែលផ្អែកលើសម្បត្តិ។ ការធ្វើបែបនេះនឹងបង្កើតចលនាទៅមុខថាមពល និងអារម្មណ៍ជាប់ជំពាក់ដែលសុទ្ធតែមានសារៈសំខាន់សម្រាប់សម្រេចបានដំណើរការនៃការពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព។

## តើអ្វីខ្លះជាផលបន្ត និងហេតុអ្វីវាមានសារៈសំខាន់សម្រាប់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន?




ផលបន្តពិនិត្យមើលអំពីថា តើអ្នកអាចប្រើប្រាស់សម្បត្តិផ្ទាល់ខ្លួនរបស់អ្នក (ដូចជា ស្មារតីអំពីគោលបំណង ភាពងប់ងល់ ការចង់ដឹង ភាពធន់ ភាពក្លាហាន និងជំនាញវិភាគ បញ្ញាស្មារតី ជំនាញ ទស្សនៈ បើកចំហ សុចរិតភាព និងសីលធម៌) បន្ទាប់មករូបអ្នកផ្ទាល់អាចមានឥទ្ធិពលមកលើសម្បត្តិសមស្របបែបណា ដែលរួមទាំងមេត្តាធម៌ ការយល់ចិត្ត ការទុកចិត្ត និងការគោរពគ្នាទៅវិញទៅមក ការប្តេជ្ញាចំពោះសមធម៌ និងសុខុមាលភាពរបស់អ្នកដទៃក៏ដូចជា ការប៉ិនប្រសប់ក្នុងកិច្ចសហការ ការផ្តល់ និងទទួលយោបល់តប ការស្តាប់ និងការតស៊ូមតិផងដែរ។

នៅទីបំផុត ការប្រើប្រាស់សម្បត្តិបុគ្គល និងទំនាក់ទំនង នឹងអាចធ្វើឱ្យអ្នកមើលឃើញ និងបង្កើតសម្បត្តិនៅក្នុងស្ថានភាព ដូចជា ការប្រឈមដែលលើកកម្ពស់ដំណោះស្រាយថ្មី ការដកថយដែលលើកកម្ពស់ឱ្យមានស្តង់ដារថ្មីៗ នៃគុណភាពការងារ កំហុសឆ្គងដែលផ្តល់នូវគំនិតថ្មីៗ និងការរៀនសូត្រ និងឱកាស ដែលលើកទឹកចិត្តឱ្យមាននវានុវត្តន៍ ភាពប៉ិនប្រសប់ និងការឈានទៅមុខ។

ក្នុងឋានៈជាអ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន ដែលនឹងលើកកម្ពស់ការចូលរួម និងដំណោះស្រាយដែលមាននិរន្តរភាពនៅក្នុងក្រុមនានា ជាពិសេស ក្រុមអ្នកទន់ខ្សោយ ប្រការសំខាន់គឺ អ្នកត្រូវតែដឹងអំពីសម្បត្តិរបស់ខ្លួន សម្បត្តិរបស់ក្រុម ពោលគឺសម្បត្តិរបស់បុគ្គលនៅក្នុងក្រុម និងរបស់ក្រុមទាំងមូលក៏ដូចជា សម្បត្តិនៃស្ថានភាពជាក់លាក់ផងដែរ។ មានការយល់ដឹងអំពីដំណើរការរបស់ខ្លួនផ្ទាល់នៃរបកគំហើញផ្ទាល់ខ្លួន និងការជួយអ្នកដទៃ ដើម្បីស្វែងរកភាពខ្លាំងរបស់ពួកគាត់នឹងបង្ហាញថាមានសារៈសំខាន់នៅក្នុងដំណើរការពាក់ព័ន្ធរបស់អ្នក។

ការគិតដែលផ្អែកលើសម្បត្តិ ចាប់ផ្តើមជាមួយវិធីដែលអ្នកមើលមកខ្លួនឯង និងរបៀបដែលអ្នកជួយដល់អ្នកដទៃឱ្យចេះមើលមកខ្លួនឯង។ ការសួរសំណួរត្រឹមត្រូវ ដោយប្រើពាក្យសំដីប្រកបដោយការបំផុសគំនិត និងរៀបចំពាក្យពេចន៍ និងឱកាសនានាដែលបង្ហាញខ្លួនឯង មានសារៈសំខាន់ចំពោះការបណ្តុះបណ្តាល។ ការយល់ដឹងអំពីតម្រូវការឱ្យមានការគិតដែលផ្អែកលើសម្បត្តិ ត្រូវតែជាភាពខ្លាំងផ្ទាល់ខ្លួនមួយរបស់អ្នកនៅគ្រប់ពេលទាំងអស់ ទើបរូបអ្នកមានជោគជ័យ ក្នុងនាមជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន។

### បន្តអនុវត្តគោលការណ៍ប្រាំ-ទល់នឹង-មួយ

- សូមគិតអំពីភាពខ្លាំង សម្បត្តិ ជំនាញ ឬ ការប៉ិនប្រសប់របស់ខ្លួនចំនួនប្រាំ ដែលបានផ្ដល់វិភាគទានយ៉ាងច្រើនចំពោះប្រសិទ្ធភាពរបស់អ្នក។
- បន្ទាប់មក គិតអំពីឱនភាពមួយ (ដែនកំណត់ ភាពខ្វះខាត ឬ ភាពទន់ខ្សោយ) ដែលជាឧបសគ្គយ៉ាងសំខាន់បំផុតចំពោះប្រសិទ្ធភាពរបស់អ្នក។
- ឥឡូវនេះ សូមគិតអំពីការប្រឈម និងឱកាសនានាដែលអ្នកប្រឈម។ តើធ្វើបែបណាទើបអ្នកអាចបង្កើនភាពខ្លាំងរបស់ខ្លួន ដើម្បីជំនះការប្រឈមរបស់អ្នក និងធ្វើសមិទ្ធកម្ម ឱកាសរបស់អ្នក?
- ផ្ដោតលើសម្បត្តិចំនួនប្រាំសម្រាប់ឱនភាពនីមួយៗ និងកសាងថាមវន្តផ្ទាល់ខ្លួនរបស់អ្នក។

### តើនេះជាវិធីថ្មីនៃការគិត ឬអ្វី?

ការគិតដែលផ្អែកលើសម្បត្តិ មិនមែនជារឿងថ្មីឡើយ។ ការបង្ហាញជូននៅទីនេះ មានបំណងគូសបញ្ជាក់អំពីសារៈសំខាន់ជាមូលដ្ឋានមួយសម្រាប់ការធ្វើឱ្យអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានបានចូលរួម និងនៅក្នុងការដោះស្រាយបញ្ហាសមធម៌។ វិធីដែលយើងគិតអំពីខ្លួនយើង និងអំពីអ្នកដទៃ តែងតែជាផ្នែកមួយនៃលក្ខខណ្ឌរបស់មនុស្ស។ ទោះជាយ៉ាងណាក៏ដោយ គុណតម្លៃនៃការគិតដែលផ្អែកលើសម្បត្តិត្រូវបានរួមបញ្ចូលទៅក្នុងវិធានដែលផ្អែកលើការប្រែប្រួលដូចជា ការសាកសួរបែបលើកសរសើរ ដែលត្រូវបានប្រើប្រាស់ផងដែរជាវិធាននៃការចាត់ចែងឱ្យមានការចូលរួម សម្រាប់ក្រុមនាំមុខ ដែលមានការឯកភាពគ្នាលើរបៀបវារៈដើម្បីអនុវត្តសកម្មភាព។

# ២. សេចក្តីផ្តើមអំពីវគ្គបណ្តុះបណ្តាល

**គោលបំណងនៃការរៀនសូត្រ**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹង៖

- កំណត់បានអត្តសញ្ញាណ និងចែករំលែករំលែកការរំពឹងទុករបស់ខ្លួនផ្ទាល់អំពីវគ្គបណ្តុះបណ្តាលនេះ។
- អាចពន្យល់អំពីគោលបំណង និងលំដាប់លំដោយនៃការបណ្តុះបណ្តាល[៥]នេះ និង
- អាចពន្យល់អំពីធាតុផ្សំនានានៃវគ្គបណ្តុះបណ្តាល និងចំណងទាក់ទងរវាងធាតុផ្សំទាំងនោះ។

**សម្ភារៈ**

ក្រដាសផ្ទាំងធំដែលរៀបចំជាមុនជាមួយហ្វឹត ក្រដាស Post-It និងរបៀបវារៈគោលបំណងព្រមទាំងឯកសារអំណាន។



**រយៈពេល**

៤០ នាទី

## ជំហានអនុវត្ត

១. បង្ហាញជូនមេរៀននេះ ដោយពន្យល់ថា អ្នកត្រូវឆ្លើយនឹងសំណួរ ហេតុអ្វី អ្វីខ្លះ និងបែបណា នៃរចនាសម្ព័ន្ធវគ្គបណ្តុះបណ្តាលនេះ ដើម្បីសិក្ខាកាមអាចយល់អំពីដំណើរការ និងថាតើវានឹងត្រូវរួមបញ្ចូលគ្នាបែបណានៅក្នុងរយៈពេលប៉ុន្មានថ្ងៃខាងមុខ។ នៅទីនេះ "ហេតុអ្វី" បង្ហាញពីហេតុផលសម្រាប់វគ្គបណ្តុះបណ្តាលនេះ "អ្វីខ្លះ" ផ្តល់មាតិកានៃវគ្គបណ្តុះបណ្តាល និង "បែបណា" ស្វែងយល់ពីវិធីសាស្ត្រនានាដែលនឹងត្រូវប្រើប្រាស់សម្រាប់វគ្គបណ្តុះបណ្តាលនេះ។

២. ពន្យល់ថា មុននឹងអ្នកបង្ហាញទម្រង់រួមនៃវគ្គនេះ អ្នកត្រូវស្វែងយល់អំពីអ្វីដែលសិក្ខាកាមសង្ឃឹមថា នាំយកទៅជាមួយបន្ទាប់ពីវគ្គបណ្តុះបណ្តាលនេះ។ សូមសរសេរលើក្រដាសផ្ទាំងធំ៖




---

៥ មេរៀននេះសំដៅលើវគ្គបណ្តុះបណ្តាលរយៈពេលប្រាំថ្ងៃ នៅក្នុងសេណារីយ៉ូនៃការបណ្តុះបណ្តាលនេះដូចមានបង្ហាញជូនក្នុងឧបសម្ព័ន្ធ១។ គេត្រូវកែសម្រួលសម្រាប់សេណារីយ៉ូផ្សេងទៀតនៃការបណ្តុះបណ្តាល ទោះបីធាតុផ្សំនានានៅតែដដែលក៏ដោយ។

**តើអ្នកចង់នាំយកអ្វីខ្លះ ទៅជាមួយបន្ទាប់ពីសិក្ខាសាលានេះ?** សូមឱ្យសិក្ខាកាមសរសេរលើក្រដាស Post-it មួយសន្លឹកម្នាក់អំពីរបស់សំខាន់បំផុត ដែលសិក្ខាកាមចង់បានពីវគ្គបណ្តុះបណ្តាលដែលអ្នកនឹងរៀបចំនេះ។ រំលឹកពួកគាត់ថា ពួកគាត់គួរតែសរសេរគំនិតតែមួយ នៅលើក្រដាស Post-it មួយសន្លឹក។ សូមទុកពេល ៥នាទី ដើម្បីពួកគាត់ សរសេរ និងសូមឱ្យពួកគាត់បិទគំនិតរបស់ខ្លួនលើក្រដាសផ្ទាំងធំ។ សូមពន្យល់ពួកគាត់ថា អ្នកនឹងត្រឡប់មក ពិនិត្យ ចម្លើយរបស់ពួកគាត់ក្រោយពេលដែលអ្នកបានឆ្លើយនឹងសំណួរ "អ្វីខ្លះ" ។

៣. ត្រូវផ្តោតលើ "ហេតុអ្វី" សូមបង្ហាញក្រដាសផ្ទាំងធំខុសគ្នាមួយ ដែលនៅលើនោះអ្នកបានសរសេរចំណងជើងវគ្គបណ្តុះបណ្តាល និងគោលបំណងនៃវគ្គដែលអ្នកបានរៀបចំនេះ។ ចូរអានចំណងជើង និងគោលបំណងឱ្យសិក្ខាកាមស្តាប់។

៤. វិលត្រឡប់មក "អ្វីខ្លះ" នៃវគ្គបណ្តុះបណ្តាលនេះវិញ និងបង្ហាញដោយសង្ខេបអំពីលំដាប់លំដោយនៃកាលវិភាគសម្រាប់វគ្គបណ្តុះបណ្តាលនេះ និងកម្រិតខុសៗគ្នា (សូមអាន ឯកសារអំណាន ប៉ុន្តែមិនត្រូវចែកក្នុងពេលនេះទេ) ដែលវគ្គបណ្តុះបណ្តាលនេះនឹងស្វែងយល់ពីជំនាញផ្ទាល់ខ្លួនរបស់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានអំពីបរិបទដែលក្នុងនោះពួកគេប្រតិបត្តិការ។ សូមឱ្យសិក្ខាកាមសួរដោយសេរី ប្រសិនបើពួកគាត់មិនទាន់ច្បាស់អំពីថា តើមេរៀនណាគួរតែស្ថិតនៅត្រង់ណា។

៥. នៅក្រោយបានពន្យល់ "អ្វីខ្លះ" ចូរឈានបន្តទៅ "បែបណា" និងត្រូវយោងទៅប្រយោគពីជំហានមុននេះ ក្នុងមេរៀននេះអំពីការគិតដែលផ្អែកលើសម្បត្តិ។ ចូរពន្យល់ថា វិធីជាច្រើនដែលបានប្រើប្រាស់នៅក្នុងវគ្គបណ្តុះបណ្តាលនេះ អាចត្រូវបានប្រើប្រាស់ដោយសិក្ខាកាមនៅក្នុងដំណើរការចូលរួមរបស់ពួកគាត់ និងដែលដំណើរការនីមួយៗមានភាពខ្លាំង និងចំណុចខ្សោយខុសៗគ្នា។ សូមពន្យល់ផងដែរថាជាតុផ្សំសំខាន់បំផុតនៃ "បែបណា" គឺថាសិក្ខាកាមទាំងអស់មានឱកាស ដើម្បីនិយាយស្មើភាពគ្នា និងចែករំលែកបទពិសោធន៍នានារបស់ខ្លួន។ អ្នកគួរតែសង្កត់ធ្ងន់ថា គេមិនសុទ្ធតែមានចម្លើយត្រឹមត្រូវចំពោះគ្រប់សំណួរទាំងអស់ឡើយ ហើយនេះជាវេទិកាមួយដែលក្នុងនោះពួកគាត់អាចលើកឡើងរាល់បញ្ហាដែលពួកគាត់មានអារម្មណ៍មិនសូវស្រួល ឬ មានជាសំណួរ។

៦. សូមគូសបញ្ជាក់ថា ទោះបីវគ្គបណ្តុះបណ្តាលនេះនឹងពិភាក្សា និងវិភាគអំពីបញ្ហានានានៅកម្រិតបរិបទក៏ដោយ ដូចជា ហេតុអ្វីសមធម៌មានសារៈសំខាន់នៅក្នុងកិច្ចផ្តួចផ្តើម REDD+ វគ្គបណ្តុះបណ្តាលនេះពិនិត្យមើលថា តើដំណើរការចូលរួមនេះអាចលើកកម្ពស់សមធម៌សម្រាប់សហគមន៍នៅថ្នាក់មូលដ្ឋានដោយរបៀបណា។ ចំណុចនេះអាចត្រូវពិចារណាជាស្នូលនៃវគ្គបណ្តុះបណ្តាលដែលជា "បែបណា" នៃការកែលម្អសមធម៌ តាមរយៈដំណើរការពាក់ព័ន្ធ។

៧. ពិនិត្យឡើងវិញប្រយោគរបស់សិក្ខាកាមនៅលើក្រដាស Post-it ដែលបង្ហាញពីការរំពឹងទុករបស់ពួក គាត់សម្រាប់វគ្គបណ្តុះបណ្តាលនេះ។ សូមសួរក្រុមនេះថា តើអ្នកណាមានកង្វល់ថា ការរំពឹងទុករបស់ពួកគាត់មិនស្របគ្នាជាមួយគោលបំណងនៃវគ្គបណ្តុះបណ្តាលនេះឬទេ។ ប្រសិនបើមានការ

លើកឡើងនូវកង្វល់ណាមួយក្នុងករណីនោះ សូមបំភ្លឺអំពីថា តើបញ្ហាទាំងនោះអាចស្របគ្នាដោយរបៀបណា និងនៅត្រង់ណា នៅក្នុងលំដាប់លំដោយនៃវគ្គនេះ។ ក្រុមនេះក៏អាចជួយបង្ហាញផងដែរ។




៨. ត្រឡប់មកដ្យាក្រាមអំពីកម្រិតនៃការពាក់ព័ន្ធ និងការលើកកម្ពស់សមធម៌ (រូបទី៣) និងសង្កត់ធ្ងន់ថា នៅត្រង់ចំណុចកណ្តាលនៃសំណួរ "បែបណា" មានគុណតម្លៃ និងជំនាញផ្ទាល់ខ្លួនរបស់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន និងវិធីដែលពួកគាត់មើលឃើញសមធម៌ នៅក្នុងបរិបទផ្ទាល់ខ្លួនរបស់ពួកគាត់។

៩. គូសបញ្ជាក់អំពីមេរៀនខុសៗគ្នាដែលនឹងបង្ហាញពីគុណតម្លៃ និងជំនាញផ្ទាល់ខ្លួនរបស់សិក្ខាកាម និងពន្យល់ថា នៅក្នុងវគ្គនេះអ្នកនឹងបកស្រាយអំពីវិធីដែលមានស្រាប់របស់សិក្ខាកាមដែលបានប្រើប្រាស់នៅក្នុងការសម្របសម្រួល។ សូមគូសបញ្ជាក់ថា ការលើកសំណួរបែបនេះគឺជាផ្នែកមួយនៃដំណើរការរៀនសូត្រ។

**១០.** បូកសរុបមេរៀននេះ ដោយពន្យល់ថា សិក្ខាកាមនឹងមានឱកាស ដើម្បីផ្តល់យោបល់តបនៅទូទាំងវគ្គបណ្តុះបណ្តាលនេះ ហើយការបើកចំហ ដើម្បីទទួលយោបល់តប នឹងអាចឱ្យអ្នកទទួលបានចម្លើយតបមកវិញ។

---

## កំណត់សំគាល់របស់គ្រូបង្គោល

ត្រូវមានដ្យាក្រាមដែលបង្ហាញពីលំដាប់លំដោយនៃវគ្គបណ្តុះបណ្តាលនេះ និងត្រូវបិទនៅត្រង់ណាមួយក្នុងបន្ទប់ដែលអាចឱ្យឃើញគ្រប់ពេលទាំងអស់។ ការធ្វើបែបនេះនឹងអាចឱ្យរូបអ្នក និងសិក្ខាកាមវិលត្រឡប់មកដ្យាក្រាមនេះ នៅទូទាំងវគ្គបណ្តុះបណ្តាលនេះ ដែលជាការពង្រឹងជាប្រចាំនូវចំណងទាក់ទងរវាងមេរៀននានា។ សិក្ខាកាមខ្លះទំនងជាមានការរំពឹងថា អាចរៀនសូត្រអំពីចំណុចបច្ចេកទេសនៃរបៀបវារៈ REDD+ និងការប្រែប្រួលអាកាសធាតុ។ ក្នុងករណីបែបនេះចូរគូសបញ្ជាក់ថា វគ្គបណ្តុះបណ្តាលនេះនឹងមិនលើកយកអំពីទិដ្ឋភាពនេះឡើយ លើកលែងតែក្នុងករណីពាក់ព័ន្ធ ហើយថាតើវាមានឥទ្ធិពលបែបណាមកលើសមធម៌។ ជាការប្រសើរត្រូវពន្យល់នៅក្នុងពេលចាប់ផ្តើមថា វគ្គបណ្តុះបណ្តាលនេះគឺអំពីដំណើរការចូលរួមដែលលើកកម្ពស់ សមធម៌ តែមិនមែនអំពីថា តើសមធម៌មានន័យបែបណានោះឡើយ។ ទោះបីវគ្គបណ្តុះបណ្តាលនេះសម្របសម្រួលការពិភាក្សាអំពីថា តើសមធម៌អាចមានន័យបែបណា នៅក្នុងបរិបទខុសៗគ្នាក៏ដោយវគ្គនេះមិនមានផ្តល់និយមន័យណាមួយ អំពីសមធម៌ឡើយ។

# លំដាប់លំដោយនៃវគ្គបណ្តុះបណ្តាល

## លំដាប់លំដោយនៃវគ្គនេះ[៦]

ដ្យាក្រាមអំពីលំដាប់លំដោយនៃវគ្គបណ្តុះបណ្តាលនេះ បង្ហាញពីទិដ្ឋភាពរួមមួយនៃហេតុផល និងលំដាប់លំដោយ សម្រាប់វគ្គបណ្តុះបណ្តាលមួយដែលមានរយៈពេលប្រាំថ្ងៃ និងធាតុផ្សំសំខាន់ៗ ដែលអាចប្រើប្រាស់ក្នុងការរៀបចំកាលវិភាគនៃវគ្គនេះ។

**កែប្រែ**វិធីដែលខ្ញុំមើលឃើញ**ខ្លួនឯង** (ការគិតដែលផ្អែកលើសម្បត្តិ)

**តើសមធម៌ជាអ្វី** និងតើវា**ខុសគ្នា**បែបណាពីសមភាព?

**ហេតុអ្វីសមធម៌**សំខាន់នៅក្នុងបរិបទ REDD+ ព្រៃឈើ និងការប្រែប្រួលអាកាសធាតុ?

ចូរអធិប្បាយអំពី**បទពិសោធន៍ជាក់ស្តែងនៃសមធម៌** និងចំណុចចាប់ផ្តើមដើម្បីមានឥទ្ធិពលមកលើសមធម៌ (បរិបទ ការបែងចែក និងនីតិវិធី)

តើយើងអាចមានឥទ្ធិពលបែបណាលើសមធម៌ ដោយលើកកម្ពស់ នីតិវិធី និងឱកាសប្រសើរជាងមុនសម្រាប់**ការចូលរួម** (សមធម៌បែបនីតិវិធី)?

ពីការចូលរួម **ឈានទៅការពាក់ព័ន្ធដោយប្រសិទ្ធភាព** - ការពន្យល់អំពី **គោលគំនិត** និងការអនុវត្តរបស់ពួកគេ

តួនាទីនៃអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានដើម្បី **លើកកម្ពស់សមធម៌** តាមរយៈ **ការពាក់ព័ន្ធកាន់តែប្រសើរជាងមុន** និង**ការស្វែងយល់អំពីអំណាច**

អធិប្បាយអំពី**ជំនាញ ឧបករណ៍** និងបទ **ពិសោធន៍** សម្រាប់ការរៀបចំដំណើរការនៃការចូលរួម (**ការរៀបចំ**ដំណើរការ)

**តាមដាន**ការពាក់ព័ន្ធតាមបែបចូលរួម ដើម្បីកែលម្អសមធម៌

---

៦ លំដាប់ថ្នាក់ទាំងនេះនៅត្រូវកែសម្រួល អាស្រ័យលើទម្រង់នៃវគ្គបណ្តុះបណ្តាលរបស់អ្នក ប៉ុន្តែដ្យាក្រាមនេះផ្តល់នូវទិដ្ឋភាពរួមមួយ អំពីលំដាប់លំដោយសមហេតុផលនៃវគ្គបណ្តុះបណ្តាលមួយដែលមានរយៈពេលប្រាំថ្ងៃ ដែលអាចប្រើប្រាស់នៅក្នុងទម្រង់នៃវគ្គបណ្តុះបណ្តាលនេះ។

## រូបទី ៣៖ លំដាប់នៃការពាក់ព័ន្ធ និងការលើកកម្ពស់សមធម៌



# គ. តើសមធម៌ជាអ្វី?

**គោលបំណងនៃការរៀនសូត្រ**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹង៖




- ស្វែងយល់ និងពិភាក្សាការយល់ឃើញរបស់ពួកគាត់អំពីខ្លឹមសារនៃសមធម៌។
- អាចពន្យល់និយមន័យងាយៗនៃសមធម៌ដែលនឹងប្រើប្រាស់នៅក្នុងវគ្គបណ្តុះបណ្តាលនេះ។
- អាចពន្យល់អំពីភាពខុសគ្នារវាងសមធម៌ និងសមភាព និង
- បានពិភាក្សាអំពីថា តើគុណតម្លៃនៃសមធម៌ត្រូវបានឆ្លុះបញ្ចាំងបែបណាក្នុងពេលបច្ចុប្បន្ននេះ នៅក្នុងកិច្ចផ្តួចផ្តើម REDD+ នៅលំដាប់ថ្នាក់ខុសៗគ្នា។

**សម្ភារៈ**

ក្រដាសផ្ទាំងធំមួយ ហ្វឺត និយមន័យសមធម៌ ដែលត្រូវបិទភ្ជាប់លើជញ្ជាំង ផ្លែឈើធំមួយ (ដូចជាឪឡឹក) កាំបិតមុតមួយ ជ្រុញ ប័ណ្ណ អំពីគុណតម្លៃ ដែលដាច់ពីគ្នាសម្រាប់អ្នកដើរតួម្នាក់ៗ (ប័ណ្ណគុណតម្លៃនេះ អធិប្បាយអំពីតួនាទីរបស់អ្នកដើរតួម្នាក់ៗ ដែលពាក់ព័ន្ធនៅក្នុងសកម្មភាពនេះ និងគុណតម្លៃផ្ទាល់ខ្លួនដែលពួកគាត់ម្នាក់ៗ នឹងនាំមកបញ្ចូលក្នុងសកម្មភាពនេះ និងឯកសារអំណាន។



**ម៉ោង**

១២០ នាទី

## ជំហានអនុវត្ត

១. សូមពន្យល់ដល់ក្រុមនេះថា មេរៀននេះស្វែងយល់ខ្លឹមសារនៃសមធម៌។ អ្នកត្រូវផ្ដោតលើអត្ថន័យនៃសមធម៌មានន័យបែបណា នៅក្នុងស្ថានភាពជាក់ស្ដែងរបស់សិក្ខាកាមម្នាក់ៗ មុននឹងអ្នកផ្ដោតលើអត្ថន័យនៅក្នុងបរិបទ REDD+។

២. ដាក់តុមួយជាមួយកៅអីចំនួនប្រាំបួននៅពីមុខបន្ទប់ និងស្នើឱ្យអ្នកស្ម័គ្រចិត្តចំនួនប្រាំបួននាក់ដើម្បីចេញមុខដើរតួ។ សូមផ្ដល់ឱ្យអ្នកស្ម័គ្រចិត្តម្នាក់ៗ នូវប័ណ្ណគុណតម្លៃមួយសន្លឹក។ សូមបំភ្លឺទៅអ្នកស្ម័គ្រចិត្តថា ពួកគាត់ត្រូវសំដែងតួ និងប្រកាន់ជំហរជាបុគ្គល/បុគ្គលិកលក្ខណៈដែលមានចែងនៅលើប័ណ្ណគុណតម្លៃនោះ។ ពួកគាត់មិនត្រូវបង្ហាញប័ណ្ណនេះដល់អ្នកដទៃឡើយ នៅក្នុងពេលដែលសំដែងតួនោះ។ នេះជាលំហាត់សំខាន់មួយ ហើយអ្នកស្ម័គ្រចិត្តត្រូវតែដើរតួតាមការណែនាំដែលបានផ្ដល់ទៅ ឱ្យ ពួកគាត់នៅក្នុងប័ណ្ណ ឱ្យបានល្អបំផុតតាមតែអាចធ្វើបាន ដើម្បីធ្វើឱ្យមានជោគជ័យ។ ត្រូវប្រាកដថា អ្នកផ្ដល់កាំបិតមួយទៅឱ្យបុគ្គលដែលកាន់ប័ណ្ណដែលមានឈ្មោះថា "ម្ចាស់កាំបិត" និងដាក់ឪឡឹក (ឬផ្លែឈើដទៃទៀត) នៅពីមុខបុគ្គលដែល "បានរកឃើញផ្លែឈើ"។

៣. សូមពន្យល់ថា សិក្ខាកាមក្រៅពីនេះត្រូវធ្វើការសង្កេត និងស្ដាប់ ដោយយកចិត្តទុកដាក់នូវអ្វីដែលកើតឡើងនៅក្នុងដំណើរការនេះ។

៤. ពន្យល់ថា កិច្ចការរបស់ក្រុមអ្នកសំដែងតួ គឺត្រូវគិតអំពីគោលការណ៍សមធម៌សម្រាប់ការចែកផ្លែឈើ ដែលកំពុងប្រឈមចំពោះពួកគាត់បច្ចុប្បន្ននេះ ហើយពួកគាត់មានរយៈពេល ២០ នាទី ដើម្បីអនុវត្តកិច្ចការនេះ។

៥. សូមពន្យល់ថា អ្នកស្ម័គ្រចិត្តម្នាក់ៗគួរតែសំដែងតួរបស់ខ្លួននៅជុំវិញគុណតម្លៃទៅតាមប័ណ្ណដែលពួកគាត់មានក្នុងដៃ ដើម្បីមានឥទ្ធិពលមកលើការពិភាក្សានៅក្នុងដំណើរការនេះជាបន្តបន្ទាប់។ សូមបញ្ជាក់ថា ពួកគាត់ត្រូវព្យាយាមសំដែងឱ្យស្របគ្នានឹងឥរិយាបថ ឬ យោបល់របស់តួនោះ។ សូមឱ្យក្រុមនេះចាប់ផ្ដើមការសំដែង។

៦. នៅពាក់កណ្ដាលលំហាត់នេះ ត្រូវរំលឹកដល់នេះអំពីពេលដែលនៅសល់ និងគូសបញ្ជាក់ថា ពួកគាត់ត្រូវតែពុះផ្លែឪឡឹកនៅចុងរយៈពេល ២០នាទី។ ត្រូវរំលឹកដល់ក្រុមនេះឡើងវិញនៅពេលសល់ត្រឹម ៥នាទី បន្ទាប់មកនៅពេលអស់ម៉ោង។

៧. ប្រសិនបើក្រុមនេះមិនទាន់អាចបញ្ចប់ការសំដែងរបស់ខ្លួនបន្ទាប់ពីអស់ម៉ោងហើយនោះ ពួកគាត់ពុំចាំបាច់បន្តឡើយ។ ក្នុងករណីដែលពួកគាត់បញ្ចប់មុនរយៈពេល ២០នាទី អ្នកអាចចាប់ផ្ដើមធ្វើការឆ្លុះបញ្ចាំងជាបន្ទាន់ ដោយចាប់ផ្ដើមជាមួយអ្នកដែលចូលរួមដោយផ្ទាល់នៅក្នុងលំហាត់នេះ។

## ការឆ្លុះបញ្ចាំងសម្រាប់អ្នកស្ម័គ្រចិត្ត

- *តើអ្នកមានអារម្មណ៍បែបណា ក្នុងឋានៈជាសមាជិកសហគមន៍នៅក្នុងលំហាត់នេះ និងហេតុអ្វី?*
- *តើមានអ្វីកើតឡើងនៅក្នុងអំឡុងពេលនៃសកម្មភាពនេះ និងហេតុអ្វី?*
- *តាមយោបល់របស់អ្នក តើមានការចែកផ្លែឈើដោយសមធម៌ និង/ឬស្មើគ្នា ឬទេ?*
- *តើអ្នកគិតថា មានភាពខុសគ្នាអ្វីខ្លះរវាងសមធម៌ និងសមភាព?*
- *តើអ្វីដែលមានឥទ្ធិពលមកលើកិច្ចព្រមព្រៀង អំពីរបៀបចែកផ្លែឈើនោះឬទេ (សិទ្ធិ អំណាច ចំណេះដឹង និងការចំណាយ) និងអ្វីខ្លះដែលមានឥទ្ធិពលមកលើដំណើរការធ្វើសេចក្តីសម្រេចចិត្តនេះ (អំណាច តំណែង យេនឌ័រ ដំណើរការសម្រាប់ផ្តល់គំនិត ការធ្វើសេចក្តីសម្រេចចិត្ត និងតម្លាភាពព័ត៌មាន)?*

## ការឆ្លុះបញ្ចាំងសម្រាប់ការសង្កេត៖

- *តើដំណើរការនេះមានឥទ្ធិពលបែបណាមកលើលទ្ធផល?*
- *អ្នកណាមានឥទ្ធិពលលើសលុបនៅក្នុងការពិភាក្សានេះ និងហេតុអ្វី?*
- *តើសមាជិកទាំងអស់មានឱកាសដូចគ្នា ឬទេក្នុងការមានឥទ្ធិពលមកលើរបៀបនៃការពុះផ្លែឪឡឹក? តើមានភស្តុតាងអ្វីខ្លះដែលនាំឱ្យអ្នកធ្វើការសន្និដ្ឋានបែបនេះ?*
- *តាមទស្សនៈរបស់អ្នក តើគោលការណ៍ទាំងនេះត្រូវបានរៀបចំឡើងដោយសមធម៌ ឬទេ និងហេតុអ្វីទើបអ្នកគិតថាបែបនេះ?*
- *តើការចែករំលែកនេះឆ្លុះបញ្ចាំងគោលការណ៍ដែលមានការឯកភាព ឬទេ និងថាតើពួកគាត់ធ្វើការឆ្លុះបញ្ចាំងគោលការណ៍ទាំងនេះដោយរបៀបណា?*
- *តើអ្នកបានកែប្រែអ្វីខ្លះ ដែលទាក់ទងនឹងដំណើរការនេះ និងហេតុអ្វី?*

## ការឆ្លុះបញ្ចាំងសម្រាប់ក្រុមទាំងមូល៖

- *ផ្អែកលើការឆ្លុះបញ្ចាំងរបស់អ្នក តើរូបអ្នកក្នុងឋានៈជាសិក្ខាកាមផ្តោតលើអ្វីខ្លះ ដែលទាក់ទងនឹងសមធម៌ ពោលគឺអំពីការបែងចែកផ្លែឈើ ឬដំណើរការដែលសមាជិកសម្រេចនៅក្នុងការពុះចែកផ្លែឈើ?*
- *តើប្រការនេះទាក់ទងបែបណា ជាមួយសមធម៌នៅក្នុងបរិបទព្រៃឈើ និងការប្រែប្រួលអាកាសធាតុ?*

- *តើលំហាត់នេះអាចទាក់ទងនឹងគោលគំនិតអំពីសមធម៌ ក្នុងគម្រោង REDD+ដែរ ឬទេ? បើទាក់ទង តើដោយរបៀបណា?*
- *តើអ្នកអាចប្រៀបធៀបអ្វីខ្លះនៅលើប័ណ្ណគុណតម្លៃ នៅក្នុងបរិបទ REDD+?*
- *តើមានអ្វីកើតឡើង នៅក្នុងដំណើរការដែលអ្នកបានឃើញក្នុងបរិបទរបស់អ្នកផ្ទាល់ទាក់ទងនឹង REDD+?*
- *តើអ្នកគិតថា តម្លៃនៃសមធម៌បច្ចុប្បន្ននេះត្រូវបានអនុវត្តក្នុងកម្រិតណា ដែលពាក់ព័ន្ធនឹង REDD+ នៅលំដាប់ថ្នាក់ខុសៗគ្នា? ហេតុអ្វីបានជាក្រុមរបស់អ្នកគិតបែបនេះ?*

៨. នៅក្រោយការឆ្លុះបញ្ចាំង ស្នើឱ្យសិក្ខាកាមវិលមកកៅអីរបស់ខ្លួនវិញ និងត្រូវពន្យល់ថា មេរៀននេះគ្រាន់តែបង្កើតឱ្យមានការពិភាក្សាខ្លីអំពីគោលគំនិតនៃសមធម៌ប៉ុណ្ណោះ។

៩. ត្រូវពិនិត្យគោលការណ៍នានាដែលក្រុមនេះបានរៀបចំនៅក្នុងអំឡុងពេលនៃសកម្មភាពពុះផ្លែឪឡឹក។ ប្រសិនបើក្រុមនេះ ពុំសរសេរគោលការណ៍ទាំងនេះទេ សូមជួយពួកគាត់ ដើម្បីរំលឹករំលឹកឡើងវិញនូវគោលការណ៍នានា ដោយផ្អែកលើអ្វីដែលពួកគាត់បានអនុវត្ត។



១០. ស្នើសិក្ខាកាមឱ្យឆ្លុះបញ្ចាំងអំពីគោលការណ៍ទាំងនេះ។ ក្រោយពីបានពាក់ព័ន្ធនៅក្នុងលំហាត់នេះ តើអ្នកអាចឱ្យនិយមន័យ"សមធម៌"បានយ៉ាងដូចម្តេច? សូមសរសេរចម្លើយនានារបស់ពួកគាត់នៅលើក្រដាសផ្ទាំងធំ និងដាក់នៅខាងមុខបន្ទប់។

១១. សូមបង្ហាញជូនយោបល់តបរបស់អ្នកអំពីនិយមន័យសមធម៌នៅក្នុងបរិបទនៃ REDD+ (សូមអានខាងក្រោម) និង ពិភាក្សា ដោយប្រៀបធៀបជាមួយនិយមន័យខុសៗគ្នាពីសិក្ខាកាមដែលបានធ្វើសេចក្តីសំយោគ។ សូមផ្សារភ្ជាប់ការពិភាក្សានេះជាមួយអ្វីដែលបានពីការពិភាក្សានៅក្នុងអំឡុងពេលនៃលំហាត់ផ្លែឈើនេះ។

**សមធម៌ គឺជាភាពសមស្របនៃការប្រព្រឹត្ត សម្រាប់គ្រប់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងអំឡុងនៃនីតិវិធី ដើម្បីរៀបចំ និងអនុវត្តគោលនយោបាយ និងនៅក្នុងការបែងចែកធនធាន និងថ្លៃចំណាយ អនុលោមតាមគោលការណ៍ដែលបានឯកភាពគ្នា។**

សូមបិទភ្ជាប់និយមន័យអំពីសមធម៌នេះនៅទីកន្លែងដែលងាយមើលឃើញលើជញ្ជាំង ដើម្បីអាចសង្កេតឃើញនៅទូទាំងអំឡុងពេលនៃវគ្គបណ្តុះបណ្តាលនេះ។

១២. សូមគូសបញ្ជាក់ពាក្យ "ក្នុងអំឡុងពេលនៃនីតិវិធី" និង "ក្នុងការបែងចែក" ដោយប្រើហ្វឺត។ សូមធ្វើការឆ្លុះបញ្ចាំងត្រឡប់ទៅការសង្កេតពីដើមដំបូងរបស់សិក្ខាកាម។ ត្រូវឱ្យប្រាកដថាសិក្ខាកាមនៅ

តែយល់អំពីភាពខុសគ្នារវាងសមធម៌ និងសមភាព ដោយផ្សារភ្ជាប់និយមន័យនេះ ដែលអ្នកទើបតែបានបិទភ្ជាប់ទៅនឹងជញ្ជាំង។

១៣. សូមសួរក្រុមនេះថា តើពួកគាត់គិតថា "គោលការណ៍ដែលបានឯកភាពគ្នា" មានន័យបែបណានៅក្នុង REDD+ ក្នុងបរិបទរបស់ពួកគាត់ផ្ទាល់។ សូមយោងទៅប្រព័ន្ធការពារសុវត្ថិភាព និងស្តង់ដារសង្គម និងបរិស្ថាន ប៉ុន្តែសូមពន្យល់ផងដែរថា ប្រព័ន្ធការពារសុវត្ថិភាពមានន័យត្រឹមតែដើម្បីធានាថា ពុំបង្កគ្រោះថ្នាក់ប៉ុណ្ណោះ - វាពុំតម្រូវឱ្យមានការកែលម្អស្ថានភាពបច្ចុប្បន្នឡើយ។

១៤. សូមបូកសរុបដោយពន្យល់ថា មេរៀនបន្តទៀតនឹងពន្យល់ពិស្តារអំពីការប្រើប្រាស់ និងសភាពជាក់ស្តែងនៃសមធម៌ ហើយនេះគ្រាន់តែជាសេចក្តីផ្តើមប៉ុណ្ណោះ។

---

## កំណត់សំគាល់របស់គ្រូបង្ហាត់

សូមកុំព្យាយាមមានឥទ្ធិពលមកលើរបៀប ដែលអ្នកស្ម័គ្រចិត្តកាត់ផ្លែឈើតាំងពីដើមដំបូងនៃលំហាត់នេះ ដោយយោងទៅសមធម៌ និងសមភាព។ ប្រសិនបើអ្នកស្ម័គ្រចិត្តសម្រេចកាត់ផ្លែឈើជាចំណែកស្មើគ្នា សូមប្រើប្រាស់សំណួរឆ្លុះបញ្ចាំងដូចគ្នា ប៉ុន្តែទាញយកតួនាទីម្នាក់ៗ ដើម្បីគូសបញ្ជាក់អំពីភាពខុសគ្នាណាមួយ។ គុណតម្លៃនៃលំហាត់នេះ គឺការដកស្រង់បទពិសោធន៍ ដែលនឹងពុំបានទទួលជោគជ័យឡើយ ប្រសិនបើដំណើរការនេះត្រូវបានរំខានដោយគ្រូបង្ហាត់។

ប្រសិនបើអ្នកមានក្រុមធំ អ្នកអាចបង្កើតតួបន្ថែម។ ប្រសិនបើអ្នកមានក្រុមតូច អ្នកអាចពុំចាំបាច់ឱ្យមានអ្នកសង្កេតការណ៍ឡើយ ឬ ពុំចាំបាច់មានតួខ្លះឡើយ។ ទោះជាយ៉ាងណាក៏ដោយ ត្រូវប្រុងប្រយ័ត្នក្នុងការរក្សាតុល្យភាពនៃតួនានាដើម្បីរក្សាភាពចម្រុះនៃថាមវន្ត និងតំណាងឱ្យទិដ្ឋភាពខុសៗគ្នាដែលអាចមានឥទ្ធិពលមកលើសមធម៌នៃដំណើរការ និងលទ្ធផល។

ឧទាហរណ៍ខ្លះៗនៃគោលការណ៍នានាសម្រាប់ការចែករំលែកផ្លែឈើ មានដូចតទៅ (ទាំងនេះគ្រាន់តែជាយោបល់សម្រាប់គ្រូបង្ហាត់តែប៉ុណ្ណោះ។ សិក្ខាកាមត្រូវបង្កើតគោលការណ៍របស់ខ្លួនផ្ទាល់ដែលអាចស្រដៀងគ្នានេះ)៖

> អ្នកកាន់កាប់សិទ្ធិលើឈើហូបផ្លែ ទទួលបាន ៧៥% នៃផ្លែឈើ ឬ ៧៥% នៃប្រាក់ចំណូលពីការលក់ផ្លែឈើនេះ។
>
> អ្នករកឃើញ ទទួលបាន ៥% ឬ គ្រាប់ពូជខ្លះសម្រាប់ដាំដាំឈើហូបផ្លែបន្ថែមទៀត។
>
> បុរសអ្នកផ្សំថ្នាំ ទទួលបាន ១០% នៃផ្លែឈើសម្រាប់ការប្រើប្រាស់របស់គាត់។
>
> អ្នកសល់ក្រៅពីនេះអាចបែងចែកស្មើគ្នាក្នុងចំណោមអ្នកដែលមានដីស្រែចំការនៅក្នុងភូមិ។

សូមជៀសវាងការពិភាក្សា នៅក្នុងក្រុមរួមអំពីបញ្ហាទាំងអស់ដែលទាក់ទងនឹងសមធម៌ ក្នុង REDD+។ ចំណុចនេះនឹងមាននៅក្នុងមេរៀនស្តីពីសមធម៌មានសារៈសំខាន់នៅក្នុង REDD+។ ត្រូវដឹងថាសិក្ខាកាមខ្លះ អាចចង់ពិភាក្សាអំពីតួនាទីរបស់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន នៅក្នុងមេរៀននេះ ប៉ុន្តែសូមព្យាយាមផ្តោតលើគោលបំណងខ្លះៗនៃមេរៀននេះ។

# ការកាត់ផ្លែឈើ

## ការបង្កើតឆាក

សូមអានអត្ថបទដែលសរសេរជាអក្សរដិតច្បាស់ ដើម្បីឱ្យក្រុមទាំងមូលបានស្តាប់ឮដែល រួមទាំងអ្នកសង្កេតការណ៍ មុននឹងចែកប័ណ្ណគុណតម្លៃ។ សូមផ្តល់ផ្លែឈើទៅអ្នកស្ម័គ្រចិត្ត ដែលមានតួនាទីជា "អ្នកបេះផ្លែឈើ" និងកាំបិតមួយទៅ "ម្ចាស់កាំបិត" និងស្នើពួកគាត់ឱ្យចាប់ផ្តើម។ សូមពន្យល់ថាពួកគាត់ត្រូវពុះផ្លែឈើមួយនៅក្រោយរយៈពេល ២០នាទី។

**អ្នកទាំងអស់គ្នាជាសមាជិកនៃសហគមន៍មួយ។ ថ្ងៃនេះបុរសម្នាក់បេះបានផ្លែឈើដ៏កម្រមួយមកពីព្រៃនៅក្បែរភូមិ ដែលពួកគាត់យល់ថាអាចប្រើប្រាស់ជាឱសថយ៉ាងស័ក្តិសិទ្ធ ប្រសិនបើយកមកចាត់ចែង និងបរិភោគបានត្រឹមត្រូវ។ នៅក្នុងរយៈពេល ២០នាទី ខាងមុខនេះ អ្នកត្រូវបង្កើត និងឯកភាពគ្នាលើគោលការណ៍សមធម៌ ដែលនឹងផ្តល់ជាការណែនាំដល់ក្រុមរបស់អ្នកនៅក្នុងការបែងចែកផ្លែឈើនេះ។ នៅក្រោយរយៈពេល២០នាទី អ្នកត្រូវកាត់ផ្លែឈើនេះ បើពុំនោះទេផ្លែឈើនេះនឹងរលាយបាត់ និងបាត់បង់ភាពស័ក្តិសិទ្ធជាឱសថ។**

(សូមចម្លងខ្លឹមសារខាងក្រោមនេះ ដាក់ក្នុងប័ណ្ណតម្លៃ សម្រាប់សិក្ខាកាមជាអ្នកស្ម័គ្រចិត្តសំដែង)

### ម្ចាស់កាំបិត



អ្នកមានកាំបិតយ៉ាងមុតមួយ សម្រាប់កាត់ផ្លែឈើនេះដើម្បីបែងចែកក្នុងចំណោមសមាជិកសហគមន៍។ នេះជាកាំបិតរបស់អ្នក ហើយអ្នកត្រូវចំណាយពេលដើម្បីរក្សាកាំបិតនេះឱ្យនៅតែមុតជាដរាប ហើយឥឡូវអ្នកមានកាំបិតនេះជាប់ជាមួយ។ គ្មានសមាជិករូបណានៅក្នុងក្រុមនេះមានកាំបិតដូចរបស់អ្នកនេះឡើយ។ អ្នកមិនទំនងជាអនុញ្ញាតឱ្យក្រុមនេះប្រើប្រាស់កាំបិតរបស់អ្នកដោយពុំបានទទួលចំណែកយ៉ាងច្រើននៃផ្លែឈើនេះឡើយ។អ្នកជឿថា ប្រសិនបើពួកគាត់ព្យាយាមរកកាំបិតផ្សេងទៀត ពួកគាត់នឹងត្រូវបាត់បង់ពេលដ៏មានតម្លៃ ហើយមនុស្សជាច្រើនទៀតនឹងចង់បានចំណែកផ្លែឈើនេះផងដែរ។



## មន្ត្រីឧទ្យានជាតិ

អ្នកគឺជាមន្ត្រីរដ្ឋាភិបាលដែលមានភារៈទទួលខុសត្រូវការពារដើមឈើនានា និងព្រៃឈើដែលជាកន្លែងបេះផ្លែឈើនេះ។ នៅពេលថ្មីៗនេះ អ្នកបានកត់សំគាល់ឃើញថាអ្នកភូមិទំនងជាបានចូលក្នុងឧទ្យានជាតិដោយគ្មានការអនុញ្ញាត និងប្រមូលផលគ្រប់យ៉ាង ដែលនេះជាសកម្មភាពល្មើសច្បាប់។ រូបអ្នកមានការព្រួយបារម្ភថា ប្រសិនបើសមាជិកសហគមន៍បរិភោគផ្លែឈើនេះ ក្រោយមកពួកគាត់នឹងវិលត្រឡប់មកកន្លែងនេះវិញ ហើយអាចបេះផ្លែឈើដទៃទៀតដែលស្ថិតក្រោមកិច្ចការពារ។ អ្នកចង់ដកហូតផ្លែឈើនេះទៅតាមច្បាប់ ហើយអ្នកមានសមត្ថកិច្ចដើម្បីផាកពិន័យចំពោះអ្នកណាដែលចូលក្នុងឧទ្យាននេះដោយគ្មានការអនុញ្ញាត - អ្នកអាចប្រើប្រាស់អំណាចនេះ ដើម្បីជាអំណះអំណាងនៅក្នុងការចរចា។ ទោះជាយ៉ាងណាក៏ដោយអ្នកបានឮក្រៅផ្លូវការជាច្រើនអំពីសារៈសំខាន់នៃផ្លែឈើនេះហើយអ្នកក៏ចង់សាកល្បងខ្លះផងដែរ។



## អ្នកបេះផ្លែឈើ

អ្នកបានទៅដងទឹក រំពេចនោះអ្នកបានឃើញផ្លែឈើមួយនៅក្នុងព្រៃនេះ ដែលស្ថិតនៅចម្ងាយប្រមាណ ៥គ.ម ពីភូមិ។ អ្នកបានកាន់ផ្លែឈើនេះមកភូមិវិញដោយប្រុងប្រយ័ត្ន ដោយពុំធ្វើឱ្យប៉ះទង្គិចអ្វីឡើយ។ ប៉ុន្តែដើម្បីធ្វើបែបនេះបាន អ្នកត្រូវទុកចោលទឹកនៅឯព្រៃ ដែលជាកន្លែងអ្នកទៅដងទឹកនោះ។ អ្នកមានអារម្មណ៍ថា សមនឹងបានចំណែកមួយនៃផ្លែឈើនេះ ជាពិសេសដោយសារតែអ្នកបានចំណាយពេលស្ទើរតែពេញមួយថ្ងៃយកផ្លែឈើនេះមកភូមិ ហើយឥឡូវនេះអ្នកកំពុងអង្គុយនៅក្នុងការប្រជុំនេះ។ អ្នកក៏ពុំបានទឹកសម្រាប់គ្រួសារដែរ ថ្ងៃនេះដោយសារតែអ្នកបានទុកចោលទឹកនៅក្នុងព្រៃ ដើម្បីអាចយកផ្លែឈើដ៏មានតម្លៃនេះមកភូមិ។



## ម្ចាស់ដើមឈើតាមប្រពៃណី

តាមប្រពៃណីអ្នកគឺជាម្ចាស់ លើដើមឈើហូបផ្លែនេះ ពោលគឺជាការទាមទារមួយដែលអាចអនុវត្តបាននៅក្រោមច្បាប់នៅក្នុងមូលដ្ឋាន មុនពេលដែលបានកែប្រែទៅជាច្បាប់ជាតិ ដែលបានដាក់ដើមឈើទាំងនេះនៅក្រោមកិច្ចការពារនៃសមត្ថកិច្ចឧទ្យានជាតិ។ ដូច្នេះអ្នកនៅតែគិតអំពីដើមឈើនេះថាជារបស់ខ្លួន របស់កូនចៅ និងបុព្វបុរសរបស់អ្នក។ អ្នកបានសង្កេតឃើញថា ផ្លែឈើជិតទុំសម្រាប់បេះនៅក្នុងពេលណាមួយខាងមុខ ប៉ុន្តែអ្នកជាប់រវល់នៅឯស្រែ និងពុំមាន ពេលគ្រប់គ្រាន់ដើម្បីពិនិត្យស្ថានភាពផ្លែឈើនេះឡើយនៅពេលថ្មីៗនេះ។ អ្នកពុំបានបេះផ្លែឈើនេះជាយូរមកហើយហើយអ្នកបានដឹងច្បាស់ណាស់ អំពីគុណតម្លៃនៃផ្លែឈើនេះសម្រាប់ជាឱសថ។ ជាសំណាងមិនល្អ ទោះបីអ្នកដឹងពីគុណតម្លៃនៃផ្លែឈើនេះសម្រាប់ជាឱសថក៏ដោយ សមាជិកគ្រួសាររបស់អ្នកដែលមានចំណេះដឹងអំពីរបៀបចាត់ចែងផ្លែឈើនេះជាឱសថ បានបាត់បង់ជីវិតទៅហើយ។ អ្នកត្រូវស្វែងរកជនណាម្នាក់ផ្សេងទៀតក្នុងមូលដ្ឋាន ដែលដឹងអំពីវិធីផ្សំផ្លែឈើនេះជាឱសថ និងប្រើប្រាស់ឱ្យមានប្រសិទ្ធភាពបំផុត។ នៅក្រោមប្រពៃណីតាមទម្លាប់នៅក្នុងភូមិនេះ អ្នកមានសិទ្ធិលក់ផ្លែឈើនេះដើម្បីយកប្រាក់ចំណូល។



## ចៅស្រីរបស់ម្ចាស់ដើមឈើព្រៃហូបផ្លែតាមប្រពៃណី

អ្នកគឺជាចៅស្រីនៃម្ចាស់តាមប្រពៃណីនៃដើមឈើហូបផ្លែនេះ។ អ្នកបានចូលរួមជាមួយជីតានៅក្នុងកិច្ចប្រជុំនេះផងដែរ។ អ្នកអាចនិយាយបានតែក្នុងករណីដែលជីតារបស់អ្នកអនុញ្ញាតតែប៉ុណ្ណោះ។ តាមធម្មតា អ្នកចូលទៅក្នុងព្រៃនេះជាមួយមិត្តភក្តិ និងបានរងចាំផ្លែឈើនេះជ្រុះ។ អ្នកមិនបានចូលទៅក្នុងព្រៃនេះអស់រយៈពេលជាយូរមកហើយដែរ ហើយឥឡូវនេះអ្នកចង់រកឃើញផ្លែឈើនេះណាស់។ អ្នកចាប់អារម្មណ៍ជាខ្លាំងថា ផ្លែឈើនេះជាកម្មសិទ្ធិរបស់គ្រួសារខ្លួន និងមិនមែនជារបស់អ្នកដទៃណាម្នាក់ឡើយ។ ទោះជាយ៉ាងណាក៏ដោយ អ្នកមានការអៀនខ្មាស់ក្នុងការនិយាយស្តី ហើយអ្នកអាចនិយាយទាក់ទងនឹងកិច្ចការនៃច្បាប់តាមប្រពៃណី ប្រសិនបើជីតារបស់អ្នកអនុញ្ញាតតែប៉ុណ្ណោះ។



## អ្នកនាំពាក្យនៅក្នុងភូមិ

អ្នកមានកាំបិតយ៉ាងមុតមួយសម្រាប់កាត់ផ្លែឈើនេះ ដើម្បីបែងចែកក្នុងចំណោមសមាជិកសហគមន៍។ នេះជាកាំបិតរបស់អ្នក ហើយអ្នកត្រូវចំណាយពេលដើម្បីរក្សាកាំបិតនេះឱ្យនៅតែមុតជាដរាប ហើយឥឡូវអ្នកមានកាំបិតនេះជាប់ជាមួយ។ គ្មានសមាជិករូបណានៅក្នុងក្រុមនេះមានកាំបិតដូចរបស់អ្នកនេះឡើយ។ រូបអ្នកពុំជាប់ទាក់ទងជាសាច់ញាតិជាមួយគ្រួសារដែលមានសិទ្ធិតាមប្រពៃណីចំពោះដើមឈើនេះឡើយ ប៉ុន្តែរូបអ្នក គឺជាមនុស្សដែលបានកត់សំគាល់ថាបុរសម្នាក់បានបេះផ្លែឈើនេះ និងយកមកក្នុងភូមិនេះ។ អ្នកបានប្រាប់ទៅម្ចាស់តាមប្រពៃណីអំពីដើមឈើនេះ ដោយបានដើរអស់រយៈពេលកន្លះថ្ងៃ ដើម្បីស្វែងរកគាត់នៅឯស្រែ។ ជើងរបស់អ្នកឈឺដោយសារតែបានដើរជាច្រើនម៉ោង ដើម្បីស្វែងរកម្ចាស់ និងបន្ទាប់មកវិលត្រឡប់មកភូមិវិញ។ អ្នកជឿថា ប្រសិនបើអ្នកមិនបានឃើញបុរសនេះយកផ្លែឈើមកភូមិទេនោះ ម្ចាស់តាមប្រពៃណីនឹងពុំបានដឹងអំពីរឿងនេះឡើយ ដូច្នេះគាត់ជំពាក់រូបអ្នកជាច្រើន។ អ្នកចង់ឱ្យម្ចាស់តាមប្រពៃណីនេះផ្តល់រង្វាន់ជាភាគចំណែកមួយនៃផ្លែឈើនេះ។



## អ្នកឯកទេសឱសថនៅក្នុងភូមិ

រូបអ្នកបានទទួលការគោរពកោតខ្លាច និងមានបទពិសោធន៍ជាគ្រូឱសថបូរាណ។ អ្នកមានចំណេះដឹងជាច្រើនអំពីរបៀបផ្សំថ្នាំ និងកែច្នៃផ្លែឈើនេះដើម្បីបង្កើតជាឱសថសក្តិសិទ្ធ។ អ្នកបានដឹងថាម្ចាស់ដើមឈើនេះ និងអ្នកផ្សេងទៀតមួយចំនួន នៅក្នុងស្រុកនេះមានបទពិសោធន៍ពិតប្រាកដក្នុងការបង្កើតឱសថពីផ្លែឈើនេះ។ អ្នកត្រៀមខ្លួនជាស្រេច ដើម្បីចែករំលែកចំណេះដឹងរបស់អ្នក ប៉ុន្តែក្នុងករណីដែលមានការដោះដូរជាមួយ យ៉ាងហោចណាស់ចំណែកស្មើគ្នានៃផ្លែឈើនេះជាមួយម្ចាស់ដើមឈើនេះ។



## អ្នកជិតខាង

រូបអ្នក គឺជាអ្នកជិតខាងនៃម្ចាស់តាមប្រពៃណីលើឈើហូបផ្លែនេះ។ ចៃដន្យរូបអ្នកមានវត្តមាននៅទីនោះ ក្នុងពេលដែលអ្នកជិតខាងរបស់អ្នកវិលត្រឡប់មកពីស្រែវិញ ជាមួយអ្នកនាំពាក្យក្នុងភូមិនេះ ដែលបានប្រាប់អំពីដំណឹងនេះថា មានអ្នកណាម្នាក់បានរកឃើញផ្លែឈើនេះ។ អ្នកមានអារម្មណ៍ថា មានសិទ្ធិក្នុងការទទួលចំណែកខ្លះនៃផ្លែឈើនេះ ដោយសារនៅពេលថ្មីៗនេះ អ្នកបានជួយម្ចាស់ដើមឈើតាមប្រពៃណីនេះជាច្រើន។ អ្នកបានឮរឿងរ៉ាវជាច្រើនអំពីសារៈសំខាន់នៃផ្លែឈើនេះជាឱសថ ហើយអ្នកចង់សាកល្បងជាខ្លាំង។ ដូច្នេះអ្នកព្យាយាមដើម្បីឱ្យប្រាកដថា ផ្លែឈើនេះត្រូវបានចែកស្មើគ្នាក្នុងចំណោមមនុស្សទាំងអស់នៅក្នុងការប្រជុំនេះ។



## មេភូមិ

អ្នកគឺជាមេភូមិ ហើយអ្នកបានមកចូលរួមនៅក្នុងការប្រជុំនេះដោយសារតែអ្នកបាន ឮការពិភាក្សានេះក្នុងចំណោមអ្នកភូមិ។ ទោះបីអ្នកបានក្លាយជាមេភូមិជាយូរមកហើយក៏ដោយនៅក្នុងភូមិនេះ អ្នកពុំធ្លាប់បានសាកល្បងផ្លែឈើនេះ ឬ មានបទពិសោធន៍ជាមួយគុណតម្លៃជាឱសថនៃផ្លែឈើនេះឡើយ។ អ្នកមើលឃើញថានេះជាឱកាសមួយសម្រាប់អ្នកក្នុងការសាកល្បង ក៏ដូចជាប្រើប្រាស់អំណាចរបស់ខ្លួន ដើម្បីឱ្យប្រាកដថា បញ្ហានេះមិនបង្កជាទំនាស់ឡើយនៅក្នុងភូមិមួយនេះ។



## បង្កើតតួផ្សេងទៀត

ប្រសិនបើអ្នកមានក្រុមធំ និងត្រូវពង្រីកចំនួនតួ អ្នកអាចបន្ថែមតួទៀតបាន។

# តើសមធម៌ ដូចគ្នានឹងសមភាព ឬទេ?

សមធម៌ត្រូវបានឱ្យនិយមន័យនៅក្នុងវចនានុក្រមភាសាអង់គ្លេស "The Oxford English Dictionary" ថាជា" គុណភាពនៃភាពស្មើគ្នា ឬ ត្រឹមត្រូវ យុត្តិធម៌ មិនលំអៀង ការចាត់ចែងបានស្មើភាព។" វាជាប់ទាក់ទងជិតស្និទ្ធទៅនឹង គោលគំនិតអំពីយុត្តិធម៌សង្គម។

## សមធម៌មិនដូចគ្នានឹងសមភាពទេ




សមធម៌ត្រូវបានចាត់ទុកថា ជាគោលការណ៍នៃភាពស្មើគ្នា ប៉ុន្តែមិនមែនជាគោលគំនិតដូចគ្នាឡើយ។ **សមភាព** សំដៅលើមនុស្សទាំងអស់ស្មើភាពគ្នាទោះជាក្នុងបរិបទណាក៏ដោយ។សមធម៌គិតបញ្ចូលថ្លៃចំណាយផលចំណេញ និងការទទួលខុសត្រូវនៅក្នុងក្របខ័ណ្ឌមួយនៃគោលការណ៍ ដែលបានបង្កើតឡើងអំពីភាពត្រឹមត្រូវ។ គេកម្រសម្រេចគោលការណ៍ សមធម៌ខាងលទ្ធផលណាស់ ប្រសិនបើគ្មានដំណើរការដោយ សមធម៌ ដែលផ្ដល់ឱកាសស្មើគ្នា សម្រាប់ការចូលរួមបើទោះជាឋានៈ និងតំណែងបែបណាក៏ដោយ។ ក្នុងបរិបទនៃពិភពលោកជាក់ស្ដែងប្រការសំខាន់ គឺ**អ្នកណា**កំណត់ និងគិតគូរអំពីដំណើរការសម្រាប់ការបង្កើតប៉ារ៉ាម៉ែត្រអំពីសមធម៌។ ដំណើរការនេះ មិនទំនងជាអាចរាប់បញ្ចូលអ្នកទាំងអស់ដែលចាត់ទុកខ្លួនឯងថា សមនឹងទទួលបានភាគចំណែកឡើយ។ អ្នកណាក៏ដោយដែលបង្កើតដំណើរការនេះ ត្រូវតែយកចិត្តទុកដាក់ចំពោះបរិបទជាក់លាក់នេះ។

## តើសមធម៌មានន័យបែបណានៅក្នុងបរិបទនៃការអភិវឌ្ឍនៅថ្នាក់មូលដ្ឋាន?

សមធម៌មិនមែនជាគោលគំនិតថ្មីមួយឡើយនៅក្នុងដំណើរការអភិវឌ្ឍន៍។ នៅក្នុងន័យចង្អៀតវាមានន័យថា ជាចាំបាច់គេត្រូវមានកម្រិតអប្បបរមានៃប្រាក់ចំណូល ដែលជានាស្តង់ដាររស់នៅជាមូលដ្ឋាន និងគុណភាពបរិស្ថានដែលមិនឱ្យអ្នកណាម្នាក់ស្ថិតនៅទាបជាងនេះឡើយ។ នៅក្នុងសហគមន៍មួយវាអាចមានន័យថា មនុស្សគ្រប់រូបគួរតែមានសិទ្ធិស្មើគ្នា ក្នុងការទទួលបានធនធានសហគមន៍ និងឱកាស ហើយក៏គ្មានបុគ្គល ឬក្រុមណាមួយត្រូវទទួលសំណើឱ្យរ៉ាប់រងបន្ទុកការងារបរិស្ថានច្រើនជាងអ្នកដទៃទៀតនៅក្នុងសហគមន៍ ដោយសារតែលទ្ធផលនៃគោលនយោបាយ ឬសកម្មភាពរបស់អ្នកខាងក្រៅឡើយ។ ជាទូទៅ មានការឯកភាពថា សមធម៌មានន័យថា តម្រូវការឱ្យមានភាពត្រឹមត្រូវ (មិនចាំបាច់តែសមភាពឡើយ) នៅក្នុងការបែងចែកផលចំណូល និងការខាតបង់ និងសិទ្ធិសម្រាប់មនុស្សគ្រប់រូបក្នុងការទទួលបានការរស់នៅតាមគុណភាព និងស្តង់ដារដែលអាចទទួលយកបាន។

គោលគំនិតអំពីសមធម៌មានបង្កប់យ៉ាងជ្រៅនៅក្នុងច្បាប់អន្តរជាតិ។ សេចក្ដីប្រកាសជាសកលអំពីសិទ្ធិមនុស្សចែងថា "ការទទួលស្គាល់ភាពថ្លៃថ្នូរ និងសិទ្ធិស្មើគ្នា ដែលមិនអាចកាត់ផ្ដាច់បាននៃគ្រប់សមាជិកទាំងអស់ក្នុងគ្រួសារមនុស្ស គឺជាមូលដ្ឋានគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក"[៧] ( Weiss, 1990, p. 9 )។ សមធម៌អាចយកទៅអនុវត្តទូទាំងសហគមន៍ ប្រជាជាតិ និងរវាងជំនាន់មនុស្ស។ សមភាពយេនឌ័រ គឺជាសមាសភាគសំខាន់មួយនៃសមធម៌ ដោយសារសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី គឺជាមូលដ្ឋានគ្រឹះសម្រាប់សមិទ្ធិកម្មលទ្ធផលនៃការអភិវឌ្ឍដោយចីរភាព និង ប្រសិទ្ធភាព។

នៅទូទាំងពិភពលោកមានវិសមភាពជាច្រើន ដោយរាប់ចាប់ពីការចូលរួម រហូតដល់ការរួមបញ្ចូលនៅក្នុងសេដ្ឋកិច្ច។ REDD+ និងអន្តរាគមន៍កាត់បន្ថយការប្រែប្រួលអាកាសធាតុដែលផ្អែកលើព្រៃឈើ នៅពុំទាន់បានពិចារណាពេញលេញនៅឡើយទេអំពីការពាក់ព័ន្ធនៃវិសមភាពទាំងនេះ។

## តើសមធម៌ជាអ្វី នៅក្នុងបរិបទនៃព្រៃឈើ ការប្រែប្រួលអាកាសធាតុ និង REDD+ ?

នៅក្នុងសេចក្ដីថ្លែងការណ៍នានាអំពី REDD+ មកទល់ពេលនេះ ការយកចិត្តទុកដាក់ បានផ្ដោតជាទូទៅលើសមធម៌អន្តរជាតិ ដែលខុសពីគោលនយោបាយជាតិ និងសមធម៌នៅសហគមន៍មូលដ្ឋាន។ សមធម៌អន្តរជាតិ នៅក្នុងបរិបទនេះ សំដៅលើការផ្ដោតចំពោះការទទួលខុសត្រូវនៃប្រទេសឧស្សាហកម្មលើការបញ្ចេញកាបូន និងកាតព្វកិច្ចស្របគ្នានៃប្រទេសទាំងនោះក្នុងការផ្ដល់ការគាំទ្រហិរញ្ញវត្ថុ ដើម្បីជួយប្រទេសកំពុងអភិវឌ្ឍន៍សម្រេចបានការកាត់បន្ថយការបញ្ចេញការបូន។ កង្វល់អំពីសមធម៌នៅថ្នាក់ជាតិទាក់ទងនឹងផលប៉ះពាល់នៃគម្រោង REDD+ មកលើរបរចិញ្ចឹមជីវិត សិទ្ធិកាន់កាប់សិទ្ធិលើកាបូន និងការចូលរួមសមស្រប នៅក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្ត។ ក្នុងប្រទេសខ្លះ កង្វល់អំពីសមធម៌កំពុងកើតចេញពីគម្រោង និងដំណើរការនានានៅថ្នាក់មូលដ្ឋាន ប៉ុន្តែវានៅពុំទាន់ច្រើនលើសលប់នៅក្នុងសេចក្ដីថ្លែងការណ៍នានាឡើយ។

## តើមានអ្វីខ្លះកំពុងអនុវត្តដើម្បីធានាសមធម៌ក្នុងគោលនយោបាយ និងអន្តរាគមន៍លើការប្រែប្រួលអាកាសធាតុ? តើប្រព័ន្ធការពារសុវត្ថិភាពជាចម្លើយសម្រាប់កែលម្អសមធម៌ដែរ ឬទេ ?

សព្វថ្ងៃនេះពាក្យថា "ប្រព័ន្ធការពារសុវត្ថិភាព" ត្រូវបានប្រើប្រាស់ នៅក្នុងស្តង់ដារអន្តរជាតិ និងក្របខ័ណ្ឌជាតិនានាសម្រាប់ REDD+ ដើម្បីការពារសិទ្ធិសហគមន៍មូលដ្ឋាន និងធានាថា ពួកគាត់មានឱកាសសមរម្យ ដើម្បីចូលរួមនៅក្នុងការបង្កើត និងអនុវត្តគោលនយោបាយ និងគម្រោងនានាស្ដីពី ការប្រែប្រួលអាកាសធាតុដែលនឹងមានឥទ្ធិពលមកលើពួកគាត់ និងការចិញ្ចឹមជីវិតរបស់ពួកគាត់។ និយាយម្យ៉ាងទៀតថា ប្រព័ន្ធការពារសុវត្ថិភាពទទួលស្គាល់ថា សហគមន៍មូលដ្ឋានមានផលប្រយោជន៍មួយ និងមានតួនាទីនៅក្នុងការធ្វើឱ្យមានឥទ្ធិពលមកលើលទ្ធផលដែលមានសមធម៌។ ទោះបីមានកិច្ចប្រឹងប្រែងជាច្រើនរួចមកហើយ ដើម្បីដាក់ឱ្យអនុវត្ត និងការបង្កើតប្រព័ន្ធការពារសុវត្ថិភាពសង្គមនៅក្នុង

៧ In Beder, S. and Scribe, N. ( 1996 ).

យុទ្ធសាស្ត្រជាតិនានាស្តីពី REDD+ ក៏ដោយ គេនៅតែមិនទាន់ច្បាស់អំពីថា តើយុទ្ធសាស្ត្រទាំងនោះជាប់ទាក់ទងគ្នាបែបណាជាមួយក្របខ័ណ្ឌគោលនយោបាយអំពីបញ្ហាដទៃទៀត ដែលអាចទំនាស់នឹងប្រព័ន្ធសុវត្ថិភាព REDD+។ ប្រព័ន្ធការពារសុវត្ថិភាពមានគោលដៅជានា "ភាពគ្មានគ្រោះថ្នាក់" ប៉ុន្តែពុំបានដោះស្រាយបញ្ហាវិសមធម៌ដែលមានអស់មួយរយៈមកហើយនោះឡើយ។

របៀបវារៈនៃការប្រែប្រួលអាកាសធាតុ និង REDD+ ផ្តល់ជាវេទិកាមួយសម្រាប់លើកយកបញ្ហាសមធម៌ដែលជាឱកាសមួយ ដើម្បីឱ្យអ្នកដទៃអាចស្តាប់សម្លេងរបស់អ្នកដែលរងការប៉ះពាល់។

គោលគំនិតអំពីសមធម៌ដែលអាចប្រើប្រាស់នៅក្នុងបរិបទ REDD+ ឬទិដ្ឋភាពដទៃទៀតនៃព្រៃឈើ និងការប្រែប្រួលអាកាសធាតុ សម្រាប់គោលបំណងនៃសេចក្តីថ្លែងការណ៍នានាជាមួយអ្នកពាក់ព័ន្ធនានានៅថ្នាក់មូលដ្ឋានគឺៈ

**ការប្រព្រឹត្តបានសមរម្យមកលើភាគីពាក់ព័ន្ធទាំងអស់ នៅក្នុងអំឡុងពេលនៃនីតិវិធី ដើម្បីបង្កើត និងអនុវត្តគោលនយោបាយ និងក្នុងការបែងចែកធនធាន និងថ្លៃចំណាយ អនុលោមតាមគោលការណ៍ដែលបានឯកភាពគ្នា។**



# ឃ. តើអ្នកណាខ្លះពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន ?

**គោលបំណងនៃការរៀនសូត្រ**

នៅទីបញ្ចប់នៃមេរៀននេះ សិក្ខាកាមៈ

- នឹងបានកំណត់អត្តសញ្ញាណភាគីពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន នៅក្នុងបរិបទនៃកម្មវិធីប្រែប្រួលអាកាសធាតុ ដែលទាក់ទងនឹងព្រៃឈើ
- អាចពន្យល់ពីសារៈសំខាន់នៃការធ្វើឱ្យអ្នកពាក់ព័ន្ធ នៅថ្នាក់មូលដ្ឋានបានចូលរួមនៅក្នុងបរិបទ REDD+ និងការប្រែប្រួលអាកាសធាតុ និង
- អាចពន្យល់ខ្លឹមសារថ្នាក់មូលដ្ឋាន នៅក្នុងកិច្ចផ្តួចផ្តើម និងបរិបទរបស់ខ្លួនផ្ទាល់

**សម្ភារៈ**

ក្រដាសផ្ទាំងធំ ហ្វឺត ប័ណ្ណ ក្រដាស Post-it, ស្កុត និងឯកសារអំណាន




**រយៈពេល**

៦០ នាទី

---

## ជំហានអនុវត្ត

១. ចាប់ផ្តើមដោយពន្យល់ថា មេរៀននេះនឹងពិនិត្យមើលខ្លឹមសារនៃ "ថ្នាក់មូលដ្ឋាន" ។ ចូរអនុវត្តលំហាត់បំផុសគំនិតខ្លីមួយ ដោយស្នើសិក្ខាកាមឱ្យសរសេរការយល់ឃើញរបស់ពួកគាត់អំពីថ្នាក់មូលដ្ឋាននៅលើក្រដាសផ្ទាំងធំ។

២. ដាក់ក្រដាសផ្ទាំងធំទៅម្ខាង (អ្នកនឹងត្រឡប់មកពិនិត្យខ្លឹមសារនៅពេលក្រោយទៀត)។ បិទនិយមន័យចំនួនបីនៃពាក្យ "ប្រជាពលរដ្ឋនៅមូលដ្ឋាន" នៅតាមកន្លែងខុសៗគ្នាលើជញ្ជាំងជុំវិញបន្ទប់ និងស្នើឱ្យសិក្ខាកាមជ្រើសរើសយកនិយមន័យ ដែលពួកគាត់គិតថាល្អជាងគេដោយផ្អែកលើការយល់ឃើញរបស់ពួកគាត់អំពីបរិបទផ្ទាល់ខ្លួនរបស់ពួកគាត់។

៣. ស្នើសិក្ខាកាមឱ្យឈរជិតនិយមន័យដែលពួកគាត់ចាត់ទុកថាពាក់ព័ន្ធជាងគេ និងពិភាក្សាមូលហេតុដែលនាំឱ្យមានការជ្រើសរើសយកនិយមន័យនោះ ជាមួយសិក្ខាកាមដទៃទៀតដែលបានជ្រើសយកនិយមន័យដូចគ្នានេះ។

៤. ផ្តល់ឱ្យក្រុមនីមួយៗ ដែលបង្កើតឡើងជាថ្មីនូវឱកាស ដើម្បីបង្ហាញពីមូលហេតុរបស់ពួកគាត់ក្នុងការជ្រើសយកនិយមន័យណាមួយជាក់លាក់ ដែលជាការគូសបញ្ជាក់ជាបណ្តើរៗ នូវភាពខុសគ្នាក្នុងចំណោមនិយមន័យនានា។

៥. ក្រោយពេលដែលក្រុមនីមួយៗ បានបញ្ចប់ការពន្យល់របស់ខ្លួនហើយ សូមផ្តល់ឱ្យសិក្ខាកាមម្នាក់ៗនូវប័ណ្ណធំមួយសន្លឹក និងស្នើពួកគាត់ឱ្យសរសេរនិយមន័យអំពីជំពូកមួយនៃអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន (ដូចជា ស្ត្រី ជនពិការ មនុស្សចាស់ ឬមេដឹកនាំក្នុងភូមិ) និងបិទភ្ជាប់នឹងខ្លួនរបស់ពួកគាត់។

៦. សូមឱ្យពួកគាត់ដើរជុំវិញក្នុងបន្ទប់ និងជួបជាមួយក្រុមអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន និងស្វែងរកព័ត៌មានបន្ថែមថាតើអ្នកណាខ្លះ ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងអត្តសញ្ញាណអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានរបស់ពួកគាត់ផ្ទាល់ ដែលអាចបង្កើតជាក្រុមដែលមានលក្ខណៈដូចគ្នាតាមធម្មជាតិ។

៧. សិក្ខាកាមត្រូវស្ថិតនៅក្នុងក្រុមដែលមានលក្ខណៈដូចគ្នាតាមធម្មជាតិ ដោយគិតពិចារណាអំពីអ្នកណាខ្លះដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងវគ្គពិភាក្សារួម ដោយលើកសំណួរឆ្លុះបញ្ចាំងដូចតទៅ៖

- *តើយើងមានក្រុមអ្នកណាខ្លះនៅទីនេះ និងហេតុអ្វី?*
- *តើក្រុមរបស់យើងមានលក្ខណៈស្របគ្នាជាមួយនិយមន័យខាងដើមរបស់យើងអំពី អ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានឬទេ និងថា តើយើងទាំងអស់គ្នាសុទ្ធតែជាអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានដែរឬទេ?*
- *តើបាត់អ្នកណាខ្លះ? ហេតុអ្វីពួកគាត់មិននៅទីនេះ?*
- *តើអ្នកណាខ្លះងាយស្រួលបញ្ចុះបញ្ចូលឱ្យចូលរួម និង ហេតុអ្វី?*
- *តើអ្នកណាខ្លះដែលលំបាកបញ្ចុះបញ្ចូលឱ្យចូលរួមជាងគេ និងហេតុអ្វី?*
- *តើអ្នកណាខ្លះ ក្នុងចំណោមអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានទាំងនេះ ដែលច្រើនតែជាអ្នកទន់ខ្សោយ និងហេតុអ្វី?*
- *តើការមិនធ្វើឱ្យអ្នកពាក់ព័ន្ធទន់ខ្សោយនានាបានចូលរួម នឹងអាចនាំមកនូវបញ្ហាអ្វីខ្លះ?*
- *តើអ្នកណាខ្លះនឹងមានការទទួលខុសត្រូវច្រើនជាងគេក្នុងការអនុវត្តគម្រោង REDD+?*
- *តើអ្នកណាខ្លះទំនងជាទទួលបានអត្ថប្រយោជន៍ច្រើនជាងគេ?*
- *ហេតុអ្វីការដែលធ្វើឱ្យអ្នកពាក់ព័ន្ធនានា នៅថ្នាក់មូលដ្ឋានទាំងអស់មានឱកាសដូចគ្នា និងបានចូលរួម និងពាក់ព័ន្ធ គឺជាកត្តាសំខាន់?*

៨. ស្នើសិក្ខាកាមឱ្យអង្គុយជាមួយគ្នា និងពិនិត្យឡើងវិញនូវខ្លឹមសារនៃថ្នាក់មូលដ្ឋាន។ សូមពន្យល់ថា នៅក្នុងវគ្គបណ្តុះបណ្តាលនេះ ពាក្យនេះបានដល់អ្នកពាក់ព័ន្ធទាំងអស់នៅកម្រិតទាបបំផុតនៃការអនុវត្តដោយផ្អែកតាមសិទ្ធិ អត្ថប្រយោជន៍ និងការទទួលខុសត្រូវរបស់ពួកគាត់។ សូមគូសបញ្ជាក់ថា អ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានទាំងនេះខ្លះ ច្រើនតែមិនបានចូលរួមនៅក្នុងដំណើរការនានា ដោយសារតែមូលហេតុមួយចំនួនដែលនឹងមានពិភាក្សានៅក្នុងមេរៀនក្រោយៗនៃវគ្គបណ្តុះបណ្តាលនេះ។ សូមពន្យល់ថា ការធ្វើឱ្យក្រុមអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានចូលរួមជាមួយជាប់រហូត ដោយផ្សារភ្ជាប់ពួកគាត់ជាមួយគ្នាទៅវិញទៅមក និងជួយពួកគាត់ក្នុងការសំដែងយោបល់របស់ខ្លួនទាមទារឱ្យមានជំនាញខុសៗគ្នាមួយចំនួន និងការតស៊ូ។

៩. អ្នកអាចចង់ស្នើឱ្យសិក្ខាកាមចែករំលែកបទពិសោធន៍របស់ពួកគាត់ ជាមួយគម្រោងមួយដែលពាក់ព័ន្ធជាមួយសហគមន៍ នៅថ្នាក់មូលដ្ឋាន ឬ ប្រជាពលរដ្ឋមូលដ្ឋាន។

១០. សូមបូកសរុបមេរៀននេះដោយសួរថា តើអ្នកណាខ្លះត្រូវបានឱ្យនិយមន័យថាជា "អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន" និងហេតុអ្វី។ ស្នើឱ្យពួកគាត់ចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនខ្លះៗអំពីកត្តាអ្វីខ្លះ ដែលធ្វើឱ្យពួកគាត់ខុសប្លែកពីអ្នកសម្របសម្រួលដទៃទៀត ដោយផ្អែកលើបញ្ហាខ្លះៗ ដែលបានគូសបញ្ជាក់នៅក្នុងមេរៀននេះ។ ចូរពន្យល់ថា តួនាទីរបស់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានគឺ ធ្វើឱ្យក្រុមអ្នកទន់ខ្សោយបានចូលរួម ដោយផ្សារភ្ជាប់ពួកគាត់ជាមួយអ្នកពាក់ព័ន្ធដទៃទៀត និងចែករំលែកទស្សនៈរបស់ពួកគាត់សម្រាប់ការបញ្ចូលទៅក្នុងគោលនយោបាយនៅថ្នាក់លើ ក៏ដូចជា ក្នុងការរៀបចំ និងការអនុវត្តគម្រោងផងដែរ។ ត្រូវធ្វើការតភ្ជាប់ការពិភាក្សានេះ តាមលំដាប់លំដោយនៃវគ្គបណ្តុះបណ្តាល ដែលបានកត់សំគាល់នៅក្នុងមេរៀននេះ ដែលបង្ហាញពីវគ្គបណ្តុះបណ្តាលនេះ (សូមអានឯកសារសម្រាប់ចែកដែលបានពីមេរៀននោះ) ដែលបង្ហាញពីថាតើអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានធ្វើការចូលរួមពាក់ព័ន្ធបែបណា នៅថ្នាក់មូលដ្ឋាន ប៉ុន្តែក៏ត្រូវតែពិនិត្យមើលរវាងលំដាប់ថ្នាក់ខុសៗគ្នាផងដែរ (ជាតិ តំបន់ និង អន្តរជាតិ) ដើម្បីធានាថា សម្លេងពីថ្នាក់មូលដ្ឋានត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវ និងមានអ្នកធ្វើសេចក្តីសម្រេចនៅលំដាប់ថ្នាក់ខុសៗគ្នាបានស្តាប់។

---

## កំណត់សំគាល់របស់គ្រូបង្ហាត់

វគ្គនេះ គឺជាការបង្ហាញសុទ្ធសាធដើម្បីឱ្យប្រាកដថា សិក្ខាកាមទាំងអស់យល់អំពីពាក្យ "ថ្នាក់មូលដ្ឋាន" នៅក្នុងដំណាក់កាលដើមដំបូងនៃវគ្គបណ្តុះបណ្តាល។ នេះជាវគ្គងាយស្រួលបំផុត ប៉ុន្តែមិនត្រូវសន្មតថាសិក្ខាកាមបានយល់ពីគោលគំនិតនេះហើយនោះទេ។ មិនត្រូវចំណាយពេលវែងពេកលើឧបសគ្គចំពោះការចូលរួមសម្រាប់ក្រុមជនទន់ខ្សោយនៅថ្នាក់មូលដ្ឋាន ដោយសារនឹងមានចែងនៅក្នុងមេរៀនក្រោយៗស្តីពីការផ្សារភ្ជាប់សមធម៌ និងការចូលរួម។

សិក្ខាកាមទំនងជាកំណត់រកអ្នកពាក់ព័ន្ធនានាជាសមូហភាព ជាងអ្នកពាក់ព័ន្ធជាក់លាក់ ដូចជា ស្ត្រី ជនពិការ អ្នកគ្មានដីធ្លី អ្នកផលិតធ្យូង ។ល។ អ្នកត្រូវតែពន្យល់ពីមូលហេតុដែលការស្គាល់ក្រុមដែលមានលក្ខណៈខុសៗគ្នាបែបនេះគឺជារឿងសំខាន់ ពោលគឺក្រុមនានានៅក្នុងក្រុមអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន ដើម្បីជៀសវាងការមើលរម្លងបុគ្គលនានា។

ប្រសិនបើក្រុមរបស់អ្នកត្រូវផ្តោតលើការពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន ប្រការសំខាន់នៅក្នុងបរិបទនៃអន្តរាគមន៍ក្នុងវិស័យព្រៃឈើ និងការប្រែប្រួលអាកាសធាតុ គឺអ្នកអាចស្នើឱ្យពួកគាត់សរសេរអំពីសិទ្ធិ និង ការទទួលខុសត្រូវ ព្រមទាំងប្រាក់ចំណូលសម្រាប់ក្រុមនីមួយៗ នៅក្នុងគម្រោង REDD+ ណាមួយ ហើយធ្វើការឆ្លុះបញ្ចាំងអំពី ថាតើក្រុមណាខ្លះដែលត្រូវការឱ្យមានការចាត់ចែងសម្រាប់ការចូលរួមពេញលេញនៅក្នុងការរៀបចំគម្រោង និងដំណើរការនៃការអនុវត្ត។



# តើអ្នកណាខ្លះពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន?

ខាងក្រោមនេះជានិយមន័យមួយចំនួនដែលអ្នកអាចសរសេរលើក្រដាសផ្ទាំងធំ និងបិទភ្ជាប់ទៅនឹងជញ្ជាំងជុំវិញក្នុងបន្ទប់បណ្តុះបណ្តាលនេះ។

## តើអ្នកណាខ្លះពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន?

ពលរដ្ឋធម្មតានៅក្នុងសង្គម ឬ អង្គការ ឬ ប្រជាជនដែលពុំមានប្រាក់ច្រើន ឬ ពុំមានអំណាច។

## តើអ្នកណាខ្លះពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន?

ប្រជាពលរដ្ឋនៅមូលដ្ឋានដែលពុំមានឱកាសដើម្បីអនុវត្តសិទ្ធិ ឬ ទទួលអត្ថប្រយោជន៍ពីអន្តរាគមន៍ណាមួយ ដែលផ្តួចផ្តើមដោយអ្នកពីខាងក្រៅ ទាំងនៅក្នុងដំណើរការនៃការរៀបចំ និងអនុវត្ត។

## តើអ្នកណាខ្លះពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន?

ប្រជាពលរដ្ឋទូទៅ ឬ ធម្មតា ជាពិសេស ដែលខុសពីក្រុមមេដឹកនាំ ឬវីរជន នៃគណបក្សនយោបាយ ឬអង្គការសង្គមណាមួយ

## តើអ្នកណាខ្លះពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន?

ក្រុមប្រជាពលរដ្ឋនៅក្នុងលំដាប់ថ្នាក់ក្រោមបំផុត ដែលច្រើនតែត្រូវគាត់មើលរំលងនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនានា។



# តើអ្នកណាខ្លះពាក់ព័ន្ធ ?

## តើពាក្យថា“ថ្នាក់មូលដ្ឋាន” មានន័យបែបណាចំពោះអ្នក ?

កាលពីដំបូង ពាក្យថា “ថ្នាក់មូលដ្ឋាន” បានកើតចេញពីចលនានយោបាយដើម្បីឱ្យមានការ កែប្រែនៅពេលដែលប្រជាពលរដ្ឋមូលដ្ឋាន មិនបានចូលរួមនៅក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្ត ក្រោយមកបានសម្រេចសំដែងទស្សនៈរបស់ខ្លួនជាក្រុមមួយ និងជំរុញឱ្យមានការកែប្រែទិសដៅតាមដែលពួកគាត់ចង់បាន។

នៅក្នុងបរិបទនៃអន្តរាគមន៍ដែលពាក់ព័ន្ធនឹងអាកាសធាតុ អ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានអាចរាប់បញ្ចូលអ្នកណាក៏ដោយដែលមានអំណាចតិចតួចបំផុត និងដែលរងការប៉ះពាល់ដោយសារអន្តរាគមន៍ដែលជំរុញពីកត្តាខាងក្រៅទាំងឡាយ ដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ព្រៃឈើរបស់ពួកគាត់។ អ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាននៅក្នុងករណីនេះ អាចរាប់បញ្ចូលគ្រួសារដែលពឹងផ្អែកលើ ព្រៃឈើ ពលរដ្ឋជាជនជាតិដើមភាគតិច អ្នកគ្រប់គ្រងព្រៃឈើនៅតាមមូលដ្ឋាន និងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ឬមន្ត្រីព្រៃឈើ។ នៅក្នុងក្រុមទាំងនេះគេអាចឃើញមានក្រុមខុសគ្នាដទៃទៀតដែលអាចរងផលប៉ះពាល់អវិជ្ជមានពីការសម្រេចចិត្តនានា ដែលរួមទាំង ស្ត្រី កុមារ អ្នកគ្មានដីធ្លី និងជំពូកជាក់លាក់នៃអ្នកប្រើប្រាស់ផលិតផលព្រៃឈើ។

## តើហេតុអ្វីការធ្វើឱ្យអ្នកពាក់ព័ន្ធនៅមូលដ្ឋានចូលរួមនៅក្នុងការរៀបចំផែនការ និងការអនុវត្តអន្តរាគមន៍ប្រែប្រួលអាកាសធាតុដែលផ្អែកលើព្រៃឈើគឺជារឿងសំខាន់ ?

ក្រុមទាំងនេះខ្លះងាយស្រួលក្នុងការបញ្ចុះបញ្ចូលឱ្យចូលរួមជាងក្រុមដទៃទៀត។ ទោះបីរដ្ឋាភិបាលមូលដ្ឋានច្រើនតែបានចូលរួមក៏ដោយ មានការសន្មតថា ការចូលរួមនេះគឺដោយសារតែពួកគាត់ជាតំណាងឱ្យមណ្ឌលរបស់ខ្លួន សូម្បីតែនៅក្នុងស្ថានភាពខ្លះ ប្រការនេះអាចមិនពិតក៏ដោយ។ ប្រសិនបើក្រុមទាំងនេះចូលរួមប្រកបដោយប្រសិទ្ធភាពទៅតាមអ្វីដែលពួកគាត់គួរតែធ្វើ ក្នុងករណីនោះ កិច្ចផ្តួចផ្តើមគម្រោងមួយ ឬ គោលនយោបាយមួយ ទំនងជានឹងបានជោគជ័យប្រសិនបើដាក់ឱ្យអនុវត្ត។ បើពុំនោះទេហានិភ័យនៃបរាជ័យនឹងមានទំហំធំ។ ជាញឹកញាប់ ក្រុមទាំងនេះគឺជាអ្នកកាន់កាប់សិទ្ធិនៃតំបន់ព្រៃឈើ ដូច្នេះគេគួរតែមានសិទ្ធិសម្រេចអំពីថា តើអន្តរាគមន៍មួយគួរតែអនុវត្តបែបណា។ ទម្លាប់នៃការឯកភាពដោយគ្មានការបង្ខំជាមួយការទទួលបានព័ត៌មានជាមុន នៅក្នុងការរៀបចំ និងកសាងផែនការអន្តរាគមន៍ប្រែប្រួលអាកាសធាតុ ដែលផ្អែកលើព្រៃឈើទាមទារឱ្យក្រុមនៅថ្នាក់មូលដ្ឋាននានាបានចូលរួមពេញ នៅក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្តទាំងនៅមុន និងក្នុងអំឡុងពេលនៃអន្តរាគមន៍ ហើយពួកគាត់ត្រូវតែមានសិទ្ធិបដិសេធអន្តរាគមន៍នានាផងដែរ។



## តើអ្នកណាគឺជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ?

អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន គឺជាបុគ្គលដែលធ្វើការជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន និងរដ្ឋាភិបាលមូលដ្ឋាន ដើម្បីជានាថា ក្រុមនានាដែលមានសិទ្ធិចំពោះព្រៃឈើ និងសិទ្ធិទទួលផលពីព្រៃឈើ ដែលរងការប៉ះពាល់ដោយសារអន្តរាគមន៍ពីខាងក្រៅ ដូចជា REDD+ អាចចូលរួមនៅក្នុងការសន្ទនាជាមួយភ្នាក់ងារពាក់ព័ន្ធ និងអ្នកធ្វើសេចក្តីសម្រេចនានា។ អ្នកសម្របសម្រួល ក៏ជួយក្រុមទាំងនេះឱ្យយល់ដឹងអំពីអំពីបញ្ហានានាចំពោះមុខ និងចែករំលែកបញ្ហាទាំងនោះនៅកម្រិតធ្វើសេចក្តីសម្រេចចិត្តដទៃទៀតផងដែរ ដែលអាចមិនស្ថិតនៅក្នុងក្រុមអ្នកមូលដ្ឋានខ្លះៗ។ និយាយម្យ៉ាងទៀតថាអ្នកសម្របសម្រួលថ្នាក់មូលដ្ឋាននេះផ្សារភ្ជាប់អ្នកពាក់ព័ន្ធនានាទៅតាមខ្សែបណ្តោយ និងខ្សែទទឹងដោយធានាថា ទស្សនៈវិស័យរបស់ពួកគាត់ដែលតាមធម្មតាត្រូវបានមើលរម្លង ត្រូវបានទទួលការយកចិត្តទុកដាក់ពីអ្នករៀបចំគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត។

# ខ. តើហេតុអ្វីសមធម៌ជារឿងសំខាន់ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលផ្អែកលើព្រៃឈើ រួមទាំង REDD+

**គោលបំណងនៃការរៀនសូត្រ**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹង៖

- ពិភាក្សាអំពីទស្សនៈរបស់ពួកគាត់អំពីហេតុអ្វីសមធម៌ គឺជាកង្វល់មួយនៅក្នុងបរិបទនៃវិស័យព្រៃឈើ និងការប្រែប្រួលអាកាសធាតុ ជាពិសេសគោលនយោបាយស្តីពី REDD+ និងកិច្ចផ្តួចផ្តើមកាត់បន្ថយដទៃទៀតនិងការពាក់ព័ន្ធជាមួយ វិសមធម៌។
- កត់ត្រា និងពិភាក្សាបញ្ហានានា ដែលទាក់ទងនឹងសមធម៌ និងអន្តរាគមន៍លើការប្រែប្រួលអាកាសធាតុដោយផ្អែកលើបរិបទរបស់ពួកគាត់ផ្ទាល់។
- អាចពន្យល់អំពីក្របខ័ណ្ឌមួយ សម្រាប់ការកំណត់គោលដៅ និងការពិនិត្យមើលទិដ្ឋភាពនានានៃសមធម៌ (បរិបទ ការ បែងចែក និងនីតិវិធី) និងផ្សារភ្ជាប់ទិដ្ឋភាពទាំងនេះជាមួយបញ្ហាអំពីបរិបទ។ និង
- អាចពន្យល់ អំពីការយកចិត្តទុកដាក់នៃវគ្គបណ្តុះបណ្តាលនេះលើសមធម៌បែបនីតិវិធី និងការបង្កើតឱកាស សម្រាប់បង្ហាញពីសម្លេងរបស់សហគមន៍ នៅក្នុងសេចក្តីថ្លែងការណ៍នានា ស្តីពីសមធម៌ នៅក្នុងបរិបទនៃ REDD+។

**សម្ភារៈ**

ក្រដាសផ្ទាំងធំហ្វីតប័ណ្ណស្អិត ក្រដាសផ្ទាំងធំ ដែលរៀបចំជាមុន ឬស្លាយ PowerPoint ជាមួយប្រយោគជាច្រើន ស្តីពីសមធម៌សញ្ញា ”ឯកភាព” និង ”មិនឯកភាព” ដែលសរសេរនៅលើនោះ៖ ច្បាប់ចម្លងនៃស្លាយនៅលើក្រដាស ឬស្លាយ PowerPoint អំពីក្របខ័ណ្ឌសមធម៌( ដែលត្រូវមានទំហំធំគ្រប់គ្រាន់ ដើម្បី



| | |
|---|---|
| | អាចមើលឃើញច្បាស់ព្រោះថា នឹងត្រូវប្រើប្រាស់សម្រាប់យោងនៅទូទាំងវគ្គបណ្តុះបណ្តាលនេះ) ក្រដាសពណ៌ដែលកាត់ជារង្វង់មូលតាមទំហំខុសគ្នា និងឯកសារអំណាន។ |
| **រយៈពេល** | ៩០នាទី (អាស្រ័យលើចំនួនប្រយោគដែលប្រើប្រាស់ និងពេលវេលាដែលគ្រោងទុក) |

---

## ជំហាននានា

១. សូមចាប់ផ្តើមដោយពន្យល់ថា នេះជាពេលដែលត្រូវស្វែងយល់បន្ថែមអំពីហេតុផល សម្រាប់ផ្តោតលើសមធម៌។

២. សូមពន្យល់ដល់សិក្ខាកាមថា ដើម្បីបង្កើតឱ្យមានការពិភាក្សា និងជំរុញការជជែកវែកញែកនេះ អ្នកត្រូវបិទប្រយោគមួយចំនួននៅជាប់នឹងជញ្ជាំង។

៣. សូមប្រាប់សិក្ខាកាមម្នាក់ៗថា ពួកគាត់គួរតែអានប្រយោគនីមួយៗដោយប្រុងប្រយ័ត្ន នៅពេលបង្ហាញបន្ទាប់មក ឈរនៅខាងសញ្ញា "ឯកភាព" ឬ ខាង "មិនឯកភាព" ជាមួយហេតុផលច្បាស់លាស់មួយសម្រាប់ជំហររបស់ខ្លួន។ ចូរពន្យល់ថា អ្នកនឹងបង្ហាញប្រយោគម្តងមួយៗ។

៤. នៅក្រោយការអានប្រយោគនីមួយៗរួច សូមស្នើអ្នកដែលឈរនៅក្រោមសញ្ញានីមួយៗពិភាក្សាមូលហេតុនានាដែលពួកគាត់ប្រកាន់យកជំហរបែបនោះ ក្នុងចំណោមពួកគាត់។ បន្ទាប់មកសូមឱ្យពួកគាត់ចែករំលែកជាមួយក្រុមទាំងមូលអំពីមូលហេតុដែលពួកគាត់ឯកភាពឬ មិនឯកភាពជាមួយប្រយោគណាមួយ។




៥. ចូរសម្របសម្រួលដោយប្រុងប្រយ័ត្ន និងឱ្យបានត្រឹមត្រូវនូវការពិភាក្សាមួយដោយត្រូវប្រាកដថា ក្រុមនីមួយបានបង្ហាញយោបល់ដល់អ្នកដទៃទាំងអស់គ្នា។ ក្នុងករណីចាំបាច់ត្រូវសម្របសម្រួល ដើម្បីឱ្យមានការបំភ្លឺ ដើម្បីឱ្យក្រុមទាំងពីរយល់ពីជំហររបស់គ្នាទៅវិញទៅមក។




៦. នៅចុងការពិភាក្សានីមួយៗ សូមផ្តោតលើក្រុមដែលឯកភាព និងសរសេរចំណុចទាំងនោះនៅលើក្រដាសផ្ទាំងធំ។ សូមជៀសវាងការចំណាយពេលច្រើនជាង ១០នាទី លើប្រយោគនីមួយៗដោយសារទស្សនៈខ្លះអាចត្រួតគ្នា។ អ្នកគួរបន្តដំណើរការនេះឱ្យឈានទៅមុខ ទោះបីជាមានការមិនចុះសម្រុងគ្នា ឬ ការចូលរួមរបស់សិក្ខាកាមបែបណាក៏ដោយ។

**៧.** នៅចុងលំហាត់នីមួយៗ និងនៅក្រោយសិក្ខាកាមបានវិលត្រឡប់មកកៅអីរបស់ខ្លួនវិញហើយនោះ សូមពិនិត្យក្រដាសផ្ទាំងធំដែលបានសរសេរនោះឡើងវិញ។ សូមពន្យល់ថា ទោះបីប្រយោគខ្លះមានភាពចម្រូងចម្រះក៏ដោយ វាតំណាងឱ្យទស្សនៈខុសៗគ្នា នៅក្នុងសេចក្ដីថ្លែងការណ៍អំពីសមធម៌។ អ្នកពុំចាំបាច់ពោលថា ប្រយោគនេះត្រូវ ឬ ខុសនោះទេ។

**៨.** បូកសរុបលំហាត់នេះ ដោយពន្យល់ថា ឥឡូវនេះយ៉ាងហោចណាស់មានគំនិតដែលបានមកពីក្រុមខុសៗគ្នា ដែលទាក់ទងនឹងសមធម៌ និង REDD+ ឬ អន្តរាគមន៍ដទៃទៀត ខាងវិស័យប្រែប្រួលអាកាសធាតុដែលទាក់ទងនឹងព្រៃឈើ។ ទីមួយ នៅពេលដែលគុណតម្លៃរបស់ប្រព័ន្ធ អេកូឡូស៊ីកើនឡើងទូទាំងពិភពលោក នៅក្នុងបរិបទប្រែប្រួលអាកាសធាតុ គេត្រូវប្រយ័ត្នដើម្បីជៀសវាងគ្រោះថ្នាក់ណាមួយចំពោះលក្ខខណ្ឌនៃសមធម៌ នៅកម្រិតមូលដ្ឋាន។ ទីពីរ REDD+ ផ្ដល់ ឱកាសដើម្បីបង្កើនការយកចិត្តទុកដាក់លើបញ្ហាសមធម៌ និងលើកកម្ពស់សមធម៌ (ដែលរួមទាំងបញ្ហាដែលមានពីមុនមក) សម្រាប់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងដើម្បីបែងចែកថ្លៃចំណាយអត្ថប្រយោជន៍ និងការសម្រេចកាន់តែមានលក្ខណៈសមស្របជាងមុនក្នុងចំណោមអ្នកពាក់ព័ន្ធនានា ទាំងនៅថ្នាក់ជាតិ និងមូលដ្ឋាន។

**៩.** សូមពន្យល់ដល់សិក្ខាកាមថា មានបញ្ហាជាច្រើនដែលឥឡូវនេះត្រូវបានយោងទៅលើ "សមធម៌" ប៉ុន្តែសមធម៌នោះ ត្រូវតែបានវិភាគទៅតាមទិដ្ឋភាព និងបរិបទខុសៗគ្នា។ ចូរស្នើសិក្ខាកាមឱ្យពិភាក្សាជាមួយអ្នកអង្គុយជាប់គ្នា។ សូមស្នើសិក្ខាកាម ក្នុងគូនីមួយៗកំណត់អត្តសញ្ញាណបញ្ហាចំនួន ប្រាំ ដែលទាក់ទងនឹងសមធម៌ និង REDD+ ដែលមានសារៈសំខាន់នៅក្នុងបរិបទ ឬ គម្រោងរបស់ពួកគាត់ផ្ទាល់ និងសរសេរចំណុចទាំងនោះនៅលើប័ណ្ណ។ ត្រូវប្រាកដថា មានតែបញ្ហាមួយគត់ដែលបានសរសេរនៅលើប័ណ្ណនីមួយៗ។ ស្នើសិក្ខាកាមក្នុងគូនីមួយៗបិទភ្ជាប់ប័ណ្ណនានាលើក្រដាសផ្ទាំងធំ។ សូមដាក់ចំណងជើង៖ "បញ្ហាសមធម៌ REDD+" ។

**១០.** ស្នើឱ្យក្រុមទាំងមូលអានបញ្ហារបស់គ្នាទៅវិញទៅមក។ សូមលើកសំណួរឆ្លុះបញ្ចាំងនានាដូចតទៅ នៅពេលដែលពួកគាត់សិក្សាបញ្ហាទាំងនេះ៖

- *តើអ្នកឃើញទម្រង់ ឬ ប្រធានបទអ្វីខ្លះ ក្នុងចំណោមបញ្ហាទាំងអស់ដែលបានកំណត់ ឬទេ? (ឧទាហរណ៍ ការបែងចែកអត្ថប្រយោជន៍ ការសម្រេចចិត្តតាមបែបចូលរួម សិទ្ធិ និងការចេញចូល និងសមត្ថភាព។)*
- *តើឃើញចំណុចខុសគ្នាអ្វីខ្លះក្នុងចំណោមបញ្ហានានា (ពាក់ព័ន្ធនឹង កម្រិត មាត្រដ្ឋាន និងក្រុមគោលដៅ)?*
- *តើបញ្ហាណាខ្លះ ដែលពាក់ព័ន្ធនឹងបរិបទជាក់លាក់?*
- *តើយើងដោះស្រាយបែបណាចំពោះបញ្ហាដែលជាក់លាក់តាមបរិបទ ដែលមានតាំងពីមុនប្រកាសគម្រោង REDD+?*

១១. ក្រោយការឆ្លុះបញ្ចាំង និងសិក្ខាកាមបានវិលត្រឡប់មកកន្លែងអង្គុយរៀងខ្លួនវិញហើយ សូមពន្យល់ថា លំហាត់ក្នុងប័ណ្ណនេះមានបំណងបង្កើតចំណាប់អារម្មណ៍អំពីអ្វីដែលត្រូវបានចាត់ទុកថាជាបញ្ហាសមធម៌ ដែលមានការប៉ះពាល់មកលើបរិបទនៃបញ្ហាទាំងនោះនៅលំដាប់ថ្នាក់ និងតាមមាត្រដ្ឋានខុសៗគ្នា។

១២. សូមពន្យល់ថា អ្នកនឹងបង្ហាញក្របខ័ណ្ឌមួយដែលនឹងជួយពួកគាត់វិភាគគោលគំនិតអំពីសមធម៌ និងក្នុងការពិនិត្យគោលដៅនៅក្នុងបរិបទរបស់ពួកគាត់ផ្ទាល់ និងថា តើវគ្គបណ្តុះបណ្តាលនេះពាក់ព័ន្ធបែបណាជាមួយគោលដៅនោះ។




១៣. រៀបចំជាបណ្តើរៗនូវដ្យាក្រាមមួយ អំពីក្របខណ្ឌសមធម៌តាមទិដ្ឋភាពខុសៗគ្នា ដូចដែលអ្នកពន្យល់ (សូមអានឯកសារអំណាន ប៉ុន្តែមិនត្រូវចែកជូននៅពេលនេះភ្លាមទេ)។

១៤. នៅលើផ្ទាំងក្រដាសមួយទៀត និងដោយប្រើប្រាស់រង្វង់ដែលមានទំហំខុសគ្នាដែលអ្នកកាត់ទុកជាមុន សូមបង្កើតរូបភាពមួយនៃក្របខ័ណ្ឌនេះ។

១៥. ដោយចាប់ផ្តើមពីរង្វង់ខាងក្នុង (អ្វីដែលជាធាតុសំខាន់នៃសមធម៌) សូមពន្យល់ថា នៅក្នុងលំហាត់ពីមុននេះសិក្ខាកាមបានកំណត់អត្តសញ្ញាណអ្វីខ្លះជាធាតុផ្សំនៃសមធម៌ ដែលទាក់ទងនឹងបញ្ហាសំខាន់ៗនៅក្នុង REDD+ (អភិបាលកិច្ច សិទ្ធិ និងអត្ថប្រយោជន៍)។ សូមពន្យល់និងផ្សារភ្ជាប់ជំពូកទាំងនេះនៃសមធម៌ទៅនឹងបញ្ហាទាំងនេះ(បរិបទ ការបែងចែក និងនីតិវិធី)។

១៦. បន្ទាប់មកសូមពន្យល់ថា ប្រការសំខាន់គឺត្រូវគិតអំពី "អ្នកណាខ្លះដែលត្រូវគិតបញ្ចូល" ទាក់ទងនឹងបញ្ហាទាំងនេះ(ដូចជាសហគមន៍ ស្ត្រី ពាណិជ្ជករ ជនពិការ អ្នកក្រីក្រជាងគេ ជនជាតិដើមភាគតិច និងកុមារ)។

១៧. ក្រោយពីពន្យល់ទិដ្ឋភាពអំពី "អ្នកណាខ្លះដែលត្រូវរាប់បញ្ចូល" សូមឈានបន្តទៅកម្រិត "ហេតុអ្វីចាំបាច់មានសមធម៌" និងត្រូវកំណត់អំពីគោលដៅនៃការលើកកម្ពស់សមធម៌។ សូមពន្យល់ថា នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ និង REDD+ គោលដៅនៃការលើកកម្ពស់សមធម៌ ត្រូវបានកំណត់ដោយមនុស្សខ្លះថា "មិនបង្កគ្រោះថ្នាក់" ចំណែកអ្នកដទៃទៀតចាត់ទុកថាជាការកែលម្អ ឬផ្តោតលើការធ្វើឱ្យប្រែប្រួលអំពីរបៀបដែលអ្នកពាក់ព័ន្ធទាំងអស់ចូលរួម និងទទួលផល។



**១៨.** នៅទីបញ្ចប់ ចូរដាក់រង្វង់ទាំងអស់ពីលើរង្វង់ធំមួយដែលគូរនៅលើផ្ទាំងក្រដាស។ សូមសួរក្រុមនេះថា អ្នកណាគួររកចម្លើយតបនឹងសំណួរទាំងអស់នៅក្នុងក្របខ័ណ្ឌនេះ និងតើពួកគាត់គួរធ្វើបែបណា។ សូមផ្តល់ឧទាហរណ៍មួយអំពីក្របខ័ណ្ឌសម្រាប់ដោះស្រាយបញ្ហាសមធម៌នៅក្នុង REDD+ ឬ គម្រោងមួយ ដើម្បីដោះស្រាយសមធម៌ក្នុងសហគមន៍ព្រៃឈើ។ បន្ទាប់មកត្រូវសួរថា៖ អ្នកណាគួរសម្រេចលើប៉ារ៉ាម៉ែត្រនៃសមធម៌? តើពួកគាត់គួរតែសម្រេចអំពីប៉ារ៉ាម៉ែត្រទាំងនោះបែបណា? សូមពន្យល់ថានេះជាទិដ្ឋភាពមួយដែលច្រើនតែត្រូវគេមើលរំលង។ សូមសួរថា តើមានសិក្ខាកាមណាម្នាក់មានបទពិសោធន៍ប្រហែលគ្នានេះដែរឬទេ។

**១៩.** សូមពន្យល់ថា នេះជាក្របខ័ណ្ឌមួយ ដើម្បីបង្ហាញអំពីទិដ្ឋភាពនានានៃសមធម៌ ប៉ុន្តែវាអាចខុសគ្នានៅក្នុងស្ថានភាពនីមួយៗ ហើយសិក្ខាកាមម្នាក់ៗត្រូវពិចារណាអំពីបរិបទ ឬទីកន្លែងរបស់ខ្លួនផ្ទាល់។

**២០.** សូមពន្យល់អំពីក្របខ័ណ្ឌនេះ និងត្រូវប្រើប្រាស់បញ្ហានានាដែលសិក្ខាកាមបានកំណត់ ដើម្បីគាំទ្រដល់សេចក្តីពន្យល់របស់អ្នក។ សូមសួរសំណួរឆ្លុះបញ្ចាំងដូចតទៅ៖

- *តើអ្នកអាចមើលឃើញទេថា តើបញ្ហាសមធម៌ ដែលអ្នកបានកំណត់ពីបរិបទរបស់អ្នកស៊ីគ្នាជាមួយក្របខ័ណ្ឌនេះ ដែរឬទេ?*
- *តើទិដ្ឋភាពណាមួយនៃសមធម៌ ដែលអ្នកគិតថា យើងអាចដោះស្រាយក្នុងនាមជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន? តើយើងអាចធ្វើកិច្ចការនោះដោយរបៀបណា?*
- *តើស្ថាប័ន ឬគម្រោងរបស់អ្នកមានគោលដៅបែបណាក្នុងការកែលម្អសមធម៌? តើមានចែងច្បាស់លាស់ឬទេ? តើអ្នកបានពិភាក្សាឬទេ អំពីថាតើអ្នកណាខ្លះជាគោលដៅជាក់ស្តែង?*
- *តើអ្នកគិតថា ការចែងឱ្យបានច្បាស់លាស់អំពី អ្វីដែលអ្នកព្យាយាមសម្រេចឱ្យបានទាក់ទងនឹងសមធម៌មានសារៈសំខាន់កម្រិតណាទាក់ទងនឹងសមធម៌? តើវាមានសារៈសំខាន់កម្រិតណា?*

**២១.** ក្រោយពីការឆ្លុះបញ្ចាំង និងក្រោយពីបានឆ្លើយនឹងសំណួរនានាអំពីក្របខ័ណ្ឌនេះ សូមពន្យល់ថា វគ្គបណ្តុះបណ្តាលនេះ ផ្តោតជារួមលើការលើកកម្ពស់សមធម៌ នៅក្នុងកិច្ចផ្តួចផ្តើម REDD+ កិច្ចការនេះអាចធ្វើបានតាមរយៈ ការគូសបញ្ជាក់បញ្ហានានាដែលទាក់ទងនឹង "សមធម៌បែបនីតិវិធី" និងកសាងទំនុកចិត្តនៅក្នុងការរៀបចំដំណើរការនៅថ្នាក់មូលដ្ឋានដែលផ្តល់ឱកាសសម្រាប់សហគមន៍នានាដើម្បីចូលរួម។ សូមពន្យល់ថា វិធាននេះបានផ្អែកលើការសន្មតថា តាមរយៈការលើកកម្ពស់សមធម៌បែបនីតិវិធី នៅថ្នាក់មូលដ្ឋាន ទិដ្ឋភាពដទៃទៀតនៃសមធម៌នឹងអាចរៀបចំ និងគូសបញ្ជាក់នៅកម្រិតអ្នកពាក់ព័ន្ធខុសៗគ្នា និងកម្រិតខុសៗគ្នានៃការធ្វើសេចក្តីសម្រេចចិត្ត។

២២. ដើម្បីបញ្ជាក់ចំណុចរៀនសូត្រពីវគ្គនេះ ចូរបញ្ចាំងភាពយន្តរយៈពេល ៨នាទី ដែលផលិតដោយ LifeMosaic មានចំណងជើងថា REDD៖ សត្វថ្មីមួយក្នុងព្រៃឈើ (www.lifemosaic.net/eng/resources/video/redd-a-new-animal-in-the-forest/) ឬឧទាហរណ៍ផ្សេងទៀតប្រហែលគ្នានេះ។

២៣. ចូរធ្វើការបូកសរុបនៅក្នុងវគ្គនេះ ដោយត្រូវស្នើឱ្យសិក្ខាកាមពិភាក្សាអំពីផលវិបាកនៃការមិនអើពើចំពោះកង្វល់អំពីសមធម៌ នៅក្នុងគោលនយោបាយ REDD+ និងការអនុវត្ត (ដូចជា ទំនាស់ការបាត់បង់ព្រៃឈើ និងកំណើនភាពក្រីក្រក្នុងចំណោមសហគមន៍នានាដែលពឹងផ្អែកលើព្រៃឈើ)។ ចំណុចនេះ អាចទាក់ទងជាមួយការគ្រប់គ្រងព្រៃឈើ ដោយនិរន្តរភាពអាស្រ័យលើចំណាប់អារម្មណ៍របស់សិក្ខាកាម។

---

## កំណត់សំគាល់របស់គ្រូបង្វាត់

មេរៀននេះមានលក្ខណៈស្មុគស្មាញ ដោយសារសិក្ខាកាមជាច្រើនអាចពុំធ្លាប់បានគិតអំពីគោលដៅនៃការដោះស្រាយបញ្ហាសមធម៌នៅក្នុងបរិបទរបស់ខ្លួន ឬសូម្បីតែទិដ្ឋភាពខុសៗគ្នានៃសមធម៌។ អ្នកត្រូវតែប្រាកដថា អ្នករក្សាគំនូសអំពីក្របខ័ណ្ឌនេះនៅកន្លែងដែលងាយមើលឃើញក្នុងបន្ទប់នេះ ដើម្បីអ្នកអាចងាយស្រួលយោងទៅក្របខ័ណ្ឌនេះ។ នេះជាឱកាសសម្រាប់អ្នកដែលមានផ្នត់គំនិតឥតកែប្រែដែលអ្នកដទៃអាចលើកមតិខុសពីនេះ និងសម្រាប់អ្នកដទៃទៀតស្វែងយល់ទៅតាមការយល់ឃើញរបស់ខ្លួន។

ក្របខ័ណ្ឌនេះអាចមានលក្ខណៈអរូបិយខ្លាំងពេកសម្រាប់សិក្ខាកាមខ្លះ មិនអាចឱ្យពួកគាត់យល់បាននៅក្នុងដំណាក់កាលដំបូងនៃវគ្គបណ្តុះបណ្តាលនេះឡើយ។ អ្នកត្រូវត្រៀមខ្លួនជាស្រេចដើម្បីបង្ហាញឧទាហរណ៍ផ្ទាល់ខ្លះៗពីសិក្ខាកាមនានា និងផ្សារភ្ជាប់ឧទាហរណ៍ទាំងនោះជាមួយក្របខ័ណ្ឌនេះ។ ទោះជាយ៉ាងណាក៏ដោយត្រូវចាំថានេះគ្រាន់តែជាមេរៀនដំបូងដែលបង្ហាញពីក្របខ័ណ្ឌនេះ។ នេះជាដំណើរការរៀនសូត្រមួយដូច្នេះមេរៀនក្រោយៗនឹងមានការបង្ហាញក្របខ័ណ្ឌនេះកាន់តែច្បាស់។

# សេចក្ដីថ្លែងការណ៍

សូមសរសេរប្រយោគដូចខាងក្រោមនេះឱ្យបានធំៗ នៅលើផ្ទាំងក្រដាសដែលអាចមើលឃើញពីចម្ងាយ ឬ បង្ហាញតាមរយៈ ស្លាយ PowerPoint។ ត្រូវបង្ហាញប្រយោគទាំងនេះម្ដងមួយៗ។ ចូរកត់សំគាល់ថា ចំណុចនីមួយៗខាងក្រោមនេះគឺជា សេចក្ដីណែនាំ ប៉ុន្តែមិនត្រូវបង្ហាញដល់សិក្ខាកាមឡើយ។ សូមស្ដាប់ដោយប្រុងប្រយ័ត្ន ដើម្បីឱ្យដឹងថា សិក្ខាកាមកំពុងនិយាយអំពីសមធម៌ឬទេ ឬ អំពីវិសមធម៌ - ពាក្យទាំងពីរនេះច្រើនត្រូវបានប្រើប្រាស់ក្នុងបរិបទដូចគ្នា។

**វិសមធម៌ តែងតែមានក្នុងចំណោមគ្រួសារនានា ដែលរស់នៅក្នុងតំបន់ព្រៃឈើអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ ដូច្នេះ REDD+ មិនត្រូវធ្វើឱ្យស្ថានភាពនេះកាន់តែធ្ងន់ធ្ងរឡើយ។**

ប្រយោគនេះបង្ហាញពីបរិបទនៃវិសមធម៌ដែលមានតាំងពីមុនពេលចាប់ផ្ដើមគម្រោង REDD+ ប៉ុន្តែគេអាចប្រែក្លាយជាខ្លឹមសារផ្ទុយពីនេះ ដោយបង្ហាញថាជាឱកាសមួយ។ មនុស្សជាច្រើនគិតថា ស្ថានភាពនេះពុំអាចអាក្រក់ជាងបច្ចុប្បន្នឡើយ។

- នៅកន្លែងខ្លះ មនុស្សជាច្រើនគិតថា ចំណាប់អារម្មណ៍លើកាបូនអាចនាំឱ្យមានការដកហូតសិទ្ធិពីអ្នកប្រើប្រាស់ និងការចែកផលមិនបានត្រឹមត្រូវ។
- ការចែកផលមិនបានត្រឹមត្រូវ និងទំនាស់ខាងផ្នែកសិទ្ធិ រវាងរដ្ឋាភិបាលថ្នាក់កណ្ដាល និងប្រជាជនមូលដ្ឋាន អាចនាំឱ្យមានការគ្រប់គ្រងដោយគ្មាននិរន្តរភាព និងកំណើនការបាត់បង់ព្រៃឈើ។
- REDD+ អាចត្រូវគេប្រើប្រាស់ជាឱកាសដើម្បីគូសបញ្ជាក់អំពីវិសមធម៌ដោយសារភាពទាក់ទាញការយកចិត្តទុកដាក់ជាអន្តរជាតិ។
- បរិបទនៃសមធម៌កើតមានជាយូរមកហើយ ដូច្នេះទោះបីមានហានិភ័យជាមួយ REDD+ ក៏ដោយ អ្នកខ្លះជឿថា វាមិនអាចកាន់តែអាក្រក់ជាងមុនឡើយ។

**ការចូលរួមរបស់ប្រជាជន នៅក្នុងមូលដ្ឋាន ក្នុងការរៀបចំគោលនយោបាយ REDD+ មិនសុទ្ធតែដោយសារពួកគាត់មានចំណេះដឹងតិចតួច និងមានអំណាចតិចតួច ក្នុងការធ្វើសេចក្ដីសម្រេចចិត្តលើបញ្ហានៃការប្រែប្រួលអាកាសធាតុពិភពលោកឡើយ។**

ប្រយោគនេះបង្ហាញពីបញ្ហានៃការចូលរួម និងនិរន្តរភាពនៃ REDD+។

- ប្រសិនបើ ប្រជាពលរដ្ឋក្នុងមូលដ្ឋានមិនចូលរួម ក្នុងការរៀបចំគោលនយោបាយទាំងនេះទេ គោលនយោបាយនានា អាចមានពាក់ព័ន្ធជាមួយពួកគាត់។ ស្ថានភាពនេះ អាចនាំឱ្យមានទំនាស់លើធនធាន ឬ ការប្រើប្រាស់ធនធានទាំងនេះដោយគ្មាននិរន្តរភាព។

- ប្រជាពលរដ្ឋក្នុងមូលដ្ឋាន គួរតែអាចបញ្ចូលគំនិតរបស់ខ្លួន ទៅក្នុងគោលនយោបាយដែលមានឥទ្ធិពលមកលើពួកគាត់ បើពុំនោះទេពួកគាត់នឹងមិនគោរពតាមគោលនយោបាយទាំងនោះ ហើយក៏នឹងគ្មានការអនុវត្តគោលនយោបាយនោះដែរ។

**ប្រសិនបើយើងដោះស្រាយបញ្ហាសមធម៌ យើងពិតជានឹងកាត់បន្ថយភាពក្រីក្រក្នុងចំណោមប្រជាពលរដ្ឋដែលពឹងផ្អែកលើព្រៃឈើ។**

ប្រយោគនេះបង្ហាញពីការពិភាក្សានានាជុំវិញគោលដៅ និងចំណោទនៃហេតុអ្វីបានជាសមធម៌ជារឿងសំខាន់។

- ភាពក្រីក្រមិនអាចកាត់បន្ថយទៅបានទេ បើគ្មានការដោះស្រាយបញ្ហាសមធម៌ ប៉ុន្តែដោះស្រាយបញ្ហាសមធម៌តែឯងនឹងមិនកាត់បន្ថយភាពក្រីក្របានឡើយ
- វាអាស្រ័យលើអ្នកណាខ្លះ ដែលត្រូវគិតបញ្ចូលនៅក្នុងបញ្ហាសមធម៌ ដោយសារមានលំដាប់ខុសៗគ្នាជាច្រើន និងបញ្ហាសមធម៌ដែលមានឥទ្ធិពលមកលើទិដ្ឋភាពខុសៗគ្នានៃភាពក្រីក្រ។

**កំណើនចំណាប់អារម្មណ៍ជាអន្តរជាតិលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី និងព្រៃឈើនៅកន្លែងណាមួយ គឺជាការគំរាមកំហែងធ្ងន់ធ្ងរមកលើសិទ្ធិរបស់ប្រជាជនមូលដ្ឋាន សិទ្ធិប្រើប្រាស់ព្រៃឈើ និងរបរចិញ្ចឹមជីវិត។**

ប្រយោគនេះបង្ហាញពីការយល់ឃើញមួយពីមូលហេតុដែលត្រូវផ្តោតលើសមធម៌ តាមរយៈប្រព័ន្ធការពារសុវត្ថិភាពជាមួយ "ការមិនបង្កគ្រោះថ្នាក់" ជាគោលដៅបឋមនៃការដោះស្រាយសមធម៌នៅក្នុង REDD+ និងភាពចាំបាច់ដើម្បីមានឥទ្ធិពលលើសមធម៌នៅលំដាប់ថ្នាក់ខុសៗគ្នា ចាប់ពីកម្រិតពិភពលោកដល់មូលដ្ឋាន។

- ការសម្រេចនានាដែលធ្វើឡើង នៅកម្រិតអន្តរជាតិ បង្កការប៉ះពាល់មកលើប្រជាជននៅថ្នាក់មូលដ្ឋាន។
- ចំណាប់អារម្មណ៍ គឺជាកត្តាកំណត់ពីគុណតម្លៃ ហើយប្រសិនបើគុណតម្លៃនៃសេវាកម្មនានាកើនឡើងអំណាចរបស់ពលរដ្ឋក្នុងមូលដ្ឋាន ក្នុងការត្រួតត្រាលើធនធាន ក្នុងមូលដ្ឋានរបស់ពួកគាត់អាចនឹងថយចុះ។
- ចំណាប់អារម្មណ៍ជាអន្តរជាតិ និងកំណើនគុណតម្លៃនៃសេវាកម្មនានា អាចជាឱកាសមួយសម្រាប់ពលរដ្ឋនានា ដើម្បីកែលម្អមុខរបរចិញ្ចឹមជីវិតរបស់ខ្លួនតាមរយៈការបង់ថ្លៃ និងការលើកទឹកចិត្តនានាដើម្បីឱ្យមានការគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាពកាន់តែច្រើនឡើង។

**ប្រសិនបើការបញ្ចេញឧស្ម័ន និងហានិភ័យនៃការប្រែប្រួលអាកាសធាតុត្រូវបានកាត់បន្ថយនៅកម្រិតពិភពលោក នៅពេលនោះទោះបីគម្លាតខាងសមធម៌អាចរីកកាន់តែធំនៅកម្រិតមូលដ្ឋានក៏ដោយ ក៏មិនមែនជារឿងសំខាន់ដែរ។**

ប្រយោគនេះបង្ហាញពីការជជែកវែកញែកអំពីកម្រិតមូលដ្ឋាន ធៀបនឹងពិភពលោក និងសំណួរអំពីសមធម៌របស់អ្នកណាដែលត្រូវបានគេគិតគូរច្រើនជាង។ ប្រយោគនេះក៏គូសបញ្ជាក់ផងដែរនូវសំណួរអំពីប្រសិទ្ធភាពនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ និង REDD+។

- ការប្រែប្រួលអាកាសធាតុនឹងបង្កការប៉ះពាល់មកលើប្រជាជននៅមូលដ្ឋាន និងបង្កើនគម្លាតខាងសមធម៌។ ជាការប្រសើរ ប្រហែលជាត្រូវផ្តោតលើគោលដៅនៃការកាត់បន្ថយការបញ្ចេញឧស្ម័នច្រើនជាងការខ្វាយខ្វល់អំពីយន្តការនានា ដែលបង្កការប៉ះពាល់មកលើសមធម៌។
- REDD+ អាចមិនមែនជាវិធីដែលមានប្រសិទ្ធភាពក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នប្រសិនបើបញ្ហាសមធម៌ត្រូវបានគិតគូរ។
- គេត្រូវដោះស្រាយបញ្ហាគម្លាតខាងសមធម៌ ដើម្បីរៀបចំគោលនយោបាយ ឬ យន្តការណាមួយឱ្យមាននិរន្តរភាព ឬ អនុវត្តជាមួយការទទួលខុសត្រូវរួមគ្នា ដែលរួមទាំង ការពាក់ព័ន្ធនៅកម្រិតមូលដ្ឋានផងដែរ។ ប្រជាជនមូលដ្ឋាននឹងពុំមានការប្តេជ្ញាចំពោះយន្តការណាមួយឡើយ ប្រសិនបើនៅតែគ្មានការដោះស្រាយបញ្ហាសមធម៌របស់ពួកគាត់ ឬ បើពួកគាត់ធ្លាក់ ក្នុងស្ថានភាពកាន់តែធ្ងន់ធ្ងរជាងមុន។

# តើហេតុអ្វីសមធម៌សំខាន់ នៅក្នុង REDD+ និងអន្តរាគមន៍ដទៃទៀតក្នុងវិស័យប្រែប្រួលអាកាសធាតុដោយផ្អែកលើព្រៃឈើ?

ការជជែកវែកញែកជាអន្តរជាតិអំពីការប្រែប្រួលអាកាសធាតុ និងបញ្ហាបរិស្ថានពិភពលោកដទៃទៀត ផ្តោតលើសមធម៌។ ការប្រកាសនានាអំពី REDD+ មិនមែនជាករណីលើកលែងឡើយ។ ទោះបី REDD+ ត្រូវបានបង្កើតឡើង ជាការឆ្លើយតបនឹងតម្រូវការដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយប្រសិទ្ធភាពក៏ដោយ ឥឡូវនេះអ្នកខ្លះមើលឃើញថានេះជាឱកាសមួយដើម្បីលើកកម្ពស់ចំណាប់អាម្មណ៍អំពីសហគមន៍ជនជាតិដើមភាគតិចទន់ខ្សោយ និងដែលជាអ្នកពឹងផ្អែកជាប្រវត្តិសាស្ត្រលើព្រៃឈើ។ ទោះជាយ៉ាងណាក៏ដោយ គេនៅពុំទាន់ច្បាស់លាស់នៅឡើយទេ ថាតើមានការយល់ដឹងដូចគ្នាអំពីគោលគំនិតនៃសមធម៌ឬទេ ដោយសារតែភាពស្មុគស្មាញនៃបញ្ហាសមធម៌។

## តើកំណើនតម្លៃសេវាប្រព័ន្ធអេកូឡូស៊ីបង្កជាការគំរាមកំហែងឬទេ?



វាមិនគ្រាន់តែ REDD+ មួយប៉ុណ្ណោះទេដែលបានលើកឡើងពីក្តីបារម្ភអំពីបញ្ហាសមធម៌។ការដាក់ជាទំនិញនូវសេវាកម្មផ្សេងទៀតនៃប្រព័ន្ធ អេកូឡូស៊ី ដូចជាការគ្រប់គ្រងទីជំរាល ការធ្វើអាជីវកម្មរ៉ែ ការធ្វើអាជីវកម្មព្រៃឈើ និងធនធានហ្សែន ត្រូវបានគូសបញ្ជាក់ថា ជាការគំរាមកំហែងចំពោះសមធម៌ នៅសហគមន៍មូលដ្ឋាន ដែលជាញឹកញាប់ទាក់ទងនឹងសិទ្ធិសេរីភាព ក្នុងការចេញចូលអត្ថប្រយោជន៍ និងមុខរបរចិញ្ចឹមជីវិត។ គេមានកង្វល់ថា សមធម៌នៅមូលដ្ឋានអាចនឹងត្រូវស្រុតចុះ ស្របជាមួយកំណើនគុណតម្លៃសកលនៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី បើទោះបីជាវាកើតឡើងដោយសារយន្តការទីផ្សារ ឬ ត្រូវបានទូទាត់តាមរយៈកិច្ចផ្តួចផ្តើមជាសកលក៏ដោយ។ ភស្តុតាងជាប្រវត្តិសាស្ត្របង្ហាញថា នៅពេលដែលធនធានធម្មជាតិបានកើនតម្លៃសហគមន៍ដែលគ្រប់គ្រង និងពឹងផ្អែកលើធនធានទាំងនោះអស់រយៈ ពេលជាច្រើនសតវត្សរ៍មកហើយនោះ ត្រូវបានរដ្ឋាភិបាល ឬ វិស័យឯកជន មើលរំលង ឬ បណ្តេញចេញដែលនាំឱ្យមានទំនាស់ធ្ងន់ធ្ងរលើ ធនធានធម្មជាតិ និងការគ្រប់គ្រងធាននេះឱ្យមាននិរន្តរភាព។

## តើការមើលរម្លងកង្វល់អំពីសមធម៌នៅក្នុង REDD+ ឬកម្មវិធីដទៃទៀត បង្កផលវិបាកអ្វីខ្លះ?

មុនពេលដែល REDD+ បានក្លាយជារបៀបវារៈអន្តរជាតិ ទីភ្នាក់ងារនានាដែលបានធ្វើការស្រាវជ្រាវអំពីការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព បានបង្ហាញពីចំណងទាក់ទងរវាងករណីទំនាស់ កង្វះភាពច្បាស់

លាស់នៃសិទ្ធិកាន់កាប់ និងការគ្រប់គ្រងព្រៃឈើដែលគ្មាននិរន្តរភាព។ ប្រការសំខាន់គឺថា ចំណុចទាំងនេះមិនត្រូវគេមើលរម្លងឡើយនៅក្នុងការជជែកអំពី REDD+ ជាពិសេសដោយសារ REDD+ ផ្តោតលើការកាត់បន្ថយការបាត់បង់ព្រៃឈើ។ មេរៀននានាពីការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាពអំពីការរួមបញ្ចូលតម្រូវការខាងសង្គម បរិស្ថាន និងសេដ្ឋកិច្ច ត្រូវបានទទួលការពិចារណា នៅពេលអនុវត្តសកម្មភាព REDD+។ ប្រសិទ្ធផល និងប្រសិទ្ធភាពនៃ REDD+ នឹងរងការប៉ះពាល់ធ្ងន់ធ្ងរ ប្រសិនបើកង្វល់អំពីសមធម៌មិនត្រូវបានយកចិត្តទុកដាក់ដោយម៉ត់ចត់ទេនោះ ហើយទំនាស់នឹងរីកដាល របរចិញ្ចឹមជីវិតនឹងត្រូវរួមតូចចំណែកការបាត់បង់ព្រៃឈើ នឹងបន្តនៅក្នុងកន្លែងនានាដែលត្រូវជំរុញ REDD+។

## លើកកម្ពស់ ឬ រក្សាគុណភាពនៃសមធម៌?

នៅក្នុងករណីនៃ REDD+ កិច្ចផ្តួចផ្តើម និងអ្នកធ្វើសេចក្តីសម្រេចចិត្តភាគច្រើនបានជ្រើសយកគោលនយោបាយ "មិនបង្កគ្រោះថ្នាក់"។ នេះដោយសារមួយផ្នែកវាជាលក្ខខណ្ឌដើម្បីរក្សា REDD+ ឱ្យនៅជាយន្តការមួយសម្រាប់កាត់បន្ថយការបញ្ចេញឧស្ម័ន និងដោយសារ REDD+ ត្រូវបានមើលឃើញតាំងពីដំបូងថាជាយន្តការមួយសម្រាប់កាត់បន្ថយការប្រែប្រួលអាកាសធាតុ - ប៉ុន្តែ មិនមែនដើម្បីសម្រួលឱ្យមានការកែប្រែសង្គមឡើយ។ ទោះជាយ៉ាងណាក៏ដោយ អង្គការ និងរដ្ឋាភិបាលជាច្រើន ដែលគាំទ្រ REDD+ ចាត់ទុកគោលដៅនានានៃយន្តការនេះថា ផ្តល់អត្ថប្រយោជន៍ដល់គ្នាទៅវិញទៅមកសម្រាប់អ្នកពាក់ព័ន្ធនានា ជាពិសេស ក្នុងករណីដែលសហគមន៍មូលដ្ឋាន ដែលជាអ្នកប្រើប្រាស់ធនធានដោយផ្ទាល់ និងអ្នកគ្រប់គ្រងចំបងៗ ដែលពាក់ព័ន្ធនៅក្នុងដំណើរការនេះ។ ក្នុងករណីខ្លះ ប្រការនេះបានបង្កើតជាការគាំទ្រដើម្បីលើកកម្ពស់សមធម៌នៅក្នុងសកម្មភាព REDD+។ វាក៏អាចទាក់ទងផងដែរជាមួយការចែកចាយផលប្រយោជន៍ ការពង្រឹងសិទ្ធិ និងការកសាងសមត្ថភាព ដែលអាស្រ័យលើបរិបទជាក់លាក់។

## កង្វះភាពច្បាស់លាស់អំពីសមធម៌

ទោះបីកិច្ចផ្តួចផ្តើមជាច្រើនមានបង្កប់ការលើកកម្ពស់សមធម៌ក៏ដោយ គេឃើញភាពមិនច្បាស់លាស់អំពីទិដ្ឋភាពនានានៃសមធម៌ ដែលកំពុងតែស្ថិតក្នុងការដោះស្រាយ។ តើសមធម៌នៅក្នុងការបែងចែកថ្លៃចំណាយនិងផលចំណេញឬទេ? តើវាជាការបែងចែកក្នុងចំណោមគ្រួសារនានានៅក្នុងសហគមន៍ រវាងអ្នកពាក់ព័ន្ធនានានៅមូលដ្ឋាន និងថ្នាក់ជាតិ ឬ រវាងមនុស្សជំនាន់ខុសៗគ្នាឬទេ? តើវាជាកង្វល់អំពីភាពត្រឹមត្រូវនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តឬទេ?ឬ មួយវាជាកង្វល់អំពីឱកាសសម្រាប់ធ្វើឱ្យអ្នកដទៃបាន ឮសម្លេងរបស់ភ្នាក់ងារដែលទន់ខ្សោយ?

## ជំពូកនៃសមធម៌

ដោយផ្អែកលើការវិភាគអំពីយុត្តិធម៌សង្គម McDermott et al. (2011) បានគូសបញ្ជាក់ជំពូកនៃសមធម៌ ដែលបង្ហាញពីភាពខុសគ្នាដូចតទៅ (តារាងទី ៣)។

### តារាងទី ៣៖ ជំពូកនានានៃសមធម៌

| ជាតុផ្សំ | គោលដៅ | ឧទាហរណ៍អំពីបរិបទនៃបញ្ហាសមធម៌បច្ចុប្បន្ននៅក្នុង REDD+ |
|---|---|---|
| ការបែងចែក | ការបែងចែក អត្ថប្រយោជន៍ ថ្លៃចំណាយ និងលទ្ធផល | ប្រព័ន្ធចែកផលដែលបានស្នើឡើងមិនច្បាស់លាស់ និងមិនត្រឹមត្រូវ។ ថ្លៃឱកាសនៃ REDD+ នៅថ្នាក់មូលដ្ឋាន ខ្ពស់ជាងផលចំណូលដែលស្នើឡើង ភាពមិនច្បាស់លាស់នៃការប្រែប្រួលថ្លៃកាបូនលើទីផ្សារ ដែលនាំឱ្យគ្មានភាពប្រាកដប្រជា។ |
| នីតិវិធី និង ការចូលរួម | ដំណើរការ ការបង្ហាញ កង្វល់ និង ការធ្វើសេចក្តី សម្រេចចិត្ត | ខ្វះព័ត៌មាន ខ្វះតម្លាភាពក្នុងចំណោមអ្នកពាក់ព័ន្ធនានានៅលំដាប់ថ្នាក់ខុសៗគ្នា យន្តការសម្រាប់ការធ្វើជាតំណាងពុំមានប្រសិទ្ធភាព មានចូលរួមតិចតួច ឬគ្មានការចូលរួម គ្មានយន្តការបណ្តឹងសារទុក្ខ យន្តការធ្វើជាតំណាងគ្មានប្រសិទ្ធភាព ខ្វះការចូលរួម ឬមានតិចតួចនៃក្រុមជាក់លាក់ ការរៀបចំគោលនយោបាយ និងដំណើរការពិគ្រោះយោបល់ ការធ្វើសេចក្តីសម្រេចចិត្តបែបបញ្ជាពីលើចុះក្រោម។ |
| បរិបទ | លក្ខខណ្ឌដំបូង | ទំនាស់លើវិភាជន៍ដីធ្លី និងការប្រើប្រាស់ធនធាន សិទ្ធិតាមប្រពៃណី សម្រាប់គ្រប់គ្រង និងកម្មសិទ្ធិ មិនបានទទួលស្គាល់តាមច្បាប់ គ្មានព្រំប្រទល់ច្បាស់លាស់លើការប្រើប្រាស់ធនធាន និងការទទួលខុសត្រូវ ផលប្រយោជន៍ដែលផ្តល់ឱ្យ និងអំណាចរបស់អ្នកពាក់ព័ន្ធជាក់លាក់ដែលធ្លាប់តែមានភាពទន់ខ្សោយ សមត្ថភាពទាបរបស់ក្រុមអ្នកទន់ខ្សោយ ដែលមិនអាចសំដែងទស្សនៈរបស់ខ្លួននៅក្នុងលក្ខខណ្ឌខ្លះនៃការដកហូតអំណាច។ |

Source: McDermott et al. (2011).

## ក្របខ័ណ្ឌសម្រាប់កំណត់សមធម៌

រាល់គម្រោង ឬ កិច្ចផ្តួចផ្តើមនានាដែលធ្វើការលើ REDD+ ឬ ការបញ្ចូលអន្តរាគមន៍ពីខាងក្រៅមកមជ្ឈដ្ឋានខាងក្នុង គួរតែមានការយល់ច្បាស់អំពីទិដ្ឋភាពនានានៃសមធម៌ដែលត្រូវរក្សាការពារ ឬកែលម្អ។ ប្រការនេះនឹងជួយកំណត់គោលដៅសម្រាប់រៀបចំគ្រោងការយុទ្ធសាស្ត្រ និងការវាយតម្លៃផលប៉ះពាល់។

ក្នុងនាមជាអ្នកសម្របសម្រួលដំណើរការចូលរួមនៅនៅថ្នាក់មូលដ្ឋាន អ្នកគួរតែបែងចែកបញ្ហាទាំងនេះឱ្យលម្អិត និងផ្តោតលើជាតុផ្សំណាខ្លះដែលអ្នកចង់ដោះស្រាយ។ ការធ្វើបែបនេះនឹងមានប្រយោជន៍នៅពេលដាក់បញ្ចូលគោលគំនិតអំពីសមធម៌ ឬបង្ហាញបញ្ហាសមធម៌នៅក្នុងកិច្ចផ្តួចផ្តើមរបស់អ្នក ជាមួយអ្នកពាក់ព័ន្ធនានាផ្សេងទៀតនៅថ្នាក់មូលដ្ឋានផងដែរ។

នៅពេលគិតគូរអំពីឱកាសស្មើគ្នាសម្រាប់បុរស ស្ត្រី កុមារា និងកុមារី ដើម្បីចូលរួម និងទទួលផលសមធម៌យេនឌ័រក៏ជាធាតុផ្សំសំខាន់មួយផងដែរ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហានេះនៅពុំទាន់បានពិចារណាទៅតាមបរិបទរបស់វានៅឡើយទេ។

**រូបទី ៤: ក្របខ័ណ្ឌសម្រាប់កំណត់សមធម៌**



# ច. ផ្សារភ្ជាប់ការចូលរួម និងសមធម៌



**គោលបំណងនៃការរៀនសូត្រ**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹង៖

- អាចពន្យល់អំពីរបៀប ដែលគុណតម្លៃស្នូលទាំងបួននៃការចូលរួម អាចអនុវត្តបាននៅក្នុងបរិបទនៃនីតិវិធីរបស់ សមធម៌។
- កំណត់បានអត្តសញ្ញាណឧបសគ្គបឋមៗ នៃការចូលរួមនៅក្នុងបរិបទ REDD+ របស់ពួកគាត់ផ្ទាល់ក្នុងពេលបច្ចុប្បន្ន និងនៅលំដាប់ថ្នាក់ខុសៗគ្នា(មូលដ្ឋានជាតិ និងអន្តរជាតិក៏ដូចជាទាក់ទងនឹងក្រុមអ្នកពាក់ព័ន្ធទន់ខ្សោយខុសៗគ្នាជាច្រើន និងដែលទាក់ទងជាមួយយេនឌ័រផងដែរ)និង
- អាចពន្យល់ភាពខុសគ្នារវាងការចូលរួម និងការធ្វើជា តំណាង។

**សម្ភារៈ**

ក្រដាសផ្ទាំងធំ ហ្វឺត ក្រដាស Post-it ស្អិតដ្យាក្រាមនៅ លំដាប់ថ្នាក់ខុសៗគ្នា ចំនួន បីសន្លឹក (រៀបចំលើក្រដាសផ្ទាំងធំ) និងឯកសារអំណាន។




**រយៈពេល**

១២០នាទី

## ជំហានអនុវត្ត

១. បង្ហាញជូនមេរៀននេះដោយសរសេរពាក្យ "ការចូលរួម" នៅលើក្រដាសផ្ទាំងធំនៅខាងមុខក្នុងបន្ទប់នេះ។ ស្នើសិក្ខាកាមផ្តល់គំនិតថា តើការចូលរួមពាក់ព័ន្ធបែបណាជាមួយសមធម៌ និងផ្សារភ្ជាប់រវាងការពិភាក្សានេះជាមួយមេរៀនមុន អំពីមូលហេតុដែលថា សមធម៌ជារឿងសំខាន់ នៅក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលផ្អែកលើព្រៃឈើ។




២. សូមពន្យល់ថា នៅក្នុងមេរៀននេះ អ្នកនឹងប្រើប្រាស់ឧទាហរណ៍ និងបរិបទ REDD+ សម្រាប់ការវិភាគ។ ត្រូវឱ្យប្រាកដថា សិក្ខាកាមផ្សារភ្ជាប់មេរៀននេះជាមួយបរិបទនៃ សមធម៌បែបនីតិវិធី។

៣. សួរសិក្ខាកាម ហេតុអ្វីចាំបាច់ត្រូវផ្សារភ្ជាប់ការចូលរួមទៅនឹងសមធម៌នៅក្នុងបរិបទ REDD+។ សូមកត់ត្រាចម្លើយរបស់ពួកគាត់លើក្រដាសផ្ទាំងធំដើម្បីអ្នកអាចពិនិត្យឡើងវិញ នៅពេលក្រោយក្នុងមេរៀននេះ។ ត្រូវប្រាកដថា ក្រុមនេះស្វែងយល់ពីមូលហេតុឱ្យបានច្រើន តាមតែអាចធ្វើបានសម្រាប់តម្រូវការឱ្យមានការចូលរួម។ ប្រសិនបើចាំបាច់អ្នកត្រូវឱ្យសិក្ខាកាមពិភាក្សាជាគូរយៈពេល ២-៣ នាទី។

៤. បង្ហាញជូនពីគុណតម្លៃស្នូលចំនួនបួននៃការចូលរួម (ការចូលរួមពេញលេញ ការយោគយល់គ្នាទៅវិញទៅមក ដំណោះស្រាយសម្រាប់ទាំងអស់គ្នា ឬគោលការណ៍ដែលមានការឯកភាពគ្នាទូលំទូលាយ និងការទទួលខុសត្រូវរួម)។ ចូរគូរចេញជាស្រទាប់ផ្កានៅលើក្រដាសផ្ទាំងធំ។

៥. ស្នើក្រុមនេះឱ្យពន្យល់ថាតើគុណតម្លៃនីមួយៗមានន័យបែបណា និងតើវាមានការពាក់ព័ន្ធគ្នាទៅវិញទៅមកបែបណា។

៦. ប្រសិនបើក្រុមនេះមិនអាចពន្យល់ទេនោះ អ្នកគួរផ្ដល់សេចក្ដីសង្ខេបខ្លីមួយដោយផ្អែកលើឯកសារអំណាន (ប៉ុន្តែមិនត្រូវចែកឯកសារនោះក្នុងពេលនេះទេ)។ ត្រូវប្រាកដថា អ្នករៀបចំគុណតម្លៃទាំងនោះ ជាលំដាប់លំដោយមួយម្ដងៗ ដោយចាប់ផ្ដើមពីការចូលរួមពេញលេញបន្តដោយការយោគយល់គ្នាទៅវិញទៅមក បន្ទាប់មកដំណោះស្រាយសម្រាប់ទាំងអស់គ្នា ឬ គោលការណ៍ដែលឯកភាពគ្នាជារួម និងទីបំផុតការទទួលខុសត្រូវរួម។

៧. ក្រោយពីបានបញ្ចប់ សូមផ្ដល់ឧទាហរណ៍មួយដែលផ្សារ ភ្ជាប់ទៅនឹងគុណតម្លៃនីមួយៗពីបរិបទ REDD+ និង សមធម៌បែបនីតិវិធី (សូមអានឯកសារអំណាន ប៉ុន្តែមិនត្រូវចែកឥឡូវនេះទេ)។

៨. សូមបិទភ្ជាប់កម្រិតខុសៗគ្នានៃបរិបទ (ដូចដែលបានកត់សំគាល់ពីខាងដើម) នៅជិតប័ណ្ណគុណតម្លៃនៃការចូលរួម។ សូមពន្យល់ថា លំហាត់បន្ទាប់ពីនេះនឹងផ្ដោតលើអ្វីដែលត្រូវកើតឡើង ដើម្បីលើកកម្ពស់គុណតម្លៃនៃការចូលរួមទាំងនេះ នៅគ្រប់លំដាប់ថ្នាក់ក្នុងបរិបទនៃ REDD+។ សូមពន្យល់ក្រុមនេះ អំពីលំដាប់នីមួយៗ ដោយផ្ដល់ឧទាហរណ៍នៅលំដាប់នីមួយៗ។




៩. ចែកសិក្ខាកាមជាបីក្រុម។ ផ្ដល់ឱ្យក្រុមនីមួយៗនូវ ក្រដាសផ្ទាំងធំជាមួយរង្វង់នៅលំដាប់ខុសៗគ្នាដែលបានគូររួចមកហើយនៅលើនោះ។ ត្រូវប្រាកដថា ក្រុមទាំងនេះមិនភ្លេចរង្វង់ខាងក្នុងនៃក្រុមអ្នកទន់ខ្សោយឡើយ។

១០. សូមឱ្យក្រុមនីមួយៗ កំណត់អត្តសញ្ញាណឧបសគ្គចំពោះការចូលរួមឱ្យបានគ្រប់គ្នានៅលំដាប់ថ្នាក់នីមួយៗ។ ពួកគាត់ត្រូវសរសេរឧបសគ្គមួយនៅលើក្រដាស Post-it មួយសន្លឹក និងបិទភ្ជាប់នៅលំដាប់ថ្នាក់ដែលពាក់ព័ន្ធ។ ពួកគាត់អាចសរសេរឧបសគ្គច្រើនជាងមួយនៅលំដាប់នីមួយៗ។ ត្រូវលើកទឹកចិត្តពួកគាត់ឱ្យគិតអំពីលំដាប់ថ្នាក់ទាំងអស់ តែមិនមែនត្រឹមលំដាប់ថ្នាក់ដែលពួកគាត់ដឹងច្បាស់ជាងគេនោះឡើយ។

១១. ផ្តល់ឱ្យសិក្ខាកាមទាំងអស់រយៈពេល ៤០នាទី សម្រាប់កិច្ចការនេះ បន្ទាប់មកប្រមូលពួកគាត់មកជុំគ្នាវិញ ដើម្បីពិនិត្យមើលតារាងរបស់គ្នាទៅវិញទៅមក។ សុំឱ្យក្រុមទាំងនេះប្តូរវេន និងពិនិត្យមើលលទ្ធផលរបស់គ្នាទៅវិញទៅមកតាមវេន (ដោយប្រើប្រាស់វិធីជប់លៀង) និងពិនិត្យមើលភាពដូចគ្នា និងខុសគ្នានៅលំដាប់ថ្នាក់នីមួយៗ និងរវាងក្រុមនានា។

១២. នៅពេលពួកគាត់បានឃើញលទ្ធផលរបស់គ្នាទៅវិញទៅមកហើយ សូមសួរសំណួរដូចទៅ៖

- *តើមានឧបសគ្គអ្វីខ្លះដែលដូចគ្នា និងខុសគ្នារវាងក្រុមទាំងអស់?*
- *តើឧបសគ្គដូចគ្នាមាននៅលំដាប់ថ្នាក់ខុសគ្នាដែរឬទេ?*
- *ប្រសិនបើ ការចូលរួមត្រូវបានរៀបចំជាគំរូដែលចាត់ចែងបានត្រឹមត្រូវល្អនៅក្នុងសហគមន៍ព្រៃឈើ និងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ហេតុអ្វីវានៅតែគ្មានប្រសិទ្ធភាពនៅក្នុងដំណើរការ REDD+?*
- *តើមានការប្រើប្រាស់យុទ្ធសាស្ត្រអ្វីខ្លះ ដើម្បីដោះស្រាយឧបសគ្គនានា នៅលំដាប់ថ្នាក់ខុសៗគ្នា?*
- *តើគុណតម្លៃណាខ្លះ ដែលជាទូទៅពិបាកសម្រេចបានជាងគេ និងតើវាទាក់ទងបែបណាជាមួយឧបសគ្គ?*
- *ប្រសិនបើការលើកកម្ពស់ការចូលរួមរបស់ក្រុមខុសៗគ្នាមានសារៈសំខាន់ និងដើម្បីធានាឱ្យមានការទទួលខុសត្រូវរួម ហេតុអ្វីប្រការនេះ នៅពុំបានទទួលការពិចារណាច្រើនជាងនេះនៅគ្រប់លំដាប់ថ្នាក់?*
- *ក្រុមណាខ្លះដែលច្រើនតែមិនបានរួមបញ្ចូលនៅក្នុងបរិបទរបស់អ្នក និងហេតុអ្វី?*
- *តើយុទ្ធសាស្ត្រអ្វីខ្លះដែលបានប្រើប្រាស់ ដើម្បីធានាថា ក្រុមទាំងនោះចូលរួម? តើការចូលរួមនេះត្រូវបានតាមដានបែបណា?*
- *តើតួនាទីរបស់អ្នកមានប្រសិទ្ធភាពកម្រិតណា ក្នុងនាមជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន នៅក្នុងការដោះស្រាយឧបសគ្គ និងការធានាឱ្យមានការចូលរួមនៅលំដាប់ថ្នាក់ ខុសៗគ្នា?*

- *តើអ្នកបានបញ្ចូលសមធម៌យេនឌ័របែបណា នៅពេលគិតអំពីឧបសគ្គ? នៅលំដាប់ថ្នាក់ណាដែលអ្នកគិតថាសមធម៌យេនឌ័រគឺជាបញ្ហាមួយ?*
- *តើលំដាប់ថ្នាក់ណាដែលអ្នកគិតថា អ្នកអាចមានឥទ្ធិពល និងហេតុអ្វី? ឬ នៅលំដាប់ថ្នាក់ណាដែលបច្ចុប្បន្ននេះរូបអ្នកមានឥទ្ធិពល និងហេតុអ្វី?*
- *តើអ្នកធ្វើបែបណា ដើម្បីមានឥទ្ធិពលមកលើការប្រើប្រាស់គុណតម្លៃនៃការចូលរួមនៅលំដាប់ថ្នាក់ខុសៗគ្នាក្នុងបរិបទ REDD+ របស់អ្នក?*

១៣. សួរក្រុមនេះថាតើពួកគាត់គិតថាមានភាពខុសគ្នាអ្វីខ្លះរវាងការចូលរួមនិងការធ្វើជាតំណាង។ តើមួយមានឥទ្ធិពលមកលើមួយទៀតដែរឬទេ និងតើអ្នកធ្វើបែបណាដើម្បីធានាថា ការធ្វើជាតំណាងនិងការចូលរួមមានគុណភាពខ្ពស់?

១៤. សូមបូកសរុបមេរៀននេះ ដោយសង្កត់ធ្ងន់ថា ប្រសិនបើយើងចង់មានឥទ្ធិពលមកលើសមធម៌បែបនីតិវិធី និងការចូលរួមនៃអ្នកពាក់ព័ន្ធ ដែលមិនសូវមានអំណាចនៅគ្រប់លំដាប់ថ្នាក់ យើងត្រូវតែដឹងអំពីឧបសគ្គ និងឆ្លើយតបទៅនឹងឧបសគ្គទាំងនោះជាមួយយុទ្ធសាស្ត្រខុសៗគ្នា។ ចូរពន្យល់ថា អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានម្នាក់អាចមានតួនាទីជាច្រើន នៅក្នុងយុទ្ធសាស្ត្រទាំងនេះទាំងនៅក្នុងក្រុមអ្នកទន់ខ្សោយ និងនៅក្នុងលំដាប់អ្នកពាក់ព័ន្ធតាមមូលដ្ឋាន។ សូមគូសបញ្ជាក់ថាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន អាចជាមធ្យោបាយមួយសម្រាប់ប្រមូលយោបល់ និងភស្តុតាងពីថ្នាក់មូលដ្ឋាន និងចែករំលែកជាមួយលំដាប់ថ្នាក់ខុសៗគ្នា (ជាតិ តំបន់ និងអន្តរជាតិ) ដោយគ្មានការបកស្រាយខុសអំពី ទស្សនៈរបស់អ្នកពាក់ព័ន្ធឡើយ។ តួនាទីនេះនឹងត្រូវពិនិត្យមើលក្នុងមេរៀនក្រោយៗ។




## កំណត់សំគាល់របស់គ្រូបង្ហាត់

មេរៀននេះនឹងជួយអ្នកដើម្បីទទួលបានអារម្មណ៍អំពីការយល់ឃើញរបស់សិក្ខាកាម ចំពោះការប្រឈមនៃការចូលរួម និងភាពជាក់ស្តែងសម្រាប់ក្រុមខុសៗគ្នានៅលំដាប់ថ្នាក់ខុសគ្នា។ មេរៀននេះក៏ផ្តល់ឱ្យអ្នកផងដែរនូវចំណាប់អារម្មណ៍អំពីថា តើក្រុមនេះយល់បែបណាពីចំណងទាក់ទងរវាងការចូលរួម និងសមធម៌ផងដែរ។

# ការកំណត់រកឧបសគ្គចំពោះការចូលរួម

## ការត្រៀមលក្ខណៈសម្រាប់ការចូលរួម

ប្រសិនបើក្រុមមួយពុំមានបទពិសោធន៍ច្រើនអំពីគោលការណ៍គ្រឹះនៃការចូលរួមនោះទេ អ្នកត្រូវរួមបញ្ចូលលំហាត់ "ថាមពល"[៨] ដែលអាចបំភ្លឺបន្ថែមទៀតអំពីគុណតម្លៃស្នូលសំខាន់ៗ។ វិធីមួយគឺការប្រើប្រាស់លំហាត់រើសសំរាមដែលក្នុងនោះអ្នកសុំឱ្យមានសិក្ខាកាមពីរក្រុមដែលមានគ្នាបួននាក់ និងមួយក្រុមជាអ្នកសង្កេតការណ៍។ ចូរពន្យល់ទៅក្រុមទាំងពីរថាពួកគាត់មានរយៈពេល ៥នាទី ដើម្បីនាំយកវត្ថុដូចខាងក្រោមនេះត្រឡប់មកក្នុងបន្ទប់នេះវិញ(ផ្កាមួយបាច់ ត្រាប្រើហើយមួយ មួកនគរបាលមួយ ផែនទីពិភពលោកមួយ ស្រមោចងាប់មួយ កាហ្វេត្រជាក់មួយពែង និងត្រីរស់មួយ)។ ចូរធ្វើការឆ្លុះបញ្ចាំងជាមួយក្រុមនីមួយៗ អំពីថាតើពួកគាត់ធ្វើការសម្រេចចិត្តបែបណាទៅការប្រមូលយកអ្វីខ្លះ និងពីទីណាហើយផ្សារភ្ជាប់ជាមួយបញ្ហានេះនូវគោលការណ៍ទាំងបួននៃការចូលរួម គឺការចូលរួមពេញលេញ ការយោគយល់គ្នាទៅវិញទៅមក ដំណោះស្រាយសម្រាប់ទាំងអស់គ្នា/គោលការណ៍ដែលបានឯកភាពគ្នាជារួម និងការទទួលខុសត្រូវរួមគ្នា។

ឯកសារបណ្ដុះបណ្ដាលនេះមិនរួមបញ្ចូលមេរៀនស្ដីពីការវិភាគអ្នកពាក់ព័ន្ធឡើយ ប៉ុន្តែប្រសិនបើក្រុមណាមួយមិនទំនងជាយល់ពីឧបករណ៍នេះ គេអាចបន្ថែមពេលបន្តិចដើម្បីពន្យល់ឧបករណ៍នេះដោយរួមបញ្ចូលជាមួយមេរៀននេះឬមេរៀនស្ដីពីអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន។គួរតែធ្វើការវិភាគឱ្យបានល្អអំពីអ្នកពាក់ព័ន្ធ ដើម្បីបំភ្លឺអំពីឧបសគ្គចំពោះការចូលរួម ដែលអាចជួយអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានក្នុងការរៀបចំដំណើរការពាក់ព័ន្ធដ៏ល្អមួយ។

ត្រូវឱ្យប្រាកដថា ក្រុមនីមួយៗមានក្រដាសផ្ទាំងធំមួយសន្លឹកជាមួយស្លាកដែលមានសរសេរពាក្យខុសៗគ្នា និងមានកន្លែងគ្រប់គ្រាន់សម្រាប់បន្ថែមក្រដាស Post-it ដែលឆ្លុះបញ្ចាំងពីឧបសគ្គនានាដែលពួកគាត់បានលើកឡើងនៅលំដាប់ថ្នាក់នីមួយៗ។




៨ លំហាត់ថាមពលគឺជាជាសកម្មភាពរហ័ស ធ្វើឲ្យរីករាយ ដើម្បីធ្វើឲ្យក្រុមមានសកម្មភាពរស់រវើក។

# ការចូលរួម និងសមធម៌

## តើការចូលរួម និងសមធម៌ទាក់ទងគ្នាដូចម្តេច?

ប្រសិនបើសមធម៌និយាយអំពី "ភាពត្រឹមត្រូវ នៃការប្រព្រឹត្តរបស់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងការរៀបចំគោលនយោបាយ និងការអនុវត្តគោលនយោបាយទាំងនោះ ដោយផ្អែកលើគោលការណ៍ដែលឯកភាពគ្នា" ( ដូចដែលបានពិភាក្សា នៅក្នុងមេរៀនខាងដើម ស្តីពីសមធម៌) ក្នុងន័យនេះ ឮ សំណួរគឺ៖ តើអ្នកណាជាអ្នកកំណត់ភាព "ត្រឹមត្រូវ" និង "គោលការណ៍ដែលឯកភាពគ្នា"?



សមធម៌ មិនដូចគ្នានឹងការចូលរួមឡើយ។ ប៉ុន្តែ គេមិនអាចមានលទ្ធផលប្រកបដោយសមធម៌ឡើយ ប្រសិនបើការចូលរួមមិនត្រូវបានចាត់ជាធាតុផ្សំចាំបាច់មួយនៅក្នុងដំណើរការ និងនីតិវិធីធ្វើសេចក្តីសម្រេចចិត្ត។ ការផ្តល់ឱកាសដូចគ្នា សម្រាប់អ្នកពាក់ព័ន្ធនានាដើម្បីមានឥទ្ធិពលមកលើថាតើនីតិវិធី ឬគោលការណ៍ណាខ្លះបានទទួលការឯកភាពបែបណា ទំនងជានឹងនាំឱ្យមានការអនុវត្តដោយនិរន្តរភាព និងការទទួលខុសត្រូវរួម។ ប្រការនេះអាចអនុវត្តបាននៅក្នុងបរិបទណាមួយនៃព្រៃឈើ ប៉ុន្តែមានលក្ខណៈស្មុគស្មាញនៅក្នុងបរិបទ REDD+ ដោយសារវាទាក់ទងជាមួយស្ថាប័នជាច្រើន នៅលំដាប់ថ្នាក់ខុសៗគ្នា ចាប់ពីថ្នាក់ពិភពលោក ដល់មូលដ្ឋាន។ វាហាក់ដូចជា មិនមែនជាគោលការណ៍ណាមួយដែលបានឯកភាពគ្នា នឹងត្រូវបានចាត់ទុកថាត្រឹមត្រូវឡើយ ប្រសិនបើក្រុមអ្នកពាក់ព័ន្ធនានាមិនត្រូវបានបញ្ចូលនៅក្នុងដំណើរការនេះទេនោះ។

## ឧបសគ្គចំពោះការចូលរួមនៅក្នុងដំណើរការ REDD+

តារាងទី ៤ អធិប្បាយអំពីឧបសគ្គខ្លះៗចំពោះការចូលរួមនៅក្នុងដំណើរការ REDD+ នៅលំដាប់ថ្នាក់ខុសៗគ្នា។ តារាងនេះក៏បង្ហាញផងដែរអំពីអ្នកពាក់ព័ន្ធខុសៗគ្នា និងការប្រឈមខ្លះៗដែលពួកគាត់ជួបប្រទះ នៅក្នុងការចូលរួមក្នុងដំណើរការ REDD+។

**តារាងទី ៤៖** ឧបសគ្គនានាចំពោះការចូលរួមនៅក្នុងដំណើរការ REDD+ នៅលំដាប់ថ្នាក់ខុសៗគ្នា

| ក្រុមអ្នកទន់ខ្សោយ | ក្រុមពហុអ្នកពាក់ព័ន្ធនៅមូលដ្ឋាន | ក្រុមពហុអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ | កម្រិតពិភពលោក |
|---|---|---|---|
| ជាប់រវល់ក្នុងជីវភាព និងជីវិតរស់នៅប្រចាំថ្ងៃ<br><br>ឧបសគ្គចំពោះរបបចិញ្ចឹមជីវិត<br><br>ទទួលបានព័ត៌មានតិចតួច<br><br>ខ្វះសិទ្ធិអំណាច ឬ សមត្ថភាពដើម្បីសំដែងយោបល់របស់ខ្លួន<br><br>គ្មានតំណាង ឬចនាសម្ព័ន្ធស្ថាប័ន ច្បាស់លាស់<br><br>នៅឆ្ងាយពីសេចក្តីថ្លែងការណ៍ និងឱកាសចូលរួមក្នុងការប្រជុំផ្លូវការទាំងចម្ងាយនិងលទ្ធភាព<br><br>ខ្វះសមធម៌យេនឌ័រ<br><br>ការមាក់ងាយចំពោះក្រុមខ្លះក្នុងសង្គម<br><br>លំដាប់ថ្នាក់នៃអំណាចនៅថ្នាក់មូលដ្ឋានក្រុមវរជនឮ្លាមយកធនធាន និងឱកាសខ្វះការយល់ដឹងពីពាក្យបច្ចេកទេសក្នុង REDD+ ភាសាស្មុគស្មាញមិនងាយយល់<br><br>ត្រូវបានដកចេញពីសេចក្តីថ្លែងការណ៍នានាដោយសារព័ត៌មានដែលមានកម្រិតកំណត់ ត្រឹមភាសាមួយចំនួនតូច(ច្រើនតែភាសាជាតិ) | ឧបសគ្គខាងភាសា<br><br>អាណត្តិនិងចំណាប់អារម្មណ៍ខុសគ្នា<br><br>ការប្រើប្រាស់ធនធាន(ពេលវេលា ប្រាក់ និងធនធានមនុស្ស)<br><br>បទពិសោធន៍តិចតួចលើការចូលរួមដោយប្រសិទ្ធភាព<br><br>ដំណើរការមានគណនេយ្យភាពទាប (សមស្របនៅលំដាប់ថ្នាក់ដទៃទៀតប៉ុណ្ណោះ)<br><br>មានពេលតិចតួចក្នុងការទទួលបានបច្ចេកវិទ្យា (មានជម្រើសតិចតួចដើម្បីកែលម្អការទទួលបានព័ត៌មាន និងទម្រង់ នៃការចូលរួម)<br><br>ពាក្យបច្ចេកទេសទាក់ទងនឹង REDD+ ស្មុគស្មាញ ឬ គ្មានការពន្យល់នៅថ្នាក់មូលដ្ឋាន<br><br>ជួនកាលស្មានថាអ្នកពាក់ព័ន្ធនៅមូលដ្ឋាន យល់នូវគោលគំនិត និងបញ្ហានានា | ឧបសគ្គខាងភាសា<br><br>ទម្លាប់ ផ្ទត់គំនិតនិងវិធានពីលើចុះក្រោម<br><br>ផលប្រយោជន៍ទំនាស់គ្នា សូម្បីក្នុងចំណោមស្ថាប័នរដ្ឋាភិបាល<br><br>ធនធានយោបាយទាបសម្រាប់សម្របសម្រួលការចូលរួមឱ្យបានទូលាយ<br><br>ចំណាយពេលច្រើន<br><br>គ្មានភាពច្បាស់លាស់នៃការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ<br><br>កិច្ចប្រឹងប្រែងតិចតួចសម្រាប់ការធ្វើសុខដុម្មនីយកម្មតាមខ្សែបណ្តោយ និងខ្សែទទឹង | ឧបសគ្គខាងភាសា<br><br>ភាពខុសគ្នានៃអំណាច<br><br>ការធ្វើជាតំណាងឱ្យយុវជន និងមនុស្សចាស់ នៅមានកម្រិតទាប និងគ្មានតុល្យភាពយេនឌ័រ<br><br>សមត្ថភាពខុសគ្នាក្នុងការចូលរួមទោះបីមានការប្តេជ្ញាពីអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ |

## គុណតម្លៃស្នូលទាំងបួននៃការចូលរួម

ចូរធ្វើការឆ្លុះបញ្ចាំងឱ្យបានស៊ីជម្រៅ អំពីគុណភាពនៃការចូលរួម នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនិងការអនុវត្ត REDD+ នៅលំដាប់ថ្នាក់ខុសៗគ្នា (មូលដ្ឋាន ជាតិ តំបន់ និងអន្តរជាតិ)។ តាមទ្រឹស្តីអំពីការចូលរួមគុណតម្លៃ ទំនងជាមានភាពច្បាស់លាស់សម្រាប់ទាំងអស់គ្នា ប៉ុន្តែគុណភាពនៃការប្រើប្រាស់គុណតម្លៃ ខុសៗគ្នានៅតែជាចំណោទនៅឡើយ សូម្បីនៅក្នុងក្រុមអ្នកពាក់ព័ន្ធជាមួយគ្នាក៏ដោយ។ គុណតម្លៃស្នូល នៃការចូលរួមត្រូវបានពន្យល់នៅក្នុងដ្យាក្រាមខាងក្រោម (រូបទី ៥)។ ដ្យាក្រាមនេះ

អធិប្បាយអំពីគុណតម្លៃស្នូលនៃការចូលរួមជាទូទៅ និងអាចប្រើប្រាស់សម្រាប់ពិភាក្សាអំពីការពាក់ព័ន្ធជាមួយសមធម៌នៅពេលពុំមានការគោរពតាមគុណតម្លៃទាំងនេះ។

ប្រការសំខាន់ផងដែរគឺត្រូវបង្ហាញភាពខុសគ្នារវាងការចូលរួម និងការធ្វើជាតំណាង។ ឧបសគ្គមួយចំពោះការចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត គឺគុណភាពនៃការចូលរួម។ ក្រុមខ្លះអាចពុំមានធន្ទះ ឬពុំអាចចូលរួម ប្រសិនបើយោបល់របស់ពួកគាត់ពុំមានឆ្លុះបញ្ចាំងនៅក្នុងសេចក្តីថ្លែងការណ៍នេះ។

ការ មានវត្តមាន ឬការធ្វើជាតំណាងមិនដូចគ្នានឹងការចូលរួមឡើយ។ គុណភាពនៃការចូលរួមគឺជាកត្តាដែលមានឥទ្ធិពលមកលើសមិទ្ធផលនៃគុណតម្លៃស្នូល។ វាមិនគ្រប់គ្រាន់ទេដែលគ្រាន់តែមានក្រុមអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការណាមួយនោះប្រសិនបើពួកគាត់មិនអាច ឬសម្រេចថាមិនសំដែង ឬចែករំលែកគំនិតរបស់ខ្លួន(ដែលរួមទាំងបង្ហាញពីការប្រយ័ត្នប្រយែងខ្លួននោះ)។

## រូបទី ៥: គុណតម្លៃស្នូលនៃការចូលរួម



# ឆ. គុណភាពនៃការប្រើប្រាស់ក្របខ័ណ្ឌសមធម៌

**គោលបំណងនៃការរៀនសូត្រ** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងៈ

- កំណត់បានអត្តសញ្ញាណបញ្ហាសមធម៌ នៅក្នុងសេណារីយ៉ូ ជាក់ស្តែងនៃ REDD+ ក្នុងសហគមន៍ព្រៃឈើ
- អាចផ្សារភ្ជាប់បញ្ហាសមធម៌ និងក្រុមគោលដៅជាមួយក្របខ័ណ្ឌសមធម៌ ដែលបានបង្ហាញជូនតាំងពីដើមដំបូង នៅក្នុងវគ្គបណ្តុះបណ្តាលនេះ
- កំណត់បានអត្តសញ្ញាណចំណុចចាប់ផ្តើម និងយុទ្ធសាស្ត្រសម្រាប់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ដើម្បីមានឥទ្ធិពលមកលើបញ្ហាសមធម៌នៅក្នុងស្ថានភាពជាក់ស្តែង។

**សម្ភារៈ** ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត និងឯកសារករណីសិក្សានេះសម្រាប់សិក្ខាកាមម្នាក់ៗ

**រយៈពេល** ៦០ នាទី

---

## ជំហានអនុវត្ត

១. បង្ហាញមេរៀននេះដោយពន្យល់ថា ដំណើរការនេះនឹងជួយសិក្ខាកាមដាក់ក្របខ័ណ្ឌសមធម៌ដែលបានពីមេរៀនមុននេះ (អំពីការផ្សារភ្ជាប់សមធម៌ និងការចូលរួម) ទៅក្នុងបរិបទជាក់ស្តែង និងការប្រើប្រាស់ករណីសិក្សាខ្លីមួយ។

២. បែងចែកសិក្ខាកាមទៅជាក្រុមដែលមានគ្នាបីទៅបួននាក់។ ចែកឯកសារករណីសិក្សាដល់សមាជិកក្រុមនីមួយៗ។

៣. ចូរពន្យល់ដល់ក្រុមទាំងអស់ថា ពួកគាត់គួរចំណាយពេលដប់នាទី ដើម្បីអានករណីសិក្សានេះ។ បន្ទាប់មក ពួកគាត់ត្រូវពិភាក្សារកចម្លើយតបនឹងសំណួរនានា និងសរសេរចម្លើយលើក្រដាសផ្ទាំងធំ។ ចូរពន្យល់ថា ពួកគាត់មានពេល ៣០នាទី ដើម្បីសរសេរចម្លើយតបនឹងសំណួរនានានៅលើក្រដាសផ្ទាំងធំ។

៤. ក្រោយពេលក្រុមនីមួយៗបានឆ្លើយតបនឹងសំណួរហើយ ចូរនាំសិក្ខាកាមមកជុំគ្នាវិញ និងបិទភ្ជាប់ក្រដាសផ្ទាំងធំជាមួយចម្លើយរបស់ពួកគាត់ជិតគ្នា ដើម្បីអាចងាយស្រួលក្នុងការប្រៀបធៀបចម្លើយទាំងនេះ។

៥. ផ្តល់ឱកាសដល់ក្រុមនីមួយៗដើម្បីដឹកនាំការឆ្លើយតបនឹងសំណួរ និងទុកឱ្យសិក្ខាកាមធ្វើការប្រៀបធៀបចម្លើយរបស់គ្នាទៅវិញទៅមក។

៦. ក្រោយបានពិភាក្សាចម្លើយតបនឹងសំណួរនានាក្នុងករណីសិក្សានេះរួចមក ចូរលើកសំណួរឆ្លុះបញ្ចាំងដូចតទៅ៖

- *តើអ្នកបានប្រឈមនឹងស្ថានភាពប្រហែលគ្នាដូចក្នុងករណីសិក្សានេះ ឬ ទេនៅក្នុងការគ្រប់គ្រងព្រៃឈើ និង/ ឬក្នុងបរិបទREDD+ ?*
- *តើអ្នកគិតថា ស្ថានភាពអ្វីខ្លះ ជាការប្រឈមចម្បងៗ សម្រាប់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ?*
- *តើអ្នកចាត់ទុកអ្វីខ្លះជាឱកាសបឋម ដើម្បីដោះស្រាយបញ្ហាសមធម៌ នៅក្នុងស្ថានភាពបែបនេះ និងហេតុអ្វី ?*
- *តើមានមូលហេតុសំខាន់អ្វីខ្លះដែលនាំឱ្យ "ខកខាន" មិនបានដោះស្រាយបញ្ហានានាទាក់ទងនឹងសមធម៌នៅក្នុងស្ថានភាពបែបនោះ ?*

៧. ចូរបូកសរុបមេរៀននេះដោយពិនិត្យ ក្របខ័ណ្ឌសមធម៌ឡើងវិញ និងសង្កត់ធ្ងន់ថា គ្រប់ជាតុផ្សំទាំងអស់នៃសមធម៌អាចដោះ ស្រា យបានតាមរយៈយុទ្ធសាស្ត្រខុសៗគ្នាទោះជាយ៉ាងណាក៏ដោយ ចូរចង្អុលបង្ហាញថា សមធម៌នីតិវិធីអាចផ្តល់ជាចំណុចចាប់ផ្តើមយ៉ាងសំខាន់សម្រាប់អ្នកសម្របសម្រួលនៅថ្នា ក់មូលដ្ឋាន ដោយធានាឱ្យមានការចូលរួម និងការពាក់ព័ន្ធនៃអ្នកទាំងឡាយដែលនៅពុំទាន់មានឱកាសដើម្បីមានឥទ្ធិពលមកលើសេចក្តីថ្លែងការណ៍នានា។

---

## កំណត់សំគាល់របស់គ្រូបង្ហាត់

ករណីសិក្សាខាងក្រោមនេះ ជួយសិក្ខាកាមក្នុងការផ្សារភ្ជាប់ស្ថានភាពជាក់ស្តែងជាមួយក្របខ័ណ្ឌសមធម៌ ដែលប្រើប្រាស់នៅក្នុងឯកសារបណ្តុះបណ្តាលនេះ តាមរយៈដំណើរការរៀនសូត្ររួមគ្នា។ អ្នកពុំចាំបាច់ចំណាយពេលវែង ដើម្បីវិភាគករណីនេះផ្ទាល់ឡើយ។ ប្រសិនបើអ្នកធ្លាប់បានពាក់ព័ន្ធនៅក្នុងគម្រោងសហគមន៍ព្រៃឈើឬ REDD+ អ្នកអាចប្រើប្រាស់វាជាឧទាហរណ៍។

# តើសមធម៌អ្នកណាខ្លះដែលគិតគូរនៅអាងៃ (Angai)?




កាលពីជាង ១៧ឆ្នាំ កន្លងទៅ នៅក្នុងស្រុកលីវ៉ាលេ ក្នុងភាគខាងត្បូងប្រទេស តង់ហ្សានី (Tanzania) ផ្ទៃដីទំហំប្រមាណ ១៦០.០០០ ហិកតា នៃដីព្រៃមីញ៉ូមបូ ត្រូវបានស្នើជាដែនបម្រុងរបស់អាជ្ញាធរមូលដ្ឋាន។ ភាគច្រើន ការស្នើបែបនេះក៏ដោយសារតែកន្លែង នេះជាច្រករបៀងដ៏សំខាន់សម្រាប់សត្វព្រៃ និងជីវៈចម្រុះដែលតភ្ជាប់ទៅនឹងដែនបម្រុងប្រមាញ់កីឡាសេលូស (Selous Game Reserve)។ ព្រៃឈើនេះស្ថិតក្នុងស្ថានភាពល្អ ដោយមានប្រភេទឈើដ៏ល្អៗ។ ដែនបម្រុងទុកនេះផ្តល់មុខងារសម្រាប់គ្រប់គ្រងទីជម្រាលដ៏សំខាន់មួយសម្រាប់ស្រុកនេះផងដែរ ដែលមានទន្លេធំមួយហូរកាត់តំបន់នេះ។ កន្លែងនេះធ្លាប់គ្របដណ្តប់ដែនដីរបស់ភូមិចំនួន ១៣។

នៅពេលដែលព្រៃនៅទីនេះត្រូវបានស្នើជាដែនបម្រុងទុករបស់អាជ្ញាធរមូលដ្ឋាន ក្រុមមេដឹកនាំក្នុងភូមិបានកៀរគរអ្នកគាំទ្រមកពីខាងក្រៅ ដើម្បីបញ្ឈប់ស្ថានភាពព្រៃឈើរបស់ពួកគាត់ពីការផ្លាស់ប្តូរ។ គម្រោងអភិវឌ្ឍន៍មួយរបស់ប្រទេសហ្វាំងឡង់បានផ្តល់ព័ត៌មាន និងជំនួយបច្ចេកទេសដើម្បីឱ្យពួកគាត់

លើកសំណើផ្សេងមួយជាជំនួស ដែលក្នុងនោះកន្លែងនេះគួរតែប្រកាសជាដែនព្រៃបម្រុងទុករបស់ភូមិទាំងនេះ។ នោះគឺជាដំណោះស្រាយមួយដែលបានគាំទ្រដោយគោលនយោបាយព្រៃឈើជាតិ។ ប្រការនេះត្រូវបានចាត់ទុកជាសមិទ្ធផលចម្បងមួយនៃគម្រោងនេះ ដោយសារការកំណត់ព្រំប្រទល់ និងការចុះបញ្ជីដីរបស់ភូមិទាំង ១៣ គឺជាជំហានដំបូងក្នុងការអនុញ្ញាតឱ្យមានការប្រកាសដែនព្រៃឈើនេះជាតំបន់ព្រៃរបស់អ្នកភូមិ តាមរយៈការទទួលស្គាល់ជា "ដែនដីរបស់ភូមិ" ។ ទោះជាយ៉ាងណាក៏ដោយមានបញ្ហាមួយចំនួនដែលបានលើកឡើង អំពីវិធីនៃការកំណត់ព្រំប្រទល់ដីព្រៃនោះ។ អ្នកភូមិខ្លះបានរាយការណ៍ថា មន្ត្រីខ្លះមកពីនាយកដ្ឋានដីធ្លីបានកំណត់ព្រំប្រទល់កន្លែងនោះ នៅថ្ងៃចុងសប្តាហ៍ ទោះបីមានការគោរពទៅតាមព្រំប្រទល់ភូមិតាំងពីបូរាណមកហើយក៏ដោយ។ នៅក្នុងករណីខ្លះទៀត ព្រំប្រទល់នោះពុំមានលក្ខណៈត្រឹមត្រូវឡើយ។ ជាផ្នែកមួយនៃដំណើរការនេះ ព្រំប្រទល់មួយសម្រាប់ដីព្រៃរបស់ភូមិទាំងនេះត្រូវបានកំណត់នៅក្នុងភូមិទាំងនេះ ហើយអ្នកភូមិបានប្រកាសមិនផ្លូវការថា នេះជាដែនបម្រុងដីព្រៃរបស់ភូមិអានថៃ។ គេនៅតែមិនទាន់ដឹងច្បាស់ថា តើព្រំប្រទល់ដីព្រៃនេះត្រូវបានកំណត់ដោយរបៀបណាទេ ព្រោះថាសូម្បីតែបច្ចុប្បន្ននេះ ព្រំប្រទល់នេះពុំយកលំនាំតាមព្រំប្រទល់ព្រៃដែលមានស្រាប់ឡើយ ហើយផ្ទៃដីព្រៃមួយចំណែកធំស្ថិតនៅក្រៅព្រំប្រទល់ព្រៃនេះ ប៉ុន្តែនៅតែស្ថិតលើដីរបស់ភូមិទាំងនេះ។

ជាសំណាងមិនល្អ ការដែលគ្រាន់តែកំណត់ព្រំប្រទល់ និងចុះបញ្ជីដីភូមិនៅតង់ហ្សានី មិនគ្រប់គ្រាន់ដើម្បីផ្តល់ឱ្យអ្នកភូមិនូវសិទ្ធិប្រើប្រាស់ស្របច្បាប់នៅលើដីព្រៃនោះឡើយ។ ដែនដីព្រៃនេះអាចត្រូវបានប្រកាសជាផ្លូវការថា ជាដែនបម្រុងព្រៃឈើរបស់ភូមិ ដែលអ្នកភូមិអាចប្រើប្រាស់ និងពួកគាត់អាចលក់ឈើ និងផលិតផលពីព្រៃនេះបាន តែក្នុងករណីដែលមានផែនការគ្រប់គ្រង និងលក្ខន្តិកៈដែលឯកសារទាំងពីរនេះត្រូវមានការអនុម័តពីកិច្ចប្រជុំនៃក្រុមប្រឹក្សាស្រុក។ ដោយសារអ្នកភូមិនៅពុំទាន់មានផែនការគ្រប់គ្រង មន្ត្រីព្រៃឈើស្រុកនៅរក្សាសមត្ថកិច្ចតាមផ្លូវច្បាប់លើព្រៃឈើទាំងនេះ និងជាសមត្ថកិច្ចដែលចេញលិខិតអនុញ្ញាតសម្រាប់ការកាប់ឈើនៅក្នុងតំបន់អានថៃផងដែរ។

អ្នកភូមិបាន និងកំពុងការពារតំបន់នេះអស់រយៈពេលច្រើនជាង១៧ឆ្នាំ និងឥឡូវនេះបានខកចិត្តដោយសារពុំមានសិទ្ធិប្រើប្រាស់ បើទោះជាមានការគាំទ្រ និងចំណាប់អារម្មណ៍ពីអ្នកក្រៅ និងគម្រោងមួយចំនួនក៏ដោយ។ ការសម្ភាសជាមួយអ្នកភូមិបានឱ្យដឹងថា ពួកគាត់ពុំពេញចិត្តចំពោះអវត្តមាននៃអត្ថប្រយោជន៍ និងខកចិត្តចំពោះស្ថាប័នពីខាងក្រៅ ដោយសារតែការសន្យាដែលមិនសម្រេចបានក្នុងការផ្តល់ការគាំទ្រដល់ការរៀបចំផែនការគ្រប់គ្រង។ របាយការណ៍ខ្លះបង្ហាញពីភស្តុតាងអំពីការកាប់ឈើល្មើសច្បាប់នៅក្នុងតំបន់អានថៃនៅក្នុងភូមិមួយចំនួនទៀតផង។

នៅក្នុងដំណាក់កាលដំបូងនៃការគាំទ្រគម្រោងនេះ ដើម្បីបង្កើតដែនបម្រុងដីព្រៃរបស់ភូមិអានថៃ សហភាពអន្តរភូមិដែលមានឈ្មោះថា មូហ៊ីម៉ា (MUHIMA) ត្រូវបានបង្កើតឡើង។ សហភាពនេះបានស្នើសុំតំណាងពីគណៈកម្មការព្រៃឈើក្នុងភូមិនីមួយៗ ដើម្បីធ្វើការសម្រេចចិត្តអំពីការគ្រប់គ្រងព្រៃឈើ និងការចែកផលប្រយោជន៍។ ជាមួយការលើកទឹកចិត្តពីអ្នកលើកស្ទួយគម្រោង នៅពេលនោះមានការសម្រេចថារាល់ផលប្រយោជន៍នឹងត្រូវបែងចែកស្មើគ្នា ហើយព្រៃឈើនេះគួរតែគ្រប់គ្រងរួមគ្នាជាតំបន់តែមួយ និងមិនបែងចែកជាផ្នែកតូចៗតាមភូមិឡើយ។ ការសម្ភាសនានាជាមួយអ្នកពីខាងក្រៅគណៈកម្មការ

នេះបង្ហាញថា ពួកគាត់មានការព្រមព្រៀងគ្នាតិចតួចអំពីប្រការនេះនៅកម្រិតមូលដ្ឋានដោយសារតែព្រៃឈើមិនស្ថិតនៅក្នុងស្ថានភាពដូចដែលធ្លាប់មានពីមុនមកឡើយ ហើយអ្នកភូមិខ្លះបានអនុញ្ញាតឱ្យប្រមូលផលដោយល្មើសច្បាប់ច្រើនជាងអ្នកដទៃទៀត។ អ្នកប្រើប្រាស់ព្រៃខ្លះឥឡូវនេះបានហៅព្រៃនេះថាជាព្រៃរបស់ មូហ៊ីម៉ា។ តាមទ្រឹស្តី គណៈកម្មការព្រៃឈើនៃភូមិនីមួយៗ គួរតែបានស្វែងរកមតិយោបល់ និងគួសបញ្ជាក់ឱ្យបានច្បាស់អំពីការសម្រេចចិត្តនានាតាមរយៈការប្រជុំជាទៀងទាត់នៅក្នុងភូមិ។ ទោះជាយ៉ាងណាក៏ដោយ ថ្មីៗនេះពុំមានកំណត់ត្រាអំពីការប្រជុំបែបនេះឡើយ។

កាលពីបួនឆ្នាំមុន និងដោយសារតែដំណើរការនយោបាយ និងបទបញ្ហានៅមូលដ្ឋាន ភូមិទាំង ១៣ ដែលមានភារៈទទួលខុសត្រូវលើតំបន់ អានចៃ ត្រូវបានបែងចែក និងក្លាយជាភូមិចំនួន ២៤ ដែលភូមិនីមួយៗមានរដ្ឋាភិបាលថ្នាក់ភូមិរៀងៗខ្លួន។ ទោះបីភូមិខ្លះដែលបានបែងចែកដាច់គ្នានៅមានឆន្ទៈធ្វើការជាមួយគ្នា ដើម្បីគ្រប់គ្រងតំបន់ អានចៃ ក៏ដោយ អ្នកដទៃទៀតមិនចង់ធ្វើដូចនេះឡើយ។ ភូមិខ្លះបានបាត់បង់លទ្ធភាពប្រើប្រាស់តំបន់ អានចៃ ដោយផ្ទាល់។ ចំណែកភូមិខ្លះទៀតនៅមានលទ្ធភាពប្រើប្រាស់ទីវាលនានានៅក្នុងតំបន់ព្រៃនេះ។ ជាមួយការបែងចែកជាភូមិតូចៗបែបនេះ រាល់ប័ណ្ណបញ្ជាក់កម្មសិទ្ធិដីធ្លីដែលមានពីដំបូងសម្រាប់ភូមិទាំង ១៣ ឥឡូវបានទុកជាមោឃៈ។ នៅក្នុងការពិភាក្សាអំពីការគ្រប់គ្រងទៅអនាគតលើតំបន់អានចៃ និងការបែងចែកផលប្រយោជន៍ គេឃើញថា គ្មាន ឬមានការគ្រប់គ្រងត្រឹមតិចតួចប៉ុណ្ណោះ។ ឥឡូវនេះមានរបាយការណ៍ដែលថា មានភស្តុតាងអំពីការជីកយករ៉ែមាសនៅខាងក្រោមព្រៃអានចៃដែលធ្វើឱ្យស្ថានភាពនេះកាន់តែស្មុគស្មាញ។ ដូច្នេះរដ្ឋបាលនៃភូមិនីមួយៗក្នុងចំណោមភូមិទាំង ២៤ មានចំណែកនៃព្រៃអានចៃរៀងៗខ្លួន។

ក្នុងពេលនេះ ជាមួយរបៀបវារៈ REDD+ តំបន់អានចៃដែលជាព្រៃសហគមន៍ដ៏ធំមួយ បានទទួលការចាប់អារម្មណ៍ពីក្រុមនានាដែលចង់បង្កើតគម្រោងអនុវត្តបង្ហាញ REDD+។ ក្រុមទាំងនោះជាច្រើនត្រូវបានរដ្ឋាភិបាលថ្នាក់កណ្តាលចាត់បញ្ជូនឱ្យមកធ្វើការវាយតម្លៃបឋម។ ប៉ុន្តែក្រុមអ្នកមានចំណាប់អារម្មណ៍ជាច្រើនមិនបានដឹងថាតំបន់ អានចៃ នៅតែស្ថិតក្រោមការប្រកាសមិនផ្លូវការជាដែនបម្រុងព្រៃឈើរបស់ភូមិ និងពុំមានសិទ្ធិប្រើប្រាស់ស្របច្បាប់ឡើយ យ៉ាងហោចណាស់នេះជាករណីសម្រាប់ដើមឈើ។

អ្នកស្រាវជ្រាវដែលបានការគាំទ្រពីស្ថាប័នខុសៗគ្នា បានចាប់ផ្តើមធ្វើការប៉ាន់ស្មានរង្វាស់កាបូនតាមឡូត៍គំរូអចិន្ត្រៃយ៍នានាជាមួយទិន្នន័យដែលបានពីឧបករណ៍វាស់ដោយពន្លឺ និងរង្វាស់ចម្ងាយ (LIDAR) ដោយមានការវាស់វែងជាពិសេស ដោយសារព្រៃឈើតំបន់នេះដែលហៅថា មីញ៉ូមបូ (Miombo) គឺជាកន្លែងដែលគួឱ្យចាប់អារម្មណ៍ ដោយសារតែមានព្រៃឈើតជាប់គ្នាលើវិសាលភាពយ៉ាងធំ។ អ្នកភូមិនៅពុំទាន់បានចូលរួមនៅក្នុងដំណើរការនេះនៅឡើយទេ។

ស្ថាប័នខ្លះបានចំណាយពេលដើម្បីពន្យល់អំពីអ្វីជា REDD+ ដល់អ្នកភូមិខ្លះៗ ដែលជាសមាជិកគណៈកម្មការព្រៃឈើភូមិ។ ទោះជាយ៉ាងណាក៏ដោយ គេពុំមានចំណងទាក់ទងរវាងកិច្ចផ្តួចផ្តើមទាំងនេះ និងកិច្ចផ្តួចផ្តើមនានារបស់អ្នកស្រាវជ្រាវឡើយ។ អ្នកភូមិទាំងឡាយដែលបានទាក់ទងជាមួយស្ថាប័ន

ទាំងនោះ ឥឡូវកំពុងរំពឹងពីប្រាក់ចំណូលដ៏ច្រើនពីផលចំណូលកាបូន។ ពួកគាត់បានបញ្ជាក់ច្បាស់ថា គ្មាន ស្ថាប័ននៅលំដាប់ថ្នាក់ណាមួយត្រូវមានចំណែកជាមួយអ្នកភូមិទាំងនេះដែលបានការពារព្រៃនេះបានយ៉ាង ល្អឡើយ សូម្បីតែព្រៃឈើនេះមានវិសាលភាពធំធេងក៏ដោយ។

## តារាងទី ១៖ ទិន្នន័យសង្ខេបអំពីភូមិ

| ភូមិ | ឃុំ | ស្រុក | ចម្ងាយពីលីវ៉ាឡេ (គ.ម) | ផ្ទៃដីសរុបរបស់ភូមិ (ហិកតា) | ព្រៃរបស់ភូមិ (ហិកតា) | ភូមិបំបែក | ភូមិថ្មី | ចំនួនសមាជិកគណៈកម្មការព្រៃឈើ | ចំនួនប្រជាជន |
|---|---|---|---|---|---|---|---|---|---|
| Nahoro | Nahoro | Kibutaku | ១១២ | ៥៨.៣៩៣ | ៤០.៩៣៩ | បំបែក | Mtunbunyu, Nahoro | ១ | |
| Nangano | Nangano | Kibutaku | ៧២ | ១៥.២៩៧ | ២.៦០១ | មិនបំបែក | | ១ | |
| Kibutuka | Kibutuka | Kibutaku | ៦៤ | ១៥.៥១៤ | ៥.៤០២ | មិនបំបែក | | ១ | ២.២១៤ |
| Kiangara | Kiangara | Kibutaku | ៥៦ | ១៦.៩៦៨ | ២.២៩៦ | បំបែក | Litu, Kiangara | ២ | ២.២៧៦ |
| Kitogoro | Kiangara | Kibutaku | ៤៨ | ១២.៩៤៩ | ៧.៤២៥ | មិនបំបែក | | ១ | ១.១៤២ |
| Mtawata-wa | Kiangara | Kibutaku | ៤០ | ១៨.១៥១ | ១១.៧៦១ | មិនបំបែក | | ១ | ១.១៦៨ |
| Mikunya | Liwale B | Liwale | ២០ | ១៨.៩៣៩ | ១.៦២៨ | បំបែក | Mikunya, Tungane, Legezam-wedo | ៣ | |
| Liwale B | Liwale B | Liwale | ៣ | ២៩.២៩៨ | ៧.១៣៥ | បំបែក | Liwale B, Mahunga, Nanjegeja | ៣ | |
| Likom-bora | Mihumo | Liwale | ១៣ | ៣១.៧៥៩ | ១៩.៨៥៥ | បំបែក | Likombora, Turuki | ២ | ២.០៣៨ |
| Mihumo | Mihumo | Liwale | ១៦ | ២៩.៥៥៥ | ១១.៧៩២ | បំបែក | Drajani, Mihumo | ១ | ២.៧៦៧ |
| Ngon-gowele | Ngon-gowele | Liwale | ៤០ | ១១៦.៩៥៩ | ៨.២៨៥ | បំបែក | Mikuyu *, Ngongow-ele | ១ | ៣.៦៧០ |
| Ngunja | Ngon-gowele | Liwale | ៤៨ | ១៩.២០០ | ៦.៦២៦ | មិនបំបែក | | ១ | ១.១៥១ |
| Lilombo | Ngon-gowele | Liwale | ៦៤ | ៨១.៤៩៣ | ១៣.៦៧៥ | បំបែក | Lilumbe *, Chigugu, Luwele | ១ | ៣.៦៥៦ |

* ភូមិថ្មីដែលពុំមានលទ្ធភាពប្រើប្រាស់ AVFR

ប្រភព: Lindi and Mtwara Agribusiness Support Project, Tanzania.

## សំណួរអំពីករណីសិក្សា

ក្រោយអានករណីសិក្សានេះ សូមឆ្លើយចំពោះសំណួរដូចតទៅ ។ ចូរសរសេរគំនិតសម្រាប់សំណួរនីមួយៗលើផ្ទាំងក្រដាស។

- តើអ្នកគិតថាអ្វីខ្លះ ជាបញ្ហាសមធម៌បឋមដែលកើតឡើងនៅក្នុងករណីសិក្សានេះ និងអ្នកណារងគ្រោះខ្លាំងជាងគេដោយសារបញ្ហានោះ ?
- តើអ្នកគិតថា បញ្ហាទាំងនោះផ្សារភ្ជាប់ដូចម្ដេចដែរនឹងជាតុផ្សំខុសៗគ្នា ក្នុងក្របខ័ណ្ឌសមធម៌ដែលបង្ហាញពីខាងដើម ?
- បើរូបអ្នកជាអ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន ដែលធ្វើការក្នុងលក្ខខណ្ឌទាំងនេះ តើអ្នកចាប់ផ្ដើមពីចំណុចណា ?
- តើយុទ្ធសាស្ត្រអ្វីខ្លះដែលអ្នកអាចប្រើប្រាស់ដើម្បីកែលម្អស្ថានភាពសមធម៌នេះ ?

# ឧទាហរណ៍ជាក់ស្តែងដើម្បីលើកកម្ពស់សមធម៌រវាងធាតុផ្សំខុសៗគ្នា

| ធាតុផ្សំ | ឧទាហរណ៍ | |
|---|---|---|
| | សហគមន៍ព្រៃឈើ និងការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ | REDD+ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុដោយផ្អែកលើព្រៃឈើ |
| **ការបែងចែក**<br><br>ការបែងចែក ឬវិភាជន៍ធនធាន ឬ ផលប្រយោជន៍ ដែល ជាលទ្ធផលនៃគោលនយោបាយ ឬ ការសម្រេចចិត្តគ្រប់គ្រងធនធាន | **យន្តការកម្រៃព្រៃឈើប្រចាំឆ្នាំ - ប្រទេសកាមេរូន**<br><br>យន្តការមួយបានបង្កើតឡើងនៅឆ្នាំ ២០០០ ដែលតាមរយៈយន្តការនេះ ប្រតិបត្តិ ករព្រៃសម្បទានជាលក្ខណៈពាណិជ្ជកម្មត្រូវបង់"កម្រៃ"ប្រចាំឆ្នាំ សម្រាប់ប្រើប្រាស់ដើម្បីគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានទូទាំងប្រទេសកាមេរូន។ កម្រៃប្រមូលបានត្រូវបានបែងចែកក្នុងចំណោមរដ្ឋាភិបាលថ្នាក់កណ្តាល មូលនិធិគាំទ្រក្រុមប្រឹក្សាវិមជ្ឈការថ្នាក់មូលដ្ឋាន (FEICOM) និងក្រុមប្រឹក្សាមូលដ្ឋាន ព្រមទាំងសហគមន៍នៅជាប់នឹងព្រៃសម្បទាននោះផងដែរ។<br><br>ចំនួនប៉ាន់ស្មាននៃអ្នកទទួលផលគឺ ៣,២លាននាក់ ដែលតំណាងដោយក្រុមប្រឹក្សាមូលដ្ឋានចំនួន៥៦ (Tapa et al., 2009)។ ចាប់ពីឆ្នាំ ២០០០មក ទឹកប្រាក់ប្រមាណ ១២លានដុល្លារអាមេរិកត្រូវបានផ្ទេរប្រចាំឆ្នាំ (ប្រមាណ ៥,៥លានដុល្លារអាមេរិកក្នុងមួយហិកតា ក្នុងមួយឆ្នាំ)។<br><br>ច្បាប់ហិរញ្ញវត្ថុឆ្នាំ១៩៩៨ តម្រូវឲ្យបង់៥០% នៃកម្រៃពីព្រៃឈើដែលប្រមូលបានប្រចាំឆ្នាំចូលរដ្ឋ ៤០% ចូលទៅក្រុមប្រឹក្សាមូលដ្ឋាន និង១០% ទៅសហគមន៍មូលដ្ឋាន។ ការបែងចែកនេះត្រូវបានកំណត់ ដើម្បីអាចយកកម្រៃនេះទៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចកាមេរូននៅលំដាប់ថ្នាក់ជាច្រើន។<br><br>ការបែងចែកកម្រៃនេះត្រូវបានកែសម្រួលនៅខែមិថុនាឆ្នាំ ២០១០ តាមរយៈអនុក្រឹត្យថ្នាក់ជាតិ។ ការកែប្រែនេះបានឆ្លើយតបនឹងការទាមទាររបស់ក្រុមប្រឹក្សាមូលដ្ឋានដែលមានចំនួនច្រើន (ក្នុងតំបន់ព្រៃឈើ និងតំបន់គ្មានព្រៃឈើ) ដើម្បីទទួលផលពីកម្រៃដែលប្រមូលបាន។<br><br>លក្ខណៈងាយស្រួលក្នុងការគណនាកម្រៃពីព្រៃឈើ និងយន្តការផ្ទេរផល បានជួយមានការយល់ដឹងទូលំទូលាយជាសាធារណៈអំពីយន្តការនេះ។ កម្រៃនេះបានផ្អែកលើទំហំដែនព្រៃសម្បទាននិងតម្លៃបានពីការដេញថ្លៃ។<br><br>កម្រៃពីព្រៃឈើបានបង្កើតឲ្យមានតួនាទីសម្រាប់ការចូលរួមរបស់សហគមន៍នៅក្នុងការសម្រេចបែងចែកភាគផលតាមរយៈលក្ខខណ្ឌរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ដែលចាត់ជាអាទិភាពគម្រោងអភិវឌ្ឍន៍មូលដ្ឋានជាមួយទឹកប្រាក់១០% ពីកម្រៃដែលបានវិភាជន៍សម្រាប់ថ្នាក់មូលដ្ឋាន។<br><br>កំណែទម្រង់គោលនយោបាយស្តីពីការប្រើប្រាស់ផលចំណូលពីការកាប់ឈើដែលផ្សារភ្ជាប់ជាមួយកម្រៃពីព្រៃឈើ ផ្តល់ឱកាសសម្រាប់កែលម្អអភិបាលកិច្ចព្រៃឈើជាមួយការចូលរួមកាន់តែច្រើននិងសិទ្ធិរបស់សាធារណជន។ | **ក្រុមសហគមន៍ព្រៃឈើ - កម្ពុជា**<br><br>ក្នុងគម្រោង REDD+ នៅកម្ពុជា ក្រុមសហគមន៍ព្រៃឈើត្រូវបាន បង្ហាញជូនឲ្យដឹងអំពីការលើកទឹកចិត្តជាសាច់ប្រាក់ កម្មសិទ្ធិដី និងការកសាងសមត្ថភាព ដើម្បីការពារ និងគ្រប់គ្រងព្រៃឈើនៅមូលដ្ឋានរបស់ពួកគេ។ វាជាការកិច្ចសហការរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋបាលព្រៃឈើ អង្គការផែកកម្ពុជា និងក្រុមហ៊ុនទែរ៉ាក្លូបលខាពីថល។<br><br>គម្រោងនៅខេត្តឧត្តរមានជ័យពាក់ព័ន្ធនឹងក្រុមសហគមន៍ព្រៃឈើចំនួន១៣ ដែលការពារដីព្រៃឈើធំជាង ៦០.០០០ហិកតា ដែលរំពឹងថាស្រូបយក ៨,៧លានតោនឌីអុកស៊ីតកាបូនិក ក្នុងរយៈពេល ៣០ឆ្នាំ។ កិច្ចព្រមព្រៀងកាបូនសហគមន៍មួយផ្តល់យ៉ាងហោចណាស់ ៥០% ផលចំណូលពីកាបូន។<br><br>ឥឡូវនេះ ក្រុមសហគមន៍ព្រៃឈើមានកម្មសិទ្ធិស្របច្បាប់លើព្រៃឈើក្នុងមូលដ្ឋានសម្រាប់រយៈពេល ១៥ ឆ្នាំ (ដែលអាចបន្ត)។<br><br>ផែនការគ្រប់គ្រងរបស់រដ្ឋាភិបាលសម្រាប់វិភាជន៍និងប្រាក់ចំណាយទាំងអស់នៃមូលនិធិសម្រាប់សកម្មភាពអភិវឌ្ឍន៍សហគមន៍គួរតែរៀបចំឡើងជាមួយ ក្រុមសហគមន៍ព្រៃឈើ និងបញ្ចូលជាផ្លូវការក្នុងកិច្ចព្រមព្រៀង មួយក្នុងចំណោមអ្នកចូលរួមនៅក្នុងគម្រោងនេះ។<br><br>ការសិក្សា (Poffenberger et al., 2009) បង្ហាញថា សហគមន៍មានការចូលរួមកម្រិតខ្ពស់នៅក្នុងកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើដែលជួយជានាតម្លាភាពក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ វត្តមាននៃក្រុមសហគមន៍ទាំងនេះក៏សម្រួលឲ្យមានការជជែកគ្នាក្នុងចំណោមអ្នកចូលរួមក្នុងគម្រោងផងដែរ។ គណៈកម្មការនេះក៏មានប្រយោជន៍ជាសំខាន់ផងដែរក្នុងការគូសបញ្ជាក់ពីព្រំប្រទល់ និងដោះស្រាយទំនាស់នានា។ |

| ធាតុផ្សំ | ឧទាហរណ៍ | |
|---|---|---|
| | **សហគមន៍ព្រៃឈើនិងការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍** | **REDD+ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុដោយផ្អែកលើព្រៃឈើ** |
| ការបែងចែក<br><br>ការបែងចែក ឬ ការចែករំលែកថ្លៃចំណាយជាលទ្ធផលនៃគោលនយោបាយ និងការសម្រេចលើការគ្រប់គ្រងធនធាន | **កម្មវិធីសម្រាប់សេវាកម្មបរិស្ថានជលសាស្ត្រ - ម៉ិចស៊ិក**<br><br>បង្កើតឡើងនៅឆ្នាំ២០០៣ ដោយគណៈកម្មការព្រៃឈើជាតិម៉ិចស៊ិក(CONAFOR), កម្មវិធីជាតិសម្រាប់សេវាកម្មសេវាកម្មបរិស្ថានជលសាស្ត្រ (PSAH) មានគោលដៅបង្កើនអត្ថប្រយោជន៍ដោយផ្ទាល់ដល់អ្នកក្រីក្រ គ្រួសារដែលមានដីតិចតួច និងក្រុមជនជាតិដើម ព្រមទាំងការពារមុខងារផ្គត់ផ្គង់ទឹកក្រោមដីនៃគម្របព្រៃឈើធម្មជាតិក្នុងប្រទេសនេះ។<br><br>ក្រុមទាំងនេះត្រូវបាន CONAFOR ចាត់ទុកថាមិនបានទទួលផលដោយសារតែការឧបត្ថម្ភធនសម្រាប់គ្រប់គ្រងព្រៃឈើឲ្យមាននិរន្តរភាពតាមវិធីធម្មតា និងនិយ័តកម្មព្រៃឈើឡើយ។ ដូច្នេះ PSAH ប្រឹងប្រែងដោះស្រាយអតុល្យភាពនេះ។ ការអនុវត្ត PSAH បានទទួលការគាំទ្រដោយដំណើរការនយោបាយនៅថ្នាក់ជាតិ និងរដ្ឋាភិបាលថ្នាក់មូលដ្ឋានដើម្បីបញ្ចូលសិទ្ធិលើដីធ្លីតាមប្រពៃណីជាផ្លូវការ។<br><br>PSAH ផ្តល់ការទូទាត់ប្រចាំឆ្នាំដល់ម្ចាស់ព្រៃឈើប្រមាណ ៤០លានដុល្លារអាមេរិកក្នុងមួយហិកតា ដោយមានលក្ខខណ្ឌថាពួកគេត្រូវថែរក្សាគម្របព្រៃឈើនៅលើដីរបស់ពួកគេ។ ម្ចាស់ដីព្រៃឈើទាំងនេះ រួមមាន៖<br>• សហគមន៍ដែលពឹងផ្អែកលើព្រៃឈើ និងសហគមន៍កសិកម្មដែលរស់នៅជិតតំបន់ព្រៃឈើ<br>• ម្ចាស់ដីឯកជន (ដែលមានដីពី ៥០ដល់ ៤.០០០ហ.តយ៉ាងហោចណាស់ ៨០% នៃដីព្រៃសរុប) និង<br>• ក្រុមសហគមន៍កសិ-រុក្ខកម្ម។<br><br>ភាគច្រើននៃអ្នកទទួលផលពីប្រព័ន្ធនេះរស់នៅក្នុងតំបន់ដែលមានផលិតកម្មកសិកម្មទាប។<br><br>ប្រព័ន្ធនេះបានផ្តល់លទ្ធផលវិជ្ជមានកម្រិតខ្ពស់ សម្រាប់សង្គមដោយសារភាគច្រើននៃដីព្រៃជាកម្មសិទ្ធិរបស់ជនជាតិដើម និងសហគមន៍ជនបទ។ PSAH ក៏ប្រើប្រាស់យន្តការផ្តោតចំគោលដៅច្បាស់លាស់ផងដែរ ដើម្បីបង្កើនអត្ថប្រយោជន៍ផ្នែកសង្គម និងបរិស្ថានពីមូលនិធិនេះ។<br><br>កត្តាសំខាន់មួយដែលបានរួមចំណែកទៅក្នុងជោគជ័យនៃប្រព័ន្ធនេះគឺថា យន្តការចែកផលបានទទួលការគាំទ្រដោយដំណើរការដើម្បីដាក់បញ្ចូលជាផ្លូវការនូវសិទ្ធិតាមប្រពៃណីនៅមូលដ្ឋាន។ | **កម្មវិធីបូលសា ហ្លរេសស្តា - ប្រទេសប្រេស៊ីល**<br><br>បង្កើតឡើងនៅឆ្នាំ ២០០៧ កម្មវិធីបាលសាហ្វរេស្តា (វិភាជន៍ព្រៃឈើ) គឺជាប្រព័ន្ធឈានមុខមួយនៃការបង់ថ្លៃសម្រាប់សេវាកម្មប្រព័ន្ធអេកូឡូស៊ី ដែលផ្តល់ឲ្យសហគមន៍ប្រពៃណីសម្រាប់ការប្តេជ្ញារបស់ពួកគេដើម្បីបញ្ឈប់ការបាត់បង់ព្រៃឈើ ដោយបែងចែកការទូទាត់សម្រាប់សេវាកម្មប្រព័ន្ធអេកូឡូស៊ី ដល់គ្រួសារសហគមន៍ និងសមាគមនៃគ្រួសារនានា។<br><br>ដើម្បីមានសិទ្ធិទទួលបានជំនួយនេះ គ្រួសារនានាត្រូវចូលរួមក្នុងវគ្គបណ្តុះបណ្តាលមួយរយៈពេលពីរថ្ងៃស្តីពីការយល់ដឹងពីបរិស្ថាន និងធ្វើការប្តេជ្ញាមិនបំផ្លាញព្រៃឈើ។ លើសពីនេះ ពួកគេត្រូវចុះឈ្មោះកូនឲ្យទៅសាលារៀន។ នៅទីចុងសិក្ខាសាលានេះ អ្នកចូលរួមក្នុងសិក្ខាសាលាបានចុះហត្ថលេខាប្តេជ្ញាដោយស្ម័គ្រចិត្តមិនបំផ្លាញព្រៃឈើ (សម្រាប់ព្រៃដើម)។ បន្ទាប់មកពួកគេទទួលបានប្រាក់ប្រចាំខែ ៥០រៀល (៣០ដុល្លារអាមេរិក)។ សមាគមនៃសហគមន៍នេះក៏អាចទទួលការទូទាត់រហូតដល់ ៤.០០០រៀល (២.៥០០ដុល្លារអាមេរិក)ផងដែរ សម្រាប់ការគាំទ្រដល់សកម្មភាពរកប្រាក់ចំណូលស្របច្បាប់ដែលមិនបង្កជាផ្សែង ដូចជា ការចិញ្ចឹមឃ្មុំយកទឹកឃ្មុំការចិញ្ចឹមត្រី ឬការគ្រប់គ្រងព្រៃឈើ។<br><br>ការបញ្ចូលកម្មវិធីនេះទៅក្នុងក្របខ័ណ្ឌស្ថាប័នត្រូវបានធ្វើឡើងតាមរយៈច្បាប់លេខ៣.១៣៥ (គោលនយោបាយរដ្ឋស្តីពីការប្រែប្រួលអាកាសធាតុ) និងច្បាប់បន្ថែមលេខ ៥៣ (ប្រព័ន្ធតំបន់ការពារធម្មជាតិរបស់រដ្ឋ)។<br><br>គម្រោងនេះដឹកនាំដោយមូលនិធិនិរន្តរភាពតំបន់អាម៉ាហ្សូន (ដែលទទួលខុសត្រូវលើការអនុវត្ត គ្រប់គ្រង និងតាមដានសមាសភាគចំនួនបួននៃកម្មវិធីនេះ) លេខាធិការដ្ឋានបរិស្ថាន និងអភិវឌ្ឍន៍ដោយចីរភាពសម្រាប់រដ្ឋអាម៉ាហ្សូន (ដែលទទួលខុសត្រូវលើលទ្ធផលនៃកម្មវិធីតាមដាន) និងគ្រឹះស្ថានសហគ្រប់គ្រងតំបន់ការពារធម្មជាតិរបស់រដ្ឋ (ដែលផ្តល់ការគាំទ្រសម្រាប់ការអនុវត្តសមាសភាគទាំងបួននៃកម្មវិធីនេះ)។<br><br>អ្នកពាក់ព័ន្ធនានាបានចូលរួមនៅក្នុងគ្រប់ដំណាក់កាលនៃកម្មវិធីនេះ។ នៅក្នុងដំណាក់កាលដំបូង សិក្ខាសាលាចំនួនពីរត្រូវបានចាត់ចែងឡើង ដែលសិក្ខាសាលាទីមួយ ដើម្បីបង្ហាញកម្មវិធី គោលដៅនិងនីតិវិធី ដល់សហគមន៍ ចំណែកសិក្ខាសាលាមួយទៀតបានជួយប្រជាជនចូលរួមដោយស្ម័គ្រចិត្តក្នុងកម្មវិធីនេះ។ សេចក្តីសម្រេចចិត្តមួយចំនួនដែលទាក់ទងនឹងការវិនិយោគធនធានបានធ្វើឡើងដោយផ្អែកលើការពិគ្រោះយោបល់ជាមួយសហគមន៍។<br><br>លទ្ធផលបន្ថែមដែលបានពីសមាសភាគទាំងបួននៃកម្មវិធីនេះគឺ៖<br>• **ប្រាក់ចំណូលបូលសារហ្វេស្តា** ដែលគ្រប់គ្រងការទូទាត់ ១៤០.០០០រៀលក្នុងមួយឆ្នាំសម្រាប់តំបន់ការពារធម្មជាតិនីមួយៗ។ កម្មវិធីនេះត្រូវបានបង្កើតឡើងដើម្បីលើកទឹកចិត្តដល់ផលិតកម្មដោយនិរន្តរភាព (ដូចជា ការនេសាទ ប្រេងបន្លែនិងគ្រាប់ធញ្ញជាតិប្រេស៊ីល)។ គោលបំណងគឺលើកកម្ពស់ការចាត់ចែងផលិតកម្ម និងចេញវិញ្ញាបនបត្រសម្រាប់ផលិតផលនៃគម្រោងនានាដើម្បីបង្កើនតម្លៃសម្រាប់អ្នកផលិត។<br>• **បូលសារហ្វេសត្រាសូស្យាល់** ដែលជាការបង់ថ្លៃប្រចាំឆ្នាំ១៤០.០០០រៀល ក្នុងតំបន់ការពារធម្មជាតិនីមួយៗនិងផ្តោតលើការអប់រំ សុខភាព គមនាគមន៍និងការដឹកជញ្ជូន។ សកម្មភាពទាំងនេះបានរៀបចំឡើងក្រោមភាពជាដៃគូជាមួយស្ថាប័នរដ្ឋាភិបាលនិងគ្រឹះស្ថានផ្សេងទៀត។<br>•**សមាគមបូលសារហ្វេស្តា**ដែលពង្រឹងអំណាចសមាគមន៍នានាដោយខ្លួនឯង និងការត្រួតពិនិត្យកម្មវិធីក្នុងសង្គម។ ទឹកប្រាក់នេះសមមូលនឹង១០% នៃការបង់ថ្លៃ សម្រាប់គ្រួសារទាំងអស់នៅតាមដែនបម្រុងនេះ។<br>•**គ្រួសារបាលសាហ្វេស្តា** ដែលមានគោលដៅធ្វើឲ្យគ្រួសារនានាចូលរួមក្នុងការកាត់បន្ថយការបាត់បង់ព្រៃឈើ និងលើកកម្ពស់ការយល់ដឹងបានប្រសើរជាងមុនអំពីស្ថានភាពសេដ្ឋកិច្ច-សង្គម និងបរិស្ថានរបស់ពួកគេ ដូច្នេះអាចបង្កើនប្រសិទ្ធភាពនៃធនធាននិងការវាយតម្លៃលទ្ធផលនៃការវិនិយោគ។ កម្មវិធីនេះត្រូវគ្នានឹងការទូទាត់ ប្រចាំខែ ៥០រៀល ដល់ស្ត្រីនៃគ្រួសារនានាដែលចុះហត្ថលេខា លើការប្តេជ្ញាដោយស្ម័គ្រចិត្ត។ |

| ធាតុផ្សំ | ឧទាហរណ៍ | |
|---|---|---|
| | **សហគមន៍ព្រៃឈើ និងការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍** | **REDD+ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុដោយផ្អែកលើព្រៃឈើ** |
| នីតិវិធី<br><br>ក្រុមសង្គមកិច្ចនៅក្នុងសហគមន៍(ដែលរួមទាំងស្ត្រី និងក្រុមនានា ដែលច្រើនតែជាអ្នកទន់ខ្សោយ)។ | **ក្លឹបសហគមន៍របរចិញ្ចឹមជីវិត - វៀតណាម**<br><br>អង្គការសហគមន៍ទាំងនេះត្រូវបានអនុវត្តសាកល្បងនៅក្នុងស្រុកចំនួនប្រាំមួយនៅខេត្តកូថូ ដែលជាផ្នែក មួយនៃគម្រោងអភិវឌ្ឍន៍ជនបទដោយនិរន្តរភាព ដើម្បីលើកកម្ពស់របរចិញ្ចឹមជីវិតរបស់កសិករក្រីក្រ និង បង្កើនការចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។<br><br>សហគមន៍នានាកំណត់អត្តសញ្ញាណគម្រោងអាទិភាពរបស់ខ្លួនផ្ទាល់ និងបង្កើតក្រុមដែលមានចំណាប់ អារម្មណ៍ដូចគ្នាសម្រាប់សកម្មភាពខុសៗគ្នា។ បន្ទាប់មក ពួកគេបង្កើតបទបញ្ជាផ្ទៃក្នុងសម្រាប់ការអនុវត្ត សកម្មភាពនោះ តាមរយៈក្លឹបសហគមន៍របរចិញ្ចឹមជីវិត។<br><br>ក្លឹបទាំងនេះបានបង្កើត និងអនុវត្តផែនការកែលម្អរបរចិញ្ចឹមជីវិត ដែលរួមទាំង ឡូតិ៍អនុវត្តបង្ហាញ និងការបណ្តុះបណ្តាលសម្រាប់សកម្មភាពចិញ្ចឹមជីត។ សមាជិកក្រុមប្រឹក្សាគ្រប់គ្រងក្លឹបក៏បានទទួលការបណ្តុះបណ្តាលអំពីការចាត់ចែងសហគមន៍ ការរៀបចំផែនការហិរញ្ញវត្ថុ និងទំនាក់ទំនងទីផ្សារ ក្នុងសំណោមសកម្មភាពដទៃទៀត។<br><br>ក្លឹបទាំងនេះបានកែលម្អការគ្រប់គ្រងព្រៃឈើ ការចែកផល និងសមធម៌។ ពីរភាគបីនៃមេដឹកនាំក្លឹបទាំងនេះគឺជាស្ត្រី។ សមាជិកគ្រួសារក្រីក្រភាគច្រើនបានបង្កើនប្រាក់ចំណូលរបស់ខ្លួនពីសកម្មភាពកសិកម្មតាមរយៈគម្រោងនេះ។ លទ្ធផលវិជ្ជមានទាំងនេះបាននាំឲ្យអាជ្ញាធររដ្ឋបាលមូលដ្ឋាន គណៈកម្មាធិការប្រជាជនឃុំ អញ្ជើញមេដឹកនាំក្លឹបចូលរួមក្នុងការប្រជុំរបស់ខ្លួន។<br><br>ការចាត់ចែងប្រជាជននៅក្នុងក្រុមតូចៗ ដែលធ្វើការលើសកម្មភាពរួម បានបង្ហាញថា មានប្រសិទ្ធភាព ក្នុងការធានាថា អត្ថប្រយោជន៍បានដល់សមាជិកនានាយ៉ាងឆាប់រហ័ស។ បន្ទាប់មកអ្នកភូមិមានឆន្ទៈកាន់តែខ្ពស់ក្នុងការបន្តចូលរួម និងធ្វើការនៅក្នុងបទបញ្ញត្តិដែលបានឯកភាពគ្នា។ | **គម្រោងស្តារព្រៃឈើក្នុងអាងទន្លេនីល - យូហ្គាន់ដា**<br><br>គម្រោងស្តារព្រៃឈើក្នុងអាងទន្លេនីល ត្រូវបានបង្កើតឡើងដើម្បីផ្តល់យន្តការហិរញ្ញវត្ថុថ្មីមួយដើម្បីកំចាត់ចោលឧបសគ្គដែលមានបច្ចុប្បន្ន នៃការបង្កើតចំការឈើនៅយូហ្គាន់ដា និងដើម្បីអាចឲ្យសហគមន៍នានាទទួលផលពីយន្តការអភិវឌ្ឍន៍ស្អាត។<br><br>គម្រោងទាំងប្រាំអនុញ្ញាតឲ្យមានការពាក់ព័ន្ធនៃកិច្ចផ្តួចផ្តើមដាំដើមឈើដោយ(ឯកជន និង) សហគមន៍ ជាមួយភាគហ៊ុនពីវិនិយោគិនខុសៗគ្នា(ប្រមាណ ៩០% មកពីអាជ្ញាធរព្រៃឈើជាតិ (NFA) និង១០%ពី សហគមន៍មូលដ្ឋានទោះបីតួលេខនេះមានភាពខុសគ្នារវាងគម្រោងខុសគ្នាក៏ដោយ)។ ក្រុមសហគមន៍ទទួលប្រាក់ទូទាត់សម្រាប់ឧស្ម័នកាបូនិកដែលព្រៃឈើស្រូបតាមថ្លៃដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងទិញការកាត់បន្ថយការបញ្ចេញរវាងអ្នកទិញ និងNFA (ប្រមាណ១៥%នៃប្រាក់ចំណូលសរុបពីកាបូន)។<br><br>តាមរយៈកិច្ចព្រមព្រៀងផ្ទៃក្នុងរបស់សមាគមនៃសហគមន៍ សមាជិកក្រុមសហគមន៍អាចទិញភាគហ៊ុនជាសាច់ប្រាក់ ឬមិនមែនជាសាច់ប្រាក់ ដែលអាចឲ្យពួកគេទទួលបានភាគចំណែកនៃផលចំណូលពីកាបូនទៅអនាគត។ ផលចំណូលទាំងនេះត្រូវបានបែងចែកតាមភាគហ៊ុន និងលក្ខណៈ វិនិច្ឆ័យផ្សេងទៀត។<br><br>នេះជាឧទាហរណ៍ដែលមានប្រយោជន៍អំពីរបៀបចែករំលែកហិរញ្ញវត្ថុក្នុងចំណោមរដ្ឋាភិបាល និងសហគមន៍ ក៏ដូចជា នៅក្នុងសហគមន៍នានាផងដែរ។ គោលការណ៍របស់ជាតិជុំវិញការគ្រប់គ្រងព្រៃឈើបែបសហការក៏ដូចជាកិច្ចព្រមព្រៀងហិរញ្ញវត្ថុកាបូនជាក់លាក់ និងលក្ខន្តិកៈផ្ទៃក្នុងរបស់ក្រុមសហគមន៍ដែលចែងអំពីរបៀបនៃការបែងចែកហិរញ្ញវត្ថុក្នុងចំណោមភ្នាក់ងារខុសៗគ្នា។ |

| ធាតុផ្សំ | ឧទាហរណ៍ | |
|---|---|---|
| | **សហគមន៍ព្រៃឈើ និងការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍** | **REDD+ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុដោយផ្អែកលើព្រៃឈើ** |
| នីតិវិធី<br><br>អ្នកពាក់ព័ន្ធនានានៅលំដាប់ថ្នាក់ខុសគ្នា (ជាតិ ថ្នាក់ក្រោមជាតិ និងមូលដ្ឋាន) | **មូលនិធិ អាម៉ាហ្សូន - ប្រទេសប្រេស៊ីល**<br><br>រដ្ឋាភិបាលប្រេស៊ីលផ្តល់ឲ្យក្រុមសហគមន៍ជនជាតិដើម កសិករ, NGOs និងរដ្ឋ ព្រមទាំងកម្មវិធីរបស់ក្រុង នូវជំនួយឥតសំណងដើម្បីអនុវត្តសកម្មភាពនានា ដែលគាំទ្រដល់ការអភិវឌ្ឍកាបូនទាបនៃតំបន់អាម៉ាហ្សូន។<br><br>មូលនិធិនេះផ្តល់ជំនួយឥតសំណងដើម្បីគាំទ្រដល់សកម្មភាពនានាដូចតទៅ៖<br>• ការត្រួតពិនិត្យបរិស្ថាន ការតាមដាន និងអធិការកិច្ច<br>• ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព<br>• សកម្មភាពសេដ្ឋកិច្ចដែលបង្កើតឡើងជាមួយការប្រើប្រាស់ព្រៃឈើដោយនិរន្តរភាព<br>• ការកំណត់តំបន់អេកូឡូស៊ី និងសេដ្ឋកិច្ច ដែនដី ការចាត់ចែង និងបទប្បញ្ញត្តិកសិកម្ម<br>• ការថែរក្សា និងប្រើប្រាស់ជីវៈចម្រុះដោយនិរន្តរភាព<br>• ការស្តារតំបន់បាត់បង់ព្រៃឡើងវិញ។<br><br>ទឹកប្រាក់សរុបចំនួន ៧,១ លានដុល្លារអាមេរិក ត្រូវបានផ្ទេរទៅឲ្យអ្នកទទួលផល គិតមកទល់ខែកុម្ភៈ ឆ្នាំ ២០១១។<br><br>ប្រភេទនៃអត្ថប្រយោជន៍ដែលផ្តល់ឲ្យរួមមាន ជំនួយឥតសំណង និងការបង់ថ្លៃឲ្យក្រុមសហគមន៍មូលដ្ឋាន តាមរយៈប្រព័ន្ធបង់ថ្លៃសម្រាប់សេវាកម្មបរិស្ថាន (PES) ការធានាកម្មសិទ្ធិដី ការកសាងសមត្ថភាពស្ថាប័ន និងការបណ្តុះបណ្តាល កម្មវិធីបរិចិញ្ចឹមជីវិតដែលទាក់ទងនឹងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារ។<br><br>អ្នកទទួលផលពីគម្រោង ចូលរួមជាមួយសហគមន៍មូលដ្ឋាន នៅក្នុងសកម្មភាពកសាងសមត្ថភាព។<br><br>• ទីភ្នាក់ងារអភិរក្សធម្មជាតិ ជួយផលិតករក្នុងវិស័យកសិកម្ម តាមរយៈច្បាប់បរិស្ថានសម្រាប់ផលិតផលរបស់ពួកគាត់។<br>• វិទ្យាស្ថាន Ouro Verde ដែលធ្វើការជាមួយគ្រួសារកសិករដើម្បីបង្កើតប្រព័ន្ធកសិ-រុក្ខកម្ម<br>• អង្គការសង្គមស៊ីវិល IMAZON ធ្វើការជាមួយអាជ្ញាធរក្រុង ដើម្បីបង្កើនសមត្ថភាពស្ថាប័នលើការចុះបញ្ជីដីធ្លី<br><br>សហគមន៍ជនជាតិដើម បានទទួលសិទ្ធិដើម្បីទទួលបានប្រាក់ចំណូលពីការបង់ថ្លៃ សម្រាប់សេវាកម្ម បរិស្ថាន និងអាចចុះកិច្ចសន្យា PES ជាមួយរដ្ឋ។ | **សូស្យូបូស្ក - ប្រទេសអេក្វាឌ័រ**<br><br>សូស្យូបូស្ក បានចាប់ផ្តើមនៅឆ្នាំ ២០០៨ ដោយរដ្ឋាភិបាលអេក្វាឌ័រ ជាកម្មវិធីអភិរក្សមួយដែលផ្អែកលើការលើកទឹកចិត្ត។ វាជាសមាសភាគស្នូលមួយនៃសំណើរបស់ប្រទេសនេះសម្រាប់ REDD+។<br><br>រដ្ឋាភិបាលផ្តល់ការទូទាត់ពីរដងក្នុងមួយឆ្នាំ តាមកិច្ចសន្យារយៈពេល ២០ឆ្នាំ ជាមួយម្ចាស់ដីឯកជន និងសហគមន៍ដើម្បីអភិរក្សព្រៃឈើនៃប្រទេសនេះ។ ការបង់ថ្លៃបានធ្វើឡើងជាមួយលក្ខខណ្ឌអំពីការផ្ទៀងផ្ទាត់សកម្មភាពអភិរក្ស ដែលបានអនុវត្តតាមរយៈការតាមដានពីផ្កាយរណប និងការពិនិត្យប្រចាំឆ្នាំដល់ទីកន្លែងពីសំណាក់មន្ត្រីក្រសួងនៅថ្នាក់មូលដ្ឋាន។<br><br>អ្នកទទួលផលសំខាន់ៗគឺសហគមន៍ដែលពឹងផ្អែកលើព្រៃឈើ និងម្ចាស់ដីឯកជន។ កម្មវិធីនេះផ្អែកលើតម្រូវការនៅមូលដ្ឋាន និងការចូលរួមដោយស្ម័គ្រចិត្តពីសហគមន៍នានា។<br><br>លក្ខខណ្ឌដំបូងមួយនៃការចូលរួមក្នុងកម្មវិធីនេះគឺ សហគមន៍ជនជាតិដើម និងសហគមន៍មូលដ្ឋានត្រូវបង្កើត "ផែនការវិនិយោគសង្គម" មួយ ដែលក្នុងនោះ អ្នកទទួលផលចែងបញ្ជាក់អំពីរបៀបដែលពួកគេនឹងចំណាយប្រាក់ដែលពួកគាត់ទទួលបានប្រចាំឆ្នាំពីសូស្យូបូស្ក (Socio Bosque)។<br><br>ផែនការវិនិយោគសង្គមត្រូវបានរៀបចំឡើងតាមវិធីដែលមានការចូលរួមពីសំណាក់សមាជិកទាំងអស់នៃសហគមន៍នេះ។ អ្នកទទួលផលមានសេរីភាពក្នុងការសម្រេចអំពីវិធីប្រើប្រាស់ការលើកទឹកចិត្តខាងសេដ្ឋកិច្ចរបស់ពួកគាត់។ |

ក្រុមមេរៀនទី

# ២



# តួនាទី និងជំនាញរបស់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានដើម្បីលើកកម្ពស់សមធម៌នៅសហគមន៍មូលដ្ឋាន

# ក. ការពង្រឹងជំនាញរបស់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានជួយលើកកម្ពស់សមធម៌នៅសហគមន៍មូលដ្ឋាន

**គោលបំណងនៃការរៀនសូត្រ**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងៈ

- កំណត់បានចំណេះដឹងជំនាញ និងឥរិយាបថ ដែលពួកគាត់គិតថា អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានត្រូវការ ដើម្បីជំរុញការចូលរួមបែបច្នៃប្រឌិត ដែលនឹងជួយលើកកម្ពស់សមធម៌ ក្នុងបរិបទរបស់ពួកគាត់ផ្ទាល់



- អាចពន្យល់អំពីគុណតម្លៃនៃការយល់ដឹងពីជំនាញនានា ដែលមានសារៈសំខាន់ សម្រាប់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន និងតើជំនាញខុសៗគ្នាមានការទាក់ទងជាមួយគ្នាបែបណា

**សម្ភារៈ**

ក្រដាសផ្ទាំងធំកាត់ជារាង អ្នកសម្របសម្រួលណាម្នាក់(មួយសន្លឹក សម្រាប់មួយក្រុម) ក្រដាស Post-it, ស្កុតក្របខ័ណ្ឌ ជំនាញបញ្ចុះបញ្ចូលការចូលរួមបែបច្នៃប្រឌិត នៅលើក្រដាសមួយសន្លឹក និងប័ណ្ណនៃក្របខ័ណ្ឌនេះ។




**រយៈពេល**

៩០ នាទី

---

## ជំហានអនុវត្ត

១. បង្ហាញមេរៀននេះ ដោយសង្ខេបបញ្ហានានា ដែលពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានមកពីមេរៀនមុន។ ចូរពិនិត្យឡើងវិញលំហាត់នៃការគិតដែលផ្អែកលើសម្បត្តិ ចាប់ពីដើមដំបូងនៃវគ្គនេះឧបសគ្គចំពោះការចូលរួម និងតួនាទីរបស់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន។ ចូរពន្យល់ថាឥឡូវនេះសិក្ខាកាមយល់អំពីរបៀបនៃការធ្វើឱ្យមានការចូលរួម ដោយផ្អែកលើការលើកកម្ពស់ កម្ពស់គុណតម្លៃនៃការចូលរួមអាចមានឥទ្ធិពលមកលើសមធម៌។ មេរៀននេះនឹងផ្តោតលើការវិភាគអំពីចំណេះដឹងជំនាញនិងឥរិយាបថដែលចាំបាច់នៅកម្រិតបុគ្គល ចាប់ពីការមានឥទ្ធិពលរហូតដល់ការកែលម្អលក្ខខណ្ឌទាំងនោះ។

២. បែងចែកសិក្ខាកាម ជាក្រុមដែលមានគ្នាប្រាំទៅប្រាំមួយនាក់។ សូមផ្តល់ឱ្យក្រុមនីមួយៗ នូវរូបអ្នកសម្របសម្រួល" មួយសន្លឹក ដែលពុំទាន់សរសេរអក្សរ។



៣. ជាដំបូងស្នើសិក្ខាកាមម្នាក់ៗ ឱ្យបំផុសគំនិតអំពីចំណេះដឹង ជំនាញគុណតម្លៃ និងឥរិយាបថចំនួន ១៥ បែបដែលអាចជាសមត្ថភាពរបស់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន និងសរសេរគំនិតទាំងនោះដោយសរសេរគំនិតមួយនៅលើក្រដាសPost-it មួយ។ ចូរសង្កត់ធ្ងន់ថា ដំហាននេះផ្តល់ឱ្យសិក្ខាកាមគ្រប់រូបនូវឱកាសដើម្បីសំដែងគំនិត និងគ្មានបញ្ហាទេប្រសិនបើមានភាពច្រំដែលខ្លះៗនោះ។ អ្នកអាចស្នើក្រុមនេះឱ្យគិតអំពីអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ឬ តួនាទីគំរូដែលពួកគាត់សរសើរ ឬ គិតអំពីភាពខ្លាំងរបស់ខ្លួនឯងផ្ទាល់។ ពួកគាត់គួរតែព្យាយាមគិតអំពីសមត្ថភាពដែលជាចំណេះដឹងជំនាញ និងឥរិយាបថខុសៗគ្នាដែលពួកគាត់គិតថាសំខាន់។ ទោះជាយ៉ាងណាក៏ដោយ ចូរស្នើសិក្ខាកាមកុំឱ្យចំណាយពេលយូរក្នុងការព្យាយាមគិតពីភាពខុសគ្នារវាងចំណេះដឹងជំនាញ និងឥរិយាបថ។

៤. ក្រោយពីសិក្ខាកាមបានបង្កើតគំនិតរបស់ខ្លួនរួចហើយត្រូវឱ្យម្នាក់ៗអានខ្លាំងៗ។ ចូរស្នើក្រុមនេះឱ្យគូសបញ្ជាក់អំពីគំនិតណាខ្លះ ដែលពួកគាត់ឯកភាព និងបន្ទាប់មកបិទភ្ជាប់គំនិតទាំងនោះនៅលើក្រដាសរូបអ្នកសម្របសម្រួល។ ចូរប្រាប់ពួកគាត់ឱ្យបិទរាល់ក្រដាស Post-it ដែលទាក់ទងនឹងចំណេះដឹងជិតក្បាលជំនាញជិតដៃ និងជើង និងឥរិយាបថ និងគុណតម្លៃនៅជិតបេះដូង។ ពួកគាត់អាចប្រើប្រាស់ក្រដាស Post-it ដែលមានពណ៌ខុសៗគ្នា ដើម្បីបង្ហាញភាពខុសគ្នាក្នុងចំណោមចំណេះដឹងជំនាញនិងឥរិយាបថទាំងនោះ។

៥. ក្រោយពេលដែលក្រុមនីមួយៗ បានបញ្ចប់លំហាត់នេះហើយ សូមឱ្យពួកគាត់បិទភ្ជាប់រូបអ្នកសម្របសម្រួលទៅនឹងជញ្ជាំងជិតគ្នា ដើម្បីក្រុមនេះអាចប្រៀបធៀបរវាងបេះដូងដៃជើង និងរវាងចំណេះដឹងជំនាញ និងឥរិយាបថ។ ចូរធ្វើការប្រៀបធៀបរវាងក្រុមទាំងនេះ ដើម្បីកំណត់អត្តសញ្ញាណអំពីកន្លែងដែលជាចំណុចត្រូវផ្តោតការយកចិត្តទុកដាក់ និងមូលហេតុនោះ។

៦. សូមសួរក្រុមនេះនូវសំណួរឆ្លុះបញ្ចាំងដូចតទៅ៖



- *តើពួកគាត់មានអារម្មណ៍បែបណាអំពីលំហាត់នេះ?*
- *តើគំនិតបែបណាខ្លះដែលអ្នកគិតថាងាយស្រួលបំផុតក្នុងការបង្កើត និងហេតុអ្វី?*
- *តើការសង្កត់ធ្ងន់ស្ថិតនៅត្រង់ណា - ចំណេះដឹង ជំនាញ ឬ ឥរិយាបថ?*
- *តើអ្វីខ្លះដែលអ្នកគិតថា យើងត្រូវការឱ្យរឹងមាំជាងគេ (ចំណេះដឹង ជំនាញ ឬ ឥរិយាបថ និង គុណតម្លៃ) និងហេតុអ្វី? តើជំនាញណាខ្លះដែលយើងច្រើនតែភ្លេច និងហេតុអ្វី?*

- *តើជំនាញដែលបានកំណត់ឃើញត្រូវគ្នាបែបណាដែរ ជាមួយនឹងតួនាទីដែលបានកំណត់ក្នុងមេរៀនមុនៗ?*
- *តើជំនាញទាំងនេះ ជួយអ្នកបែបណានៅក្នុងការរៀបចំដំណើរការជំរុញការពាក់ព័ន្ធឱ្យមានប្រសិទ្ធភាព?*
- *តើជំនាញ និងឥរិយាបថណាខ្លះដែលអ្នកគិតថា ធ្វើឱ្យមានភាពខុសគ្នារវាងអ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព និងគ្មានប្រសិទ្ធភាព?*



៧. នៅក្រោយការឆ្លុះបញ្ចាំងនេះ ត្រូវធ្វើបទបង្ហាញខ្លីមួយអំពីការចាត់ជំនាញជាក្រុម និងបង្ហាញពីផ្ទះជំនាញ ជំរុញការចូលរួមបែបច្នៃប្រឌិត(រូបទី៦)។ ចូរបង្កើតជាន់ថ្នាក់ និងប្រើប្រាស់ប័ណ្ណនានា ជាធាតុផ្សំដើម្បីតំណាងឱ្យជំនាញខុសៗគ្នា។

៨. បង្កើតផ្ទះជំនាញជំរុញការចូលរួមបែបច្នៃប្រឌិតជាណ្តើរៗ ចាប់ពីគ្រឹះរហូតដល់ដំបូលជាជំហានៗ ទន្ទឹមនឹងនេះ បញ្ជាក់អំពីជំនាញនីមួយៗ ព្រមជាមួយឧទាហរណ៍ផ្សេងៗ។ សូមឱ្យប្រាកដថា សិក្ខាកាមយល់ថា "ជាន់ថ្នាក់នៃជំនាញ" សង់បន្តបពីលើគ្នា។ បើគ្មានជាន់ទីមួយនៃជំនាញប្រាស្រ័យទាក់ទងងាយៗទេនោះ គេលំបាកនឹងបង្កើតជាន់ទីពីរនៃជំនាញ និងជាបន្តបន្ទាប់។ ចូរគូសបញ្ជាក់ថា រាល់ចំណេះដឹងដែលត្រូវការសម្រាប់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន គួរតែទាក់ទងគ្នាជាមួយដំណើរការឧបករណ៍ ឬឋាមវន្តសង្គមដោយសារភាគច្រើនអ្នកសម្របសម្រួលម្នាក់ៗនៅថ្នាក់មូលដ្ឋាន ត្រូវតែមានជំហរអព្យាក្រឹត្យ។ សូមស្វែងយល់ជាមួយសិក្ខាកាមអំពីជាន់ថ្នាក់នៃជំនាញដែលច្រើនតែត្រូវគេបំភ្លេច និងអំពីផលវិបាកដែលពាក់ព័ន្ធ។

៩. ចូរបូកសរុបមេរៀននេះដោយពន្យល់ថា ប្រការសំខាន់គឺត្រូវចាត់ទុកខ្លួនឯងជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន និងត្រូវមានការយល់ដឹងអំពីឥរិយាបថរបស់ខ្លួនផ្ទាល់ និងវិធីនៃការប្រើប្រាស់ជំនាញរបស់ខ្លួន។ តាមរយៈការវិភាគជំនាញទាំងនេះ យើងអាចឆ្លុះបញ្ចាំងលើអ្វីខ្លះដែលយើងប្រើប្រាស់ច្រើនជាងគេបំផុត អ្វីខ្លះដែលយើងប្រើប្រាស់តិចជាងគេបំផុត និងអ្វីខ្លះដែលយើងត្រូវការចម្លើយតបដើម្បីកែលម្អ។ សូមផ្សារភ្ជាប់ចំណុចនេះទៅនឹងមេរៀនមុនស្តីពី ការគិតដែលផ្អែកលើសម្បត្តិដែលសិក្ខាកាមបានផ្តោតការយកចិត្តទុកដាក់លើភាពខ្លាំងរបស់ខ្លួន និងអំពីការប្រើប្រាស់ភាពខ្លាំងទាំងនោះ ដើម្បីជួយអ្នកដទៃទៀតទទួលស្គាល់ភាពខ្លាំងរបស់ពួកគាត់។

---

## កំណត់សំគាល់របស់គ្រូបង្ខាត់

សិក្ខាកាមមិនធ្លាប់ "បំបែក" គោលគំនិតនានាឡើយ ដូច្នេះពួកគាត់ទំនងជាចាត់បញ្ចូលជំនាញនានានៅក្រោមពាក្យនានាដូចជា "ការប្រាស្រ័យទាក់ទង" ឬ "ទំនាក់ទំនងបុគ្គល"។ នៅក្នុងករណីនេះត្រូវព្យាយាមជួយបង្ហាញទំនាក់ទំនងនៃពាក្យនានារបស់ពួកគាត់ ជាមួយជំនាញខុសៗគ្នា ដែលស្រង់យកនៅក្នុងផ្ទះជំនាញជំរុញការចូលរួមបែបច្នៃប្រឌិត។

អាស្រ័យលើបទពិសោធន៍របស់សិក្ខាកាម អ្នកគួរតែដេញដោលខ្លះៗចំពោះតារាងចំណេះដឹងនេះ។ ជាញឹកញាប់នេះជាពេលដែលបញ្ហាអព្យាក្រឹត្យភាពនឹងលេចឡើង។ សិក្ខាកាមជាច្រើនទំនងជាជឿថា ចំណេះដឹងមានសារៈសំខាន់ក្នុងការជួយផ្តល់ដំណោះស្រាយណាមួយជាងមានជំនាញដើម្បីជួយអ្នកដទៃក្នុងការស្វែងរកដំណោះស្រាយ។គ្រូបង្ហាត់ត្រូវដេញដោលចំណុចនេះ។

សិក្ខាកាមតាមធម្មតានឹងសរសេរគុណភាពផ្ទាល់ខ្លួនជាច្រើន ដែលខុសពីឥរិយាបថជាក់ស្តែង ដូចជា "កំប្លែង" ។ ចូរដេញដោលពួកគាត់ និងសួរថា តើអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានម្នាក់ៗគួរតែមានដូចជាកំប្លែងដែរឬទេ។ ចូរពន្យល់ភាពខុសគ្នារវាងអត្តចរិករបស់បុគ្គល និងឥរិយាបថរបស់បុគ្គលនិងត្រូវផ្តោតលើឥរិយាបថជាមូលដ្ឋាននិងការប្រើប្រាស់ជំនាញ។

# ផ្ទះជំនាញជំរុញការចូលរួមបែបច្នៃប្រឌិត

**រូបទី ៦៖ ផ្ទះជំនាញជំរុញការចូលរួមដោយច្នៃប្រឌិត**



# ២. តួនាទីរបស់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានសម្រាប់លើកកម្ពស់សមធម៌នៅសហគមន៍មូលដ្ឋាន

**គោលបំណងនៃការរៀនសូត្រ**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងៈ

- កំណត់បានអំពីតួនាទីរបស់អ្នកសម្របសម្រួល នៅថ្នាក់មូលដ្ឋាន បន្ទាប់ពីបានពិចារណាអំពីឧបសគ្គ ចំពោះការចូលរួម នៅក្នុងកិច្ចផ្តួចផ្តើម REDD+ និងបញ្ហាផ្សេងទៀតនៃសមធម៌។
- ឆ្លុះបញ្ចាំងអំពីតួនាទីរបស់អ្នកសម្របសម្រួល នៅថ្នាក់មូលដ្ឋាន ដែលពួកគាត់បានផ្តោតការយកចិត្តទុកដាក់បំផុត នៅក្នុងការងារផ្ទាល់ខ្លួនរបស់ពួកគាត់។ និង
- ឆ្លុះបញ្ចាំងអំពីតួនាទីរបស់អ្នកសម្របសម្រួល នៅថ្នាក់មូលដ្ឋាន ដែលមានសក្តានុពល ដើម្បីលើកកម្ពស់សមធម៌។

**សម្ភារៈ**

ហ្វឺត ក្រដាស Post-it ក្រដាសធំពណ៌ខុសៗគ្នាដែលកាត់ជា រាងខុសៗគ្នា មួកដែលមានរាងខុសៗគ្នា (គ្រប់ចំនួនសិក្ខាកាម) និងឯកសារអំណាន។



**រយៈពេល**

៦០ នាទី

---

## ជំហានអនុវត្ត

១. បង្ហាញមេរៀននេះដោយពន្យល់ថា សិក្ខាកាមនឹងវិភាគតួនាទីរបស់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន សម្រាប់លើកកម្ពស់សមធម៌នៅក្នុងសហគមន៍ព្រៃឈើ និង REDD+។

២. ត្រូវប្រាកដថាសិក្ខាកាមយល់ពីពាក្យ "តួនាទី" ដោយបង្ហាញភាពខុសគ្នានៃជំនាញពីគុណភាពបុគ្គល។ចូរពន្យល់ថាតួនាទីអាចប្រៀបធៀបបានជាមួយ "មួក" ខុសៗគ្នាដែលអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន អាចពាក់ដើម្បីដោះស្រាយឧបសគ្គនានានៃការចូលរួម និងលើកកម្ពស់សមធម៌។ សូមផ្តល់ឧទាហរណ៍មួយអំពីតួនាទីដែលបានកត់សំគាល់នៅក្នុងមេរៀនពីមុន។សូមកុំផ្តល់ឧទាហរណ៍ច្រើនពេក - សូមទុកឱ្យក្រុមនេះធ្វើការ។



៣. បែងចែកសិក្ខាកាមទៅជាក្រុមដែលមានសមាជិកពីបួន ទៅប្រាំនាក់។ ផ្តល់ឱ្យក្រុមនីមួយៗសន្លឹកក្រដាសផ្ទាំងធំដែលកាត់ជារាងមួក។ មួកនេះត្រូវតែមានទំហំគ្រប់គ្រាន់ដែលអាចបិទភ្ជាប់តួនាទីនានានៅលើនេះ និងអាចមើលឃើញបានច្បាស់ពីចម្ងាយ។

៤. ស្នើសិក្ខាកាមធ្វើការពិភាក្សាបំផុសគំនិតជាមុន អំពីអ្វីដែលពួកគាត់គិតថាជាតួនាទីខុសៗគ្នារបស់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ដើម្បីលើកកម្ពស់សមធម៌ និងបន្ទាប់មកសរសេរតួនាទីទាំងនោះនៅលើក្រដាស Post-it ។ ត្រូវប្រាកដថា ពួកគាត់សរសេរគំនិតតែមួយនៅលើក្រដាសនេះមួយសន្លឹក។

៥. ចូរគូសបញ្ជាក់ថា ពួកគាត់អាចប្រើប្រាស់លទ្ធផលពីមេរៀនមុននេះ ដើម្បីគិតឱ្យបានស៊ីជម្រៅអំពីអ្វីដែលគួរតែជាតួនាទីរបស់ពួកគាត់ ដើម្បីកែប្រែស្ថានភាពបច្ចុប្បន្ន និងឆ្លើយតបចំពោះបញ្ហាសមធម៌។

៦. ក្រោយពីបុគ្គលម្នាក់ៗបានផ្តល់គំនិតខ្លះរួចមក ចូរស្នើក្រុមនីមួយៗឱ្យពិភាក្សាលើគំនិតទាំងនោះ ដោយត្រូវប្រាកដថា ពួកគាត់យល់ពេញលេញនូវគំនិតនានារបស់គ្នាទៅវិញទៅមក ហើយពួកគាត់បិទក្រដាសគំនិតទាំងនោះនៅលើមួក។ ចូរពន្យល់ថាប្រសិនបើមានគំនិតច្រំដែលពួកគាត់អាចសរសេរឡើងវិញជាតួនាទីតែមួយនៅលើក្រដាស Post-it មួយសន្លឹក។ សូមទុកពេល ២០នាទីសម្រាប់ជំហាននេះ។



៧. ក្រោយរយៈពេល ២០នាទី សូមស្នើក្រុមនេះបង្ហាញមួករបស់ពួកគាត់ដល់គ្នាទៅវិញទៅមកជាមួយក្រដាស Post-it ទាំងអស់បិទនៅលើនោះ។

៨. សូមទុកពេលឱ្យក្រុមទាំងនេះ ៥ នាទីដើម្បីសង្កេតនិងអានតួនាទីរបស់គ្នាទៅវិញទៅមក

៩. ក្រោយពេលដែលពួកគាត់បានឃើញលទ្ធផលនៃក្រុមរបស់គ្នា ទៅវិញទៅមករួចហើយ ចូរនាំសិក្ខាកាមមកជួបជុំគ្នាឡើងវិញ និងសួរសំណួរឆ្លុះបញ្ចាំងដូចតទៅ៖

- *តើក្រុមទាំងអស់មានតួនាទីដូចគ្នា ឬខុសគ្នា ឬទេ សម្រាប់អ្នកសម្របសម្រួលនៅមូលដ្ឋានដើម្បីលើកកម្ពស់សមធម៌ ?*
- *តើមានតួនាទីណាខ្លះដែលអ្នកមិនឯកភាពជាមួយ ដែលក្រុមទាំងនេះបានកំណត់ឃើញ និងហេតុអ្វី ?*
- *តើតួនាទីណាខ្លះដែលអ្នកគិតថា សំខាន់បំផុតសម្រាប់អ្នកសម្របសម្រួលនៅមូលដ្ឋានទាក់ទងនឹងការលើកកម្ពស់សមធម៌ និងហេតុអ្វី ?*

- *តើតួនាទីទាំងនេះណាខ្លះ ដែលអ្នកផ្តោតការយកចិត្តទុកដាក់ខ្លាំងជាងគេ និងហេតុអ្វី?*
- *តើតួនាទីទាំងនេះណាខ្លះ ដែលមានផ្លុះបញ្ចាំងច្រើនបំផុត ដោយអ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន និងហេតុអ្វី?*

១០. ក្រោយពេលសិក្ខាកាមបានផ្លុះបញ្ចាំងរួចហើយ ចូរគូសបញ្ជាក់អំពីតួនាទីនានាដែលមិនមាននៅក្នុងក្រុមទាំងនេះ ប៉ុន្តែមាននៅក្នុងឯកសារអំណាន។ ចំណុចនេះអាចធ្វើដោយបន្ថែមតួនាទីទាំងនោះទៅក្នុងក្រុមនៃមួកនានាជាពណ៌ខុសគ្នានៅលើក្រដាស Post-it ។

១១. ចូរបូកសរុបមេរៀននេះ ដោយពន្យល់ថា អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានត្រូវពាក់មួកខុសៗគ្នានៅក្នុងពេលខុសគ្នាសម្រាប់មូលហេតុខុសគ្នា ប៉ុន្តែតួនាទីមិនដាច់ពីគ្នាឡើយ។ ក្នុងនាមជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន អ្នកត្រូវតែដឹងអំពីតួនាទីរបស់ខ្លួនឯងនៅក្នុងបរិបទបច្ចុប្បន្នដោយពិចារណាអំពីឧបសគ្គ និងបញ្ហាសមធម៌ចំពោះមុខ។

---

## កំណត់សំគាល់របស់គ្រូបង្ហាត់

សិក្ខាកាមខ្លះនឹងមានការយល់ច្រឡំរវាងជំនាញនិងតួនាទី។តាមធម្មតាក្រុមទាំងនេះនឹងអធិប្បាយអំពីតួនាទីតាមរបៀបខុសៗគ្នា។ អ្នកពុំចាំបាច់បារម្ភអំពីរឿងនេះទេ ពីព្រោះអ្នកអាចបង្ហាញឱ្យច្បាស់សម្រាប់ពួកគាត់ នៅពេលអ្នកបន្ថែមលើតួនាទីទាំងនេះ ដោយផ្អែកលើអ្វីដែលបានពិភាក្សានៅក្នុងឯកសារសម្រាប់ចែកជូន។

អាស្រ័យលើមេរៀនពីមុនមក សិក្ខាកាមអាចបាត់បង់ការប្រមូលផ្តុំ និងពិចារណាអំពីគ្រប់តួនាទីរបស់អ្នកសម្របសម្រួលនៅថ្នាក់ក្រោមជាតិ។ ចូរព្យាយាមផ្សារភ្ជាប់តួនាទីទាំងនោះទៅនឹងមេរៀននានាស្តីពីសមធម៌ និងឧបសគ្គជាក់លាក់ ចំពោះការចូលរួម នៅក្នុង REDD+ និងសេចក្តីថ្លែងការណ៍អំពីការប្រែប្រួលអាកាសធាតុ។ និយាយម៉្យាងទៀតថា ត្រូវប្រាកដថា ពួកគាត់ពិភាក្សាអំពីតួនាទីរបស់អ្នកសម្របសម្រួល ដើម្បីលើកកម្ពស់សមធម៌នៅសហគមន៍មូលដ្ឋាន។

# តើអ្នកសម្របសម្រួលមានតួនាទីអ្វីខ្លះដើម្បីលើកកម្ពស់សមធម៌នៅសហគមន៍មូលដ្ឋាន

អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានអាចទទួលយកតួនាទីខុសៗគ្នា ឬ "ពាក់មួកខុសគ្នា" នៅពេលប្រឈមនឹងបញ្ហាសមធម៌ និងឧបសគ្គនានាចំពោះការចូលរួមនៅលំដាប់ថ្នាក់ខុសៗគ្នា។ គុណតម្លៃសំខាន់បំផុតមួយសម្រាប់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន គឺត្រូវមានជំហរអព្យាក្រឹត្យ។ នេះមានន័យថា អ្នកសម្របសម្រួលមិនត្រូវធ្វើសេចក្តីសម្រេចចិត្ត ឬ ប្រកាន់ជំហរណាមួយក្នុងនាមក្រុមអ្នកពាក់ព័ន្ធណាមួយឡើយ ប៉ុន្តែត្រូវទុកជំហរនោះឱ្យអ្នកពាក់ព័ន្ធទាំងនោះ។ អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានអាចណែនាំក្រុមណាមួយនៃអ្នកពាក់ព័ន្ធដែលគាត់ធ្វើការជាមួយ ដើម្បីអាចធ្វើការសម្រេចចិត្តណាមួយ ឬ ប្រកាន់យកជំហរណាមួយជាក់លាក់។

### មួកមួយចំនួនរបស់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានអាចពាក់សម្រាប់លើកកម្ពស់សមធម៌៖

**អ្នកចាត់ចែងសហគមន៍** - អាចជួយសហគមន៍ក្នុងការត្រៀមលក្ខណៈ ដែលរួមទាំងសម្រួលឱ្យមានការកំណត់របៀបវារៈរបស់ក្រុមអ្នកដែលពុំមានតំណាងគ្រប់គ្រាន់។

**អ្នករៀបចំ និងណែនាំអំពីដំណើរការ** - អាចបង្កើតដំណើរការនៃការពាក់ព័ន្ធរស់រវើក និងមានប្រសិទ្ធភាពសម្រាប់រយៈពេលខ្លី និងវែងដែលកំណត់គោលបំណង និងនាំទៅរកការឯកភាពមតិ និងការព្រមព្រៀងក្នុងចំណោមអ្នកពាក់ព័ន្ធនានា។



**អ្នកកសាងទំនុកចិត្ត**-អាចជួយក្រុមអ្នកពាក់ព័ន្ធដែលពុំសូវមានអំណាច ដើម្បីឱ្យមានទំនុកចិត្តនៅក្នុងការសំដែងទស្សនៈរបស់ខ្លួនអំពី បញ្ហាដែលពួកគាត់គិតថាមានសារៈសំខាន់។

**អ្នកផ្តល់ និងអ្នកពន្យល់ព័ត៌មាន** - ដឹងព័ត៌មានថ្មីៗបំផុតអំពីការវិវត្តថ្មីៗ ស្តង់ដារ និងព័ត៌មានស្តីពី REDD+ និងអាចពន្យល់ដោយពុំបញ្ចេញឥទ្ធិពលឡើយ។

**អ្នកតភ្ជាប់ឬអ្នកបង្កើតបណ្តាញ**-អាចដឹងអំពីទម្រង់ និងការតភ្ជាប់គ្នារវាងក្រុមនានា និងបញ្ហានានា ព្រមទាំងទំនុកចិត្តក្នុងការឈានទៅស្វែងរកជំនួយនៅពេលត្រូវការ។

**អន្តរការីដែលស្មោះត្រង់** - អាចផ្សារភ្ជាប់សហគមន៍ និងផលិតផលនានាជាមួយទីផ្សារដែលត្រឹមត្រូវ និងមានតម្លាភាព។

**អ្នកបង្កើតលំហសម្រាប់ចម្រាញ់យកទស្សនៈ និងអ្នកនិទានរឿង** - អាចជ្រើសរើសរកឧបករណ៍ និង ស្វែងរកឱកាសដើម្បីនាំយកទស្សនៈដែលមិនសូវមានអ្នកឮ ទៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តជាសាធារណៈ។

**អ្នកចងក្រងជាឯកសារ** - អាចចងក្រងជាឯកសារប្រកបដោយភាពច្នៃប្រឌិតនូវទស្សនទាននានា ដោយគ្មានកែប្រែខ្លឹមសារដើម និងចែករំលែកទស្សនៈទាំងនោះជាមួយអ្នកដទៃ។

**អ្នកដឹកនាំសមធម៌យេនឌ័រ** - អាចបង្ហាញពីភាពជាអ្នកដឹកនាំនៅក្នុងការប្រឈមជាមួយភាពខុសគ្នាខាងអំណាចដែលផ្អែកលើយេនឌ័រ និងនិយាម ព្រមទាំង អាចជួយឱ្យបុរស និងស្ត្រីមានការចូលរួមដោយស្មើភាពនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។

**អ្នកលើកស្ទួយការពិភាក្សាដែលមានអ្នកពាក់ព័ន្ធចម្រុះ** - អាចបង្កើតឱកាស និងប្រើប្រាស់បច្ចេកទេសដើម្បីលើកទឹកចិត្តឱ្យមានការសន្ទនា និងឈានដល់ការយោគយល់គ្នារវាងទស្សនៈវិស័យខុសៗគ្នា។

**អ្នកពុះពារ** - អាចធ្វើការយ៉ាងសកម្មដើម្បីធានា និងលើកកម្ពស់ការពាក់ព័ន្ធរបស់សហគមន៍ជនជាតិដើមភាគតិច និងសហគមន៍ដែលពឹងផ្អែកលើព្រៃឈើ នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តអំពី REDD+ នៅក្នុងករណីដែលពុំការពាក់ព័ន្ធបែបនេះពុំកើតមាន។



# គ. អនុវត្តជំនាញចោទសួរ

**គោលបំណងនៃការរៀនសូត្រ** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចៈ

- ពន្យល់អំពីហេតុអ្វីសំណួរនានាត្រូវបានប្រើប្រាស់ដោយអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានដែលធ្វើការដោះស្រាយសមធម៌តាមរយៈដំណើរការចូលរួម
- បង្កើតសំណួរប្រកបដោយ "អានុភាព" មួយចំនួន
- ពន្យល់អំពី ការសួរសំណួរបែបលើកសរសើរអាចបង្កើតថាមពលដោយរបៀបណា នៅក្នុងក្រុមមួយឬការសន្ទនា មួយដើម្បីធ្វើឱ្យមានការចូលរួមប្រសើរជាងមុន
- អនុវត្តគំរូសំណួរជំនួយ ដើម្បីស្វែងយល់ពីជម្រើសនានា សម្រាប់ដោះស្រាយបញ្ហាសមធម៌ នៅក្នុងបរិបទរបស់ខ្លួន។

**សម្ភារៈ** ក្រដាសផ្ទាំងធំ ជាមួយគំរូបញ្ជីសំណួរមួយ ឈុត ហ្វឺត សន្លឹក ប័ណ្ណ ស្កុត និង ឯកសារអំណាន




**រយៈពេល** ៧៥ នាទី

---

## ជំហានអនុវត្ត

១. បង្ហាញមេរៀននេះដោយពន្យល់ថា អ្នកនឹងពិនិត្យមើលស៊ីជម្រៅអំពីជំនាញនានា ដែលបានគូសបញ្ជាក់អំពីលំដាប់នៃជំនាញប្រាស្រ័យទាក់ទងងាយៗ នៃផ្ទះជំនាញជំរុញការចូលរួមដោយច្នៃប្រឌិត។ សូមយោងទៅប្រអប់ស្តីពីការចូលរួម (សូមអានក្រុមមេរៀនទី៣) និងផ្ទះជំនាញជំរុញការចូលរួមបែបច្នៃប្រឌិតពីមេរៀនមុននេះ។

២. សូមបង្ហាញសំណួរទាំងបួនដែលសរសេរលើក្រដាសផ្ទាំងធំៈ តើសមធម៌សំខាន់ឬទេ? តើសមធម៌មានន័យដូចម្តេច? តើការសន្មតអ្វីខ្លះអំពីសមធម៌ដែលនៅពុំទាន់បានស្វែងយល់នៅឡើយ? តើវាមានន័យបែបណាសម្រាប់យើង ប្រសិនបើរាល់ការគ្រប់គ្រងព្រៃឈើ និងកិច្ចផ្តួចផ្តើម REDD+ មានសមធម៌?

៣. សូមសួរសិក្ខាកាម ប្រសិនបើពួកគាត់ត្រូវដាក់ពិន្ទុតាមមាត្រដ្ឋានពី ១ ដល់ ១០ សម្រាប់កម្រិតអំណាចនៃសំណួរទាំងនេះ តើសំណួរណាខ្លះដែលពួកគាត់ដាក់ពិន្ទុខ្ពស់ជាងគេ និងហេតុអ្វី។

៤. ក្រោយពីប្រមូលបានពិន្ទុហើយ សូមពិភាក្សាជាមួយក្រុមនេះ អំពីអ្វីដែលធ្វើឱ្យសំណួរនានាមានអនុភាព (ដូចជា សំណួរនានាដែលបំផុសគំនិតជំរុញភាពរំជួលចិត្តបង្កើតភាពងឿងឆ្ងល់ ឬ ស្វែងយល់ពីការ សន្មតសំខាន់ៗ)។



៥. សូមពន្យល់ដល់សិក្ខាកាមថា ដើម្បីត្រៀមខ្លួនអ្នកត្រូវធ្វើលំហាត់មួយដែលហៅថាសំណួរប្រកបដោយអនុភាពខ្លាំងបំផុតទាំង ១០។

៦. ចូរពន្យល់ថា ប្រការចាំបាច់គឺអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ត្រូវគិតអំពីវិធីដែលពួកគាត់បង្កើតសំណួរ ដើម្បីឱ្យអ្នកទាំងឡាយដែលពួកគាត់ធ្វើការជាមួយចង់គិតអំពីអ្វីខ្លះ ដែលពួកគាត់ត្រូវសួរ និងរបៀបឆ្លើយ។ និយាយម្យ៉ាងទៀតថា ក្នុងនាមជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន តើយើងអាចធ្វើបែបណា ដើម្បីបង្កើត និងរៀបចំសំណួរនានាដែលលើកទឹកចិត្ត និងបង្កើតចលនា ឬសកម្មភាពទៅមុខនៅក្នុងដំណើរការនៃការចូលរួម? សូមណែនាំក្រុមនេះឱ្យយោងទៅមេរៀនដំបូងអំពីការគិតដែលផ្អែកលើសម្បត្តិ និងសួរពួកគាត់ថា តើការគិតដោយផ្អែកលើសម្បត្តិអាចមានឥទ្ធិពលបែបណាមកលើវិធីសួរសំណួរ។

៧. សូមឱ្យសិក្ខាកាមម្នាក់ៗសរសេរលើប័ណ្ណនីមួយៗ ពាក្យប្រាំម៉ាត់ ដែលពួកគាត់យល់ថាផ្ដល់ការលើកទឹកចិត្ត ឬមានអានុភាព និងបណ្ដាលឱ្យមានអារម្មណ៍វិជ្ជមានក្នុងចំណោមពួកគាត់។ អ្នកអាចផ្ដល់ឧទាហរណ៍ផ្ទាល់ខ្លួនមួយអំពីពាក្យដែលបំផុសស្មារតី ឬ ដែលផ្ដល់អំណាច ដូចជាសុបិនឱកាសលទ្ធភាព និងបំណងប្រាថ្នា។ សូមទុកពេលបីនាទីឱ្យពួកគាត់ធ្វើលំហាត់នេះ។

៨. ស្នើសិក្ខាកាមម្នាក់ៗឱ្យរកដៃគូម្នាក់ទៀតដែលមិនអង្គុយក្បែរខ្លួន និងប្ដូរប័ណ្ណនេះ ជាមួយបុគ្គលនោះ។ ក្រោយពេលដែលពួកគាត់បានទទួលប័ណ្ណពីអ្នកណាម្នាក់ ហើយនោះត្រូវសុំឱ្យពួកគាត់បង្កើតសំណួរគិតដែលផ្អែកលើសម្បត្តិដែលអាចយកមកប្រើប្រាស់ដើម្បីផ្ដួចផ្ដើម ឬ ជំរុញការចូលរួមឱ្យឈានទៅមុខជាមួយពាក្យជ្រើសរើសមួយចំនួន ជាមួយបុគ្គលដែលផ្ដល់ប័ណ្ណនោះដល់ពួកគាត់។ ពួកគាត់គួរសរសេរសំណួរនីមួយៗនៅលើប័ណ្ណខុសៗគ្នា។ សូមទុកពេល៥នាទីសម្រាប់លំហាត់នេះ។

៩. ស្នើសិក្ខាកាមស្វែងរកដៃគូដែលផ្ដល់ឱ្យពួកគាត់ពាក្យផ្ដើមសំណួរ និងចែករំលែកសំណួរនានាជាមួយដៃគូនោះ។ បន្ទាប់មក សុំឱ្យពួកគាត់ធ្វើការកែសម្រួលសំណួរទាំងនោះជាមួយគ្នា ដើម្បីបង្កើតសំណួរដែលកាន់តែមានប្រសិទ្ធភាព។ សូមឱ្យពួកគាត់ធ្វើការជាក្រុម ដើម្បីបង្កើតសំណួរ "ប្រកបដោយអានុភាព" ចំនួនដប់ ដែលអាចប្រើប្រាស់នៅក្នុងដំណើរការបង្កើតការចូលរួម។

១០. សូមស្នើក្រុមនេះ ចាត់ចែងសំណួររបស់ពួកគាត់ជាទម្រង់ដែលមានអានុភាពជាងគេបំផុត ចំនួនដប់នៅលើពាក់កណ្ដាលក្រដាសផ្ទាំងធំមួយសន្លឹក និងបន្ទាប់មកបិទភ្ជាប់ភ្ជាប់ផ្ទាំងក្រដាសនេះលើជញ្ជាំង នៅកន្លែងដែលដែលសរសេរថា៖ សំណួរដែលមានអានុភាពបំផុតចំនួនដប់សម្រាប់បង្កើតការចូលរួម។

១១. ចូរធ្វើការឆ្លុះបញ្ចាំងជាមួយក្រុមអំពីលំហាត់នេះ៖

- *តើអ្នកយល់ថាលំហាត់នេះលំបាក ឬ ងាយស្រួល និងហេតុអ្វី?*
- *តើសំណួរណាខ្លះដែលអ្នកចូលចិត្តជាងគេ និងតើអ្វីខ្លះដែលធ្វើឱ្យអ្នកចូលចិត្តសំណួរនោះ?*
- *ហេតុអ្វីអ្នកគិតថា យើងមិនអើពើចំពោះការបង្កើតសំណួរដែលមានអានុភាពឬយ៉ាងណា?*
- *តើអ្នកដឹងបានក្នុងកម្រិតណាអំពីសំណួរដែលមានអានុភាពនៅក្នុងបរិស្ថានជុំវិញខ្លួនអ្នក?*
- *ហេតុអ្វីអ្នកគិតថា ការដឹងអំពីរបៀបដែលអ្នកបង្កើតសំណួរនៅក្នុងដំណើរការបង្កើតការចូលរួមគឺជារឿងសំខាន់?*

១២. ចូរសរសេរសំណួរដូចតទៅនេះនៅលើក្រដាសផ្ទាំងធំ៖ ហេតុអ្វីអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានប្រើប្រាស់សំណួរនានា នៅក្នុងការបង្កើតការចូលរួមបែបច្នៃប្រឌិត? សូមសួរសិក្ខាកាមដែលពិភាក្សាជាគូ ដើម្បីរកចម្លើយឱ្យបានពីរ ឬ បី។

១៣. នរយៈពេលប៉ុន្មាននាទីក្រោយមក សូមសួរក្រុមនីមួយៗដែលធ្វើការជាគូ ដើម្បីផ្តល់មកឱ្យអ្នកនូវចម្លើយមួយខុសៗគ្នា និងសរសេរចម្លើយរបស់ពួកគាត់នៅលើក្រដាសផ្ទាំងធំ។

១៤. ចូរពន្យល់ថា សំណួរនានាមានមុខងារជាច្រើនក្នុងការលើកកម្ពស់ការចូលរួម ប៉ុន្តែសំណួរទាំងនោះមានប្រសិទ្ធភាពក្នុងកម្រិតខុសៗគ្នា។ ចូរពន្យល់ថា វាមិនមែនគ្រាន់តែជាបញ្ហានៃការការសួរសំណួរណាមួយនោះទេ ប៉ុន្តែភាសានៅក្នុងសំណួរទាំងនោះក៏ជាចំណុចសំខាន់ដូចគ្នាផងដែរថា តើសំណួរទាំងនោះត្រូវបានរៀបចំដោយរបៀបណា និងរៀបតាមលំដាប់លំដោយយ៉ាងដូចម្តេចនៅពេលដែលគេប្រើនោះ។

១៥. សូមសួរសិក្ខាកាមថា ប្រសិនបើពួកគាត់ស្គាល់សំណួរ "បើក" ចំនួនប្រាំមួយ (ជួនកាលហៅថាសំណួរ "ជំនួយ")។ ចូរពន្យល់ថា សំណួរទាំងនេះគឺជាជំពូកសំណួរដែលផ្តល់លទ្ធភាពក្នុងការផ្តល់ចម្លើយច្រើនជាងមួយ (ពេលណា ទីណា អ្នកណា អ្វី បែបណា និងហេតុអ្វី)។

១៦. សូមណែនាំគំរូនៃការសួរសំណួរ (រូបទី៧) ដោយបង្កើតត្រីកោណ និងប្រើប្រាស់សំណួរបើកចំនួនប្រាំមួយ។ សូមបង្ហាញពីរបៀបដែលអាចបង្កើតលំដាប់ថ្នាក់ខុសៗគ្នា នៅក្នុងលំដាប់មួយ ដើម្បីជួយក្រុមមួយ ឬ បុគ្គលម្នាក់ក្នុងការកំណត់រកជម្រើសសម្រាប់ដោះស្រាយកង្វល់ផ្ទាល់ខ្លួនរបស់ពួកគាត់។

### រូបទី ៧៖ គំរូមួយសម្រាប់ការសួរសំណួរ




**១៧.** សូមស្នើសិក្ខាកាមឱ្យបង្កើតក្រុមដែលមានគ្នាបីនាក់ និងប្តូរវេន ដើម្បីអនុវត្តការសួរសំណួរការឆ្លើយសំណួរ និងការសង្កេត។ ចូរពន្យល់ថា បុគ្គលម្នាក់ៗគួរជ្រើសរើសយកបញ្ហាសមធម៌មួយដែលពួកគាត់កំពុងជួបប្រឈមក្នុងពេលបច្ចុប្បន្ន នៅក្នុងបរិបទផ្ទាល់ខ្លួនរបស់ពួកគាត់ និងចូរលើកសំណួរអំពីការប្រឈមនោះ។ ចូរពន្យល់ថា បុគ្គលដែលត្រូវបានសួរចំបញ្ហារបស់ខ្លួន គួរឆ្លើយសំណួរនោះឱ្យបានល្អបំផុតតាមតែអាចធ្វើបាន។

**១៨.** ចូរពន្យល់ថា ទោះក្នុងកាលៈទេសៈណាក៏ដោយ មិនអនុញ្ញាតឱ្យអ្នកលើកសំណួរប្រើប្រាស់គំនិតផ្ទាល់ខ្លួន ដើម្បីដោះស្រាយបញ្ហា នៅក្នុងការពិភាក្សានេះឡើយ។ ត្រូវដឹងថា សិក្ខាកាមត្រូវព្យាយាមលើកសំណួរនាំមុខជាមួយគំនិតផ្ទាល់របស់ខ្លួន នៅក្នុងសំណួរនោះដូចជា៖ តើអ្នកធ្លាប់បានសាកល្បង...? អ្នកសង្កេតគួរតែកត់ត្រាអំពីអ្វីដែលលេចឡើង និងមិនត្រូវបង្អាក់ជួយ ឬបន្ថែមគំនិតនៅត្រង់ចំណុចណាមួយឡើយ។

**១៩.** ក្រោយពីសិក្ខាកាមម្នាក់ៗ នៅក្នុងក្រុមគ្នាបីនាក់បានប្តូរវេនគ្រប់គ្នារួចមក (ម្នាក់ ៥នាទី ដូច្នេះ ១៥ នាទី សម្រាប់ទាំងអស់គ្នា) សូមបញ្ឈប់សិក្ខាកាម និងសួរសំណួរឆ្លុះបញ្ចាំងដូចតទៅ៖

- *តើមានអ្វីខ្លះដែលបានកើតឡើង? តើវាងាយស្រួល ឬ លំបាក? ហេតុអ្វី?*

- *តើអ្នកធ្វើអ្វីខ្លះ ប្រសិនបើអ្នកឃើញថាគំនិតរបស់ខ្លួនផ្ទាល់ពាក់ព័ន្ធមិនលេចធ្លោសោះនៅក្នុងសំណួរនោះ?*
- *តើអ្នកប្រើប្រាស់ម៉ូដែលនោះបែបណា?*
- *តើសំណួរបែបណាដែលអ្នកបានសួរ - សុទ្ធតែជាសំណួរបើក ឬ ចង្អុរ?*
- *តើអ្នកមានអារម្មណ៍បែបណានៅពេលដែលបុគ្គលដែលមានបញ្ហាត្រូវបានសាកសួរ?*
- *តើលំដាប់លំដោយនៃសំណួរទាំងនោះមានឥទ្ធិពលបែបណាមកលើចម្លើយ?*

២០. ក្រោយពីការឆ្លុះបញ្ចាំង សូមបូកសរុបមេរៀននេះដោយសង្កត់ធ្ងន់អំពីអានុភាពនៃសំណួរបើកក្នុងនាមជា អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ត្រូវទទួលយកគ្រប់ហេតុផលទាំងអស់ដែលក្រុមនេះបានកំណត់តាំងពីដើមដំបូងនៃវគ្គនេះ។ ចូរពន្យល់ថាប្រការសំខាន់គឺអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានតែងតែអនុវត្តការសួរសំណួរ។ សូមបង្ហាញគន្លឹះដែលមានផ្តល់ក្នុងឯកសារអំណាន ដើម្បីសង្ខេបឡើងវិញចំណុចសំខាន់ៗនៃមេរៀននេះ។

---

## កំណត់ត្រារបស់គ្រូបង្ហាត់

សិក្ខាកាមខ្លះអាចគិតថា ពួកគាត់បានដឹងរួចមកហើយអំពីរបៀបសួរសំណួរឱ្យបានសមស្រប។ ចូរគ្រាន់តែសង្កត់ធ្ងន់ថា នេះជាលំហាត់ប្រកបដោយសុវត្ថិភាព ដែលក្នុងនោះជំនាញនានាអាចយកមកអនុវត្តជាមួយអ្នកដទៃ ដើម្បីយើងបានដឹងកាន់តែច្រើនជាងមុនអំពីឥរិយាបថរបស់យើង និងថាមនុស្សគ្រប់រូបសុទ្ធតែអាចកែលម្អមូលដ្ឋាននៃជំនាញរបស់ខ្លួនបានផងដែរ។

# ការប្រើប្រាស់សំណួរដែលមានអានុភាព

"បើខ្ញុំមានពេលមួយម៉ោង ដើម្បីដោះស្រាយបញ្ហាមួយ ហើយជីវិតរបស់ខ្ញុំពឹងផ្អែកលើដំណោះស្រាយនោះខ្ញុំនឹងចំណាយពេល ៥៥នាទីដំបូង ដើម្បីកំណត់សំណួរសមស្របសម្រាប់សួរ។ ព្រោះខ្ញុំដឹងថា បើខ្ញុំដឹងសំណួរសមស្របហើយនោះ ខ្ញុំអាចដោះស្រាយបញ្ហានោះក្នុងរយៈពេលត្រឹមតិចជាង ៥នាទីប៉ុណ្ណោះ"។ Albert Einstein

## តើអ្វីខ្លះដែលធ្វើឱ្យសំណួររបស់អ្នកអស្ចារ្យ?[៩]



ការសួរសំណួរដែលមានអំណាច គឺជាសិល្បៈមួយ។ សំណួរដែលមានអានុភាពមានសមត្ថភាពក្នុងការ "ផ្សព្វផ្សាយដោយងាយស្រួល" និងសាយភាយចេញពីកន្លែងចាប់ផ្តើម ទៅក្នុងបណ្តាញដ៏ទូលាយ នៃការសន្ទនាក្នុងសហគមន៍ ឬស្ថាប័ននានា។

ការសួរសំណួរប្រកបដោយអានុភាព និងការប្រើប្រាស់ភាសា និងរៀបចំសំណួរបានត្រឹមត្រូវអាចបើកឱកាសឱ្យមានលទ្ធភាពជាច្រើន នៅក្នុងដំណើរការនៃការចូលរួម។ សំណួរប្រកបដោយអនុភាពអាច៖

- ជួយពង្រឹងទំនាក់ទំនងគ្នារវាងបុគ្គលនានា ទាំងអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន និង ក្រុម ព្រមទាំងសមាជិក នៅក្នុងក្រុមជាមួយគ្នា។
- ជួយជំរុញឱ្យមានការបង្ហាញសាច់រឿង ជាជាងរកទ្រឹស្តីអរូបិយ៍ និងទស្សនៈនានា
- ជាលក្ខណៈបុគ្គល និងមានប្រសិទ្ធភាពដែលអាចធ្វើឱ្យអារម្មណ៍ និងស្មារតីរបស់មនុស្សរំភើប
- ពឹងផ្អែកលើបទពិសោធន៍ជីវិតពិត និងការងាររបស់មនុស្សទាំងឡាយ ដែលពួកគាត់មិនបានយកចិត្តទុកដាក់កាលពីមុន
- បង្កើតរូបភាពក្នុងស្មារតី និងទម្រង់នៃគំនិត ដែលក្នុងនោះពួកគាត់ពុំធ្លាប់បានឃើញអត្ថន័យពីមុនមកឡើយ
- បានលើកស្ទួយដោយសារ វាផ្តល់រូបភាពវិជ្ជមានដែលទាក់ទាញ ដែលជំរុញទឹកចិត្តឱ្យចង់ឃើញអ្វីដែលអាចធ្វើបាន
- ផ្តល់សេរីភាពក្នុងការបង្កើតក្តីស្រមៃ ដោយសារវានាំយកមនុស្សទាំងឡាយទៅរកអនាគត និង ជួយពួកគាត់ស្រមៃអំពីលទ្ធភាពវិជ្ជមានមួយដែលគ្មានដែនកំណត់

---

៩ ស្រង់ចេញពី Whitney and Trosten-Bloom (2010).

- លើកសំណើសកម្មភាព និងជួយមនុស្សទាំងឡាយឱ្យពិចារណាអំពីជំហ៊ានបន្ទាប់នាពេលខាងមុខ និង
- មានលំហូរស្មារតី និងហេតុផលចំពោះពួកគាត់។

សំណួរនីមួយៗ ដែលអាចចាត់ទុកថា ជាសំណួរអស្ចារ្យត្រូវមានធាតុផ្សំចំនួនបី។ ទីមួយ គឺ**និម្មាបនកម្ម** ដែលទាក់ទងនឹងពាក្យដែលអ្នកប្រើ និងជម្រៅនៃសំណួរបើក (សូមអានសេចក្ដីពន្យល់បន្ថែមដែលទាក់ទងនឹងសំណួរបើក) ដែលអ្នកជ្រើសយក។ សំណួរណាមួយគួរតែមានរចនាសម្ព័ន្ធងាយ។ ប្រសិនបើសំណួរមួយមានគំនិតច្រើនជាងមួយ វានឹងនាំឱ្យមានភាពច្របូកច្របល់។ និម្មាបនកម្ម ក្នុងសំណួរគឺពិតជាអំពីរចនាបថ និងជាការច្នៃប្រឌិត។ ការគិតអំពីសំណួរដោយឡែកមួយ ដែលនឹងជួយដល់ដំណើរការមួយ គឺជាដំណើរការច្នៃប្រឌិតយ៉ាងខ្លាំងមួយ និងត្រូវការពេលវេលា។




ទិដ្ឋភាពទីពីរគឺ **វិសាលភាព**។ ប្រការសំខាន់គឺ ត្រូវឱ្យប្រាកដថា សំណួរនេះកំណត់អំពីវិសាលភាពដែលអ្នកត្រូវការ។ ប្រសិនបើអ្នកត្រូវការពង្រីកការគិតរបស់ក្រុមនេះ ដើម្បីរួមបញ្ចូលការគិតតាមទិសដៅខុសៗគ្នា[១០] អ្នកគួរសួរសំណួរដែលមានវិសាលភាពខុសគ្នា ពីករណីដែលអ្នកចង់បញ្ចូលគំនិតរបស់ពួកគេទៅក្នុងការគិតដែលមានទិសដៅរកគ្នា។[១១]

ទិដ្ឋភាពទីបីគឺ **ការសន្មត**។ សំណួរស្ទើរតែទាំងអស់របស់យើងនឹងមានការសន្មតខ្លះៗនៅក្នុងនោះដែលអាចបង្ហាញច្បាស់ ឬ មិនច្បាស់។ អ្នកត្រូវតែដឹងអំពីការសន្មតិនានាដែលអ្នកបានលើកឡើងនៅក្នុងសំណួរមួយ ឬ អ្នកអាចចង់ឱ្យមានយោបល់ផ្ទុយពីសំណួរនោះ។ តាមរយៈការដឹងអំពីការសន្មតរបស់អ្នក និងមិនធ្វើការសន្មត ដែលរារាំងដំណើរការគិត ឬ ជំរុញឱ្យមានការការពារខ្លួន អ្នកអាចបង្កើតសំណួរដ៏ល្អដែលឱ្យបើកលទ្ធភាពជាច្រើន។

---

១០ ការគិតតាមទិសខុសគ្នា គឺជាដំណើរការ ឬ វិធីនៃការគិតដែលបានប្រើប្រាស់ដើម្បីបង្កើតគំនិតច្នៃប្រឌិត ដោយស្វែងយល់អំពីដំណោះស្រាយដែលអាចមាន។ ស្រង់ចេញពី Gray, Brown and Macanufo (2010).

១១ ការគិតតាមទិសរកគ្នា អនុវត្តតាមជំហានសមហេតុផលមួយ ដើម្បីឈានដល់ដំណោះស្រាយមួយ ដែលក្នុងករណីខ្លះ វាជាដំណោះស្រាយ "ត្រឹមត្រូវ" ។ ស្រង់ចេញពី Gray, Brown and Macanufo (2010).

**រូបទី ៧៖ គំរូមួយសម្រាប់ការសួរសំណួរ**




សំណួរបើកទាំងប្រាំមួយ អាចពិនិត្យមើលវិធីខុសៗគ្នា ធៀបនឹងអ្វីដែលបានបង្ហាញក្នុងគំរូលើកមុន (រូបទី៧)។ សំណួរបើកអាចទទួលបានព័ត៌មានខុសៗគ្នា និងបង្កើតការយោគយល់គ្នាក្នុងចំណោមសមាជិកក្រុមតាមវិធីខុសៗគ្នា។ "ហេតុអ្វី" គឺជាសំណួរដែលអាចមានលក្ខណៈតឹងតែងបំផុត ដោយសារវាស្ទង់មើលគុណតម្លៃ និងជំនឿរបស់យើងដែលអាចមានបុគ្គលលក្ខណៈផ្ទាល់ខ្លួន។ ទោះបីសមាជិកក្រុមគួរតែយល់នូវតម្លៃ និងជំនឿរបស់គ្នាទៅវិញទៅមកក៏ដោយ ជួនកាលការបកស្រាយតបនឹងសំណួរហេតុអ្វីអាចបង្កើតជាឥរិយាបថបង្ករឿង ឬ ការពារខ្លួន។ អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានត្រូវតែដឹងអំពីពេលវេលា និងរបៀបដែលពួកគាត់ប្រើប្រាស់សំណួរហេតុអ្វី។ អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានអាចបើកកកាយ និងលើកទឹកចិត្តឱ្យចែករំលែកជំនឿ តាមរយៈការបង្កើតរូបភាពមួយដោយប្រើប្រាស់គំរូនៃការសួរ។ ឧទាហរណ៍ ជំនួសឱ្យការសួរដោយត្រង់ អ្នកអាចសួរថា៖ តើអ្វីដែលនាំឱ្យអ្នកគិតបែបនោះ? ឬ៖ តើអ្នកធ្វើបែបណា ទើបឈានដល់ការសន្និដ្ឋានបែបនោះ?

គេក៏អាចប្រើប្រាស់គំរូនេះ ដើម្បីជួយបុគ្គល ឬ ក្រុមណាមួយ ក្នុងការវិភាគបញ្ហារបស់ពួកគាត់ផ្ទាល់ និងកំណត់អត្តសញ្ញាណជម្រើសសកម្មភាព ដោយពុំត្រូវការយោបល់របស់អ្នកសម្របសម្រួលឡើយ។ និយាយម៉្យាងទៀតថា គំរូនេះអាចជួយអ្នកឱ្យស្ថិតនៅអព្យាក្រឹត្យ ដើម្បីភាពម្ចាស់ការលើជម្រើស ហើយសកម្មភាពនេះ នៅតែជារបស់ក្រុមនេះ និងមិនផ្អែកលើជំនាញរបស់អ្នកឡើយ។

## សំណួរសម្រាប់គ្រប់វគ្គកាល[១២]

សំណួរនានាអាចបង្កើតឡើងសម្រាប់គោលបំណងខុសៗគ្នា ដោយផ្អែកលើក្រុម និងដំណើរការខុសៗគ្នា។ ទោះជាយ៉ាងណាក៏ដោយ មានសំណួរបង្កើនគំនិតខ្លះ ដែលមានប្រយោជន៍សម្រាប់សម្រួលដល់ការគិតបែបច្នៃប្រឌិត ដែលអាចកែសម្រួលសម្រាប់ការប្រើប្រាស់បាន ដូចខាងក្រោមនេះ៖

---

១២ ស្រង់ចេញពី Isaacs and the World Cafe Community (2005).

### សំណួរសម្រាប់ផ្តោតការយកចិត្តទុកដាក់៖

- តើស្ថានភាពនេះផ្តល់អ្វីខ្លះ ដែលមានសារៈសំខាន់ចំពោះអ្នក និងហេតុអ្វីអ្នកយកចិត្តទុកដាក់ចំពោះវា ?
- តើមានអ្វីខ្លះដែលអ្នកនៅត្រូវការរៀនសូត្រអំពីស្ថានភាពនេះ ?
- តើអ្វីខ្លះដែលទាក់ទាញអ្នកឱ្យយកចិត្តទុកដាក់ចំពោះបញ្ហា និងសំណួរនេះ ?
- តើអ្នកអាចមើលឃើញឱកាសអ្វីខ្លះនៅក្នុងស្ថានភាពនេះ ?
- ហេតុអ្វីបញ្ហានេះមានតម្លៃសម្រាប់កិច្ចប្រឹងប្រែងរបស់អ្នក ?
- តើការសន្មតអ្វីខ្លះដែលអ្នកនៅត្រូវជម្រះមន្ទិលសង្ស័យអំពីស្ថានភាពនេះ ?

### សំណួរសម្រាប់តភ្ជាប់គំនិតនានា និងស្វែងរកការឆ្លុះបញ្ចាំងស៊ីជម្រៅបន្ថែមទៀត៖

- តើអ្វីខ្លះកើតឡើងដែលជំរុញទឹកចិត្ត និងជារឿងថ្មីសម្រាប់អ្នក ?
- តើអ្វីខ្លះជាការតភ្ជាប់ថ្មីៗដែលអ្នកកំពុងបង្កើត ?
- តើអ្វីខ្លះជាការគិតគូរនៅកម្រិតថ្មីមួយដែលអ្នកត្រូវបង្ហាញ ?
- តើអ្វីខ្លះជាការយល់ឃើញរបស់អ្នករហូតមកទល់ពេលនេះ ?
- តើបញ្ហាទាំងនោះមានការពាក់ព័ន្ធបែបណា ?

### សំណួរដែលបង្កើតចលនាទៅមុខ៖

- តើគេត្រូវការអ្វីខ្លះដើម្បីបង្កើតឱ្យមានការកែប្រែលើបញ្ហានេះ ?
- តើអ្វីខ្លះអាចកើតឡើង ដែលអាចធ្វើឱ្យអ្នកមានអារម្មណ៍ជាប់ជំពាក់នឹងស្ថានភាពនេះ និងមានថាមពល ?
- តើអ្វីខ្លះដែលត្រូវការនូវការយកចិត្តទុកដាក់របស់អ្នកដើម្បីឈានទៅមុខ ?
- ប្រសិនបើគេអាចធានាជោគជ័យបានទាំងស្រុង តើជំហ៊ានដោយក្លាហានអ្វីខ្លះដែលអ្នកជ្រើសយក ?
- តើអ្នកអាចផ្តល់វិភាគទានដោយឡែកណាខ្លះ ដើម្បីជំរុញអ្វីមួយឱ្យឈានទៅមុខ ?
- តើយើងគួរធ្វើអ្វីបន្ទាប់ពីនេះ ?

# ឃ. ការនិទានរឿង

**គោលបំណងនៃការរៀនសូត្រ**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាចៈ

- ពន្យល់អំពីរបៀប និងពេលវេលាដែលពួកគាត់គួរតែប្រើវិធីនិទានរឿង ក្នុងនាមជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន នៅក្នុងដំណើរការនៃការជំរុញការចូលរួម។
- ពន្យល់ពីគុណតម្លៃនៃរឿងរ៉ាវ ដើម្បីធ្វើឱ្យក្រុម ឬ បុគ្គលនានាជាប់ជំពាក់លើបញ្ហាសមធម៌។
- ប្រើប្រាស់ធាតុផ្សំទាំងប្រាំ នៃការនិទានរឿងដ៏ល្អមួយ នៅក្នុងការបង្កើតសាច់រឿងរបស់ខ្លួនផ្ទាល់ និង
- អនុវត្តជំនាញប្រាស្រ័យទាក់ទង និងជំនាញនិទានរឿងរបស់ខ្លួន។

**សម្ភារៈ**

ក្រដាសផ្ទាំងធំ ការជ្រើសរើសវត្ថុមួយចំនួន ដោយឥតគ្រោងទុក (ធ័ត្រ កំសៀវ ត្រា សំពត់រ៉ូប។ល។) នាឡិកាកំណត់ពេលឯកសារ អំពីប្រយោគសម្រាប់បើកសាច់រឿង និងឯកសារអំណាន។



**រយៈពេល**

១២០ នាទី

---

## ជំហានអនុវត្ត

១. ចូរបង្ហាញមេរៀននេះដោយពន្យល់ថា អ្នកនឹងពិនិត្យឱ្យបានលម្អិតចំពោះជាន់ខាងលើនៃផ្ទះជំនាញជំរុញការចូលរួមដោយច្នៃប្រឌិត នៅក្នុងការនិទានរឿង។

២. ចូរស្នើឱ្យសិក្ខាកាមរំលឹកឡើងវិញរឿងរ៉ាវណាមួយដែលល្បីល្បាញ ដែលនាំឱ្យរំភើប។ សូមដើរទៅជិតសិក្ខាកាម និងសុំឱ្យពួកគាត់ប្រាប់អ្នកនូវចំណងជើងនៃរឿងនោះ និងហេតុអ្វីបានជាវាធ្វើឱ្យមានការដក់ជាប់អារម្មណ៍។

៣. ផ្អែកលើយោបល់របស់ពួកគាត់ សួរសិក្ខាកាមថា ហេតុអ្វីពួកគាត់គិតថារឿងរ៉ាវទាំងនោះមានអានុភាពខ្លាំង (ផ្តល់ខ្លឹមសារ ចែករំលែកបទពិសោធន៍ ជួយបង្កើតទស្សនៈ ធ្វើឱ្យដក់ចិត្ត និងចាប់អារម្មណ៍ និងធ្វើឱ្យមានមនោសញ្ចេតនា)។

៤. ស្នើឱ្យសិក្ខាកាមចូលជាគូដែលមានគ្នាពីរនាក់ជាមួយអ្នកដែលស្ថិតនៅជាប់គ្នា និងពិភាក្សាបំផុសគំនិតអំពីថា តើអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន អាចប្រើប្រាស់ការនិទានរឿងបែបណានៅក្នុងដំណើរការធ្វើឱ្យមានការចូលរួមបែបច្នៃប្រឌិត។ សូមទុកពេល៣នាទី និងបន្ទាប់មកសុំគំនិតពីគូនីមួយៗ។ សូមសរសេរគំនិតទាំងនោះ នៅលើផ្ទាំងក្រដាស។

៥. បូកសរុបគំនិតទាំងនេះ ដោយត្រូវប្រាកដថា ពួកគាត់បានពិចារណារាល់ឱកាស ដើម្បីប្រើប្រាស់ការនិទានរឿង (ដោយផ្អែកលើឯកសារសម្រាប់អំណាន ដែលនៅពុំទាន់បានចែកជូន)។ សូមគូសបញ្ជាក់ថា អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានអាចប្រើប្រាស់ការនិទានរឿងជាបច្ចេកទេសមួយដែលនៅក្នុងនោះបុគ្គល ឬ ក្រុមនានានិទានរឿង ឬ ប្រាស្រ័យទាក់ទងគំនិតមួយជាជាងផ្តល់បទឧទ្ទេសនាមអំពីរឿងនោះ។

៦. ចូរពន្យល់ថា មិនមែនរឿងទាំងអស់ត្រូវតែជារឿងប្រឌិត ឬ ការស្រមៃនោះឡើយ ប៉ុន្តែមានរឿងនានាដែលអាចផ្តល់បទពិសោធន៍ និងព័ត៌មាន។

៧. ចូរពន្យល់ថា មេរៀននេះស្វែងយល់ពីរបៀបនិទានរឿងល្អៗ និងវិភាគរចនាសម្ព័ន្ធនៃរឿងដែលល្អមួយ។

៨. ចូរពន្យល់ថា អ្នកទាំងអស់គ្នានឹងមានឱកាសដើម្បីនិទានរឿងនៅចំពោះមុខក្រុម។ ការធ្វើបែបនេះនឹងផ្តល់ឱ្យពួកគាត់នូវឱកាស ដើម្បីអនុវត្តជំនាញប្រាស្រ័យទាក់ទងងាយៗ និងភាសាកាយវិការរបស់ពួកគាត់ផងដែរ។

៩. ចូរពន្យល់ថា សិក្ខាកាមម្នាក់ៗនឹងត្រូវជ្រើសយកវត្ថុណាមួយពីក្នុងថង់(ឬប្រអប់) បន្ទាប់មកជ្រើសយកប្រយោគចាប់ផ្តើមរឿងមួយ ដែលសរសេរនៅលើសន្លឹកក្រដាសតូចមួយ ដែលយកចេញពីប្រអប់ ឬ ថង់នោះផងដែរ (សូមអានលំហាត់)។



១០. មុននឹងបង្ហាញលំហាត់នេះ ចូរពន្យល់ថាអ្នកចង់ឱ្យពួកគាត់ គិតអំពីធាតុផ្សំទាំងប្រាំនៃរឿងដ៏ល្អមួយ។ បង្ហាញធាតុផ្សំទាំងប្រាំនោះ(តួក្នុងសាច់រឿង ស្ទៀតការសន្ទនា និងសម្រង់សំដីទំនាស់ និងភាពតានតឹង និងការសន្យាដែលបានបំពេញ) ដោយប្រើប្រាស់ខ្សែរឿងមួយដែលសិក្ខាកាមនឹងបានស្គាល់ទាំងអស់គ្នា។ប្រសិនបើចាំបាច់ ចូរប្រើប្រាស់ផ្នែកមួយនៃសាច់រឿង Alice in Wonderland ដែលមាននៅក្នុងឯកសារអំណាន ដើម្បីស្វែងយល់ពីការយល់ឃើញរបស់សិក្ខាកាមអំពីធាតុផ្សំទាំងនេះ។

**១១.** ប្រាប់សិក្ខាកាមម្នាក់ៗថា ពួកគាត់ត្រូវនិទានរឿងមួយរយៈពេល ២នាទី អំពីវត្ថុរបស់ពួកគាត់ និងដោយផ្អែកលើប្រយោគនានានៃខ្សែរឿងរបស់ពួកគាត់។ ចូរប្រាប់ពួកគាត់ថា រឿងនីមួយៗគួរតែមានចំណុចចាប់ផ្ដើមតួរឿង និងចុងបញ្ចប់។ ពួកគាត់ត្រូវពិចារណាធ្វើបែបណា ដើម្បីឱ្យសាច់រឿងរបស់ពួកគាត់មានឥទ្ធិពល ដើម្បីសម្រេចបានគុណតម្លៃដែលបានកំណត់ពីខាងដើម នៅក្នុងមេរៀននេះ។ ពួកគាត់អាចបង្ហាញរឿងផ្ទាល់ខ្លួនក្នុងការងារឬការប្រឌិត។ ចូរពន្យល់ថាលំហាត់នេះត្រូវបានបង្កើតឡើង ដើម្បីជំរុញឱ្យពួកគាត់គិតអំពីផ្នែក "សាច់រឿង" នៃការ "និទាន" ដោយសារជួនកាលយើងចែករំលែកបទពិសោធន៍របស់យើងតាមវិធីដែលមិនជាទីចាប់អារម្មណ៍ ឬ ដែលមិនធ្វើឱ្យទាក់ចិត្តឡើយ។

**១២.** ទុកពេលឱ្យសិក្ខាកាម ១០នាទី ដើម្បីរៀបចំសាច់រឿងរបស់ពួកគាត់ ដោយគូសបញ្ជាក់ថា ពួកគាត់គួរសរសេរសាច់រឿងនោះ ប៉ុន្តែត្រូវគិតតែអំពីចំណុចសំខាន់ៗ និងក្របខ័ណ្ឌរួមប៉ុណ្ណោះ។

**១៣.** ក្រោយរយៈពេល ១០នាទី សូមស្នើសិក្ខាកាមទាំងអស់អង្គុយជុំកង់លើកៅអីដោយគ្មានតុ ឬ ផ្ទាល់លើកម្រាលឥដ្ឋ និងបើកឆាកសម្រាប់ការនិទានរឿង។ សូមលើកទឹកចិត្តសិក្ខាកាមឱ្យចេញមកជាក្រុម ដែលមានគ្នាបួននាក់ និងនិទានរឿងម្ដងម្នាក់ៗ។ ត្រូវកំណត់ម៉ោងឱ្យបានត្រឹមត្រូវដោយប្រើប្រាស់នាឡិកាកំណត់ពេល។ ក្រោយពេលដែលក្រុមមានគ្នាបួននាក់នីមួយៗបាននិទានរឿងរួចមក ចូរធ្វើការឆ្លុះបញ្ចាំងអំពីការនិទានរឿង និងកំណត់អំពីផ្នែកនានាដែលអ្នកនិទានរឿងដទៃទៀតអាចប្រើប្រាស់ ដើម្បីកែលម្អរចនាសម្ព័ន្ធ និងជំនាញនិទានរឿងរបស់ពួកគាត់។



**១៤.** ចូរប្រើប្រាស់សំណួរដូចតទៅ ដើម្បីជួយក្រុមនេះធ្វើការឆ្លុះបញ្ចាំងក្រោយបាននិទានរឿងចំនួនបួនម្ដងៗ៖

- *តើអ្នកមានអារម្មណ៍បែបណានៅពេលនិទានរឿង និងហេតុអ្វី?*
- *តើអ្នកអាចកែប្រែអ្វីខ្លះនូវវិធីដែលអ្នកនិទានរឿងឥឡូវនេះ និងហេតុអ្វី?*
- *តើរឿងអ្វីខ្លះដែលអ្នកចងចាំជាងគេ និងហេតុអ្វី?*
- *សាច់រឿងរបស់អ្នកណា ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ និងអ្វីខ្លះដែលធ្វើឱ្យអ្នកចាប់អារម្មណ៍បែបនោះ?*
- *តើរឿងទាំងអស់មានធាតុផ្សំទាំងប្រាំឬទេ? សូមផ្ដល់ឧទាហរណ៍ខ្លះៗ។*
- *តើអ្នកនិទានរឿងធ្វើឱ្យអ្នកមានអារម្មណ៍បែបណា នៅក្នុងពេលនិទានរឿងរបស់ពួកគាត់?*

- *តើពួកគាត់គួរតែអាចធ្វើអ្វីខ្លះដើម្បីធ្វើឱ្យសាច់រឿងនោះកាន់តែមានឥទ្ធិពលចំពោះអ្នក ?*
- *តើបច្ចេកទេសប្រាស្រ័យទាក់ទងផ្ទាល់ខ្លួនអ្វីខ្លះដែលពួកគាត់ប្រើប្រាស់ដែលធ្វើឱ្យសាច់រឿងនោះរស់រវើក ?*

១៥. ក្រោយពេលដែលក្រុមទាំងអស់បាននិទានរឿងរបស់ខ្លួនគ្រប់ៗគ្នាហើយ ចូរសិក្ខាកាមទាំងអស់គ្នាធ្វើការឆ្លុះបញ្ចាំងអំពីបទពិសោធន៍របស់ពួកគាត់៖

- *តើអ្នកប្រើប្រាស់សាច់រឿងញឹកញាប់កម្រិតណា ដើម្បីប្រាស្រ័យទាក់ទង នៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក ?*
- *តើអ្នកប្រើប្រាស់សាច់រឿងញឹកញាប់កម្រិតណា នៅក្នុងការបង្ហាញព័ត៌មាន ក្នុងការិយាល័យរបស់អ្នក ឬ ជាមួយអ្នកពាក់ព័ន្ធនានា ?*
- *ហេតុអ្វីអ្នកគិតថា មនុស្សជាច្រើនចូលចិត្តចំណាយពេលបង្ហាញព័ត៌មាន តាមរបៀបធម្មតាជាងតាមរយៈការនិទានរឿង ឬ ការស្នើឱ្យមនុស្សទាំងឡាយនិទានរឿងរបស់ពួកគាត់ ?*
- *តើអ្នកគិតថារឿងរ៉ាវនានាអាចជួយក្រុមទន់ខ្សោយបែបណា ដើម្បីបង្កើតទំនុកចិត្ត និងការជាប់ចិត្តជាមួយអ្នកពាក់ព័ន្ធដទៃទៀត ?*

**១៦.** ចូរបូកសរុបមេរៀននេះដោយពន្យល់ថា សិក្ខាកាមគួរដឹងអំពីរបៀបដែលពួកគាត់ប្រើប្រាស់សាច់រឿងនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគាត់។ ចូរបញ្ជាក់ថា ការតភ្ជាប់រូបភាព និងការនិទានរឿងគឺជាដំណើរការប្រកបដោយអំណាចទាំងសម្រាប់ការវេចខ្ចប់ព័ត៌មាន និងការបង្កើតថាមពល និងចំណងទាក់ទងក្នុងចំណោមមនុស្ស។ ចូរពន្យល់ថា វិធីនេះអាចកែលម្អបន្ថែមទៀតតាមរយៈការពិចារណាអំពីទម្រង់នៃវិធីធ្វើឱ្យមានការពាក់ព័ន្ធ និងការជ្រើសរើសយកឧបករណ៍។ សូមគូសបញ្ជាក់ថា គេអាចបង្កើតឧបករណ៍នានាបានដើម្បីបង្កើត និងចែករំលែកសាច់រឿងហើយឧបករណ៍ទាំងនេះនឹងមានពិភាក្សាថែមទៀតក្នុងមេរៀនក្រោយៗ។

---

## កំណត់សំគាល់របស់គ្រូបង្គោល

ប្រសិនបើអ្នកមានសិក្ខាកាមជាចំនួនច្រើន អ្នកអាចចង់អនុវត្តការនិទានរឿងជាគូ ឬ បែងចែកសិក្ខាកាមជាក្រុម ដោយមានគ្រូបង្ហាត់ម្នាក់សម្រាប់ក្រុមនីមួយៗ។

វាជាការលើកទឹកចិត្តសម្រាប់បុគ្គលម្នាក់ៗ ក្នុងការនិទានរឿង ដើម្បីពួកគាត់មានបទពិសោធន៍ក្នុងការនិទានរឿង និងមានអ្នកស្តាប់។ ត្រូវរំលឹកសិក្ខាកាមថា រឿងនានាអាចប្រើប្រាស់នៅក្នុងគ្រប់បរិបទសម្រាប់គោលបំណងជាក់លាក់។

ខ្សែវីដេអូនេះអាចពង្រឹងចំណុចរៀនសូត្រនេះ៖ http:/j99u.comjvideosj6857jjay-ocallahan-the-power-of-storytelling

# ការនិទានរឿង

ចូរព្រីន និងកាត់យកផ្នែកនានានៃប្រយោគចាប់ផ្តើមសាច់រឿង និងស្នើឱ្យសិក្ខាកាមជ្រើសយកតែមួយពីក្នុងថង់ ឬ ប្រអប់។ អ្នកក៏អាចបង្កើតមួយសម្រាប់ខ្លួនឯងផ្ទាល់ផងដែរ។

| | |
|---|---|
| នៅពេលខ្ញុំបើកទ្វារ ខ្ញុំបានឃើញពន្លឺក្រហមលោតភ្លឹបភ្លែតៗ... | ខ្ញុំបានឃើញនទ្វដ៏ធំមួយពីចម្ងាយ... |
| កាលពីព្រេងនាយ... | ព្រះអាទិត្យបញ្ចេញរស្មីចែងចាំង... |
| សូមជូនពរថ្ងៃបុណ្យកំណើត សូមជូនពរថ្ងៃ បុណ្យកំណើត... | ថាមពលនៅជុំវិញខ្ញុំ... |
| សម្លេងតូចមួយផុសចេញពីក្បាលខ្ញុំ... | " ស៊ីសសសសសសសស" សម្លេងនោះបន្លឺឡើង... |
| ប៉ាំង! ខ្ទាយ! ភឹង!!! ... | ខ្ញុំបានឡើងដល់កំពូល... |
| ខ្ញុំពុំដែលរំពឹងថា ... | ត្រៀមរួចហើយមែនទេ? តោះចេញដំណើរ... |
| សម្លេងមនុស្សសើច... | សម្លេងទូរស័ព្ទរោទ៍... |
| នេះជាអំណោយល្អបំផុតដែលខ្ញុំពុំដែលបានទទួលពី មុនមក... | ពួកគាត់កំពុងច្រៀង... |
| ខ្ញុំអាចឮពីចម្ងាយ... | វាជាអ្វីដែលខ្ញុំពុំដែលបានគិតដល់សោះ... |
| នេះជារឿងអាថ៌កំបាំងដែលខ្ញុំពុំដែលប្រាប់អ្នកណាឡើយ... | បាទ! ឥឡូវនេះច្បាស់ហើយ... |
| ហ៊ឺស យន្តហោះចេញដំណើរហើយ... | អស្ចារ្យណាស់ ពិភពចម្លែក... |
| ពាក្យស្លោកមានន័យជ្រាលជ្រៅបំផុតដែលខ្ញុំធ្លាប់បានឮគឺ... | សូមសរសេរដោយខ្លួនឯង... |
| វាជារបស់ធំជាងគេ... | សូមសរសេរដោយខ្លួនឯង... |
| ខ្ញុំមានអារម្មណ៍ថាខ្ញុំកំពុងហោះហើរតាម... | សូមសរសេរដោយខ្លួនឯង... |
| ខ្ញុំចង់ឱ្យមនុស្សទាំងឡាយ... | សូមសរសេរដោយខ្លួនឯង... |

# តើហេតុអ្វីការនិទានរឿងមានអានុភាពខ្លាំង?

## តើហេតុអ្វីរឿងមួយមានឥទ្ធិពល?

រឿងនានាត្រូវបាននិទានជាច្រើនឆ្នាំមកហើយ ដើម្បីនាំមនុស្សមកជួបជុំគ្នា និងឆ្លុះបញ្ចាំងខ្លឹមសារមួយ។ រឿងដែលនិទានបានល្អដែលមានខ្លឹមសារសំខាន់សម្រាប់អ្នកស្ដាប់ នឹងអាចចងចាំ និងមានអានុភាពលើមនុស្សជាច្រើន។

រឿងនានាមានឥទ្ធិពល ពីព្រោះវាអាចៈ




- បញ្ជូនអត្ថន័យ ជាងព័ត៌មាន
- ចែករំលែកបទពិសោធន៍ តែមិនមែនទិន្នន័យ
- ជំរុញឱ្យមានចក្ខុវិស័យ និងការស្រមៃ
- បណ្ដាលឱ្យមានការរំជួលចិត្ត និងការជាប់ចិត្ត។

## តើអាចប្រើប្រាស់រឿងរ៉ាវនានាដោយរបៀបណានៅក្នុងការបង្កើតការពាក់ព័ន្ធ និងដំណើរការសមធម៌?

ការពាក់ព័ន្ធគឺជាការតភ្ជាប់មនុស្ស និងអារម្មណ៍រំភើប ឬ ចំណាប់អារម្មណ៍របស់ពួកគាត់ ដើម្បីធ្វើសកម្មភាពលើបញ្ហានានាដែលពួកគាត់ចាប់អារម្មណ៍។ អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានត្រូវតែជឿលើអានុភាពនៃសាច់រឿងថាជាឧបករណ៍មួយសម្រាប់ជំរុញការពាក់ព័ន្ធ និងក៏ជាឧបករណ៍សម្រាប់ចម្រាញ់រកនិងប្រាស្រ័យទាក់ទងគំនិតនានា និងព័ត៌មានផងដែរ។ សាច់រឿងគឺជាមធ្យោបាយដ៏មានអានុភាពសម្រាប់ផ្ដល់ទិន្នន័យ និងព័ត៌មានដល់ក្រុមជាក់លាក់។ វាក៏ជាវិធីមួយដើម្បីតភ្ជាប់មនុស្សតាមរយៈបទពិសោធន៍ផងដែរ។ កម្មវិធីបង្កើតការពាក់ព័ន្ធនៃពលរដ្ឋជាច្រើនបានទទួលជោគជ័យក្នុងការប្រើប្រាស់ការនិទានរឿង ជាមួយក្រុមអ្នកទន់ខ្សោយ ដើម្បីជួយតភ្ជាប់ពួកគាត់នៅក្នុងមជ្ឈដ្ឋានរបស់ខ្លួន និងដើម្បីបង្កើតទំនុកចិត្តនៅក្នុងការបង្កើតទំនាក់ទំនង និងការអនុវត្តសកម្មភាពនានា។

ក្នុងនាមជាអ្នកសម្របសម្រួលនៅមូលដ្ឋាន អ្នកអាចប្រើប្រាស់ជំនាញនិទានរឿង តាមវិធីនានាដូចតទៅៈ

- និទានរឿងមួយដើម្បីបញ្ជូនសារ ឬ គោលគំនិតជាក់លាក់ គឺជាផ្នែកមួយនៃការបង្ហាញតាមរយៈគំហើញ
- ការប្រើប្រាស់បច្ចេកទេសនិទានរឿង ជាផ្នែកមួយនៃដំណើរការសម្របសម្រួល ដើម្បីជួយសមាជិកនានា មើលឃើញភាពតជាប់គ្នា និងទម្រង់នៃការរំជួលចិត្តក្នុងចំណោមពួកគាត់អំពីបញ្ហាជាក់លាក់

- ការប្រើប្រាស់បទពិសោធន៍និទានរឿង ដើម្បីបង្កើតរបៀបវារៈទូទៅរួមគ្នាសម្រាប់សកម្មភាពក្នុងស្ថានភាពជាក់លាក់មួយ
- ការប្រើប្រាស់ការនិទានរឿង ដើម្បីជួយក្រុមមួយបង្កើតចក្ខុវិស័យ (ប្រសិនបើ ...) និង
- បង្កើត និងចងក្រងសាច់រឿងពីបុគ្គលនានា និងនិទានរឿងទាំងនោះ តាមវិធីដែលមានអានុភាពលើអ្នកដទៃ។

ទោះបីការនិទានរឿងកើតមានជាទូទៅក្នុងគ្រប់សង្គមមនុស្សក៏ដោយ ការនិទានរឿងមានន័យថាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានត្រូវតែដឹងអំពីរបៀបនិទានរឿងឱ្យបានល្អ ហេតុអ្វីសាច់រឿងត្រូវបាននិទាន និងថាតើពួកគាត់និទានរឿងបានល្អកម្រិតណា?

## តើនៅក្នុងរឿងដែលល្អមានជាតុផ្សំអ្វីខ្លះ?



រឿងរ៉ាវល្អៗទាំងអស់ផ្សំឡើងដោយរចនាសម្ព័ន្ធ ដែលមានចំណុចចាប់ផ្ដើម តួឯកនិងចុងបញ្ចប់។ រឿងល្អមានចំណុចនានាដូចតទៅៈ

**តួអង្គចំបង** - នេះជាបុគ្គលដែលជា "តារា" នៃសាច់រឿង និងជុំវិញអារម្មណ៍ និងឥរិយាបថរបស់អ្នកណា ដែលផ្ដោតក្នុងរឿងនោះ។

**ស្នៀត** - នេះជាសំណួរ ឬបញ្ហាដែលធ្វើឱ្យអ្នកស្ដាប់បន្តយកចិត្តទុកដាក់ស្ដាប់រឿងនោះដោយជឿថា នៅទីបញ្ចប់ចម្លើយតបនឹង "ស្នៀតនោះ" នឹងបង្ហាញឱ្យដឹង។

**ការសន្ទនា និងសម្រង់សំដី** - គ្រប់រឿងល្អៗ នឹងមានការសន្ទនាខ្លះៗជាការចង្អុលបង្ហាញ ឬរាយការណ៍អំពីអ្វីដែលតួឯកពោល ឬ ធ្វើ។

**ភាពតានតឹង និងជម្លោះ** - គ្រប់រឿងល្អៗមានជម្លោះ ឬវិនាដកម្មតាមបែបខ្លះៗ។ នេះមិនមានន័យថា នៅក្នុងគ្រប់រឿងទាំងអស់ត្រូវតែមានការវាយប្រហារឡើយ ប៉ុន្តែវាត្រូវតែមានភាពតានតឹងខ្លះៗ សម្រាប់អ្នកស្ដាប់ ដើម្បីឱ្យមានកំហឹង និងជាប់ជំពាក់ ដើម្បីស្វែងរកអ្វីដែលនឹងកើតឡើង នៅក្នុងវគ្គបន្ទាប់។

**បំណងប្រថ្នាដែលសម្រេចបាន** - សាច់រឿងល្អមួយតែងតែបញ្ចប់ដោយសម្រេចបំណងប្រាថ្នា។ ពីដើមដំបូងនៃខ្សែរឿង គេមានស្នៀត និងនៅទីបញ្ចប់នៃសាច់រឿង គេត្រូវតែមានសារច្បាស់លាស់ ឬចំណុចបញ្ចប់ដែលផ្អែកលើស្នៀតនោះ។

នៅពេលនិទានរឿង សូម្បីតែរឿងនោះអំពីបទពិសោធន៍ផ្ទាល់ខ្លួន ឬជាបញ្ហាបច្ចេកទេសក៏ដោយ អ្នកនិទានរឿងអាចគិតអំពីការរួមបញ្ចូលធាតុផ្សំបឋមនានា និងសិល្បវិធី ដើម្បីធ្វើឱ្យអ្នកស្តាប់មានចំណាប់អារម្មណ៍។ ឧទាហរណ៍ ប្រសិនបើវាជារឿងមួយអំពីការប្រែប្រួលអាកាសធាតុពិភពលោក និង REDD+ ចូរអ្នកគិតអំពីតួអង្គដែលត្រូវបង្កើត ស្នៀត និងរបៀបបង្កើតភាពតានតឹង និងការសន្ទនា។ តួអង្គនានាអាចជា ប្រទេស អ្នកចរចា អ្នកបញ្ចេញឧស្ម័ន ។ល។ ការធ្វើបែបនេះនឹងមានភាពទាក់ទាញជាខ្លាំងជាងបទបង្ហាញបច្ចេកទេសអំពីការប្រែប្រួលអាកាសធាតុ។ ទោះជាយ៉ាងណាក៏ដោយ គេក៏ត្រូវតែមានការគិតគូរអំពីហេតុអ្វីត្រូវប្រើការនិទានរឿង និងបន្ទាប់មក សាច់រឿងត្រូវតែនិទានតាមវិធីដែលធ្វើឱ្យមានការទាក់ទាញ។

## រួមផ្សំសាច់រឿង និងរូបភាព

សាច់រឿង ដែលអាចមើលឃើញរួមផ្សំការបង្កើតរូបភាព និងការនិទានរឿង និងមានសារៈសំខាន់បំផុតក្នុងការ បញ្ចុះបញ្ចូល និងមានអានុភាពដើម្បីការកែប្រែ ប្រសិនបើប្រើប្រាស់តាមវិធីត្រឹមត្រូវ។ ទាំងការបង្កើតរូបភាព និងសាច់រឿងទាក់ទាញអឌ្ឍគោលខាងស្តាំនៃខួរក្បាល( ផ្នែកវិភាគរូបភាព)និងសម្រួលឱ្យអ្នកពាក់ព័ន្ធ ឬ ក្រុមនានាគិតអំពីមូលហេតុ ដែលពួកគាត់យកចិត្តទុកដាក់ចំពោះបញ្ហា ឬ ផលប្រយោជន៍ណាមួយ។ ការស្នើក្រុមមួយឱ្យយកចិត្តទុកដាក់ និងផ្តល់ឱ្យពួកគាត់នូវឱកាសដើម្បីសំដែងអំពីថា តើពួកគាត់យកចិត្តទុកដាក់ប៉ុណ្ណាអាចធ្វើទៅបាន ដោយប្រើប្រាស់បច្ចេកទេសនិទានរឿងដែលអាចឃើញ។ ការបង្កើតរូបភាពក៏អាចពាក់ព័ន្ធនឹងការប្រើប្រាស់វត្ថុពិត និងវត្ថុច្នៃ ឬ ស្នើសិក្ខាកាម ឱ្យប្រើប្រាស់វត្ថុទាំងនោះផងដែរ។




**ដើម្បីមានប្រសិទ្ធភាព អ្នកត្រូវតែមានអានុភាពលើមនុស្ស។ សាច់រឿង និងរូបភាព អាចជួយអ្នកបាន។**

## ហេតុអ្វីការនិទានរឿងដែលអាចមើលឃើញ មិនត្រូវបានប្រើប្រាស់ញឹកញាប់ដោយអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ?

ជាសំណាងអាក្រក់ការឈានទៅមុខខាងបច្ចេកទេសនៃកម្មវិធីសម្រាប់ធ្វើបទបង្ហាញ និងការពឹងផ្អែកលើព័ត៌មាន និងទិន្នន័យជាងការស្វែងរកខ្លឹមសារពីព័ត៌មាន និងបទពិសោធន៍ បាននាំឱ្យមានភាពលប់នៃសុន្ទរកថានិងបទបង្ហាញ - ដែលពុំផ្តល់ផលខ្ពស់ឡើយសម្រាប់លើកទឹកចិត្តឱ្យមានការជជែកគ្នា។ អ្នកខ្លះយល់ថា ការនិទានរឿង និងការបង្កើតរូបភាពពុំផ្តល់ភាពម៉ត់ចត់ និងបារម្ភថា វានឹងត្រូវអ្នកពាក់ព័ន្ធនានាបដិសេធ។ ប៉ុន្តែអ្នកដែលបានប្រើប្រាស់វិធីនេះ អាចបង្ហាញអំពីអានុភាពក្នុងការបើកចំហអំណាចដែលបង្កប់ និងតភ្ជាប់បុគ្គលនានា ដែលពុំធ្លាប់បានសំដែងអំពីខ្លួនឯងពីមុនមក។ អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានត្រូវបង្កើតទំនុកចិត្តរបស់ខ្លួនលើការនិទានរឿង។ ពួកគាត់ត្រូវរួមបញ្ចូលការនិទានរឿង ជាសមាសភាគស្នូលមួយនៅក្នុងដំណើរការជំរុញការចូលរួមរបស់ពួកគាត់ និងនៅពេលវេចខ្ចប់ព័ត៌មាន។

“តើអ្នកប្រាប់ខ្ញុំបានទេ តើខ្ញុំត្រូវចេញពីទីនេះតាមផ្លូវណា ?”

ឆ្មាឆ្លើយថា “វាអាស្រ័យជាខ្លាំងថាតើអ្នកចង់ទៅណា”

អាលីសឆ្លើយថា “ខ្ញុំមិនចាប់អារម្មណ៍ច្រើនថាទៅណាទេ”

ឆ្មាពោលថា “ក្នុងករណីនោះ ទោះទៅតាមផ្លូវការក៏មិនសំខាន់ដែរ”

អាលីសបន្ថែមដោយពន្យល់ថា “ឱ្យតែខ្ញុំបានទៅដល់កន្លែងណាមួយ”

ឆ្មាពោល “អូ! ពិតហើយ អ្នកត្រូវធ្វើបែបនេះ។ ប្រសិនបើអ្នកដើរឱ្យបានឆ្ងាយ។”

**Lewis Carroll: Alice’s Adventures in Wonderland**

# ខ. អនុវត្តជំនាញបង្កើតរូបភាព

**គោលបំណងនៃការរៀនសូត្រ**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងៈ

- អាចពន្យល់ពីគុណតម្លៃនៃការបង្កើតរូបភាព នៅក្នុងដំណើរការរៀនសូត្ររួមគ្នា ឬ ការចូលរួមពាក់ព័ន្ធ
- ពិភាក្សាអំពីការយល់ឃើញរបស់ខ្លួន នៅក្នុងការប្រើប្រាស់ការបង្កើតរូបភាព ក្នុងនាមជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន
- អនុវត្តជំនាញគូររូបងាយៗ ដើម្បីពន្យល់លក្ខខណ្ឌសំញ៉ាំ
- មានទំនុកចិត្តកាន់តែច្រើនឡើង នៅក្នុងវិធីបង្កើតរូបគំនូរងាយៗ ដោយប្រើសណ្ឋានងាយៗ និង
- សរសេរគំនិតមួយចំនួន អំពីវិធីបង្កើតរូបភាព ដែលអាចប្រើប្រាស់នៅក្នុងដំណើរការបង្កើត ការចូលរួមបែបច្នៃប្រឌិត។




**សម្ភារៈ**

ក្រដាសផ្ទាំងធំ ហ្វឺតរូបដំរីទឹក ប័ណ្ណវេននាក្រុម ដោយរូបភាពអំពីការប្រែប្រួលអាកាសធាតុ នាឡិកាកម្រិតម៉ោង ច្បាប់ចម្លងនៃសៀវភៅ Sketchnote Handbook (Rhode, 2013, pp. 153–162) និងឯកសារសម្រាប់អំណាន។



**រយៈពេល**

៩០ នាទី

---

## ជំហាននានា

១. បង្ហាញមេរៀននេះ ដោយយោងត្រឡប់មកផ្ទះជំនាញជំរុញការចូលរួមដោយច្នៃប្រឌិត និងជាន់ខាងលើបំផុតនៃផ្ទះនេះ ដែលមានដាក់ជំនាញបង្កើតរូបភាព។ ចូរពន្យល់ថា ទោះបីជំនាញនេះត្រូវបានដាក់នៅជាន់លើបំផុតក៏ដោយ វាអាចជួយអ្នកសម្របសម្រួលថ្នាក់មូលដ្ឋានជាមួយការប្រាស្រ័យទាក់ទងងាយៗរបស់ពួកគាត់។

២. ចូរផ្តល់ឱ្យសិក្ខាកាមម្នាក់ៗនូវក្រដាសមួយសន្លឹក និងពន្យល់ថា អ្នកនឹងអធិប្បាយអំពីសត្វមួយ ហើយអ្នកចង់ឱ្យពួកគាត់គូរសត្វនោះជាបណ្តើរៗ ទន្ទឹមនឹងពេលដែលអ្នកអានសេចក្តីអធិប្បាយនោះ មួយបន្ទាត់ម្តងៗ។ សូមកុំប្រាប់សិក្ខាកាមអំពីឈ្មោះសត្វនោះ។

៣. ត្រូវចាប់ផ្តើមអានសេចក្តីពិពណ៌នា ដោយដកឃ្លាវាងប្រយោគនីមួយៗ៖ "សត្វមួយជាត់ខ្លាំងណាស់ដែលមានដងខ្លួនធំមាំមួន ... វាមានជើងបួនរឹងប៉ឹងដែលនៅចុងជើងទាំងបួនមានម្រាមជាចំនួនគូ ... វាមានក្បាលមាំសំប៉ែត ជាមួយភ្នែកតូចៗ ត្រចៀក និងរន្ធច្រមុះនៅពីលើក្បាល ... មាត់របស់វាធំ និងអាចបើកបានយ៉ាងទូលាយ ដោយមានអណ្តាតមួយរឹង ... វាមានកន្ទុយខ្លីតូចមួយ។

៤. ក្រោយពីបានអានសេចក្តីពិពណ៌នានេះរួចមក ស្នើឱ្យសិក្ខាកាមលើកបង្ហាញរូបគំនូររបស់ពួកគាត់នៅក្នុងរង្វង់មួយ។ចូរសាកល្បងជ្រើសយកឧទាហរណ៍មួយចំនួនដែលមានរូបភាពខុសគ្នាជាខ្លាំង។

៥. សួរសិក្ខាកាមនូវសំណួរឆ្លុះបញ្ចាំងដូចតទៅ៖

- *តើអ្នកមានអារម្មណ៍បែបណានៅពេលអនុវត្តសកម្មភាពនោះ ?*
- *តើអ្នកផ្តោតជាងគេលើអ្វី នៅពេលកំពុងស្តាប់សេចក្តីពិពណ៌នានោះ ?*
- *តើអ្នកចាប់ផ្តើមគូររូបនៅពេលណា និងតើអ្នកចាប់ផ្តើមពីអ្វីជាមុន ?*
- *តើអ្នកធ្វើការសន្មតអ្វីខ្លះ និងហេតុអ្វី ?*
- *តើគំនូររបស់អ្នកទាំងអស់គ្នាខុសគ្នាបែបណាខ្លះ និងហេតុអ្វី ?*
- *តើការបកស្រាយខុសៗគ្នាអំពីអ្វីមួយដែលអ្នកគ្រាន់តែបានឮកើតមានក្នុងស្ថានភាពជាក់ស្តែងដែរឬទេ និងហេតុអ្វី ?*

៦. ក្រោយធ្វើការឆ្លុះបញ្ចាំងចូរបង្ហាញរូបសត្វដំរីទឹកដល់សិក្ខាកាម។ ចូរពន្យល់ថា នេះគឺជាសត្វដែលអ្នកបានពិពណ៌នា។ បន្ទាប់មកចូរពន្យល់ថា មានសុភាសិតមួយ៖ រូបមួយបង្ហាញមួយពាន់អត្ថន័យ។" ចូរសង្កត់ធ្ងន់ថា សកម្មភាពខ្លីមួយនេះបង្ហាញថារូបភាពមួយអាចបញ្ជូនទិដ្ឋភាពនានានៃគោលគំនិតឬរឿងរ៉ាវមួយដែលមិនអាចធ្វើបានតាមរយៈការនិយាយ។ ការរួមបញ្ចូលភាសានិយាយ និងការមើលឃើញជាមួយគ្នា នៅក្នុងដំណើរការណាមួយនឹងបង្កើតភាពចងចាំ និងការរំលឹកឡើងវិញ។



៧. សូមស្នើសិក្ខាកាម ឱ្យចាប់គូ និងពិភាក្សាបំផុសគំនិតអំពី ហេតុអ្វីការបង្កើតរូបភាពមានសារៈសំខាន់ នៅក្នុងដំណើរការបង្កើតការចូលរួម(អាចដេញដោលការសន្មត និងការ

យល់ឃើញនានា ចូរបង្កើតការតភ្ជាប់ និងជំរុញភាពរំជួលចិត្តត្រូវផ្តោតលើរឿងដោយឡែកផ្ទាល់ខ្លួនជួយបំភ្លឺ និងពន្យល់អំពីគោលគំនិត ជួយបកស្រាយពាក្យក្រោមភាសា បង្កើតការយោគយល់គ្នា ជួយបង្កើតចក្ខុវិស័យរួម និងសម្រួលដល់ការស្រមៃ)។

៨. ចូរពង្រឹងការពិភាក្សាតាមក្រុម ដោយបន្ថែមការពន្យល់របស់អ្នកដែលស្រង់ពីឯកសារអំណាន និងសូមផ្តល់ឧទាហរណ៍។ ចូរពន្យល់គោលគំនិតអំពីខួរក្បាលខាងឆ្វេងនិងខាងស្តាំ និងមុខងាររបស់ដែលផ្នែកម្ខាងៗត្រួតត្រាមកលើមនុស្ស។ ចូរពន្យល់ថា ការបង្កើតរូបភាព អាចជួយមនុស្សតភ្ជាប់គ្នា និងជាមួយបញ្ហានានា។ តាមធម្មតារហូតដល់ ៥០% នៃមនុស្សក្នុងក្រុមណាមួយក៏ដោយគឺជាអ្នកគិតតាមរូបភាព - ពួកគាត់គិត និងផ្សារភ្ជាប់ភាគច្រើនជាមួយរូបភាពនានា និងមិនមែនជាមួយពាក្យឡើយ ដោយសារពួកគាត់គិតច្រើនជាង តាមរយៈខួរក្បាលខាងស្តាំដែលត្រួតត្រាការវិភាគរូបភាព។

៩. ចូរពន្យល់ដល់ក្រុមនេះថា អ្នកនឹងអនុវត្តសកម្មភាពដើម្បីបង្កើតរូបភាព និងអនុវត្តជំនាញគូររូបងាយៗ។ សូមសួរទៅក្រុមនេះថា តើពួកគាត់ធ្លាប់ឮល្បែងវចនានុក្រមដោយរូបភាពឬទេ។

១០. បែងចែកក្រុមនេះជាពីរក្នុងចំនួនស្មើគ្នា។ ចូរពន្យល់អំពីគោលការណ៍នៃវចនានុក្រមរូបភាពអំពីការប្រែប្រួលអាកាសធាតុ ដែលមាននៅក្នុងលំហាត់។ ត្រូវប្រាកដថា អ្នកតាមដានម៉ោងនៅពេលសមាជិកណាម្នាក់ដល់វេន និងត្រូវរក្សាពិន្ទុ។ សមាជិកម្នាក់ៗគួរតែត្រៀមខ្លួនមកជំនួសពីអ្នកដែលត្រូវដល់វេនបន្ត ដើម្បីជៀសវាងភាពដាច់គ្នាវែងរវាងវេននៃពួកគាត់នៅក្រោយពេលដែលពួកគាត់បានគូររូប និងអស់ម៉ោង។

១១. ត្រូវឱ្យប្រាកដថា សមាជិកក្នុងក្រុមទាំងពីរមានវេនរបស់ខ្លួន ដោយសារសកម្មភាពនេះក៏ទាក់ទងនឹងការជំនះភាពមិនទុកចិត្តខ្លួនឯង នៅក្នុងជំនាញគូររូបងាយៗនេះផងដែរ។

១២. ក្រោយពីបានបញ្ចប់លំហាត់វចនានុក្រមដោយរូបភាពអំពីការប្រែប្រួលអាកាសធាតុរួចមក ចូរធ្វើការឆ្លុះបញ្ចាំងសកម្មភាពនេះ៖

- *តើអ្នកមានអារម្មណ៍បែបណា នៅពេលអនុវត្តសកម្មភាពនេះ និងតើអ្វីខ្លះធ្វើឱ្យអ្នកមានអារម្មណ៍បែបនោះ?*
- *តើវាងាយស្រួល ឬ លំបាកសម្រាប់អ្នក?*
- *តើអ្វីខ្លះជាការលំបាកសម្រាប់អ្នក នៅពេលអ្នកព្យាយាមគូររូបភាពអ្វីមួយ និងហេតុអ្វីទើបអ្នកមានការលំបាកបែបនោះ?*
- *តើអ្នកចាប់ផ្តើមគូរដោយរបៀបណា? តើអ្នកចាប់ផ្តើមពីអ្វី និងហេតុអ្វី?*

- *តើអ្នកតែងតែគូររូបភាពដោយផ្ទាល់ តាមលក្ខខណ្ឌដែលផ្តល់ឱ្យអ្នកឬអ្វី?*
- *តើអ្វីខ្លះដែលជួយអ្នកដើម្បីគិតអំពីអ្វីដែលត្រូវគូរ?*
- *តើអ្វីខ្លះជួយមនុស្សទាំងឡាយដើម្បីយល់អំពីគំនូររបស់អ្នក?*
- *តើអ្នកបានឃើញគំនូរងាយៗនៅក្នុងការពន្យល់ ឬ ការបង្ហាញបញ្ហា ឬ សំណួរញ៉ែកញ៉ាប់កម្រិតណា?*

**១៣.** ក្រោយការឆ្លុះបញ្ចាំង ចូរពន្យល់ថា ការជំនះឧបសគ្គរបស់បុគ្គលនានានៅក្នុងការគូររូបភាពងាយៗ អាចធ្វើបានតាមរយៈការអនុវត្ត ហើយគំនូរងាយៗ មិនដូចរូបភាពសាំញ៉ាំឡើយ។ ចូរសង្កត់ធ្ងន់ថា ការបង្កើតរូបភាព គឺជាភាសាមួយ និងថាសិក្ខាកាមអាចបង្កើតវចនានុក្រមរូបភាពរបស់ខ្លួន។ ចូរអនុវត្តការគូររូបខុសៗគ្នា ដោយប្រើប្រាស់សណ្ឋានងាយៗខុសគ្នាចំនួនប្រាំ។

**១៤.** បែងចែកលំហាត់គូររូបភាពដែលមាននៅក្នុងឯកសារ សម្រាប់អំណាន និងពន្យល់ឧទាហរណ៍ងាយៗ មួយចំនួនអំពីរបៀបគូរសណ្ឋាននានា។

**១៥.** ចូរពន្យល់ថា ដើម្បីបូកសរុបមេរៀននេះ អ្នកចង់ឱ្យក្រុមវចនានុក្រមតាមរូបភាពនីមួយៗ ធ្វើការពិភាក្សាបំផុសគំនិត អំពីបច្ចេកទេសបង្កើតរូបភាពចំនួនប្រាំ ដែលអាចប្រើប្រាស់នៅក្នុងដំណើរការបង្កើតការចូលរួមបែបច្នៃប្រឌិត។ ចូរពន្យល់ថា ឧទាហរណ៍ខ្លះៗមានប្រើប្រាស់រួចមកហើយនៅក្នុងវគ្គបណ្តុះបណ្តាលនេះ។ សូមឱ្យក្រុមនីមួយៗចំណាយពេល ៥នាទី ដើម្បីគិតអំពីឧទាហរណ៍ចំនួន ២៥ និងសរសេរនៅលើក្រដាសផ្ទាំងធំ។ ត្រូវប្រាកដថា ក្រុមនេះផ្តល់ហេតុផលតាំងពីដើមដំបូងអំពីពេលវេលាដែលផ្តល់ឱ្យដើម្បីពួកគាត់មិនបាត់បង់គំនិតរបស់ខ្លួន។ អ្នកត្រូវគ្រប់គ្រងពេលវេលាឱ្យហ្មត់ចត់។

**១៦.** ក្រោយរយៈពេល ៥នាទី សូមឱ្យក្រុមនេះពិនិត្យមើលរូបរបស់គ្នាទៅវិញទៅមក។ ចូរគូរផ្កាយ ដើម្បីគូសបញ្ជាក់អំពីគំនូរដែលមានលក្ខណៈខុសគេ។ ត្រូវប្រាកដថា សិក្ខាកាមយល់ពីគុណតម្លៃនៃការប្រើប្រាស់វិធីបង្កើតរូបភាពជាផ្នែកមួយនៃវិធីសាស្ត្រចូលរួម (ដូចជា កងចក្រផ្ទាល់ខ្លួន ដែលបានប្រើប្រាស់នៅក្នុងមេរៀនដំបូងស្តីពីការគិតដែលផ្អែកលើសម្បត្តិ) និងមិនត្រឹមតែសម្រាប់ការពន្យល់អ្វីមួយឡើយ។

**១៧.** ចូរធ្វើការឆ្លុះបញ្ចាំងជាមួយសិក្ខាកាមអំពីថា តើពួកគាត់ជួបប្រទះ ឬ ប្រើប្រាស់វិធីបង្កើតរូបភាពបានញឹកញាប់ប៉ុណ្ណា នៅក្នុងដំណើរការរបស់ពួកគាត់ផ្ទាល់ មិនត្រឹមតែក្នុងបទបង្ហាញប៉ុណ្ណោះទេ។ សូមសួរសិក្ខាកាមថា ហេតុអ្វីពួកគាត់គិតថា អ្នកសម្របសម្រួលភាគច្រើននៅថ្នាក់មូលដ្ឋានមិនប្រើប្រាស់ការបង្កើតរូបភាព។ ចូរពន្យល់ថា ការបង្កើតរូបភាពអាចជាឧបករណ៍ដ៏មានអានុភាពខ្លាំងក្លានៅពេលធ្វើការជាមួយក្រុមណាមួយ ដែលរាប់ចាប់ពីមន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាលរហូតដល់សមាជិកសហគមន៍។

១៨. ចូរធ្វើការបូកសរុបមេរៀននេះ និងគូសបញ្ជាក់ពីគុណតម្លៃនៃការបង្កើតរូបភាពថា សិក្ខាកាមបានកំណត់ឃើញពីមុនមកហើយ និងចូរបង្ហាញគន្លឹះសម្រាប់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានដែលមានក្នុងទំព័រចុងក្រោយនៃឯកសារសម្រាប់អំណាន។

---

## កំណត់ត្រារបស់គ្រូបង្វាត់

ប្រការសំខាន់គឺត្រូវឱ្យប្រាកដថា សិក្ខាកាមយល់ថា ការបង្កើតរូបភាពមានសារៈសំខាន់ សម្រាប់បង្កើតអារម្មណ៍ជាប់ជំពាក់ និងថាមពលនៅក្នុងក្រុម។ ពួកគាត់នឹងបានដឹងអំពីការប្រើប្រាស់តាមធម្មតានូវវិធីបង្កើតរូបភាព សម្រាប់ជួយពន្យល់បញ្ហា និងគោលគំនិតនានា ប៉ុន្តែពួកគាត់អាចមិនបានគិតអំពីបច្ចេកទេសបង្កើតរូបភាពដែលអាចបង្កើតការប្តេជ្ញារួម និងការជាប់ជំពាក់នៅក្នុងក្រុមឡើយ។ ពួកគាត់ក៏អាចផ្តោតលើការគូររូប ជាងប្រើប្រាស់សម្ភារៈរូបភាពខុសៗគ្នាពីប្រភពខុសគ្នាផងដែរ។

ពាក្យនានាដែលប្រើប្រាស់នៅក្នុងវចនានុក្រមដោយរូបភាពអំពីការប្រែប្រួលអាកាសធាតុអាចធ្វើឱ្យងាយស្រួល អាស្រ័យលើក្រុមខុសគ្នា។

# រូបភាពមួយតំណាងឱ្យមួយពាន់អត្ថន័យ





សត្វដំរីទឹក៖ សត្វមួយធាត់ខ្លាំងណាស់ ដែលមានដងខ្លួនធំមាំមួន ... វាមានជើងបួនរឹងប៉ឹងដែលនៅចុងជើងទាំងបួនមានម្រាមជាចំនួនគូ ... វាមានក្បាលមាំសំប៉ែត ភ្នែកតូចៗ ត្រចៀក និងរន្ធច្រមុះនៅពីលើក្បាល ... មាត់របស់វាធំ និងអាចបើកបានយ៉ាងទូលាយ ដោយមានអណ្តាតមួយរឹង ... វាមានកន្ទុយខ្លីតូចមួយ។

# ផ្គុំពាក្យតាមរូបភាពអំពីព្រៃឈើ និងការប្រែប្រួលអាកាសធាតុ

ជ្រើសរើសពាក្យដូចខាងក្រោមនេះ ដែលសមស្របសម្រាប់ក្រុមសិក្ខាកាមរបស់អ្នក។ ចូរសរសេរលើប័ណ្ណ ហើយមូរប័ណ្ណទាំងនោះ និងដាក់ទៅក្នុងប្រអប់ ឬថង់មួយ (មូរប័ណ្ណទាំងនេះ ដើម្បីសិក្ខាកាមមិនអាចមើលឃើញនៅពេលដែលសិក្ខាកាមទាញចេញមកក្រៅ)។

## គោលការណ៍នៃល្បែង

- សមាជិកម្នាក់ៗនៅក្នុងក្រុម ចាប់យកប័ណ្ណមួយសន្លឹក ប៉ុន្តែមិនអាចបង្ហាញទៅក្រុមរបស់ខ្លួន ឬ ក្រុមមួយទៀតឡើយ។ ពួកគាត់ត្រូវគូររូបមួយ ហើយក្រុមរបស់ពួកគាត់មានពេលមួយនាទី ដើម្បីរកពាក្យ ឬ ប្រយោគដែលតំណាងដោយរូបនោះ។
- ប្រសិនបើក្រុមរបស់ខ្លួនទាយត្រូវពាក្យនោះហើយ ពួកគាត់បានទទួលពិន្ទុមួយ។
- ប្រសិនបើមិនអាចទាយត្រូវទេ ត្រូវផ្តល់ឱកាសនេះទៅក្រុមមួយទៀត។ ប្រសិនបើក្រុមនោះទាយត្រូវ ពួកគាត់បានពិន្ទុមួយ។
- សមាជិកក្រុមនេះប្តូរវេនគ្នាដើម្បីគូរ ហើយសមាជិកដែលគូរ មិនអាចអនុញ្ញាតឱ្យនិយាយ ឬ ប្រើពាក្យនៅក្នុងដំណើរការបង្កើតរូបរបស់ខ្លួនឡើយ។

| | | |
|---|---|---|
| **កាបូនព្រៃឈើ** | REDD+ | **ការប្រែប្រួលអាកាសធាតុ** |
| **ការកាត់បន្ថយការប្រែប្រួលអាកាសធាតុដោយផ្អែកលើព្រៃឈើ** | **កាបូនដី** | **ការបញ្ចេញឧស្ម័ន** |
| **សម្រួបកាបូន** | **ការវាយតម្លៃជីវៈម៉ាសកាបូន** | **ឥណទានកាបូន** |
| **ផលផ្ទះកញ្ចក់** | **ស្រទាប់អូហ្សូន** | **ការឯកភាពដោយគ្មានការបង្ខំ និងទទួលដំណឹងជាមុន** |
| **កម្រិតយោង** | **ការប្រែប្រួលការប្រើប្រាស់ដី** | **សិទ្ធិលើកាបូន** |
| **ការបង់ថ្លៃដោយផ្អែកលើលទ្ធផល** | **ប្រព័ន្ធការពារសុវត្ថិភាពសង្គម និងបរិស្ថាន** | **ប្រព័ន្ធតាមដាន រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV)** |

# ការប្រើប្រាស់វិធីបង្កើតរូបភាពនៅក្នុងការជំរុញការចូលរួមដោយច្នៃប្រឌិត

### តើការបង្កើតរូបភាពជាអ្វី?

ការបង្កើតរូបភាព គឺជាការវិភាគគោលគំនិតទស្សនៈព័ត៌មាននិងចំណេះដឹងដែលអាចមើលឃើញតាមរយៈរូបថតរូបភាពទម្រង់ និងទំនាក់ទំនងនានា ដោយប្រើប្រាស់ផ្នែកមួយនៃខួរក្បាល ជាលក្ខណៈរូបារម្មណ៍ និងបែបច្នៃប្រឌិត។




មនុស្សប្រមាណ ៥០% លើពិភពលោក គឺជាអ្នកគិតតាមរូបភាព។ នេះមានន័យថា ពួកគាត់ច្រើនតែគិត និងវិភាគតាមរយៈរូបភាព។ ការបង្កើតរូបភាពប្រើប្រាស់ខួរក្បាល នៅភាគខាងស្តាំដែលផ្សារភ្ជាប់ទៅនឹងការរំភើប និងអារម្មណ៍។

### ហេតុអ្វីការបង្កើតរូបភាពគឺជាធាតុផ្សំដ៏សំខាន់សម្រាប់ជំរុញការចូលរួម?

ការបង្កើតរូបភាព គឺជាធាតុសំខាន់មួយសម្រាប់ដំណើរការនៃការចូលរួមដែលមានភាពជោគជ័យ ដោយសារវាជាឧបករណ៍មួយដើម្បីពង្រឹងភាពតជាប់ និងថាមពល ក្នុងចំណោមបុគ្គល និងបញ្ហានានា ព្រមទាំងរវាងក្រុម និងអ្នកពាក់ព័ន្ធនានា។ ក្រុម និងបុគ្គលនានាតែងតែមានវត្តមាន និងចូលរួមនៅក្នុងដំណើរការនានាដោយគ្មានការបង្កើតរូបភាព ប៉ុន្តែពួកគាត់មិនទំនងជាមានអារម្មណ៍ជាប់ជំពាក់ឡើយ។ ការបង្កើតរូបភាព និងការបង្កើតឡើងរួមគ្នា នូវការយល់ដឹងតាមរូបភាព ឬ ចក្ខុវិស័យរួម ជួយសមាជិកក្រុមនៅក្នុងការបង្កើតអារម្មណ៍ជាប់ជំពាក់ជាមួយគ្នាទៅវិញទៅមក។

### អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន អាចប្រើប្រាស់ការបង្កើតរូបភាពដើម្បី៖




- **បង្កើតការយល់ដឹងអំពីទម្រង់ និងអារម្មណ៍ជាប់ជំពាក់៖** ការប្រើប្រាស់ ប័ណ្ណ ឬ ក្រដាស Post-it ដើម្បីបង្ហាញពីអារម្មណ៍ជាប់ជំពាក់ជាក្រុម និងទំនាក់ទំនងនៅលើផ្ទាំងក្រដាសគឺ ជាទម្រង់មួយនៃការបង្កើតរូបភាព។ អារម្មណ៍ជាប់ជំពាក់បែបនេះច្រើនតែមិនអាចសម្រេចបានឡើយតាមរយៈត្រឹមបច្ចេកទេសផ្ទាល់មាត់។ តាមធម្មតានិងជាប្រពៃណីវេទិកាខ្លះៗច្រើនប្រើប្រាស់សេចក្តីសង្ខេបនៅចុងនៃថ្ងៃនីមួយៗ ដែលមិនបានបង្ហាញឱ្យឃើញជារូបភាព

ឡើយ។ ការរំលឹកឡើងវិញ និងភាពចងចាំសេចក្ដីសង្ខេបបែបនេះ មិនទំនងជាបានល្អដូចការសង្ខេបដែលធ្វើឡើងជាក្រុម និងការដាក់តាំងបង្ហាញតាមទម្រង់ច្បាស់លាស់ ឬ ជាក្រុមនោះឡើយ។

- **ការប្រឈមនឹងការសន្មត និងការយល់ឃើញ៖** ការប្រើប្រាស់រូបភាព ផ្ដល់ឱកាសឱ្យមានការពិភាក្សានៅក្នុងក្រុម។ ពាក្យនីមួយៗអាចមានន័យខុសគ្នាចំពោះមនុស្សខុសគ្នា ហើយការប្រើប្រាស់រូបភាពអាចបង្ហាញអំពីការសន្មតនានាដែលពុំបានបង្ហាញឱ្យដឹងពីមុនមក។

- **បង្កើតអារម្មណ៍ជាប់ជំពាក់ និងការធ្វើឱ្យរំជួលចិត្ត៖** ជាទូទៅ មនុស្សអាចសំដែងអារម្មណ៍របស់ខ្លួនតាមរូបភាពបានល្អជាងតាមពាក្យសំដី។ ការស្នើឱ្យសិក្ខាកាមគូរអំពី អារម្មណ៍របស់ពួកគាត់ថតរូប ឬ ជ្រើសរើសរូបភាពមួយពីសម្ភារៈនានា ដែលមាននៅក្នុងមូលដ្ឋានអាចផ្ដល់ឱ្យពួកគាត់នូវការលើកទឹកចិត្ត និងទំនុកចិត្តក្នុងការសំដែងអំពីខ្លួនឯង និងកម្រិតអារម្មណ៍ទាំងចំពោះបញ្ហានានា និងជាមួយមនុស្សនានាផងដែរ។

- ចូរផ្ដោតលើសាច់រឿងដោយឡែករបស់បុគ្គល។ ជាញឹកញាប់ សាច់រឿងនានាបង្កើតឱ្យមានរូបភាព និងអារម្មណ៍ជាប់ជំពាក់ជាលក្ខណៈបុគ្គល។ ការស្នើក្រុម និងបុគ្គលនានាឱ្យនិទានរឿងតាមរយៈបច្ចេកទេសបង្កើតរូបភាព ជួយពួកគាត់ឱ្យផ្ដោតលើកាលៈទេសៈសំខាន់ៗ និងអារម្មណ៍ជាងលើសេចក្ដីពិស្ដារផ្សេងទៀត ដែលអ្នកដទៃអាចពុំមានអារម្មណ៍ជាប់ជំពាក់ជាមួយ។

- ចូរបញ្ជូលគោលគំនិត និងពន្យល់ពាក្យគ្រាមភាសា។ ការយល់ខុសជាច្រើន និងគំនិតខុសៗគ្នានៅក្នុងគោលគំនិតជាក់លាក់ណាមួយ ឬ ពាក្យណាមួយ អាចបង្កើតជាឧបសគ្គនៅក្នុងដំណើរការចូលរួម។ ជាញឹកញាប់ ប្រការនេះកើតឡើងដោយសារការពឹងផ្អែកខ្លាំងហួសហេតុលើបច្ចេកទេសផ្ទាល់មាត់។ ការដេញដោលក្រុម ឬ បុគ្គលនានា ដើម្បីដកស្រង់ ឬ បង្ហាញពីការយល់ដឹងរបស់ពួកគាត់អំពីពាក្យមួយតាមរយៈរូបភាព និងបន្ទាប់មកចែករំលែក ដោយចំហអាចផ្ដល់ឱកាសសម្រាប់ការឯកភាពយល់គ្នាកាន់តែច្បាស់ និងយល់អំពីពាក្យ និងគោលគំនិត។

- បង្កើតការយោគយល់៖ ការបង្កើតរូបភាព អាចបំបែកឧបសគ្គនានានៅពេលដែលក្រុមមួយមានទស្សនៈខុសគ្នាប៉ុន្តែឥតប្រែប្រួល។ តាមធម្មតា ក្រុមនានាទំនងបំផុតថា មើលឃើញទម្រង់នានា និងការព្រមព្រៀងរួមគ្នាទៅតាមហេតុផលរបស់ពួកគាត់ នៅពេលប្រើប្រាស់ការបង្កើតរូបភាព។ ការបង្កើតរូបភាពក៏អាចបង្ហាញឱ្យឃើញពីភាពខុសគ្នានៃគំនិត ការយល់ ឃើញការគិត ឬ ទស្សនៈ ដែលមនុស្សនានានៅពុំទាន់បានស្គាល់នៅឡើយផងដែរ។ នេះក៏អាចជាករណីមួយផងដែរសម្រាប់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន។

- សម្រួលឱ្យមានការស្រមៃនិងបង្កើតចក្ខុវិស័យរួមគ្នាមួយ៖ ការបង្ហាញពីសុបិននិងលទ្ធភាពនានាសម្រាប់អនាគតទាមទារឱ្យមានការបង្កើតក្ដីស្រមៃ និងទាមទារឱ្យក្រុមមនុស្សងាកចេញពីក្របខ័ណ្ឌនៃការគិតតាមរបៀបបច្ចុប្បន្ន។ការប្រើប្រាស់រូបភាពនិងការបង្កើតរូបភាពគឺជាបច្ចេកទេសដ៏មានអានុភាពមួយសម្រាប់បញ្ហានេះ។ មនុស្សទូទៅទំនងជាមានសេរីភាពក្នុងការបង្កើតក្ដីស្រមៃរបស់ខ្លួន នៅពេលវិភាគរូបភាពពិត ឬរូបគែច្នៃរបស់ពួកគាត់ ជាងតាមរយៈពាក្យសំដី។

## គន្លឹះសម្រាប់ការបង្កើតរូបភាព សម្រាប់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន




- **ជឿលើវិធីនេះ:** និងបង្កើតទំនុកចិត្តផ្ទាល់ខ្លួនលើការបង្កើតរូបភាព ដើម្បីទទួលអារម្មណ៍ពីអានុភាពរបស់វា។
- ធ្វើឱ្យ**ងាយ** និងដោយ**ក្លាហាន**។
- **បង្កើតចក្ខុវិស័យរួមគ្នា** ជាមួយក្រុមមួយ ដែលជាផ្នែកមួយនៃដំណើរការសម្របសម្រួល។
- ប្រើប្រាស់អ្វី**ដែលមាន** ដូចជារូបគំនូរងាយៗ រូបសិល្បៈវិមាត្រ បី រូបថត ទស្សនាវដ្តី សារព័ត៌មាន ប័ណ្ណ ការវេចខ្ចប់ផលិតផល។
- ប្រើប្រាស់វាជា**បន្ត និងមិនមែនធ្វើតែមួយលើកឡើយ** ដើម្បី**បង្កើតអារម្មណ៍តភ្ជាប់គ្នា**ជាប្រចាំ និងពង្រឹងស្ថានភាពដែលអ្នកសម្រេចបានរួចមកហើយ។
- ធានាថា មានការតាំងបង្ហាញ និងបានពិនិត្យឡើងវិញ ដែលជាផ្នែកមួយនៃដំណើរការបង្កើតការចូលរួមរបស់អ្នក។
- គិតអំពីការសម្រួលឱ្យមានគំហើញ និង**រៀបចំបង្កើតលំហ**ដែលអ្នកប្រើប្រាស់សម្រាប់សកម្មភាពជាក្រុមដោយព្យួររូបភាពធំ ដែលបង្ហាញពីភាពក្លាហាននៅលើជញ្ជាំង **ការបង្កើត**ច្រកទ្វារនៃក្តីស្រមៃ ឬ សូម្បីតែស្លៀកពាក់ និងតែងខ្លួន ដែលធ្វើឱ្យអ្នកផងគិត និងចាប់អារម្មណ៍អំពីអ្វីដែលខុសពីមុន និងមាន**សេរីភាពក្នុងការគិត** និងការប្រព្រឹត្តក្នុងនាមខ្លួនឯង។
- កាលណាអ្នក**មានការយល់ដឹងកាន់តែច្រើន** អំពីវិធីដែលអ្នកបង្កើតរូបភាពប្រកបដោយទំនុកចិត្ត ក្នុងនាមជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ក្នុងករណីនោះសិក្ខាកាមកាន់តែតិចដែលយល់អំពីខ្លួនឯងកាន់តែនឹងមានអារម្មណ៍ថា ជាផ្នែកមួយនៃសកម្មភាពបង្កើតរូបភាព។

# ច. អនុវត្តជំនាញពន្យល់

**គោលបំណងនៃការរៀនសូត្រ** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងៈ

- កំណត់ឃើញសំណួរជាច្រើន ស្តីពីការលើកកម្ពស់សមធម៌ និងការចូលរួម
- អាចអធិប្បាយគោលការណ៍នៃការពន្យល់ងាយៗ និង
- អនុវត្តជំនាញចម្រុះ ក្នុងការរួមបញ្ចូលជំនាញនៃការផ្តល់សេចក្តីពន្យល់ងាយៗ និងច្បាស់លាស់ដើម្បីឆ្លើយតបនឹងសំណួរមួយស្តីពីការលើកកម្ពស់សមធម៌ និងការចូលរួម ព្រមទាំងបានទទួលចម្លើយតបផងដែរ។

**សម្ភារៈ** ក្រដាសផ្ទាំងធំ ហ្វឺត ប៉័ណ្ណ ក្រដាស Post-it ឧទាហរណ៍នៃវីដេអូមួយស្តីពី REDD+ ទស្សនាវដ្តី សារព័ត៌មាន សំណួរចំនួនបួន ឬប្រធានបទដែលបានបង្កើតឡើងនៅចុងវគ្គបណ្តុះបណ្តាលលើកមុនក្នុងថ្ងៃទទួលយោបល់តប និង ឯកសារសម្រាប់អំណាន។

**រយៈពេល** ផ្នែកទីមួយ ៖ ៦០ នាទី
ផ្នែកទីពីរ៖ ៦០ នាទី

---

## ជំហានអនុវត្ត

### ផ្នែកទីមួយ

១. បង្ហាញជូនមេរៀននេះ ដោយពន្យល់ថា វគ្គនេះត្រូវបានចែកចេញជាពីរផ្នែក និងមានគោលដៅអនុវត្តមុខងារជាគ្លីនិកសម្រាប់ការចូលរួម ជាមួយវិធីដ៏រីករាយ។ ចូរគូសបញ្ជាក់ថា មេរៀននេះក៏នឹងស្វែងយល់ផងដែរអំពីជំនាញពន្យល់ងាយៗ (យោងត្រឡប់ទៅផ្ទះ៖ ជំនាញជំរុញការចូលរួមបែបច្នៃប្រឌិត) និងរួមបញ្ចូលជំនាញទាំងនេះជាមួយជំនាញដទៃទៀតរបស់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន។

២. ចូរពន្យល់ថា ផ្នែកទាំងពីរនឹងត្រូវចែករវាងពេលព្រឹក និងរសៀល។ ផ្នែកសម្រាប់ពេលព្រឹកនឹងផ្តោតលើការពន្យល់នានានិងអំពីរបៀបបំបែកគោលគំនិតឱ្យងាយយល់ និងបន្ទាប់មកសិក្ខាកាមនឹងរៀបចំសម្រាប់ការត្រៀមបង្ហាញជាក្រុមនៅពេលរសៀល។

៣. ចូរគូសបញ្ជាក់ថា ការផ្តោតនៃវគ្គក្នុងមេរៀននេះគឺ លើជំនាញពន្យល់។ សូមសួរសិក្ខាកាម តើពួកគាត់អាចប្រាប់អ្នកបានទេថា តើពួកគាត់យល់យ៉ាងណាដែរចំពោះពាក្យ “ការពន្យល់”។ ចូរសរសេរចម្លើយរបស់ពួកគាត់លើក្រដាសផ្ទាំងធំ។

៤. បង្ហាញថាពាក្យ “ពន្យល់” មានន័យថា “ធ្វើឱ្យដឹងធ្វើឱ្យងាយធ្វើឱ្យស្រួលយល់”។ ចូរបន្តដោយគូសបញ្ជាក់ថា ការពន្យល់មួយអធិប្បាយអំពីការណ៍ពិតតាមវិធីដែលធ្វើឱ្យងាយយល់បាន។ វាជួយក្រុមនៃបុគ្គលទាំងនេះមើលឃើញអ្វីៗច្បាស់លាស់ ឬ បង្ហាញវត្ថុនានាជាកញ្ចប់ដែលអាចយល់បាន។ ចូរគូសបញ្ជាក់ថា ការធ្វើបែបនេះទាមទារឱ្យមានកម្រិតនៃការយល់ចិត្តដែលផ្តោតលើអ្នកស្តាប់ ឬបុគ្គលដែលត្រូវការសេចក្តីពន្យល់។

៥. ចូរបង្ហាញវីដេអូដែលមានសកម្មភាពពន្យល់ងាយៗអំពី REDD+។ នៅចុងវីដេអូនេះ សូមសួរសិក្ខាកាមនូវសំណួរឆ្លុះបញ្ចាំងដូចតទៅ៖

- *តើវីដេអូនេះព្យាយាមពន្យល់អំពីអ្វី និងហេតុអ្វី?*
- *តើអាចយល់បានកម្រិតណា បើចាត់តាមមាត្រដ្ឋានពី ១ ដល់ ១០?*
- *តើកត្តាអ្វីខ្លះដែលធ្វើឱ្យការពន្យល់នេះងាយស្រួលយល់?*
- *តើបរិបទនៃការពន្យល់នេះដូចម្តេចដែរ?*
- *តើអ្វីខ្លះដែលធ្វើឱ្យកាន់តែលំបាកយល់?*
- *តើយើងអាចរៀនបានអ្វីខ្លះពីវីដេអូនេះអំពីការពន្យល់អ្វីមួយ?*

៦. ស្នើឱ្យក្រុមនេះពិភាក្សាបំផុសគំនិតជាមួយគ្នាពីរៗនាក់ ដើម្បីស្វែងរកចម្លើយតបនឹងសំណួរនេះ។ តើខ្ញុំក្នុងនាមជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន អាចធ្វើបែបណាដើម្បីពន្យល់អ្វីមួយឱ្យងាយ?

៧. ក្រោយរយៈពេលប្រាំនាទី ត្រូវបញ្ឈប់គូទាំងនេះ និងសួរគូនីមួយៗឱ្យប្រាប់ចម្លើយ។ សូមសរសេរចម្លើយរបស់ពួកគាត់នៅលើក្រដាសផ្ទាំងធំ។ ចូរគូសបញ្ជាក់ថា ការពន្យល់អ្វីមួយឱ្យបានច្បាស់គឺជាការបំបែកវាជាផ្នែកតូចៗ និងការពន្យល់ពីថាហេតុអ្វីវាមានន័យបែបនោះនៅក្នុងបរិបទនៃអ្នកស្តាប់នោះ។ ការយកចិត្តទុកដាក់គួរតែផ្តោតលើហេតុអ្វី និងក្រុមអ្នកស្តាប់ជាក់លាក់។ ចូរប្រើប្រាស់គន្លឹះនៅក្នុងឯកសារសម្រាប់អំណាន (ប៉ុន្តែពុំត្រូវចែកក្នុងពេលនេះទេ) ដើម្បីផ្តល់ការណែនាំដល់រូបអ្នកអាស្រ័យលើចម្លើយរបស់សិក្ខាកាម។

៨. សូមសួរសិក្ខាកាមហេតុអ្វីពួកគាត់គិតថាការពន្យល់ជាច្រើនមិនបានផល (ការសន្មត លាក់កំបាំងនៅពីក្រោយពាក្យ កង្វះការយល់ដឹងរបស់ខ្លួនយើងផ្ទាល់ ចង់ឱ្យគេឃើញថាឈ្លាសវៃ គ្មានបរិបទ ស្មុគស្មាញពេក)។

៩. ចូរបែងចែកសិក្ខាកាមជាក្រុមដែលមានចំនួនស្មើគ្នា និងផ្ដល់ឱ្យក្រុមនីមួយៗនូវសំណួរមួយដែលបង្កើតឡើងដោយសិក្ខាកាមនៅក្នុងចម្លើយតបក្នុងមេរៀនថ្ងៃមុន។ ចូរពន្យល់ថា កិច្ចការរបស់ក្រុមនីមួយៗគឺរៀបចំការពន្យល់ងាយមួយ ដើម្បីឆ្លើយបានច្បាស់លាស់ចំពោះអ្វីដែលអាចឱ្យមនុស្សគ្រប់រូបយល់បាន សូម្បីតែកុមារ។ ពួកគាត់គួរតែគ្រោងជាមុន និងរៀបចំសេចក្ដីពន្យល់ ដោយគិតថាតើធ្វើបែបណាដើម្បីឱ្យមានទម្រង់ងាយ និងរួមបញ្ចូលជំនាញដទៃទៀត ដូចជា ការបង្កើតរូបភាព។

១០. ចូរពន្យល់ថា ក្រុមនីមួយៗមានពេល ៥នាទី ដើម្បីផ្ដល់ការពន្យល់ងាយៗ និងច្បាស់លាស់ ក្នុងទម្រង់ជាចម្លើយតបនឹងសំណួរដែលពួកគាត់បានទទួល ហើយពួកគាត់គួរប្រើប្រាស់ពេលដែលនៅសល់ក្នុងមេរៀននេះ ដើម្បីរៀបចំ (៣០នាទី)។ ចូរចែកឯកសារអំណាន និងស្នើពួកគាត់ឱ្យគិតអំពីជំហាននានាដូចតទៅដើម្បីធានាថា ពួកគាត់ផ្ដល់សេចក្ដីពន្យល់ដោយប្រសិទ្ធភាព និងរួមបញ្ចូលជំនាញដទៃទៀត ដូចជា ការបង្កើតរូបភាព និងការនិទានរឿង ដែលពួកគាត់បានរៀននៅក្នុងវគ្គនេះ។

១១. ចូរពន្យល់ថា នៅក្នុងមេរៀនគ្លីនិកនាពេលរសៀល ពួកគាត់នឹងត្រូវបង្ហាញចម្លើយរបស់ខ្លួន ដោយប្រើប្រាស់សម្ភារៈនានា ដែលពួកគាត់បានរៀបចំ។ ត្រូវបញ្ជាក់ជាមួយក្រុមនេះឱ្យច្បាស់ថា នេះជាលំហាត់អំពីការពន្យល់។ នៅក្នុងស្ថានភាពនេះ ពួកគាត់ពុំចាំបាច់សម្រួលឱ្យមានការចូលរួមទេ ប៉ុន្តែគ្រាន់តែរិះរកវិធីមួយ ដើម្បីធ្វើឱ្យចម្លើយមានភាពច្បាស់លាស់ប៉ុណ្ណោះ។



**ផ្នែកទីពីរ**

១. ចាប់ផ្ដើមផ្នែកទីពីរនៃមេរៀននេះដោយ ស្នើឱ្យសិក្ខាកាមទាំងអស់អង្គុយជារង្វង់។ រំលឹកក្រុមនេះអំពីសំណួររបស់ពួកគាត់កាលពីថ្ងៃមុន។

២. ស្នើក្រុមអ្នកពន្យល់ឱ្យចេញមកខាងមុខ ម្នាក់ម្ដងៗតាមលំដាប់លំដោយ អាស្រ័យលើសំណួរដែលពួកគាត់បានបែងចែក។

៣. សូមសួរក្រុមអ្នកពន្យល់នីមួយៗ ឱ្យបង្ហាញសំណួរដែលពួកគាត់បានទទួលកាលពីថ្ងៃមុនឱ្យបានច្បាស់លាស់ មុននឹងចាប់ផ្ដើមការពន្យល់។

៤. ក្រុមនីមួយៗមានរយៈពេល ៥នាទី។ បន្ទាប់មកបើកឱកាសសម្រាប់អ្នកដទៃទៀតក្នុងចំណោមសិក្ខាកាមឱ្យសួរសំណួរអំពីបញ្ហាចំពោះមុខ និងសុំឱ្យក្រុមអ្នកពន្យល់ធ្វើការឆ្លើយតប។

៥. នៅចុងនៃការពន្យល់ទាំងអស់ ស្នើឱ្យសិក្ខាកាមទាំងអស់ធ្វើការឆ្លុះបញ្ចាំងអំពីដំណើរការពន្យល់ដោយប្រើប្រាស់សំណួរដូចតទៅ៖

- *តើសេចក្តីពន្យល់ណាខ្លះដែលច្បាស់ជាងគេ និងងាយស្រួលជាងគេសម្រាប់អ្នក និងហេតុអ្វី?*
- *តើអ្វីខ្លះជួយអ្នកនៅក្នុងការពន្យល់?*
- *តើអ្វីខ្លះរារាំងការពន្យល់របស់អ្នក?*
- *តើអ្នករៀបចំដំណើរការពន្យល់របស់អ្នកដូចម្តេច?*
- *តើនៅពេលណាដែលអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានប្រើប្រាស់ជំនាញពន្យល់?*
- *ហេតុអ្វីចាំបាច់ត្រូវធ្វើការពន្យល់ឱ្យមានលក្ខណៈងាយ និងអាចយល់បានសម្រាប់ទាំង អស់គ្នា?*
- *តើមានការលំបាកអ្វីខ្លះ ក្នុងការរក្សាសេចក្តីពន្យល់ឱ្យងាយ នៅក្នុងស្ថានភាពដែលមានអ្នកពាក់ព័ន្ធខុសៗគ្នាច្រើន?*
- *តើការពន្យល់បានល្អត្រូវការជំនាញអ្វីខ្លះ?*

៦. សូមសួរសិក្ខាកាមថា តើពួកគាត់មានសំណួរដែលនៅពុំទាន់បានឆ្លើយឬទេ និងត្រូវបញ្ជាក់ឱ្យច្បាស់ថា នៅក្នុងគ្លីនិកនៃការពន្យល់ស្តីពីការលើកកម្ពស់សមធម៌ក្នុងអន្តរាគមន៍ REDD+។ ចូរបញ្ជាក់ឱ្យច្បាស់ថា សិក្ខាកាមដទៃទៀតត្រូវបំភ្លឺ ក្នុងករណីចាំបាច់។

៧. សូមបូកសរុបមេរៀននេះដោយសង្កត់ធ្ងន់ថា ភាពច្បាស់លាស់ និងភាពងាយយល់ គឺជាតម្លៃស្នូលនៃការពន្យល់បានល្អ ដូច្នេះវាគួរតែបានបញ្ចូលជាមួយការប្រាស្រ័យទាក់ទងបានល្អ ការបង្កើតរូបភាព និងការនិទានរឿង។

---

## កំណត់សំគាល់របស់គ្រូបង្ហាត់

ចូរប្រើប្រាស់វីដេអូដែលមានរូបភាពងាយៗដែល សូម្បីតែសិក្ខាកាមណាម្នាក់ក៏អាចបង្កើតបានដែរ។ សូមអានឧទាហរណ៍ក្នុង៖ www.youtube.com/watch?v=-dnL0OTdmLY&list=PL3EC96F2A7354BFBB ឬ http://cc.commoncraft.com/video-train ។

អ្នកអាចគ្រោងសម្រាប់ក្រុមជាច្រើន និងសំណួរជាច្រើនទៅតាមពេលវេលាដែលមាន។ សម្រាប់ការអនុវត្តជំនាញ និងចម្លើយតប គេអាចត្រូវការឱ្យមានក្រុមជាច្រើនដើម្បីសិក្ខាកាមគ្រប់រូបអាចចូលរួម និងទទួលខុសត្រូវលើការពន្យល់។

ចំណុចនានាដូចខាងក្រោមនេះ ផ្តល់នូវសំណួរខ្លះៗ ដែលអាចផ្តល់ជាកិច្ចការសម្រាប់ការពន្យល់។ ចំណុចទាំងនេះត្រូវបានរួមបញ្ចូលគ្រាន់តែសម្រាប់បង្ហាករណីដែលត្រូវការតែប៉ុណ្ណោះ។ ជាការប្រសើរប្រសិនបើសំណួរបានមកពីសិក្ខាកាម។

- តើធ្វើបែបណាទើបយើងអាចធានាឱកាស "ស្មើគ្នា" នៅក្នុងដំណើរការជំរុញការចូលរួម និងបញ្ចៀសការទាញយកផលប្រយោជន៍ដោយក្រុមវរជនទទ្ទឹមនឹងធ្វើឱ្យប្រាកដថា សម្លេងរបស់ជនទន់ខ្សោយដែលរួមទាំងស្ត្រី និងយុវជនត្រូវបានគេយកចិត្តទុកដាក់ស្តាប់?
- ធ្វើយ៉ាងណាទើបជំរុញសមធម៌ឱ្យឈានហួសពីគោលការណ៍នៃប្រព័ន្ធការពារសុវត្ថិភាព?
- និន្នាការនៃការឈានត្រឡប់ទៅកេក្របខ័ណ្ឌមជ្ឈការនៃការគ្រប់គ្រងព្រៃឈើ អាចធ្វើឱ្យខូចទឹកចិត្តនៃសមធម៌នៅក្នុងការចូលរួមនៅថ្នាក់មូលដ្ឋាន ដូច្នេះ តើយើងអាចធ្វើអ្វីបានអំពីបញ្ហានេះ?
- តើយើងធ្វើបែបណា ដើម្បីដោះស្រាយបញ្ហានៃការចូលរួមរបស់អ្នកពាក់ព័ន្ធដែលមានឥទ្ធិពលដូចជាវិស័យឯកជន នៅក្នុងដំណើរការនេះ?
- តើយើងធ្វើបែបណា ដើម្បីបង្កើតឆន្ទៈ ក្នុងការលើកកម្ពស់សមធម៌ ក្នុងចំណោមអ្នកពាក់ព័ន្ធនានា?
- នៅពេលធ្វើការគ្រប់គ្រងធនធានធម្មជាតិ តើអ្វីខ្លះជាតួនាទីរបស់គោលនយោបាយ និងដំណើរការគោលនយោបាយនៅក្នុងការបង្កើតឱកាសស្មើគ្នា សម្រាប់សហគមន៍អ្នកទន់ខ្សោយ?
- តើសមធម៌បង្ហាញរូបភាពបែបណានៅក្នុងដំណើរការនៃការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព?
- តើមានភាពខុសគ្នាអ្វីខ្លះរវាងសមធម៌ និងសមភាព?
- តើការចូលរួម និងសមធម៌ មានការផ្សារភ្ជាប់គ្នាបែបណា?

សូមចាំថា កិច្ចការរបស់ក្រុមនេះគឺពន្យល់ចម្លើយតបទៅនឹងសំណួរមួយ និងមិនមែនធ្វើឱ្យសំណួរនេះងាយយល់បាននោះឡើយ។ ការធ្វើបែបនេះនឹងអាចឱ្យអ្នកវាយតម្លៃកម្រិតនៃការយល់ដឹង ឬ ការយល់ច្រឡំ ក្នុងចំណោមសិក្ខាកាម អំពីបញ្ហាជាក់លាក់នានានៅក្នុងវគ្គបណ្តុះបណ្តាល ហើយទន្ទឹមនឹងនេះត្រូវលើកទឹកចិត្តពួកគាត់ឱ្យអនុវត្តជំនាញពន្យល់របស់ពួកគាត់។



# គន្លឹះសម្រាប់ការពន្យល់ងាយៗ

## តើការពន្យល់មួយបានល្អ អាស្រ័យលើអ្វីខ្លះ?

យើងប្រហែលជាពន្យល់អ្វីមួយដល់អ្នកណាម្នាក់ជារៀងរាល់ថ្ងៃតាមវិធីខុសៗគ្នា - រហូតដល់កម្រិតមួយដែលយើងស្មានថា អ្វីមួយទើបតែបានកើតឡើង។ វាជារឿងកម្រក្នុងការពិចារណា ឬធ្វើឱ្យមានការពន្យល់មួយយ៉ាងមានប្រសិទ្ធភាព។

ពាក្យថា "ការពន្យល់" អាចបំបែកដើម្បីឱ្យឃើញថា ខ្លឹមសារស្នូលរបស់វាមានលក្ខណៈសាមញ្ញ។ តើធ្វើបែបណាដើម្បីឱ្យអ្វីមួយមានលក្ខណៈងាយ និងច្បាស់លាស់តាមតែអាចធ្វើបានសម្រាប់អ្នកទទួល។ ដូច្នេះ ការពន្យល់គឺធ្វើឱ្យអ្វីមួយអាចយល់បានចំពោះបុគ្គល ឬ ក្រុមមួយផ្សេងទៀត។

## តើហេតុអ្វីការពន្យល់ភាគច្រើនមិនបានផល?

ការអប់រំស្ថានភាពវិជ្ជាជីវៈ និងអំណាចមានឥទ្ធិពលមកលើរបៀបដែលបុគ្គល និងក្រុមនានាធ្វើទំនាក់ទំនងជាមួយគ្នានៅក្នុងបរិបទជាក់លាក់។ ដោយសារអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានមានតួនាទីមួយ ដើម្បីបង្កើនលទ្ធភាពទទួលបានព័ត៌មាន និងកសាងសមត្ថភាពរបស់ក្រុមអ្នកទន់ខ្សោយដើម្បីពួកគាត់អាចចូលរួមកាន់តែស្មើគ្នា ការផ្តល់សេចក្តីពន្យល់ងាយៗក្លាយជាជំនាញជាក់លាក់មួយប៉ុន្តែវាជាប្រការចាំបាច់។ នេះជាប្រការចាំបាច់សម្រាប់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ប៉ុន្តែក៏សម្រាប់អ្នកជំនាញ ឬ គ្រូបង្ហាត់ដែលធ្វើការជាមួយសហគមន៍ ឬ ក្រុមអ្នកទន់ខ្សោយផងដែរ។ ការដែលអាចជ្រើសរើសអ្នកជំនាញដែលមានជំនាញក្នុងការពន្យល់មានសារៈសំខាន់ណាស់។ វាមិនគ្រប់គ្រាន់ទេដែលបានគ្រាន់តែពេញចិត្តចំពោះគុណវុឌ្ឍិ (គុណសម្បត្តិ) ឬសាវតាខាងការងាររបស់អ្នកណាម្នាក់ ប្រសិនបើពួកគាត់មិនអាចពន្យល់អ្វីមួយបានច្បាស់លាស់ និងដោយងាយស្រួលយល់នោះ។

## មូលហេតុខ្លះៗដែលធ្វើឱ្យការពន្យល់មិនបានជោគជ័យ

**ការសន្មត៖** នៅក្នុងគ្រប់ការពន្យល់ មានការសន្មតអំពីកម្រិតទំនុកចិត្ត នៃក្រុមគោលដៅ។ នៅក្នុងក្រុមមួយ អ្នកខ្លះអាចដឹងច្រើនជាងអ្នកដទៃទៀត។ ការពន្យល់នានាច្រើនតែបរាជ័យ និងបន្តឱ្យមានការយល់ខុស ដោយសារតែការសន្មតអំពីការយល់របស់អ្នកណាម្នាក់អំពីគោលគំនិតងាយៗ ឬ ពាក្យបំព្រួញ។ ហេតុផលមួយក្នុងចំណោមហេតុផលនានាគឺ គោលគំនិតខ្លះត្រូវបានបន្តប្រាស្រ័យទាក់ទងទាំងការយល់ខុស គឺដោយសារតែខ្លឹមសារនៃគោលគំនិតនេះមិនមានការពន្យល់បានច្បាស់លាស់។

**វប្បធម៌នៃភាសា៖** គ្រប់មុខជំនាញវិជ្ជាជីវៈច្រើនតែប្រើគ្រាមភាសា និងពាក្យបំព្រួញ។ ជួនកាលនៅក្នុងក្រុមមួយ គេអាចសន្មតចំណេះដឹងមួយអំពីវាក្យស័ព្ទនោះដោយពុំមានបញ្ហា ចំណែកនៅក្នុងក្រុមដទៃទៀត វាមិនអាចធ្វើទៅកើតទេ។ ជាញឹកញាប់ សមាជិកក្រុម និងអ្នកសម្របសម្រួលនានាប្រើប្រាស់ពាក្យនានាជាការបិទបាំងនូវការយល់ដឹងអំពីគោលគំនិតសាំញ៉ាំដែលពួកគាត់យល់មិនបានពេញលេញ។ ឧទាហរណ៍ មានវាក្យស័ព្ទជាក់លាក់ជាច្រើនដែលប្រតិបត្តិករខាងការប្រែប្រួលអាកាសធាតុប្រើប្រាស់។

វាក្យស័ព្ទនេះមិនមែនងាយស្រួលយល់ឡើយសម្រាប់សាធារណជនទូទៅ ឬ សូម្បីតែមន្ត្រីរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន ហើយវាមានវិសាលភាពក្នុងកម្រិតកំណត់។

**ភាពឆ្លាតវៃក្នុងការជជែក៖** គេអាចប្រើប្រាស់សំដីជាអាវុធ និងដើម្បីបង្កើតអាថ៌កំបាំងដែលនឹងពង្រឹងទាំងស្ថានភាពសង្គម និងជំហរនៃអំណាច។ ការពន្យល់ខ្លះៗត្រូវបានធ្វើឱ្យសាំញ៉ាំដោយចេតនាដើម្បីប្រជាជនមិនអាចយល់បាន ដោយមានការយល់ថា បុគ្គលដែលធ្វើការពន្យល់នោះនៅតែជា "អ្នកជំនាញ"។ តាមពិតការធ្វើបែបនេះ ធ្វើឱ្យខូចគោលបំណងនៃការពន្យល់!

**គ្មានបរិបទ៖** និយមន័យមួយឬសេចក្តីអធិប្បាយមួយមិនមែនជាការពន្យល់ឡើយ។ការពន្យល់មួយតែងតែមានបរិបទ ដែលតាមធម្មតាជាការឆ្លើយនឹងសំណួរ "ហេតុអ្វី" សម្រាប់អ្នកទទួល។ ឧទាហរណ៍ការពន្យល់មួយនឹងទទួលបរាជ័យ ប្រសិនបើអ្នកអធិប្បាយថាតើ REDD+ ជាអ្វី ទៅស្ត្រីនៅជនបទម្នាក់ក្នុងប្រទេសនេប៉ាល់ ប៉ុន្តែពុំបានផ្តល់ឱ្យគាត់នូវបរិបទដែលគាត់អាចផ្សារភ្ជាប់។

## គន្លឹះនៃការពន្យល់សម្រាប់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន




តើដំណើរការពន្យល់ចាប់ផ្តើមពីចំណុចណា និងចប់នៅត្រង់ណា? សូមគូសបញ្ជាក់ចំណុចគន្លឹះដូចខាងក្រោមនេះ នៅក្នុងក្រុមណាមួយដែលអ្នកធ្វើការជាមួយ៖

### ១. ចូរគ្រោងការពន្យល់របស់អ្នក ដោយប្រើប្រាស់មាត្រដ្ឋាននៃការពន្យល់

សូមកុំចាត់ទុកថា ការពន្យល់ជាលក្ខណៈម្តងម្កាល និងមានប្រសិទ្ធភាព។ ប្រសិនមានគេសុំឱ្យអ្នកពន្យល់អ្វីមួយជាមុន អ្នកគួរតែត្រៀម និងរៀបចំជាផែនការសម្រាប់ថាតើអ្នកនឹងធ្វើវាដោយបៀបណា។ ការគិតអំពីក្រុមមួយ ឬ បុគ្គលនានា និងការយល់ឃើញរបស់ខ្លួនអ្នកផ្ទាល់អំពីបញ្ហាមួយតាមមាត្រដ្ឋានពី ក ដល់ អ ដែលក្នុងនោះ ក មានការយល់ដឹងតិចតួច និង អ ការយល់ដឹងច្រើន គឺជាទម្លាប់ល្អមួយ។ ការងាររបស់អ្នក គឺពន្យល់អំពីការធ្វើបែបណា ដើម្បីជំរុញអ្នកណាម្នាក់ឱ្យឈានចេញពី ក ទៅ អ។ ការវាយតម្លៃអំពីថាតើ ពួកគាត់ស្ថិតនៅទីណាលើមាត្រដ្ឋាននោះ និងថាតើអ្នកចង់នាំពួកគាត់ទៅទីណានឹងអាចជួយអ្នកឱ្យគិតអំពីការរៀបចំផែនការមួយ សម្រាប់ការពន្យល់ និងសូម្បីតែវាយតម្លៃអំពីភាពខ្វះចន្លោះផ្ទាល់ខ្លួនរបស់អ្នកនៅក្នុងការយល់ដឹងផងដែរ។ ការធ្វើបែបនេះនឹងអាចឱ្យអ្នកធ្វើលំហាត់នេះ ដើម្បីត្រៀមលក្ខណៈសម្រាប់ការពន្យល់។ ជាញឹកញាប់បំផុត យើងប៉ុនប៉ងពន្យល់អ្វីមួយ ដែលខ្លួនយើងផ្ទាល់ពុំយល់បានពេញលេញផងទេ។ ប្រការនេះនឹងជួយយើងក្នុងការកំណត់អំពីការសន្មតរបស់យើងផ្ទាល់ ដែលអ្នកអាចចាត់ទុកថាជាផ្នែកមួយនៃដំណើរការពន្យល់។

### ២. ឈានចេញពីតួនាទីរបស់អ្នក និងបំបែកគំនិតគោល

ឈានចេញពីតួនាទីរបស់យើង ក្នុងនាមជាប្រតិបត្តិករនៅថ្នាក់មូលដ្ឋាន និងគិតអំពីអ្នកណាដែលរូបអ្នកនឹងធ្វើការពន្យល់អ្វីមួយ ដែលគេពិតជាចាំបាច់ត្រូវដឹង។ ចូរជ្រើសរើសយកគោលគំនិតដែលនឹង

មានសារៈសំខាន់សម្រាប់ក្រុមអ្នកស្តាប់នោះ ឬ អ្នកទទួល។ ចូរបំបែកគំនិតទាំងនោះទៅកម្រិតងាយៗ ដែលអ្នកអាចធ្លាប់បានគិតពីមុនមក។ បន្ទាប់ពីនោះ អ្នកត្រូវបំលែងកែសម្រួលឡើងវិញ និងដាក់គំនិតទាំងនោះទៅតាមលំដាប់លំដោយ។ ចូរគិតអំពីគោលគំនិតទាំងនោះ ជាធាតុផ្សំសម្រាប់ការចាត់ចែងដំណើរគិតគូររបស់អ្នកណាម្នាក់អំពីបញ្ហាជាក់លាក់ ដើម្បីបង្កើនការយល់ដឹងរបស់ពួកគាត់។




## ៣. រៀបចំឡើងវិញគំនិតសំខាន់ៗសម្រាប់អ្នកទទួល

នៅពេលដែលអ្នកបានពិចារណាគម្លាត និងបំបែកគំនិតគោលសម្រាប់ខ្លួនអ្នករួចហើយ ដែលផ្អែកតាមទស្សនទានរបស់អ្នកស្តាប់ អ្នកត្រូវតែវេចខ្ចប់គំនិតទាំងនោះឡើងវិញ។ ការធ្វើបែបនេះពាក់ព័ន្ធនឹង៖

**ការផ្តល់បរិបទ៖** ការធ្វើបែបនេះនឹងផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ការពន្យល់ និងអាចឱ្យក្រុមអ្នកស្តាប់ដឹងអំពីមូលហេតុ ហេតុអ្វីមានសារៈសំខាន់សម្រាប់ពួកគាត់។ ឧទាហរណ៍ នៅក្នុងឯកសារអំណានបរិបទសម្រាប់អ្នកអានគឺការពាក់ព័ន្ធនៃការពន្យល់របស់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន។

**ខ្សែរឿង៖** ការប្រើប្រាស់ខ្សែរឿងនានានៅក្នុងការពន្យល់ នឹងជួយអ្នកទទួលឱ្យមានការផ្សារភ្ជាប់តាមអារម្មណ៍ និងផ្សារភ្ជាប់ទៅនឹងគោលគំនិតបានប្រសើរជាងមុន។

**អារម្មណ៍ផ្សារភ្ជាប់៖** ការបង្កើតចំណងជាមួយរបស់នានាដែលមនុស្សទាំងឡាយបានយល់រួចមកហើយ ឬ ការប្រៀបធៀប និងការផ្ទឹមគ្នាជាមួយអ្វីដែលអ្នកស្តាប់បានដឹង នឹងជួយសម្រួលឱ្យមានការយល់ដឹងបានប្រសើរជាងមុន។

**សេចក្តីអធិប្បាយ៖** ការអធិប្បាយ "បែបណា" នៅក្នុងការពន្យល់ផ្តល់ឱ្យអ្នកទទួលនូវគំនិតស៊ីជម្រៅធៀបនឹង "ហេតុអ្វី" ដែលមានចែងនៅក្នុងបរិបទនេះ។

**ការសន្និដ្ឋាន៖** នៅក្នុងការពន្យល់ណាមួយក៏ដោយ ប្រការចាំបាច់ត្រូវមានការបូកសរុប និងសង្ខេប ប៉ុន្តែត្រូវផ្តោតលើការពាក់ព័ន្ធសម្រាប់អ្នកស្តាប់ ដោយផ្សារភ្ជាប់ទៅនឹងរូបភាពធំសម្រាប់បរិបទរបស់ពួកគាត់ផ្ទាល់។

## ៤. ធ្វើឱ្យងាយស្រួល និងមានមោទនភាពក្នុងការធ្វើឱ្យអ្វីៗមានភាពងាយស្រួល

គន្លឹះសំខាន់បំផុតគឺធ្វើឱ្យអ្វីៗឱ្យមានភាពងាយស្រួល - ភាសា គំហើញ សាច់រឿង និង ដំណើរការនៃការពន្យល់។ ការធ្វើឱ្យមានភាពងាយស្រួលគឺជាការលំបាក។ ការធ្វើឱ្យរឿងអ្វីមួយកាន់តែស្មុគស្មាញគឺជាការងាយស្រួលជាង។ ជាសំណាងមិនល្អ ការធ្វើឱ្យរឿងនានាងាយស្រួល ច្រើនតែត្រូវបានចាត់ទុកថា

ជាវិធីសម្រាប់កូនក្មេង។ ដោយទទួលស្គាល់ការលំបាកនេះ និងប្រឹងប្រែងដើម្បីពន្យល់រឿងនានាឱ្យងាយស្រួលនោះអ្នកនឹងបានទទួលការកើតសរសើរដោយសារតែកិច្ចការនេះ។

**នៅពេលដែលអ្នកពន្យល់អ្វីមួយដល់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ឬ អ្នកជំនាញ៖**

- **ត្រូវបញ្ជាក់គោលបំណងរបស់អ្នកតាំងពីដើមដំបូង៖** ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីអ្វីដែលអ្នកចង់ពន្យល់ អ្នកនឹងពន្យល់ដោយរបៀបណា និងហេតុអ្វី។
- **ត្រូវដោះស្រាយបញ្ហា៖** ប្រសិនបើអ្នកអាចបង្កើតការពន្យល់ ដែលដោះស្រាយបញ្ហាមួយសម្រាប់អ្នកស្ដាប់ ពួកគាត់ទំនងជាមានទំនុកចិត្តអំពីគោលគំនិត និងស្ដាប់ការពន្យល់របស់អ្នក។
- **ត្រូវរក្សាការពន្យល់ឱ្យខ្លី៖** ប្រជាជនមានការរវល់ ដូច្នេះកម្រិតនៃការយកចិត្តទុកដាក់របស់ពួកគាត់កាន់តែខ្លីទៅៗ។
- **ត្រូវកាត់បន្ថយចំណុចមិនពាក់ព័ន្ធ៖** ចូរគិតអំពីអ្វីដែល "ត្រូវដឹង" និងអ្វីដែល "កាន់តែល្អបើដឹង" ពាក់ព័ន្ធនឹងព័ត៌មាន សេចក្ដីពិស្ដារ និងការរំខានចំពោះគោលបំណងរបស់អ្នក។
- **ត្រូវប្រើប្រាស់គំហើញ និងទទួលស្គាល់ភាពមិនសុក្រឹត្យ៖** មនុស្សជាច្រើនគឺ ជាកសិករពិតប្រាកដ ហើយការបង្កើតគំហើញ ជាផ្នែករួមមួយនៃការពន្យល់របស់អ្នកនឹងមានប្រយោជន៍។ មិនត្រូវប្រើគំហើញសម្រាប់ការតែងលំអឡើយ ដោយសារវានឹងក្លាយជា "ការរំខាន"។ ការដែលគ្រាន់តែគូរគំនូរងាយៗគឺ ជាការគ្រប់គ្រាន់ដោយពុំចាំបាច់មានក្រាហ្វិកដែលត្រឹមត្រូវឥតខ្ចោះឡើយ។ ការយកចិត្តទុកដាក់របស់អ្នកគឺ លើខ្លឹមសារទោះបីគំហើញមិនមែនជាក្រាហ្វិកសុក្រឹត្យក៏ដោយ។
- **ត្រូវបន្ថយល្បឿន៖** អ្នកត្រូវប្រើប្រាស់ពេលតាមការចាំបាច់ ដើម្បីពន្យល់ឱ្យមានលំដាប់លំដោយបានច្បាស់លាស់។ មិនត្រូវផ្ដល់សេចក្ដីពិស្ដារច្រើនពេកទេនៅក្នុងរយៈពេលខ្លី ឬពន្យល់លឿនពេកទៅតាមដំណើរការដែលអ្នកបានគ្រោងទុកនោះឡើយ។
- **ត្រូវបង្កើតភាពរីករាយ៖** ត្រូវបង្កើតបរិយាកាសមិនផ្លូវការ និងទំនាក់ទំនងតាមរយៈការពន្យល់របស់អ្នកជាមួយអ្នកស្ដាប់។សូម្បីប្រធានបទសំខាន់ៗក៏ត្រូវផ្សារភ្ជាប់ខាងអារម្មណ៍ផងដែរទើបមានការចូលរួមដោយប្រសិទ្ធភាព។

# ឆ. ការបង្កើតជំនាញដឹកនាំ-យេនឌ័រ

គោលបំណងនៃការរៀនសូត្រ

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងៈ

- អាចពន្យល់អំពីភាពខុសគ្នារវាងយេនឌ័រ និងភេទ
- កំណត់បានថា ហេតុអ្វីបានជាគុណភាពយេនឌ័រ ជាគោលដៅសម្រាប់សម្រេចគុណភាព នៅក្នុងដំណើរការពាក់ព័ន្ធ
- ធ្វើការឆ្លុះបញ្ចាំងអំពីគោលគំនិតនៃ "ប្រអប់បុរស" និង "ប្រអប់ស្ត្រី" ពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគាត់ និងរបៀបដែលវាមានឥទ្ធិពលមកលើឥរិយាបថរបស់ស្ត្រី និងបុរសនៅក្នុងស្ថានភាពរបស់ក្រុម និងការប្រែប្រួលជាបន្តបន្ទាប់
- ពន្យល់អំពីស្ថានភាពផ្ទាល់ខ្លួន ដែលទាក់ទងនឹងយេនឌ័រដែលពួកគាត់បានឆ្លើយតប និង
- ឆ្លុះបញ្ចាំងអំពីឥរិយាបថផ្ទាល់ខ្លួន និងការប្តេជ្ញាចំពោះសមភាពយេនឌ័រ និងបានវាយតម្លៃអំពីខ្លួនឯង ដោយប្រើប្រាស់វិធាននៃសមធម៌យេនឌ័រ។

សម្ភារៈ

ក្រដាសផ្ទាំងធំ ហ្វឺត ក្រដាស Post-it និងវីដេអូសមស្រប ដូចជា www.ted.com/talks/tony_porter_a_call_to_men.html




រយៈពេល

៩០ នាទី

---

## ជំហានអនុវត្ត

១. ណែនាំអំពីវគ្គនានា ដោយពន្យល់ថា វាផ្តោតលើគោលគំនិតនៃភាពជាអ្នកដឹកនាំខាងយេនឌ័រ។ សូមពន្យល់ថា មេរៀននេះនឹងមិនថែងអំពីជាតុផ្សំសំខាន់ៗនៃគុណភាពយេនឌ័រឡើយ ប៉ុន្តែសន្មតថា អ្នកទាំងនោះភាគច្រើនបានដឹងអំពីភាពខុសគ្នារវាងយេនឌ័រ និងភេទ។

២. ពិនិត្យមើលជាមួយសិក្ខាកាមថា ការសន្មតរបស់អ្នកត្រឹមត្រូវដែរឬទេ និងស្នើឱ្យសិក្ខាកាមម្នាក់ ឬពីរនាក់ ធ្វើការចែករំលែកការយល់ឃើញរបស់ខ្លួនអំពីភាពខុសគ្នារវាងយេនឌ័រ និងភេទ។

៣. ស្នើក្រុមនីមួយៗឱ្យធ្វើការជាគូ ដែលមានបុរសម្នាក់ និងស្ត្រីម្នាក់ ប្រសិនបើអាចធ្វើបាន និងគិតអំពីសំណួរដូចតទៅ៖ ហេតុអ្វីដែលអ្នកត្រូវគិតអំពីសមភាពយេនឌ័រនៅពេលលើកកម្ពស់សមធម៌? សូមឱ្យសិក្ខាកាមបញ្ជាក់ឱ្យបានជាក់លាក់តាមតែអាចធ្វើបាននៅក្នុងចម្លើយរបស់ពួកគាត់។

៤. ក្រោយពេលដែលគូទាំងនេះបានពិភាក្សារួចហើយ ត្រូវស្នើសិក្ខាកាមឱ្យចែករំលែក និងសរសេរចម្លើយរបស់ពួកគាត់លើក្រដាសផ្ទាំងធំ។

៥. ចូរពន្យល់ថា អ្នកនឹងបង្ហាញវីដេអូខ្លីមួយដែលសង្ខេបពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកណាម្នាក់អំពីឥរិយាបថដែលទាក់ទងនឹងយេនឌ័រ និងការឆ្លុះបញ្ចាំង។ សូមបញ្ចាំងវីដេអូដែលពាក់ព័ន្ធមួយ (សូមមើលវីដេអូដែលគួរចាក់បញ្ចាំង)

៦. បន្ទាប់ពីបានចាក់វីដេអូរួច សូមអញ្ជើញសិក្ខាកាមឱ្យឆ្លុះបញ្ចាំងខ្លឹមសារក្នុងវីដេអូនោះ។ សួរពួកគាត់ដាច់ពីគ្នារវាងបុរស និងស្ត្រី៖

- *តើអ្នកមានអារម្មណ៍បែបណាពេលទស្សនាវីដេអូ?*
- *តើខ្លឹមសារក្នុងវីដេអូ ពាក់ព័ន្ធបែបណាជាមួយការយល់ដឹងរបស់អ្នកអំពី យេនឌ័រ?*
- *តើឥរិយាបថបែបណា ដែលទាក់ទងនឹងយេនឌ័រដែលអ្នកគិតថា ត្រូវបានបំពាក់លើរូបអ្នកកាលពីនៅកុមារ និងថាតើអ្នកធ្លាប់បានជំទាស់ដែរឬទេ?*

៧. បង្ហាញគំរូប្រអប់បុរស និងស្ត្រី។ សូមឱ្យសិក្ខាកាមគូរប្រអប់បុរស ឬ ស្ត្រីរបស់ខ្លួន (ទៅតាមភេទនិងបរិបទរបស់ខ្លួន ឬ បទពិសោធន៍ផ្ទាល់ខ្លួន និងគិតអំពីឥរិយាបថ ឬ គុណតម្លៃដែលពួកគាត់បានរៀនសូត្រ (ទៅតាមភេទរបស់ពួកគាត់) ដែលមានឥទ្ធិពលមកលើរបៀបដែលធ្វើ ឱ្យអ្នកដទៃចូលរួម ឬ ផ្សារភ្ជាប់ជាមួយអ្នកដទៃ។




៨. ស្នើឱ្យពួកគាត់ វិលត្រឡប់មកគូររូបរបស់ខ្លួនវិញដូចពីមុនក្នុងមេរៀននេះ និងពន្យល់ពីប្រអប់បុរស ឬ ស្ត្រីរបស់ពួកគាត់។ បន្ទាប់មក ស្នើពួកគាត់ឱ្យធ្វើការឆ្លុះបញ្ចាំងជាក្រុមរួម៖

- *តើឥរិយាបថរបស់អ្នកមានលក្ខណៈដូចគ្នា ឬខុសគ្នា និងហេតុអ្វី?*
- *តើវាខុសគ្នាបែបណា និងហេតុអ្វី?*

- *តើឥរិយាបថទាំងនេះ មានឥទ្ធិពលមកលើសមភាពយេនឌ័រ នៅក្នុងដំណើរការចូលរួមបែបណាដែរ?*

៩. ស្នើបុគ្គលម្នាក់ៗឱ្យគិតអំពីស្ថានភាពផ្ទាល់ខ្លួន ដែលពួកគាត់ធ្លាប់ឆ្លងកាត់ នៅក្នុងពេលដែលសមភាពយេនឌ័រនៅជាបញ្ហាមួយ (អាចនៅក្នុងជីវិតប្រចាំថ្ងៃការប្រជុំមួយឬការជជែកក្នុងវិជ្ជាជីវៈ) និងរំលឹកឡើងវិញអំពីសកម្មភាពផ្ទាល់ខ្លួនដែលបានធ្វើ។ ចូរសរសេរនៅលើសន្លឹកប័ណ្ណ។

១០. ស្នើសិក្ខាកាមបង្កើតជាក្រុម ដោយរើសយកសិក្ខាកាមពីរគូដែលបានបង្កើតពីមុនមកចូលរួមជាមួយគ្នា។ ស្នើពួកគាត់ឱ្យចែករំលែកបទពិសោធន៍។ នៅពេលបានបញ្ចប់ការពិភាក្សានេះហើយ ស្នើពួកគាត់ចូលរួមជាមួយគ្នាឡើងវិញជាក្រុមតែមួយ និងឆ្លុះបញ្ចាំងអំពីសំណួរដូចតទៅ៖

- *តើអ្វីខ្លះ ដែលធ្វើឱ្យអ្នកឆ្លើយតបនឹងស្ថានភាពមួយដែលក្នុងនោះសមភាពយេនឌ័រគឺ ជាបញ្ហា?*
- *តើអ្នកធ្វើបែបណាដើម្បីធានាថា អ្នកកំពុងដោះស្រាយសមភាពយេនឌ័រ នៅក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន និងក្នុងនាមជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន?*
- *ហេតុអ្វីអ្នកសម្របសម្រួលចាំបាច់ត្រូវដើរតួជាជនគំរូ?*
- *តើអ្នកសម្របសម្រួលអាចធ្វើអ្វីខ្លះ ដើម្បីដោះស្រាយសមភាពយេនឌ័រនៅក្នុងស្ថានភាពនៃការជំរុញការចូលរួម?*
- *តើមានការលំបាកអ្វីខ្លះ សម្រាប់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានលើសមភាពយេនឌ័រនៅក្នុងស្ថានភាពនៃការចូលរួម?*
- *តើធ្វើការឆ្លើយតបដោយរបៀបណា ប្រសិនបើវប្បធម៌ត្រូវបានកំណត់ឃើញថាជាឧបសគ្គមួយក្នុងការដោះស្រាយវិសមភាពយេនឌ័រ?*

## រូបទី ៨៖ ឧបករណ៍សមភាពយេនឌ័រ




* និយាម៖ សំដៅទៅលើឥរិយាបថ និងការអនុវត្ត

* ប្រព័ន្ធមួយផ្សំដោយរចនាសម្ព័ន្ធ ការអនុវត្ត និងទំនាក់ទំនងដែលមានអន្តរអំពើលើគ្នាទៅវិញទៅមក។

សម្ភារៈនេះបានបង្កើតឡើងដោយ ក្រុមការងារអន្តរទីភ្នាក់ងារទទួលបន្ទុកយេនឌ័រ (IGWG) ។
អាចទាញយកបាននៅក្នុង៖ http://www.igwg.org/training/ProgrammaticGuidance/GenderContinuum.aspx

**១១.** ចូរបូកសរុបមេរៀននេះ ដោយពន្យល់សង្ខេបអំពីវិធានសមធម៌យេនឌ័រ ដើម្បីផ្តល់គំនិតអំពីអ្វីដែលអ្នកយល់ថា ជាអវត្តមានយេនឌ័រ និងការយល់ដឹងអំពីយេនឌ័រ - អវត្តមានយេនឌ័រសំដៅលើសកម្មភាព ឥរិយាបថ ទស្សនៈគោលនយោបាយ កម្មវិធីនានាដែលមិនអើពើចំពោះបញ្ហាយេនឌ័រជាមួយគ្នា ចំណែកការយល់ដឹងអំពីយេនឌ័រ មានន័យថា មានចេតនាពិចារណាអំពីយេនឌ័រ និងការដោះស្រាយកត្តានានាដែលពាក់ព័ន្ធនឹងបញ្ហាយេនឌ័រ ដែលរំពឹងទុក។

**១២.** ស្នើសិក្ខាកាមឱ្យគិតអំពីថា តើពួកគាត់ស្ថិតនៅក្នុងស្ថានភាពណា ពាក់ព័ន្ធនឹងចម្លើយរបស់ពួកគាត់ តបនឹងសំណួរ អំពីហេតុអ្វីពួកគាត់ចាប់អារម្មណ៍អំពីសមភាព និងសមធម៌យេនឌ័រ។

# មេរៀនទី ៣



# ការរៀបចំ និងតាមដានដំណើរការចូលរួម ដោយប្រសិទ្ធភាពនៅសហគមន៍មូលដ្ឋាន ដើម្បីលើកកម្ពស់សមធម៌

# ក. តើការពាក់ព័ន្ធដោយប្រសិទ្ធភាពគឺជាអ្វី?

**គោលបំណងនៃការចូលរួម** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងៈ

- អាចពន្យល់ពីភាពខុសគ្នារវាងការចូលរួម និងការពាក់ព័ន្ធដោយប្រសិទ្ធភាព
- ឆ្លុះបញ្ចាំងអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគាត់ អំពីការធ្វើឱ្យពាក់ព័ន្ធ និង
- អាចពន្យល់អំពីលក្ខណៈវិនិច្ឆ័យសម្រាប់ដំណើរការ ដែលមានប្រសិទ្ធភាពនៃការធ្វើឱ្យពាក់ព័ន្ធ។

**សម្ភារៈ** ក្រដាសផ្ទាំងធំ ហ្វឺត សន្លឹកប័ណ្ណ ស្កុត ក្រដាសផ្ទាំងធំជាមួយនិយមន័យ អំពីការធ្វើឱ្យពាក់ព័ន្ធ នៅលើផ្ទាំងក្រដាសនេះ រូបបង្ហាញពីកម្រិតនៃការចូលរួម ប័ណ្ណធំ ជាមួយសិទ្ធិខុសៗគ្នារបស់មនុស្សដែលសរសេរ នៅលើសន្លឹកនីមួយៗ ("ប័ណ្ណសិទ្ធិ") ប្រអប់ទទេ បី ឬ បួន ដែលមានគម្របជាក្រដាសស និងឯកសារអំណាន។




**រយៈពេល** ៩០ នាទី

---

## ជំហានអនុវត្ត

**១.** ចូរចាប់ផ្តើមដោយសរសេរពាក្យ "ធ្វើឱ្យមានការចូលរួម" លើក្រដាសផ្ទាំងធំ។ ស្នើសិក្ខាកាមនៅក្នុងក្រុមរួមឱ្យគិតអំពីថាតើពាក្យនេះមានន័យបែបណាចំពោះពួកគាត់និងសរសេរចម្លើយរបស់ពួកគាត់នៅលើក្រដាសផ្ទាំងធំ ដើម្បីអាចឃើញទាំងអស់គ្នា។

**២.** ចូរពន្យល់ថា ជាដំបូងអ្នកចង់អនុវត្តលំហាត់មួយដែលនឹងជួយឱ្យមានការឆ្លុះបញ្ចាំង នៅក្នុងការពិភាក្សានៅក្នុងពេលបន្តបន្ទាប់នេះ។ ស្នើឱ្យសិក្ខាកាមរំកិលកៅអី ដើម្បីឱ្យមានទីធ្លាធំដែលក្នុងនោះពួកគាត់ទាំងអស់គ្នាអាចដើរចុះឡើងនៅក្នុងបន្ទប់នោះ។ ស្នើសិក្ខាកាមអង្គុយនៅតាមជុំវិញលំហដែលបានបង្កើតឡើងនេះ។ សួរពួកគាត់ថា តើពួកគាត់យល់បានអ្វីខ្លះអំពីពាក្យ "សិទ្ធិ" (បទប្បញ្ញត្តិជាមូលដ្ឋានគ្រឹះ អំពីអ្វីដែលអនុញ្ញាតចំពោះមនុស្ស ឬ សង្គម)។

៣. ដាក់ "ប័ណ្ណសិទ្ធិ" នៅលើកម្រាលឥដ្ឋ នៅទីន្លែងធំគ្រប់គ្រាន់។ ស្នើឱ្យសិក្ខាកាមដើរជុំវិញក្នុងបន្ទប់ និងជ្រើសយកប័ណ្ណសិទ្ធិណាមួយដែលជិតខ្លួន។ ស្នើពួកគាត់ឱ្យជ្រើសយកសិទ្ធិមនុស្សមួយដែលសំខាន់ចំពោះពួកគាត់ដោយផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួន និងគិតអំពីរឿងផ្ទាល់ខ្លួនមួយ ដែលបង្ហាញពីមូលហេតុដែលសិទ្ធិនេះសំខាន់សម្រាប់ពួកគាត់។ សូមពន្យល់ថា នេះមិនមែនជាការប្រកាន់ជំហរឡើយ ប៉ុន្តែអំពីការផ្សារភ្ជាប់ជាមួយសិទ្ធិមនុស្ស ដែលបុគ្គលម្នាក់គួរតែមានដែលពួកគាត់ចាប់អារម្មណ៍ជាខ្លាំង ដោយសារតែបទពិសោធន៍ជាក់លាក់របស់ខ្លួន។




៤. សួរថា តើអ្នកណាមានឆន្ទៈក្នុងការចំណាយពេល ៥នាទី ដើម្បីចែករំលែករឿងរ៉ាវរបស់ខ្លួនជាមួយក្រុម។ សូមអញ្ជើញសិក្ខាកាមមួយចំនួនដែលស្ម័គ្រចិត្តឱ្យចេញមកខាងមុខ។ គេពុំចាំបាច់ស្តាប់សាច់រឿងមូលឡើយ។ អាស្រ័យលើថាតើសិក្ខាកាមណាខ្លះមានបំណងចែករំលែក សូមជ្រើសយកសាច់រឿងណាដែលបង្ហាញពីមូលហេតុផ្ទុយ ឬ ខុសគ្នា ពីមូលហេតុដែលសិក្ខាកាមជ្រើសយកប័ណ្ណសិទ្ធិទាំងនោះ។ ការធ្វើបែបនេះនឹងអាចឱ្យមានការពិភាក្សាសំបូរបែបក្នុងចំណោមសិក្ខាកាម។

៥. ក្រោយពេលដែលសិក្ខាកាមមួយចំនួនតូចបាននិទានរឿងរបស់ខ្លួនរួចមក សូមស្នើសិក្ខាកាមទាំងអស់ឈរនៅតាមជញ្ជាំង នៅចុងម្ខាងនៃបន្ទប់នេះ។ គួរតែមានកន្លែងធំគ្រប់គ្រាន់សម្រាប់សិក្ខាកាមដើម្បីអនុវត្តកិច្ចការបន្ទាប់ ដែលជា "ការដើរដើម្បីសិទ្ធិ" ។ ចូរជ្រើសយកប័ណ្ណសិទ្ធិដែលនៅសល់។

៦. សូមអានសំណួរដូចតទៅ និងស្នើឱ្យសិក្ខាកាមឈានមួយជំហានទៅមុខ ប្រសិនបើពួកគាត់អាចឆ្លើយថា ត្រូវសម្រាប់សំណួរណាដែលទាក់ទងនឹងសិទ្ធិដែលពួកគាត់ជ្រើសយកពីមុនមក។ ត្រូវពន្យល់ថា ពួកគាត់ត្រូវឆ្លើយជាលក្ខណៈបុគ្គល។

- *តើអ្នកនឹងនិយាយអំពីសិទ្ធិនេះជាសាធារណៈឬទេ?*
- *តើអ្នកនឹងដឹកនាំយុទ្ធនាការ និងឈានមុខដើម្បីសិទ្ធិនេះឬទេ?*
- *តើអ្នកនឹងការពារសិទ្ធិនេះ ឬទេ សូម្បីមានអ្នកដទៃពេបជ្រាយចំពោះអ្នក?*
- *តើអ្នកនឹងប្រយុទ្ធដើម្បីសិទ្ធិនេះឬទេ?*
- *តើអ្នកសុខចិត្តជាប់ពន្ធនាគារដើម្បីសិទ្ធិនេះឬទេ?*
- *តើអ្នកនឹងត្រៀមខ្លួនក្នុងការប្រថុយជីវិតដើម្បីសិទ្ធិនេះឬទេ?*

៧. ក្រោយបញ្ចប់លំហាត់នេះហើយ និងក្រោយពេលដែលសិក្ខាកាមបានវិលត្រឡប់មកកៅអីរបស់ខ្លួនវិញហើយ សូមសួរសំណួរឆ្លុះបញ្ចាំងដូចតទៅ៖

- *តើអ្នកមានអារម្មណ៍បែបណាក្នុងពេលអនុវត្តលំហាត់នេះ?*
- *តើអ្នកមានអារម្មណ៍មិនស្រួលដែរឬទេ និងអ្វីដែលធ្វើឱ្យអ្នកមានអារម្មណ៍បែបនោះ?*
- *តើអ្នកធ្វើការសម្រេចបែបណាក្នុងការឈានទៅមុខ ឬ មិនទៅ?*
- *តើមានអ្វីខុសគ្នារវាងឈានទៅមុខឬនៅដដែល(ការវាយតម្លៃហានិភ័យបទពិសោធន៍កន្លងមក ខ្លាចអ្នកដទៃសើច និងបារម្ភអំពីសិក្ខាកាមផ្សេងទៀតគិតអំពីអ្នក)?*
- *តើអ្នកស្ថិតក្រោមឥទ្ធិពលនៃអ្នកដទៃទៀតដែលឈានទៅមុខ ឬ ស្ថិតនៅកន្លែងដដែលឬទេ?*
- *ក្នុងស្ថានភាពជាក់ស្តែង តើអ្នកណានិយាយការពារសិទ្ធិផ្ទាល់ខ្លួនរបស់គាត់? ហេតុអ្វីអ្នកគិតបែបនោះ?*
- តើអ្នកគិតថា លំហាត់នេះទាក់ទងបែបណាទៅនឹងការធ្វើឱ្យអ្នកពាក់ព័ន្ធ នៅមូលដ្ឋានបានចូលរួម?
- តើស្ថានភាពនេះ និងជំហររបស់អ្នកពាក់ព័ន្ធក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ ឬ ព្រៃឈើមានឥទ្ធិពលលើការចូលរួមរបស់ពួកគាត់ឬទេ និងហេតុអ្វី?

៨. ស្នើសិក្ខាកាមឱ្យបំបែកជាក្រុមដែលមានគ្នាពី ៤ ទៅ ៥នាក់។ ចូរពន្យល់ថា បុគ្គលម្នាក់ៗត្រូវគិតអំពីបទពិសោធន៍វិជ្ជមានចំនួនបីអំពីការចូលរួមផ្ទាល់ខ្លួន ដែលក្នុងនោះ ការយកចិត្តទុកដាក់របស់ពួកគាត់ពិតជាបានធ្វើឱ្យអ្នកដទៃកោតសរសើរ និងតម្រូវឱ្យពួកគាត់ចូលរួមជាមួយអ្នកដទៃដើម្បីធ្វើកិច្ចការខ្លះៗ។ ចូរបញ្ជាក់ថា វាអាចជាបទពិសោធន៍មួយ ដែលក្នុងនោះពួកគាត់មានការចូលរួមដោយផ្ទាល់ ឬ តាមវិជ្ជាជីវៈ។ ស្នើឱ្យពួកគាត់សរសេរបទពិសោធន៍ទាំងនោះនៅលើប័ណ្ណដាច់ដោយឡែកពីគ្នា។

៩. ក្រោយពេលពួកគាត់បានសរសេរអំពីកាលៈទេសៈទាំងបីនោះរួចហើយ ចូរស្នើឱ្យសិក្ខាកាមម្នាក់ៗពន្យល់ពីបទពិសោធន៍ទាំងនោះ។ សម្រាប់បទពិសោធន៍នីមួយៗ ពួកគាត់ត្រូវពន្យល់ពីមូលហេតុដែលពួកគាត់ចូលរួមយ៉ាងមានប្រសិទ្ធភាពនៅក្នុងដំណើរការនោះ។

១០. ក្រោយពេលសិក្ខាកាមម្នាក់ៗបានបញ្ចប់ហើយ ចូរពន្យល់ថា អ្នកនឹងផ្តល់ឱ្យក្រុមនីមួយៗប្រអប់ទទេមួយ និងក្រដាសពុំទាន់សរសេរ។ ចូរពន្យល់ថា អ្នកចង់ឱ្យក្រុមនីមួយៗផ្អែកលើដំណើរការឆ្លុះបញ្ចាំង និងរួមបញ្ចូលគំនិតទាំងអស់របស់ពួកគាត់ទៅក្នុងការធ្វើជាតំណាងដែលអាចមើលឃើញមួយដោយប្រើប្រាស់ប្រអប់នោះ។

១១. ចូរពន្យល់ថា ការងាររបស់ពួកគាត់គឺ មិនមែនតែងលម្អប្រអប់នោះទេ។ ផ្ទុយទៅវិញតាមរយៈការចាត់ចែង និងការដាក់រូបភាព នៅលើប្រអប់នេះពួកគាត់បង្ហាញ (ពន្យល់) អំពីអ្វីដែលជាអត្ថន័យនៃពាក្យធ្វើឱ្យមានការចូលរួម និងអ្វីដែលធ្វើឱ្យមានប្រសិទ្ធភាព។ ប្រអប់នេះនឹងក្លាយជាផលិតផលសម្រាប់ "លក់" របស់ពួកគាត់ សម្រាប់ពន្យល់អំពីការចូលរួម និងជាតុផ្សំនានាដែលចាំបាច់សម្រាប់ការចូលរួមប្រកបដោយប្រសិទ្ធភាព។ និយាយម្យ៉ាងទៀតថាពួកគាត់ត្រូវ "លក់" គំនិតរបស់ពួកគាត់ ដោយប្រើប្រាស់ "ប្រអប់ចូលរួម"។



១២. ផ្តល់ឱ្យក្រុមនេះទស្សនាវដ្តី សារព័ត៌មាន ប័ណ្ណ ហ្វឹត កន្ត្រៃ និងជ័រកាវ ចូរពន្យល់ថា ក្រុមនីមួយៗនឹងមានពេល ២៥នាទី ដើម្បីកែប្រែប្រអប់របស់ខ្លួន ដោយផ្អែកលើការយល់ឃើញរួមគ្នាអំពីការចូលរួម។ ចូរសង្កត់ធ្ងន់ថា ពួកគាត់មានសិទ្ធិធ្វើអ្វីដែលពួកគាត់ចូលចិត្តសម្រាប់ប្រអប់នោះ ដែលរួមទាំងដាក់វត្ថុនៅខាងក្នុង ឬ កែទម្រង់របស់វា។

១៣. ក្រោយរយៈពេល ២៥នាទី ចូរប្រាប់ក្រុមនីមួយៗថា ពួកគាត់នឹងមានពេល ៣នាទី សម្រាប់ម្នាក់ៗដើម្បីបង្ហាញប្រអប់របស់ខ្លួន និងការយល់ឃើញរបស់ពួកគាត់អំពីការចូលរួម។ ចូរផ្តល់ឱ្យពួកគាត់ ៥នាទី ដើម្បីត្រៀមសម្រាប់ការបង្ហាញ។

១៤. ក្រោយរយៈពេល៥ នាទី ស្នើឱ្យក្រុមទាំងនេះធ្វើការបង្ហាញ។

១៥. ក្រោយពួកគាត់បានបង្ហាញរួចហើយ ឱ្យពួកគាត់ចូលក្នុងក្រុមរួមវិញ និងស្នើពួកគាត់ឱ្យធ្វើការឆ្លើយនឹងសំណួរឆ្លុះបញ្ចាំងដូចតទៅ៖

- *ផ្អែកតាមការបង្ហាញរបស់អ្នក តើអ្នកយល់បែបណាអំពីការធ្វើឱ្យអ្នកដទៃពាក់ព័ន្ធ?*
- *តើការធ្វើឱ្យពាក់ព័ន្ធ ទាក់ទងបែបណាជាមួយការចូលរួម?*
- *តើអ្វីខ្លះដែលធ្វើឱ្យការពាក់ព័ន្ធ មានភាពខុសគ្នាពីការចូលរួម?*
- *តើអ្នកគិតថាអ្វីខ្លះ ដែលធ្វើឱ្យការពាក់ព័ន្ធមានប្រសិទ្ធភាព? ផ្អែកលើសាច់រឿង និងបទពិសោធន៍របស់អ្នក?*
- *តើការធ្វើឱ្យពាក់ព័ន្ធបែបនេះ ទាក់ទងយ៉ាងណាជាមួយការលើកកម្ពស់សមធម៌?*

១៦. សួរសិក្ខាកាមម្នាក់ៗថា តើពួកគាត់បានយល់អំពីកម្រិតខុសៗគ្នានៃការចូលរួម ឬទេ។ ចូរបង្ហាញដោយត្រួសៗអំពីដំណាក់កាលនានានៃការចូលរួម។ ក្រោយពីបានបញ្ចប់ហើយ សូមសួរសិក្ខាកាម

ថា តើការធ្វើឱ្យចូលរួមស្ថិតនៅត្រង់ណា? ដាក់បណ្ណមួយសន្លឹកដែលសរសេរថា "ការធ្វើឱ្យចូលរួម" នៅចុងខាងស្តាំនៃបន្ទាត់ស្តីពីការចូលរួមនេះ។ (គួរតែបិទភ្ជាប់ផ្សាក្រាមនេះទៅនឹងជញ្ជាំង) ដើម្បីឱ្យសិក្ខាកាមយល់ថាការចូលរួមគឺជាជំហានមួយខ្ពស់ជាងការពាក់ព័ន្ធ។ ប្រកាសសំខាន់ផងដែរគឺត្រូវបញ្ជាក់ថា ការពាក់ព័ន្ធមិនអាចកើតឡើងបានឡើយ នៅក្នុង ឬ រវាងក្រុមនានា បើគ្មានការអនុវត្តគុណតម្លៃនៃការចូលរួម។

១៧. ប្រសិនបើ អ្នកចង់ដេញដោលក្រុមនេះជាបន្ត អ្នកអាចស្នើឱ្យមានអ្នកស្ម័គ្រចិត្តមួយចំនួនគិតអំពីស្ថានភាពរបស់ពួកគាត់នៅកន្លែងណាមួយ ក្នុងកាហ្វ្រិកអំពីការចូលរួម ដោយផ្អែកតាមបទពិសោធន៍របស់ខ្លួន (គម្រោង ឬ សហគមន៍ ដែលពួកគេធ្វើការជាមួយ)។ អ្នកស្ម័គ្រចិត្តទាំងនេះបន្ទាប់មកអាចធ្វើការវាយតម្លៃខ្លួនឯង អំពីកម្រិតនៃការពាក់ព័ន្ធរបស់ពួកគាត់ ជាមួយសហគមន៍ទាំងនោះ និងចែករំលែកមូលហេតុរបស់ខ្លួនអំពីការដាក់ត្រង់កន្លែងណាមួយនៅតាមខ្សែបន្ទាត់នៃការចូលរួមនេះ។

១៨. ស្នើសិក្ខាកាមទាំងអស់គ្នា ឱ្យគិតអំពីឧទាហរណ៍ជាក់លាក់ អំពីអ្វីដែលដំណើរការបាន និងអ្វីដែលមិនអាចដំណើរការបាន នៅពេលជំរុញការចូលរួមនៅក្នុងបរិបទ REDD+ ដោយផ្អែកលើបទពិសោធន៍របស់ខ្លួន។




១៩. ចូរបូកសរុបមេរៀននេះ ដោយរំលឹកឡើងវិញនូវនិយមន័យអំពីការចូលរួម ដែលបានប្រើប្រាស់នៅក្នុងពេលរៀបចំបទបង្ហាញ អំពីប្រអប់កាលពីមុននេះនៅក្នុងមេរៀននេះ (ការពាក់ព័ន្ធបែបចូលរួមគឺជាដំណើរការមួយ ដែលពង្រឹងភាពចម្រុះរបស់មនុស្ស និងផ្តោតលើការបង្កើតថាមពលតាមរយៈការរំជួលចិត្ត និងអារម្មណ៍ជាប់ជំពាក់ ឆ្ពោះទៅសកម្មភាពដាច់ដោយឡែក និងសកម្មភាពរួមគ្នាលើបញ្ហានានាដែលជាកង្វល់រួម)។

២០. ក្នុងពេលដែលពិនិត្យឡើងវិញអំពីការពាក់ព័ន្ធ និងការប្រឈមនានានៃការធ្វើឱ្យអ្នកដែលមិនសូវមានអំណាចបានចូលរួម ចូរសង្កត់ធ្ងន់អំពីភាពចាំបាច់ ដើម្បីជំរុញឱ្យមានអារម្មណ៍ជាប់ជំពាក់ក្នុងចំណោមមនុស្ស។ ចូរសង្កត់ធ្ងន់ថា ក្នុងនាមជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន អារម្មណ៍ជាប់ជំពាក់របស់ពួកគាត់ផ្ទាល់ជាមួយមនុស្សដទៃទៀត ដែលពួកគាត់សម្របសម្រួលមានសារៈសំខាន់ណាស់ដែលជាដំណើរការផ្ទាល់មួយ។ ចូរពន្យល់ថា មេរៀនដទៃទៀតនឹងពិនិត្យមើលរចនាបថនៃដំណើរការ និងឧបករណ៍នានាសម្រាប់ការចូលរួមប្រកបដោយប្រសិទ្ធភាព។

## កំណត់សំគាល់របស់គ្រូបង្ហាត់

ប្រការសំខាន់គឺត្រូវបង្កើតចំណងទាក់ទងរវាងការដើរដើម្បីសិទ្ធិ និងដំណើរការទាំងមូលនៃការចូលរួម។ ការដើរ ដើម្បីសិទ្ធិត្រូវបានរួមបញ្ចូលដើម្បីបង្ហាញថា ក្រុមមនុស្សខុសៗគ្នាត្រូវបានបញ្ចុះបញ្ចូល ដើម្បីឱ្យធ្វើសកម្មភាព ឬ ពាក់ព័ន្ធនៅក្នុងបញ្ហាខុសៗគ្នា និងនេះជាការតភ្ជាប់គ្នាខាងសញ្ចេតនា (តែមិនមែនជាកាតព្វកិច្ចសង្គម) ដែលជំរុញមនុស្សឱ្យចូលរួមនោះឡើយ។

មេរៀននេះអាច បំបាត់ចោលមន្ទិលសង្ស័យនៃការយល់ឃើញរបស់សិក្ខាកាមអំពីតួនាទីរបស់ពួកគាត់ជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន។ អ្នកខ្លះជឿថា សហគមន៍មិនបានត្រៀមខ្លួនដើម្បីចូលរួម និងត្រូវការឱ្យមាន "ការបណ្តុះបណ្តាល" តាមវិធីអកម្មមុននឹងអាចធ្វើឱ្យពួកគាត់ចូលរួម។ អ្នកត្រូវតែត្រៀមខ្លួនជាស្រេចដើម្បីជំនះការសន្មតនេះ និងផ្តល់ឧទាហរណ៍អំពីអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានដែលនៅពេលបានទទួលឱកាសសមស្របពួកគាត់អាចរួមចំណែកជាគំនិតរបស់ខ្លួនទៅក្នុងដំណើរការនានា ដូចជាអ្នកពាក់ព័ន្ធនានាដទៃទៀតដែរ។ចូរប្រើប្រាស់ក្រាហ្វិកអំពីការចូលរួមដើម្បីស្នើឱ្យសិក្ខាកាមបង្ហាញពីជំហររបស់ខ្លួន(នៅក្នុងការវាយតម្លៃខ្លួនឯងដោយស្មោះត្រង់)ស្ថិតនៅត្រង់ណាមួយដែលពួកគាត់ជឿថា ការឆ្លុះបញ្ចាំងអំពីការងារភាគច្រើនរបស់ពួកគាត់។ ពួកគាត់ត្រូវគិតអំពីមូលហេតុ (ដែលអាចជាឧបសគ្គ ឬ ការកំហិត) សម្រាប់បញ្ហានេះ។

# ការដើរដើម្បីសិទ្ធិ

ចូររៀបចំ "ប័ណ្ណសិទ្ធិ" មួយឈុត ដែលមានពាក្យនានាដូចខាងក្រោម។ ប័ណ្ណនីមួយៗគួរតែមានទំហំ A4 ឬយ៉ាងហោចណាស់ធំល្មមដែលអាចឱ្យក្រុមទាំងមូលមើលឃើញ។ ប័ណ្ណទាំងនេះនឹងត្រូវដាក់នៅលើកម្រាលឥដ្ឋ ហើយសិក្ខាកាមនឹងត្រូវស្នើឱ្យជ្រើសយកមួយ។ អ្នកអាចបន្ថែមពាក្យដទៃទៀតអំពីសិទ្ធិ ដែលអាចពាក់ព័ន្ធសម្រាប់ការពិភាក្សា ជាមួយក្រុមសិក្ខាកាមជាក់លាក់របស់អ្នក។

| | |
|---|---|
| សិទ្ធិទទួលបានសន្តិសុខ | សិទ្ធិក្នុងការជម្រះក្តីដោយយុត្តិធម៌ |
| សិទ្ធិមានសេរីភាពក្នុងការធ្វើដំណើរ | សិទ្ធិចាកចេញ និងត្រឡប់មកប្រទេសវិញ |
| សិទ្ធិចំពោះទ្រព្យសម្បត្តិ | សិទ្ធិមានសេរីភាពដើម្បីគិត ដឹង និង សាសនា |
| សិទ្ធិក្នុងការជួបប្រជុំ | សិទ្ធិបោះឆ្នោត |
| សិទ្ធិទទួលបានម្ហូបអាហារ | សិទ្ធិទទួលបានការសិក្សា |
| សិទ្ធិមានសុខភាពល្អ | សិទ្ធិធ្វើការ |
| សិទ្ធិចំពោះគ្រួសារ | សិទ្ធិមានបរិស្ថានដែលគ្មានការបំពុល |
| សិទ្ធិក្នុងការប្រើប្រាស់ព្រៃឈើ | សិទ្ធិដក់បារី |
| សិទ្ធិក្នុងការប្រើប្រាស់ព្រៃឈើ | សិទ្ធិក្នុងការស្លៀកពាក់តាមចំណូលចិត្ត |
| បន្ថែមគំនិតផ្ទាល់ខ្លួន<br>សិទ្ធិ ______________ | បន្ថែមគំនិតផ្ទាល់ខ្លួន<br>សិទ្ធិ ______________ |

# ការចូលរួមយ៉ាងមានប្រសិទ្ធភាព?

**ការពាក់ព័ន្ធតាមបែបចូលរួមគឺជាដំណើរមួយដែលពង្រឹងភាពចម្រុះរបស់មនុស្ស និងផ្ដោតលើការកសាងថាមពល តាមរយៈការរំជួលចិត្ត ការទំនាក់ទំនង និងការសន្ទនា ជាមធ្យោបាយឈានទៅធ្វើសកម្មភាពជាលក្ខណៈបុគ្គល និងជាសមូហភាព លើបញ្ហានានាដែលជាកង្វល់រួម។[១៣]**

និយមន័យជំនួសមួយ ដែលអធិប្បាយអំពីលទ្ធផលខ្លះៗនៃការចូលរួមពិតប្រាកដគឺ "ដំណើរការនៃការធ្វើការសហការជាមួយគ្នា និងតាមរយៈក្រុមនានារបស់ប្រជាពលរដ្ឋ ដែលមានការពាក់ព័ន្ធតាមរយៈភាពស្ថិតនៅជិតគ្នាចំណាប់អារម្មណ៍ពិសេស ឬស្ថានភាពប្រហែលគ្នាដើម្បីដោះស្រាយបញ្ហានានា ដែលមានការប៉ះពាល់ មកលើសុខុមាលភាពរបស់ប្រជាពលរដ្ឋទាំងនោះ។ វាច្រើនតែពាក់ព័ន្ធជាមួយភាពជាដៃគូ និងសម្ព័ន្ធភាពដែលជួយកៀរគរធនធាន និងមានឥទ្ធិពលមកលើប្រព័ន្ធនា នាកែប្រែទំនាក់ទំនង ក្នុងចំណោមដៃគូ និងមាន តួ នាទីជាកត្តាជំរុញ ដើម្បីឱ្យមានការកែប្រែគោលនយោបាយកម្មវិធី និងការអនុវត្ត"។




ពាក្យថា "ការពាក់ព័ន្ធ" និង "ការចូលរួម" ច្រើនតែប្រើប្រាស់ជំនួសគ្នាទៅវិញទៅមក - ប៉ុន្តែវាមិនដូចគ្នាទេ។ ការពាក់ព័ន្ធ ច្រើនតែសំដៅលើឱកាសដែលសហគមន៍មួយអាចមានឥទ្ធិពលមកលើបញ្ហាសាធារណៈ និងជាការប្ដេជ្ញាមួយផងដែរចំពោះសកម្មភាព ឬ ការជាប់ទាក់ទង។ សមាជិកម្នាក់ក្នុងសង្គម ឬ ក្រុមមួយ អាចចូលរួមនៅក្នុងព្រឹត្តិការណ៍ ឬ សេចក្ដីថ្លែងការណ៍ណាមួយ ប៉ុន្តែមិនសុទ្ធតែចាប់អារម្មណ៍ថាជាផ្នែកមួយនៃដំណោះស្រាយ ឬ ដំណើរការ ឬអនុវត្តសកម្មភាពសម្រាប់រយៈពេលវែងឡើយ ដែលក្នុងករណីនេះពួកគាត់មិនមានការពាក់ព័ន្ធឡើយ។ ការចូលរួម គឺជាផ្នែកសំខាន់មួយនៃដំណើរការពាក់ព័ន្ធ។ ប៉ុន្តែ ដំណើរការនៃការពាក់ព័ន្ធ នឹងឈានមួយជំហានទៅមុខ ដោយសារតែគោលដៅ គឺការបង្កើតដំណោះស្រាយដែលមាននិរន្តរភាព និងការកំណត់របៀបវារៈនៅក្នុងក្រុមមួយ និង/ឬ រវាងក្រុមនានា។

ក្នុងរយៈពេលពីរសប្ដាហ៍កន្លងទៅ គំរូនៃការចូលរួមត្រូវបានលើកកម្ពស់នៅក្នុងការគ្រប់គ្រងព្រៃឈើ និងដីធ្លី ដើម្បីការពារអត្ថប្រយោជន៍សម្រាប់អ្នកពាក់ព័ន្ធទាំងអស់ ទន្ទឹមនឹងពង្រឹងការទទួលខុសត្រូវរួមគ្នា។ ប៉ុន្តែ គម្លាតនៅតែមាននៅឡើយ រវាងការអនុវត្ត និងការប្រែប្រួលពិតប្រាកដ សម្រាប់សហគមន៍ដែលពឹងផ្អែកលើព្រៃឈើ និងក្រុមទន់ខ្សោយ។ ប្រការនេះ អាចពាក់ព័ន្ធមួយផ្នែកជាមួយបញ្ហានៃភាពខុសគ្នាខាងអំណាច រវាងក្រុមដែលមានចំណាប់អារម្មណ៍ខុសៗគ្នា និងមួយផ្នែកដោយសារតែការកែប្រែ

---

១៣ ផ្អែកតាមបទពិសោធន៍របស់អ្នកនិពន្ធផ្ទាល់ និងការសំយោគអំពីនិយមន័យនានាអំពីការចូលរួមនៅក្នុងឯកសារនានា។

សេចក្តីថ្លែងការណ៍ និងនយោបាយលើការគ្រប់គ្រងធនធានធម្មជាតិ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ក៏ដូចជាការយកចិត្តទុកដាក់នៅកម្រិតសកលផងដែរ ចំពោះសេវាកម្មបរិស្ថាន។ តាមធម្មតាវិធាននានា សម្រាប់ការចូលរួមពុំធ្លាប់មានគោលដៅដើម្បីសម្របសម្រួលឱ្យមានការពិភាក្សា និងការសន្ទនាក្នុងចំណោមអ្នកពាក់ព័ន្ធនានាឡើយ ឬ សូម្បីនៅក្នុងក្រុមអ្នកពាក់ព័ន្ធនានា។ ផ្ទុយទៅវិញការសង្កត់ធ្ងន់គឺ ទៅលើការផ្តល់ព័ត៌មាន និងស្វែងរកយោបល់នានា ជាងការសន្ទនាជាប់ជាបន្តអំពីការកែប្រែអនាគតនៃសហគមន៍ព្រៃឈើ តាមរយៈក្រុមទាំងនេះ។

វិធានខុសៗគ្នាមួយសម្រាប់ការពាក់ព័ន្ធរវាងក្រុមនានានៅក្នុងសហគមន៍ និងរវាងអ្នកពាក់ព័ន្ធនានាគឺជាការចាំបាច់ ពោលគឺវិធានមួយដែលឈានហួសការអនុវត្តនៃការចូលរួមដូចបច្ចុប្បន្ន។ ដើម្បីឱ្យការពាក់ព័ន្ធទទួលជោគជ័យ ការជំរុញឱ្យមានអារម្មណ៍ជាប់ជំពាក់រវាងមនុស្ស និងការរំជួលចិត្ត គឺជាតម្រូវការចាំបាច់។ ការអនុវត្តបច្ចុប្បន្ននៃការចូលរួមមិនសុទ្ធតែព្យាយាមអនុវត្តបែបនេះឡើយ។ ជាញឹកញាប់សេចក្តីថ្លែងការណ៍ គឺស្ថិតក្រោមឥទ្ធិពលខ្លាំងពីសំណាក់គំនិតមួយចំនួនតូច ដូច្នេះពុំមានភាពម្ចាស់ការលើលទ្ធផលឡើយ។ ដូច្នេះ ការពាក់ព័ន្ធសម្រាប់រយៈពេលវែងត្រូវកាត់បន្ថយ។

## តើការចូលរួម និងការពាក់ព័ន្ធមានទំនាក់ទំនងគ្នាបែបណា?

លំដាប់តជាប់គ្នានៃការចូលរួម (រូបទី ៩) ពន្យល់អំពីថា តើការចូលរួមអាចខុសគ្នាដោយរបៀបណានៅលំដាប់ថ្នាក់ខុសៗគ្នា និងគុណភាពនៃអន្តរកម្មតាមបែបចូលរួម។

### រូបទី ៩៖ លំដាប់នៃការចូលរួម




ការឆ្លុះបញ្ចាំងអំពីថា តើភាគច្រើននៃបទពិសោធន៍របស់យើងបានមកពីលំដាប់ណាមួយនៅក្នុងលំដាប់នៃការចូលរួមផ្តល់ជាគំនិតជ្រាលជ្រៅ។ នៅក្នុងបរិបទនៃ REDD+ ជាការមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីវាយតម្លៃការចូលរួម និងការពាក់ព័ន្ធនៅលំដាប់ថ្នាក់ខុសៗគ្នា ចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន។ ការពាក់ព័ន្ធអាចសម្រេចបាននៅពេលដែលប្រជាជនធ្វើការជាមួយគ្នា ដើម្បីចាត់វិធានការលើបញ្ហានានាដែលជាកង្វល់រួមនៅជុំវិញបញ្ហា REDD+ និងព្រៃឈើ និងការប្រែប្រួលអាកាសធាតុ។

### តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីឱ្យមនុស្សជាច្រើនពិតជាពាក់ព័ន្ធនៅក្នុង និងរវាងក្រុមអ្នកពាក់ព័ន្ធនានា?

ជាញឹកញាប់ ក្រុមអ្នកពាក់ព័ន្ធដែលមានអំណាចតិចតួច និងទន់ខ្សោយអាចមិនមានទម្លាប់ចូលរួមនៅក្នុងវេទិកាធំៗ ឬពាក់ព័ន្ធហួសពីការប្រជុំឡើយ។ ក្នុងនាមជាអ្នកសម្របសម្រួលនៅមូលដ្ឋាន តួនាទីរបស់អ្នកគឺរៀបចំដំណើរការនៃការពាក់ព័ន្ធ និងវេទិកានានាដែលប្រើប្រាស់ជំនាញរបស់អ្នកដើម្បីជួយអ្នកពាក់ព័ន្ធនានាក្នុងការ "ស្វែងរកសម្លេងរបស់ខ្លួន" ។ ជាក់ស្ដែង នេះមិនគ្រាន់តែនៅក្នុងក្រុមអ្នកទន់ខ្សោយប៉ុណ្ណោះទេ ប៉ុន្តែក៏នៅក្នុងក្រុមអ្នកពាក់ព័ន្ធដែលមានអំណាចផងដែរ ដែលសម្លេងរបស់បុគ្គលម្នាក់ៗមិនដែលបានសំដែងចេញឡើយ។ ការប្រឈមរបស់អ្នកក្នុងនាមជាអ្នកសម្របសម្រួលនៅមូលដ្ឋាន គឺត្រូវធានាថា ការចូលរួមនៅក្នុងដំណើរការ និងវេទិកាទាំងនោះមានលក្ខណៈជាបរិយាប័ន្ន ដែលក្នុងនោះអ្នកពាក់ព័ន្ធទាំងអស់អាចរួមចំណែក និងសំដែងអំពីខ្លួនឯង ដូច្នេះពួកគាត់មានឱកាសសមរម្យដើម្បីមានឥទ្ធិពលមកលើរបៀបវារៈ និងលទ្ធផល។ ពួកគាត់នឹងធ្វើការនេះ ប្រសិនបើពួកគាត់យកចិត្តទុកដាក់អំពីបញ្ហានេះ ហើយពួកគាត់បង្កើតអារម្មណ៍ជាប់ជាមួយអ្នកដទៃទៀតដែលពិភាក្សាអំពីរឿងនេះ។

ការជួយប្រជាជនសំដែងអំពីខ្លួនឯង និងស្វែងរកសម្លេងរបស់ខ្លួន ឬឈានមួយជំហានទៅមុខ និងពាក់ព័ន្ធក្នុងការសន្ទនាអំពីអ្វីមួយដែលពួកគាត់យកចិត្តទុកដាក់ ទាមទារភាពច្នៃប្រឌិត ការស្រមៃ និងអារម្មណ៍ភ្ជាប់គ្នារវាងមនុស្ស។ នេះមានន័យថាការយល់ដឹងអំពីថាតើខួរក្បាលមានដំណើរការបែបណា និងពាក់ព័ន្ធទាំងជាមួយការរំជួលចិត្តនិងភាពសមហេតុផល។

ជាញឹកញាប់ឧបករណ៍ការប្រជុំនិងការសន្ទនានានាត្រូវបានរៀបចំឡើង ដើម្បីផ្ដោតលើមុខងាររបស់អឌ្ឍគោលខាងឆ្វេងនៃខួរក្បាល។ គេមិនអាចបង្កើតអារម្មណ៍ជាប់ជំពាក់ឡើយ រវាងបញ្ហានេះ និងក្រុមនេះ ឬ សូម្បីរវាងបុគ្គលនានា។ អ្នកដែលរៀបចំ និងសម្រួលការប្រជុំបណ្ដាញ និងវេទិកានានាមានការបារម្ភ ក្នុងការធ្វើកិច្ចការនានាបែបច្នៃប្រឌិត ឬ ខុសពីមុន។ ពួកគាត់ប្រើប្រាស់ឧបករណ៍ដូចគ្នា និងកន្លែងដូចគ្នាជារៀងរាល់លើក។ ក្នុងនាមជាអ្នកសម្របសម្រួល នៅថ្នាក់មូលដ្ឋានការប្ដេជ្ញាដំបូងរបស់អ្នក គួរតែជួយអ្នកទាំងនោះដែលតាមធម្មតាពុំមានឱកាស ដើម្បីសំដែងអំពីខ្លួនឯងបង្កើតជំនាញចាំបាច់ ដើម្បីសំដែងអំពីខ្លួនឯង និងធ្វើការតភ្ជាប់ជាមួយអ្នកដទៃ។



# ២. ការពន្យល់អំពីសមធម៌ និងការពាក់ព័ន្ធ

**គោលបំណងនៃការរៀនសូត្រ៖** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹង៖

- វិភាគអំពីដំណើរការពាក់ព័ន្ធពិតប្រាកដមួយសម្រាប់ REDD+ ឬសកម្មភាពសហគមន៍ព្រៃឈើមួយ ដែលទាក់ទងនឹងការលើកកម្ពស់សមធម៌ និងជាមួយធាតុផ្សំនានានៃក្របខ័ណ្ឌសមធម៌ និង
- ពិភាក្សាអំពីកត្តាជោគជ័យ សម្រាប់ដំណើរការពាក់ព័ន្ធដែលមានគោលដៅលើកកម្ពស់សមធម៌ នៅសហគមន៍មូលដ្ឋាន។

**សម្ភារៈ** ក្រដាសផ្ទាំងធំ ហ្វឺត សន្លឹកប័ណ្ណ ក្រដាស Post-it ស្កុត និងករណីសិក្សាមួយ (ប្រើប្រាស់ករណីសិក្សាមួយ ប្រសិនបើគ្មានសិក្ខាកាមណាម្នាក់អាចចែករំលែកបទពិសោធន៍ជាក់លាក់នៅក្នុងការសម្របសម្រួលសហគមន៍មូលដ្ឋាន)




**រយៈពេល** ១២០ នាទី

---

## ជំហានអនុវត្ត

**១.** បង្ហាញមេរៀននេះ ដោយពន្យល់ថា ការគិតគូរអំពីថា តើការពាក់ព័ន្ធជាអ្វី និងជំនាញនានារបស់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន បន្ទាប់មក សិក្ខាកាមនានានឹងផ្សារភ្ជាប់ដំណើរការនៃការពាក់ព័ន្ធនៅក្នុងក្របខ័ណ្ឌសមធម៌ ដែលបានពិភាក្សាពីខាងដើមនៅក្នុងវគ្គបណ្តុះបណ្តាលនេះ។

**២.** គូសបញ្ជាក់ថា មេរៀននេះផ្តោតលើបទពិសោធន៍ពិតប្រាកដជាមួយដំណើរការនៃការពាក់ព័ន្ធ។ ចូរជ្រើសយកយ៉ាងហោចណាស់សិក្ខាកាម ៣-៤នាក់ ដែលអ្នកដឹងថា មានបទពិសោធន៍សម្របសម្រួលដំណើរការពាក់ព័ន្ធសម្រាប់រយៈពេលវែង នៅក្នុងបរិបទនៃសហគមន៍ព្រៃឈើ ឬ REDD+។ អ្នកទាំងនេះនឹងក្លាយជា "អ្នកផ្តល់យោបល់"។ សូមចែកសិក្ខាកាមដទៃទៀតជា បី ឬ បួនក្រុម ដែលក្រុមនីមួយៗមានអ្នកផ្តល់យោបល់ម្នាក់។ ជាការត្រៀមលក្ខណៈ ចូរពន្យល់សង្ខេបដល់អ្នកផ្តល់យោបល់ និងសិក្ខាកាមមុន



វគ្គនេះ ដើម្បីអ្នកផ្ដល់យោបល់អាចដឹងអំពីការរំពឹងទុកថា តើទិដ្ឋភាពណាខ្លះ នៃដំណើរការពាក់ព័ន្ធដែលត្រូវគូសបញ្ជាក់ និងវិស័យនានាដែលពួកគាត់គួរចែករំលែកដូចជា ឧបសគ្គ ឬ ការកំហិតទម្លាប់ល្អ និងមេរៀនដែលទទួលបាន។

៣. ចូរពន្យល់ថា ក្រុមនីមួយៗនឹងវិភាគករណីសិក្សាមួយ ដោយសម្ភាសអ្នកផ្ដល់យោបល់។ ការធ្វើបែបនេះនឹងអាចឱ្យពួកគេអនុវត្តជំនាញសួររបស់ខ្លួន។ ចូរស្នើឱ្យអ្នកផ្ដល់យោបល់ម្នាក់ៗ ចាប់ផ្ដើមលំហាត់នេះ នៅក្នុងក្រុមរបស់ខ្លួនដោយផ្ដល់ព័ត៌មានអំពីសាវតារយៈពេល ៥នាទី អំពីករណីសិក្សានេះដែលពួកគេគ្រោងចែករំលែក និងបរិបទនៃដំណើរការនៃការពាក់ព័ន្ធ។

៤. ចូរពន្យល់ដល់សិក្ខាកាមដទៃទៀត (ក្រៅពីអ្នកផ្ដល់យោបល់) នៅក្នុងក្រុមនេះថា តាមរយៈការសម្ភាស អ្នកចង់ឱ្យពួកគាត់សួរសំណួរដូចខាងក្រោមនេះ និងវិភាគដំណើរការនៃការពាក់ព័ន្ធជាជំហានៗ។ ក្រុមនេះនឹងរៀបចំបទបង្ហាញមួយលើក្រដាសផ្ទាំងធំសម្រាប់ក្រុមដទៃទៀត។

- *តើអ្វីខ្លះជាគោលបំណងនៃការពាក់ព័ន្ធនេះដែលទាក់ទងនឹងសមធម៌?*
- *តើអ្នកណាខ្លះជាក្រុមគោលដៅ និងហេតុអ្វីក្រុមនេះត្រូវបានជ្រើសយក?*
- *តើជាតុផ្សំអ្វីខ្លះនៃសមធម៌ដែលបានដោះស្រាយ និងតើកិច្ចការនេះបានធ្វើឡើងដូចម្ដេច?*
- *តើជំហាន និងឧបករណ៍អ្វីខ្លះដែលបានយកមកប្រើប្រាស់?*
- *តើមានអ្វីខ្លះជាភាពខ្លាំងនៃដំណើរការនេះ និងតើអាចកែលម្អបន្ថែមបែបណា?*

៥. សូមរំលឹកសិក្ខាកាមថា នៅពេលសួរសំណួរត្រូវចងចាំអំពីក្របខ័ណ្ឌសមធម៌ ដែលបានពិភាក្សាពីខាងដើម។ ចូរផ្ដល់ឱ្យក្រុមនេះរយៈពេលយ៉ាងហោចណាស់ ៦០នាទី ដើម្បីអនុវត្តកិច្ចការនេះ។ នៅក្រោយដែលពួកគាត់បានបញ្ចប់លំហាត់នេះ ចូរស្នើឱ្យពួកគាត់បិទភ្ជាប់លទ្ធផលរបស់ពួកគាត់នៅលើជញ្ជាំងសម្រាប់អ្នកដទៃទៀតអាន។

៦. ចូរផ្ដល់ឱ្យក្រុមនីមួយៗរយៈពេល ៥នាទី ដើម្បីអានលទ្ធផលរបស់ក្រុមផ្សេងទៀត មុននឹងសុំឱ្យពួកគាត់ប្ដូរ ទៅអានលទ្ធផលរបស់ក្រុមផ្សេង។ នៅចុងបញ្ចប់ ពួកគាត់ត្រូវអានបទបង្ហាញរបស់ក្រុមទាំងអស់។



៧. ក្រោយពេលដែលក្រុមនេះបានអនុវត្តមួយជុំហើយ ចូរស្នើសិក្ខាកាមម្នាក់ឱ្យបង្ហាញដោយសង្ខេបអំពីគំនិតរបស់ក្រុមខ្លួន ប៉ុន្តែត្រូវរំលឹកពួកគាត់ថា ពួកគាត់ត្រូវបង្ហាញសេចក្តីពិស្តារទាំងអស់។ ចូរផ្តោតលើការស្រាយបំភ្លឺអំពីទំនាក់ទំនងជាមួយគោលដៅនៃការកែលម្អសមធម៌ និងភាពខ្លាំងនៃដំណើរការនេះ។

៨. ក្រោយដែលក្រុមទាំងអស់បានធ្វើបទបង្ហាញរួចហើយ សូមសួរសិក្ខាកាមសំណួរឆ្លុះបញ្ចាំងដូចតទៅ៖

- *ផ្អែកលើករណីទាំងនេះ តើការពាក់ព័ន្ធនេះមានឥទ្ធិពលកម្រិតណាមកលើសមធម៌?*
- *តើអ្វីជាចំណុចចាប់ផ្តើមសម្រាប់មានឥទ្ធិពលមកលើសមធម៌ តាមរយៈដំណើរការនៃការចូលរួម - កន្លែងណា និងពេលណាដែលអ្នកឃើញថា អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានធ្វើការលើដំណើរការបង្កើនការពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព?*
- *តើមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ អំពីជោគជ័យសម្រាប់ការពាក់ព័ន្ធ ដើម្បីមានឥទ្ធិពលមកលើសមធម៌?*
- *តើមានផលវិបាកបែបណាសម្រាប់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន នៅក្នុងការរៀបចំដំណើរការនៃការពាក់ព័ន្ធ?*

៩. ចូរសង្ខេបអំពីការឆ្លុះបញ្ចាំង និងលំហាត់នេះ ដោយរំលឹកឡើងវិញអំពីកត្តាជោគជ័យពីករណីដែលបានពិភាក្សា។

១០. ក្រោយពីការឆ្លុះបញ្ចាំង ចូរបូកសរុបមេរៀននេះដោយសង្កត់ធ្ងន់លើគុណតម្លៃនៃការបង្កើតឱ្យមានចំណងទាក់ទងដោយដឹងរវាងដំណើរការនៃការពាក់ព័ន្ធ និងការលើកកម្ពស់សមធម៌ដោយត្រូវបញ្ជាក់ឱ្យបានជាក់លាក់អំពីបញ្ហាសមធម៌នានា ហើយដំណើរការនេះនឹងដោះស្រាយ (ធាតុផ្សំនានា) ដែលគួរតែបានរួមបញ្ចូលនៅពេលទាក់ទងនឹងការលើកកម្ពស់សមធម៌ នៅក្នុងដំណើរការនៃការពាក់ព័ន្ធ និងតើអ្វីជាគោលដៅរួម។

---

## កំណត់សំគាល់សម្រាប់គ្រូបង្ហាត់

វគ្គនេះមានតម្លៃសំខាន់ណាស់ដោយសារ វាគិតគូរអំពីបញ្ហាខ្លះៗនៅក្នុងស្ថានភាពនៃជីវិតពិតសម្រាប់លើកកម្ពស់សមធម៌។ វានឹងកាន់តែមានប្រសិទ្ធភាព ប្រសិនបើអ្នកអាចប្រើប្រាស់ករណីនានា ឬសាច់រឿងមកពីសិក្ខាកាម។ នៅពេលជ្រើសរើសករណីសិក្សា ត្រូវធានាថា មេរៀនមានលក្ខណៈចម្រុះពាក់ព័ន្ធនឹងធាតុផ្សំខុសៗគ្នានៃសមធម៌។

ប្រសិនបើអ្នកមានករណីសិក្សាល្អមួយរបស់ខ្លួនផ្ទាល់ អ្នកអាចសរសេរជាសាច់រឿង និងប្រើប្រាស់។ ទោះជាយ៉ាងណាក៏ដោយ សារៈសំខាន់នៃមេរៀននេះគឺការជ្រើសរើសករណីសិក្សាខុសៗគ្នាអំពីការពាក់ព័ន្ធ និងការពិភាក្សារវាងក្រុមនានាលើករណីសិក្សានោះ។

ដើម្បីឱ្យមេរៀននេះបានទទួលជោគជ័យ អ្នកត្រូវធ្វើឱ្យប្រាកដថា សិក្ខាកាមផ្សារភ្ជាប់ការពិភាក្សានេះទៅនឹងក្របខ័ណ្ឌសមធម៌ ហើយពួកគាត់មិនប្រើប្រាស់ក្របខ័ណ្ឌរបស់ពួកគាត់ផ្ទាល់ ឬ ក្របខ័ណ្ឌសមធម៌ផ្សេងទៀតឡើយ ដើម្បីវិភាគបទពិសោធន៍នេះ។

# គ. អំណាច និងការពាក់ព័ន្ធ

**គោលបំណងនៃការរៀនសូត្រ** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមអាច៖

- ពន្យល់អំពីការសំដែងអំពីអំណាចខុសៗគ្នា និងថាតើវាទាក់ទងគ្នាបែបណាទៅនឹងសមធម៌ និងការពាក់ព័ន្ធ
- យល់បានថា តើអំណាចអាចមានការជាប់ទាក់ទង និងឋាមវន្តបែបណា
- ពន្យល់អំពីជាតុផ្សំខុសៗគ្នានៃអំណាច (ទម្រង់ លំហ និង កម្រិត) និង
- ពន្យល់ថា តើការវិភាគអំណាចជួយបែបណា នៅក្នុងការជ្រើសរើសយុទ្ធសាស្ត្រពង្រឹងសិទ្ធិអំណាច និងការរៀបចំដំណើរការនៃការពាក់ព័ន្ធ។

**សម្ភារៈ** ក្រដាសផ្ទាំងធំមួយ ជាមួយដ្យាក្រាមគូបអំណាច ហ្វឺត ស្កុត ប័ណ្ណ ″ការសំដែងអំណាច″ ប័ណ្ណ ″ចំណាត់ថ្នាក់អំណាច″ ប័ណ្ណមួយសន្លឹកដែលមានស្លាកសញ្ញា ដើម្បីបង្កើតដ្យាក្រាម និងឯកសារសម្រាប់អំណាន។

**រយៈពេល** ១២០ នាទី

---

## ជំហានអនុវត្ត

**១.** បង្ហាញមេរៀននេះដោយពន្យល់ថា សិក្ខាកាមបានវិភាគគោលគំនិតខុសៗគ្នារួចមកហើយដែលទាក់ទងនឹងសមធម៌ និងឧបសគ្គចំពោះការចូលរួម។ ចូរពន្យល់ថាទោះបីដំណើរការតាមបែបចូលរួមត្រូវបានជំរុញនៅក្នុងបរិបទធនធានធម្មជាតិ (និងជាពិសេស ក្នុងការគ្រប់គ្រងព្រៃឈើក៏ដោយ) សម្រាប់រយៈពេល ១៥-២០ឆ្នាំកន្លងមកនេះ ការកែប្រែប្រកបដោយអត្ថន័យនៅពុំទាន់បានបង្ហាញច្បាស់នៅឡើយ នៅពេលនិយាយអំពីការលើកកម្ពស់សមធម៌។ ចូរគូសបញ្ជាក់ថា ឧបសគ្គមួយក្នុងចំណោមឧបសគ្គសំខាន់ៗបំផុត គឺតើឋាមវន្តនៃទំនាក់ទំនងអំណាចមានឥទ្ធិពលបែបណាមកលើដំណើរការតាមបែបចូលរួម និងការចែករំលែក និងចែកចាយអត្ថប្រយោជន៍នៃធនធានធម្មជាតិប្រកបដោយសមធម៌។ អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានណាម្នាក់ ដែលចង់ធ្វើឱ្យមានភាពខុសគ្នា ត្រូវតែឆ្លុះបញ្ចាំងអំពីថា តើអំណាចបង្កការប៉ះពាល់បែបណាមកលើដំណើរការនៃការពាក់ព័ន្ធណាមួយ។

**២.** សុំឱ្យសិក្ខាកាមពន្យល់អំពីថា តើពួកគាត់គិតបែបណាអំពីអំណាចដែលទាក់ទងជាមួយសមធម៌។ ចូរសម្របសម្រួលឱ្យមានការពិភាក្សាខ្លីមួយ។

**៣.** ចូរសួរក្រុមនេះថា តើពួកគាត់ឱ្យនិយមន័យដូចម្តេច។ ចូរបង្ហាញនិយមន័យពីឯកសារអំណាន (មិនទាន់ចែកនៅពេលនេះទេ) ការពិនិត្យមើលថា សិក្ខាកាមមានការយល់ឃើញប្រហែលគ្នា។ សូមសួរសិក្ខាកាមថា តើពួកគាត់គិតថាអំណាចមានលក្ខណៈវិជ្ជមាន ឬ អវិជ្ជមាន។

**៤.** ចូរពន្យល់ថា មានវិធីបួនយ៉ាង ដែលអាចសំដែងឱ្យឃើញពីអំណាចដែលអាចមានទាំងវិជ្ជមាន និងអវិជ្ជមាន។ ត្រូវត្រៀមប័ណ្ណចំនួនបួនសន្លឹកជាស្រេច ដែលបង្ហាញពីការសំដែងទាំងបួននៃអំណាចដែលត្រូវស្វែងយល់នៅក្នុងសកម្មភាពនេះ៖ អំណាចលើ អំណាចដើម្បីអំណាច នៅក្នុង និងអំណាចជាមួយ។ ចូរបិទប័ណ្ណនីមួយៗនៅលើក្រដាសផ្ទាំងធំ ទន្ទឹមនឹងពន្យល់ថា តើប្រយោគនីមួយៗផ្តល់សញ្ញាបែបណា។ សួរសិក្ខាកាមថា តើប្រយោគមួយណាដែលពួកគាត់គិតថា ជាករណីទូទៅ និងហេតុអ្វី។ សុំឱ្យសិក្ខាកាមបង្ហាញទំនាក់ទំនងនៃប្រយោគនេះ ទៅនឹងបទពិសោធន៍របស់ពួកគាត់ជាមួយ REDD+ ឬការគ្រប់គ្រងព្រៃឈើដោយផ្អែកលើការប្រែប្រួលអាកាសធាតុ។ សួរពួកគាត់ថា តើមានភាពខុសគ្នាអ្វីខ្លះរវាងប្រយោគនីមួយៗ។ ចូរឱ្យពួកគាត់ពិភាក្សារហូតដល់ពេលដែលអ្នកចាប់អារម្មណ៍ថា ពួកគាត់បានយល់ច្បាស់អំពីភាពខុសគ្នានានា។ ភាពខុសគ្នាខ្លះៗអាចត្រឹមតិចតួចប៉ុន្តែទន្ទឹមនឹងនេះក៏ស្មុគស្មាញផងដែរ។ ត្រូវប្រាកដថាសិក្ខាកាមបានដឹងអំពីរឿងនេះ។ ចូរសួរថា ប្រយោគណាខ្លះដែលពួកគាត់គិតថាទាក់ទងនឹងការពាក់ព័ន្ធភាគច្រើននិងបង្កើនគុណភាព។ (ឯកសារអំណានសម្រាប់វគ្គនេះអាចផ្តល់ការណែនាំដល់រូបអ្នក។ ចូរកុំស្ទាក់ស្ទើរក្នុងការប្រើប្រាស់បទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក)។

**៥.** ចូរពន្យល់ថា ដើម្បីបង្ហាញពីភាពខុសគ្នានៃអំណាច និងប្រភពនៃអំណាច អ្នកត្រូវអនុវត្តសកម្មភាពចាត់ថ្នាក់អំណាច ជាមួយសិក្ខាកាមទាំងអស់។ មានទិដ្ឋភាពចំនួនបីសម្រាប់អនុវត្តលំហាត់នេះ៖ អំណាចផ្ទាល់ខ្លួន អំណាចសង្គម និងអំណាចតំណែង។ សិក្ខាកាមនឹងស្វែងយល់ទិដ្ឋភាពនីមួយៗតាមរយៈសកម្មភាពមួយដែលហៅថា ល្បែងអំណាច។

**៦.** ចូរស្នើសិក្ខាកាម ឱ្យបំបែកជាពីរក្រុម ដែលមានសិក្ខាកាមក្នុងចំនួនស្មើគ្នា។ ចូរផ្តល់ឱ្យសិក្ខាកាមនូវប័ណ្ណ "អំណាចផ្ទាល់ខ្លួន" ដែលអធិប្បាយអំពីទិដ្ឋភាពនានានៃអំណាច។ សូមឱ្យក្រុមនេះឈរតម្រង់ជួរ ដោយផ្អែកលើសេចក្តីអធិប្បាយផ្ទាល់ខ្លួនដែលពួកគាត់បានទទួល។ ស្នើក្រុមនេះឱ្យពិភាក្សាថាតើអ្នកណាគួរឈរនៅទីណាដោយហេតុថាអ្នកណាខ្លះមានអំណាចច្រើនជាងអ្នកដទៃ។ ត្រូវបញ្ជាក់ឱ្យច្បាស់ថា ចុងខាងណាដែលមានអំណាចខ្លាំងជាងគេ និងចុងខាងណាដែលមានអំណាចតិចជាងគេដើម្បីជៀសវាងការច្របូកច្របល់។ សូមផ្តល់ពេល ២-៣នាទី ដើម្បីក្រុមនេះចាត់ចែងដោយខ្លួនឯង។

៧. មិនត្រូវប្រឌិតសាច់រឿង ឬ ផ្តល់សេចក្តីពិស្តារបន្ថែម អំពីតួនាទីនៃប័ណ្ណអំណាច ឬ ផ្តល់ព័ត៌មានណាមួយអំពីកម្រិតនៃតួនាទីនានាណាមួយឡើយ ដូចជា មនុស្សគ្រប់រូបរស់ក្នុងភូមិដូចគ្នា។ ប្រការនេះនឹងធ្វើឱ្យលំហាត់នេះគ្មានលក្ខណៈធម្មជាតិ ហើយសិក្ខាកាមនឹងមានសេរីភាពក្នុងការសំដែងអំពីខ្លួនឯងឡើយ។

៨. ក្រោយពេលដែលបានបង្កើតខ្សែបន្ទាត់ទៅតាមលំដាប់លំដោយរបស់ខ្លួនហើយ ត្រូវសួរសិក្ខាកាមម្នាក់ម្តងៗថា តើគាត់នៅទីណា ហើយបង្ហាញពីទំនាក់ទំនងនៃតំណែងរបស់ពួកគាត់ជាមួយប្រជាជនដទៃទៀតនៅក្នុងខ្សែនោះ។ ប្រសិនបើ អ្នកមានការភ្ញាក់ផ្អើលចំពោះតំណែងដែលខ្លួនបានតែងតាំង សូមសួរក្រុមនេះ ឬក្រុមដទៃទៀត។ សួរអ្នកទាំងនោះ អំពីហេតុអ្វីពួកគាត់ជ្រើសយកតំណែងនេះ។



៩. ក្រោយពីអ្នកបានពិភាក្សាអំពីលំដាប់របស់ពួកគាត់ហើយ (មូលហេតុដែលពួកគាត់ឈរនៅត្រង់កន្លែងដែលពួកគាត់ឈរនោះ) ចូរផ្តល់ប័ណ្ណដល់ពួកគាត់សម្រាប់លំដាប់បន្ទាប់ ប័ណ្ណ "អំណាចសង្គម" ។ ចូរព្យាយាមផ្តល់ឱ្យពួកគាត់នូវប័ណ្ណមួយសន្លឹកដែលកែប្រែស្ថានភាពអំណាចពីមុនមករបស់ពួកគាត់គ្រប់ពេលទាំងអស់ដែលពួកគាត់សង្កេតឃើញអំពី កន្លែងដែលពួកគាត់ឈរនៅក្នុងជួរនោះ។

**១០.** ជាថ្មីម្តងទៀត ចូរផ្តល់ឱ្យពួកគាត់រយៈពេល ៣នាទី ដើម្បីពិភាក្សា និងរៀបចំឡើងវិញដោយខ្លួនឯង។ ចូរស្វែងយល់ជាមួយពួកគាត់អំពី មូលហេតុដែលពួកគាត់ប្រកាន់យកកន្លែងដែលពួកគាត់បានឈរ ដើម្បីឱ្យក្រុមជាអ្នកសម្រេចអំពីតំណែងរបស់ពួកគាត់។

**១១.** ចូរធ្វើលំហាត់នេះឡើងវិញ ដោយផ្តល់ឱ្យពួកគាត់លំដាប់ទីបី ដែលសរសេរថា "អំណាចនៃតំណែង" ។ លើកនេះ ចូរធ្វើការឆ្លុះបញ្ចាំងអំពីថា តើតំណែងរបស់ពួកគាត់បានប្រែប្រួលបែបណាចាប់តាំងពីជុំដំបូង។ ជាការប្រសើរជាង ប្រសិនបើអ្នកអាចផ្តល់ឱ្យអ្នកដែលស្ថិតនៅកាំខាងក្រោមនៃជណ្តើរអំណាចកាលពីជុំមុន នូវប័ណ្ណដែលមានអំណាចនៃតំណែងខ្ពស់ជាង ដើម្បីសិក្ខាកាមងាយស្រួលមើលឃើញពីភាពខុសគ្នា។

**១២.** ក្រោយពីបានបញ្ចប់ជុំទីបី ដោយប្រើប្រាស់ប័ណ្ណអំណាចនៃតំណែង ចូរសួរក្រុមនេះសំណួរឆ្លុះបញ្ចាំងដូចតទៅ៖

- *តើអ្នកមានអារម្មណ៍បែបណាក្នុងពេលអនុវត្តលំហាត់នេះ?*
- *តើមានអ្វីកើតឡើង នៅក្នុងដំហាននីមួយៗនៃលំហាត់នេះ និងហេតុអ្វី?*
- *តើអ្នកណាខ្លះ មានលំដាប់ខុសគ្នាខ្លាំងនៃអំណាចរវាងជុំចាប់ផ្តើម និងជុំចុងក្រោយនៃលំហាត់នេះ និងហេតុអ្វី?*
- *អ្នកណាខ្លះមានអំណាចក្នុងលំដាប់ប្រហែលគ្នា នៅក្នុងជុំទាំងបី និងស្ថិតក្នុងកន្លែងដដែលនៅទូទាំងលំហាត់នេះ?*
- *តើអ្នកបានសម្រេចដោយខ្លួនឯងបែបណាអំពីស្ថានភាពរបស់ខ្លួនឯង?*
- *តើអ្នកដទៃទៀតធ្វើបែបណាដើម្បីកែប្រែស្ថានភាពរបស់អ្នក?*
- *តើអ្នកគិតថាអ្វីខ្លះដែលជាធាតុផ្សំខុសៗគ្នា នៃអំណាច ដែលស្ថិតនៅក្នុងជុំទាំងបីនៃប័ណ្ណ?*
- *តើប័ណ្ណណាខ្លះដែលអ្នកគិតថាមានឥទ្ធិពលមកលើជំហររបស់អ្នកខ្លាំងជាងគេ និងហេតុអ្វី?*
- *តើលំហាត់នេះ ទាក់ទងបែបណាទៅនឹងប្រយោគអំណាច ដែលបានពិភាក្សាពីខាងដើម (អំណាចលើអំណាចនៅក្នុង និងអំណាចជាមួយ)?*
- *តើលំហាត់នេះទាក់ទងបែបណាទៅនឹងការពាក់ព័ន្ធ និងការលើកកម្ពស់សមធម៌?*

**១៣.** ក្រោយបញ្ចប់ការឆ្លុះបញ្ចាំងនេះ ចូរពិនិត្យឡើងវិញនូវនិយមន័យដែលបានផ្តល់នៅពេលចាប់ផ្តើម និងសង្កត់ធ្ងន់ថា លំហាត់នេះបង្ហាញយ៉ាងច្បាស់ថា អំណាចមិនស្ថិតនៅថេរឡើយ (វាប្រែប្រួល) និងអាស្រ័យលើទំនាក់ទំនងនានា។ ចូរសង្កត់ធ្ងន់ថា ទោះបីភាពជាក់ស្តែងនេះ ធ្វើឱ្យអំណាចមានលក្ខណៈស្មុគស្មាញក៏ដោយ ប្រការសំខាន់គឺត្រូវយល់អំពីអំណាចឱ្យកាន់តែច្បាស់ថែមទៀតនៅក្នុងបរិបទរបស់យើង និងមិនត្រូវធ្វើការសន្មតណាមួយឡើយ។

១៤. ចូរពន្យល់ថា មានទិដ្ឋភាពបីនៃអំណាច ដែលត្រូវពិចារណា នៅពេលយើងគិតអំពីការលើកកម្ពស់សមធម៌ និងប្រការនេះអាចបង្ហាញជាគូបអំណាចវិមាត្របី។




១៥. ចូរបង្ហាញគូបនេះដោយប្រើប្រាស់រូបទទេនៃគូបមួយ និងចាប់ផ្តើមពីវិមាត្រ "ទម្រង់នៃអំណាច"។ ដោយប្រើប្រាស់ឧទាហរណ៍ មកពីលំហាត់ខាងដើម ជាបឋមត្រូវផ្តោតលើការយល់ដឹងរបស់សិក្ខាកាមអំពីទម្រង់ខុសៗគ្នានៃអំណាចៈ អំណាចមើលឃើញ អំណាចលាក់កំបាំង និងអំណាចមើលមិនឃើញ (សូមអានឯកសារអំណាន)

១៦. ក្រោយពេលដែលអ្នកបានបញ្ចប់ទម្រង់អំណាចរួចមក ត្រូវឈានទៅទិដ្ឋភាពមួយផ្សេងទៀត ពោលគឺ "លំហ"។ ចូរពន្យល់ថា ការយល់ដឹងអំពីវិធី និងកន្លែងដែលប្រជាជនប្រើប្រាស់អំណាចរបស់ពួកគាត់ គឺជាគន្លឹះនៃការយល់ដឹងអំពីចំណុចចាប់ផ្តើមសម្រាប់ការកែប្រែ និងឥទ្ធិពលនៅពេលនិយាយអំពីការធ្វើឱ្យមានតុល្យភាពអំណាច ដែលទាក់ទងនឹងសមធម៌នៅក្នុងបរិបទណាមួយ។ ចូរពន្យល់អំពីជាតុផ្សំនានានៃលំហ ម្តងមួយៗ ដោយផ្តល់ឧទាហរណ៍ៈ លំហបិទ លំហអញ្ជើញ និងលំហបង្កើត។ ដើម្បីបញ្ជាក់ឱ្យសិក្ខាកាមយល់ច្បាស់ អ្នកអាចសួរពួកគាត់អំពីឧទាហរណ៍នៅក្នុងបរិបទ REDD+ របស់គាត់។

១៧. ចូរបន្តទៅជាតុផ្សំ "លំដាប់" ចុងក្រោយ និងបិទប័ណ្ណអំពីលំដាប់ខុសៗគ្នានៅលើគូប។ ចូរសួរសិក្ខាកាមថា តើពួកគាត់យល់យ៉ាងណាអំពីការប្រែប្រួលនៃអំណាចរវាងលំដាប់ខុសៗគ្នា។ ត្រូវឱ្យប្រាកដថា អ្នកក៏ផ្តល់ឧទាហរណ៍ផងដែរអំពីលំដាប់ថ្នាក់ខុសៗគ្នានៅក្នុងបរិបទមូលដ្ឋាន ដូចជា ភូមិ ឬ គ្រួសារ។

**១៨.** បន្ទាប់ពីបានពន្យល់អំពីគូបអំណាចរួចមក ចូរសួរសិក្ខាកាមថា តើធាតុផ្សំទាំងនេះ និងគូបអាចជួយពួកគាត់វិភាគអំណាច និងបង្កើតយុទ្ធសាស្ត្រសម្រាប់លើកកម្ពស់សមធម៌ដោយរបៀបណា។

**១៩.** ចូរពន្យល់ថា ដើម្បីអធិប្បាយបន្ថែមទៀតអំពីការពាក់ព័ន្ធនៃគូបនេះ អ្នកសូមស្នើឱ្យសិក្ខាកាមប្រើប្រាស់ធាតុផ្សំនានាដែលបានពន្យល់រួចមកហើយ ដើម្បីមានឥទ្ធិពលមកលើអំណាចរបស់អ្នកពាក់ព័ន្ធជាក់លាក់ណាមួយ។ បន្ទាប់មកបែងចែកសិក្ខាកាមទៅជាក្រុមដែលមានគ្នាបួន ឬ ប្រាំនាក់។ ស្នើឱ្យពួកគាត់ជ្រើសយកអ្នកពាក់ព័ន្ធមួយ ដែលពួកគាត់ដឹងថាបានក្លាយជាក្រុមអ្នកទន់ខ្សោយនៅក្នុងបរិបទ REDD+។

**២០.** ស្នើឱ្យពួកគាត់ប្រើប្រាស់គូបនេះ ដើម្បីកំណត់ថា កន្លែងណាដែលពួកគាត់គិតថា អ្នកពាក់ព័ន្ធនោះទាក់ទងច្រើនបំផុតនៅក្នុងគូបអំណាច និងថាតើយុទ្ធសាស្ត្រណាខ្លះដែលអាចប្រើប្រាស់បាន ដើម្បីប្តូរអ្នកពាក់ព័ន្ធនានាទៅកែទម្រង់លំហ និងកម្រិតខុសៗគ្នានៃអំណាច។ ចូរស្នើឱ្យក្រុមនេះសរសេរយុទ្ធសាស្ត្រទាំងនេះ នៅលើក្រដាសផ្ទាំងធំ។

**២១.** រយៈពេល ២០នាទីក្រោយមក សូមស្នើសិក្ខាកាមឱ្យពន្យល់ថាតើអ្នកពាក់ព័ន្ធណាដែលពួកគាត់បានជ្រើសរើស និងហេតុអ្វី ព្រមទាំងនិយាយអំពីយុទ្ធសាស្ត្រខ្លះៗដែលពួកគាត់បានប្រើប្រាស់។ ត្រូវធ្វើឱ្យប្រាកដថា ពួកគាត់ផ្សារភ្ជាប់ការពិភាក្សានេះជាមួយធាតុផ្សំនៃគូបអំណាច។

**២២.** ក្រោយពីបានពន្យល់អំពីយុទ្ធសាស្ត្រ ត្រូវសួរសំណួរឆ្លុះបញ្ចាំងដូចតទៅ៖

- *តើក្រុមទាំងនេះមានយុទ្ធសាស្ត្រដូចគ្នា ឬ ខុសគ្នាសម្រាប់អ្នកពាក់ព័ន្ធដូចគ្នា? ហេតុអ្វីប្រើប្រាស់យុទ្ធសាស្ត្រដូចគ្នា ឬ ខុសគ្នា?*
- *តើឧបករណ៍បែបណាដែលអាចជួយក្រុមមួយ ដើម្បីពង្រឹងអំណាចបង្កប់របស់ពួកគាត់ និងប្តូរទៅកែទម្រង់ដែលកាន់តែងាយស្រួលឃើញ?*
- *តើអ្នកបានវិភាគអំណាចបានច្បាស់លាស់ក្នុងកម្រិតណា និងតើវាទាក់ទងបែបណា ទៅនឹងអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានដែលអ្នកធ្វើការជាមួយ?*
- *តើការវិភាគអំណាចបែបនេះ ជួយអ្នកបែបណាទៅអនាគត?*

**២៣.** ចូរបូកសរុបមេរៀននេះ ដោយវិលត្រឡប់មកប្រយោគអំណាច (អំណាច លើអំណាច ដើម្បីអំណាចក្នុង និងអំណាចជាមួយ) និងបញ្ជាក់ឱ្យបានច្បាស់ថា ដើម្បីដោះស្រាយសមធម៌តាមរយៈដំណើរការនៃការពាក់ព័ន្ធប្រយោគ បីចុងក្រោយ គឺជាអ្វីដែលអ្នកសម្របសម្រួលថ្នាក់មូលដ្ឋានត្រូវធ្វើការជាមួយ។

## កំណត់សំគាល់របស់គ្រូបង្ហាត់

នេះជាមេរៀនសំខាន់មួយ ដើម្បីផ្សារភ្ជាប់ការពាក់ព័ន្ធជាមួយសមធម៌។ សិក្ខាកាមត្រូវតែយល់បានពេញលេញថា តើពួកគាត់អាចមានឥទ្ធិពលបែបណាមកលើទំនាក់ទំនងអំណាច ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់ពួកគាត់សម្រាប់ការពាក់ព័ន្ធប្រកបដោយការពិចារណា និងច្បាស់លាស់នៃក្រុមអ្នកទន់ខ្សោយ។

ប្រការសំខាន់ គឺត្រូវអានឯកសារអំណានឱ្យបានពេញលេញ នៅមុនអ្នកអនុវត្តមេរៀននេះ។ ប្រការសំខាន់ គឺអ្នកត្រូវយល់អំពីគូបអំណាច និងទិដ្ឋភាពនានានៃអំណាចដែលនឹងត្រូវបង្ហាញនៅក្នុងវគ្គនេះ ដើម្បីជៀសវាងការធ្វើឱ្យសិក្ខាកាមច្របូកច្របល់។ ចូរព្យាយាមផ្តល់ឧទាហរណ៍ឱ្យបានច្រើនតាមតែអាចធ្វើបានពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកឬបរិបទរបស់អ្នក និងប្រសិនបើចាំបាច់ចូរត្រៀមឧទាហរណ៍ជាមុន។

នៅក្នុងក្រុមខ្លះ សិក្ខាកាមមានឆន្ទៈមោះមុតក្នុងការបង្ហាញថា ពួកគាត់គោរពអំណាចរបស់មេដឹកនាំមូលដ្ឋាន ហើយពួកគេជំរុញមេដឹកនាំមូលដ្ឋានទៅរកកំពូលនៃលំដាប់អំណាច។ នេះជាប្រការដែលពាក់ព័ន្ធនៅពេលបណ្តុះបណ្តាលដល់សមាជិកមកពីអង្គការសង្គមស៊ីវិល ដែលមានបំណងបង្ហាញពីការគោរពចំពោះប្រជាជននៅមូលដ្ឋាន។ ទោះជាយ៉ាងណាក៏ដោយក្នុងនាមជាគ្រូបង្ហាត់ អ្នកត្រូវតែបំបាត់ចោលការសង្ស័យបែបនេះ ឬ លើកទឹកចិត្តដល់សមាជិកដទៃទៀតនៃក្រុមនេះឱ្យដេញដោលសិក្ខាកាមទាំងនោះ ដើម្បីបង្ហាញ និងវិភាគអំពីស្ថានភាពពិតនៃឋាមវន្តអំណាចពិតប្រាកដ។ អ្នកអាចប្រើប្រាស់ជំនាញសម្របសម្រួលខុសៗគ្នា ដូចជាការសួរ និងការបង្កើតជាទម្រង់សំណួរ ដើម្បីសម្រេចគោលដៅនេះ។

# ការចាត់អំណាចជាលំដាប់ថ្នាក់

ចូរសរសេរពាក្យដូចខាងក្រោមនេះ នៅលើប័ណ្ណខុសៗគ្នា និងរក្សាទុកដាច់ដោយឡែកទៅតាមជួរឈរ។ ចូរបន្ថែមប័ណ្ណទៅតាមការចាំបាច់ដោយរក្សាលក្ខណៈវិនិច្ឆ័យនៃការអធិប្បាយ និងផ្អែកតាមចំណងជើងនៃជួរឈរនីមួយៗ។

| ផ្ទាល់ខ្លួន (ប័ណ្ណសម្រាប់ជុំទីមួយ) | សង្គម (ប័ណ្ណសម្រាប់ជុំទីពីរ) | តំណែង (ប័ណ្ណសម្រាប់ជុំទីបី) |
|---|---|---|
| បុរសទាប | គ្រូបង្រៀននៅមូលដ្ឋាន | អ្នកនយោបាយនៅមូលដ្ឋាន |
| ស្ត្រីស្អាត | ស្ត្រីមេម៉ាយ | ទីប្រឹក្សាអភិបាលខេត្ត |
| ស្ត្រីចំណាស់មានប្រាជ្ញា | មេដឹកនាំសាសនា | មេដឹកនាំចលនាស្ត្រី |
| ក្មេងស្រីកម្ជិល | ជនអវិជ្ជា | មេដឹកនាំសមាគមកសិករ |
| កុមារាឧស្សាហ៍ | រៀបការ និងមានកូនច្រើន | ឆ្មាំព្រៃឈើ |
| បុរសមានសាច់ដុំរឹងមាំ | មន្ត្រីនគរបាលចូលនិវត្តន៍ | នាយកអង្គការមិនមែនរដ្ឋាភិបាល |
| កុមាររូបអាក្រក់ | អ្នកនៅលីវ | មេដឹកនាំតាមប្រពៃណី |
| បុរសសុចរិត | ម្ចាស់ក្រុមហ៊ុនកសិកម្ម | អ្នកបញ្ចុះបញ្ចូលនៅថ្នាក់ជាតិ |
| បុរសចំណាស់និយាយច្រើន | មានការអប់រំផ្លូវការខ្លះៗ | ប្រធានរដ្ឋបាលថ្នាក់ភូមិ |
| ស្ត្រីពិការភ្នែក | ពាណិជ្ជករក្នុងមូលដ្ឋាន | សមាជិកជាប់ឆ្នោត |
| ក្មេងស្ត្រីអៀនប្រៀន | មានសញ្ញាបត្រថ្នាក់បណ្ឌិត | មេធាវីបរិស្ថាន |
| បំពេញដោយខ្លួនឯង ........... | បំពេញដោយខ្លួនឯង ........... | បំពេញដោយខ្លួនឯង ........... |
| បំពេញដោយខ្លួនឯង ........... | បំពេញដោយខ្លួនឯង ........... | បំពេញដោយខ្លួនឯង ........... |
| បំពេញដោយខ្លួនឯង ........... | បំពេញដោយខ្លួនឯង ........... | បំពេញដោយខ្លួនឯង ........... |

# តើអំណាចជាអ្វី ?

**"អំណាចជាសមត្ថភាពរបស់មនុស្ស ដើម្បីសម្រេចការផ្លាស់ប្តូរមួយតាមការចង់បាន [របស់ពួកគាត់]។ វាមានលក្ខណៈជាឋាមវន្ត ទំនាក់ទំនងធៀប និងពហុសណ្ឋាន។" ១៤**

## តើអ្នកអាចមើលឃើញអំណាចដោយរបៀបណា ?

| | | |
|---|---|---|
| តើវាជាអ្វីមួយដែល "អវិជ្ជមាន" ដោយមានអ្នកខ្លះ មានការត្រួតត្រាលើអ្នកដទៃទៀត ដូចគ្នានឹងការគ្រប់សង្កត់ | ឬ | តើវាជាអ្វីមួយដែល "វិជ្ជមាន" និងចាំបាច់សម្រាប់ទីភ្នាក់ងារ និងសកម្មភាពផលិតកម្ម ? |
| តើវាជាអ្វីមួយដែល "ស្ថិតក្នុង" (មិនស្ថិតក្នុង) ដៃរបស់មនុស្ស (អ្នកមានអំណាច និងអ្នកគ្មានអំណាច) | ឬ | តើវាជាអ្វីមួយដែលជាផ្នែកមួយនៃជីវិតរបស់យើង ក្នុងគ្រប់ទំនាក់ទំនងនិងការថ្លែងហេតុ |
| តើវាជាអ្វីមួយ ជាមួយ "តុល្យភាពសុទ្ធសូន្យ" ពោលគឺ តែងមានអ្នកឈ្នះ-មានអ្នកចាញ់ | ឬ | តើវាជាអ្វីមួយដែលងាយប្រែប្រួល និងអាចបង្កើនបាន និងជាធនធានដែលគ្មានដែនកំណត់ ? |

## ហេតុអ្វីចាំបាច់ឱ្យអ្នកសម្របសម្រួលថ្នាក់មូលដ្ឋានវិភាគអំពីអំណាច ?

ក្រុម និងបុគ្គលនានាអាចសំដែងអំណាចតាមវិធីខុសៗគ្នា។ ដោយសារអំណាចមានការប្រែប្រួលជាប្រចាំ អាស្រ័យលើទំនាក់ទំនងនៅក្នុងក្រុមណាមួយ ឬរវាងអ្នក ពាក់ព័ន្ធនានា ដូច្នេះប្រចាំចាំបាច់ គឺត្រូវស្វែងយល់អំពីរបៀបខុសៗគ្នានៃការសំដែងអំណាច។




"អំណាចលើ" សំដៅលើសមត្ថភាពរបស់ភ្នាក់ងារដែលមានអំណាចធៀប ក្នុងការធ្វើឱ្យមានឥទ្ធិពលមកលើសកម្មភាព ឬ ការគិតរបស់អ្នកដែលមានអំណាចទាបជាង។ ជាញឹកញាប់ត្រូវបានគេមើលឃើញថា ជាការគ្របសង្កត់ ឬ ត្រួតត្រាលើបុគ្គលម្នាក់ ក្រុម ឬ ស្ថាប័នមួយលើស្ថាប័ន ឬ ក្រុមមួយផ្សេងទៀត។ នេះជាការសំដែងអំណាចដែលជាញឹកញាប់ត្រូវបានទទួលស្គាល់ដោយអ្នកខាងក្រៅ និងអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន។

---

១៤ ស្រង់ចេញពី Hunjan, R. and Pettit J. (2011).

**"អំណាចដើម្បី"** សំដៅលើសមត្ថភាពរបស់បុគ្គលក្នុងការធ្វើសកម្មភាព ដើម្បីដំណើរការស្ថាប័ន និង អនុវត្តសក្តានុពលនៃសិទ្ធិភាពជាពលរដ្ឋ ឬសម្លេង។

**"អំណាចនៅក្នុង"** សំដៅលើកំណើនការដឹងអំពីអត្តសញ្ញាណផ្ទាល់ខ្លួនទំនុកចិត្ត និងការដឹងដែល ជាលក្ខខណ្ឌដំបូងសម្រាប់ធ្វើសកម្មភាព។ តាមរយៈការពង្រឹងអំណាចនៅក្នុង បុគ្គលនានាអាចកសាង សមត្ថភាពរបស់ខ្លួន ដើម្បីគិតស្រមៃ និងបង្កើនបំណងប្រាថ្នាអំពីការកែប្រែ។

**"អំណាចជាមួយ"** សំដៅលើភាពបំពេញគ្នា ដែលអាចកើតឡើងតាមរយៈភាពជាដៃគូ និងកិច្ច សហការជាមួយអ្នកដទៃ ឬតាមរយៈដំណើរការនានានៃសកម្មភាពរួមគ្នា និងការបង្កើតសម្ព័ន្ធភាព។ វាជា សមត្ថភាពដើម្បីធ្វើសកម្មភាពជាសមូហភាពដោយធ្វើជាមួយគ្នា។ វាជួយសាងសង់ស្ពានឆ្លងកាត់ចំណាប់ អារម្មណ៍ បទពិសោធន៍ និងចំណេះដឹងខុសៗគ្នា។

ថាមវន្តនៃអំណាច(អ្នកណាមានអំណាចលើអ្នកណា អ្នកណាអាចកសាងអំណាចជាមួយអ្នកណា អាចអនុវត្តអំណាចរបស់ខ្លួន ដើម្បីអ្នកណាមានអារម្មណ៍ថាមាន ឬ គ្មានអំណាចនៅក្នុង) ត្រូវបានឱ្យ និយមន័យនៅក្នុងបរិបទនីមួយៗ និងទំនាក់ទំនងនីមួយៗ។ ឧទាហរណ៍ កសិករតូចតាចម្នាក់រស់នៅក្នុង ភាពក្រីក្រ ងាយរងគ្រោះដោយសារអំណាច និងជួនកាលអំពើហឹង្សាពីសំណាក់អ្នកមានដីធំ និងក្រុមហ៊ុន ពាណិជ្ជកម្មពហុជាតិសាសន៍។ ប៉ុន្តែ ទន្ទឹមនឹងនេះ កសិកររូបនេះអាចបានបង្កើតទំនាក់ទំនងផ្តាច់ការ និង ហឹង្សាជាមួយសមាជិកស្ត្រីក្នុងគ្រួសាររបស់គាត់ ជាពិសេស (ទោះបីមិនសុទ្ធតែបែបនេះ) ប្រសិនបើគាត់ ស្ថិតនៅក្នុងវប្បធម៌បិតាធិបតេយ្យ ដោយមាននិយាម និងការអនុវត្តជាក់លាក់ ដែលពង្រឹង មើលរំលង ឬ គ្មានការគ្រប់គ្រងឥរិយាបថហឹង្សាទាំងនេះ។

តាមប្រវត្តិកន្លងមក នៅក្នុងសហគមន៍ជាច្រើនលទ្ធភាពទទួលបានធនធាន សិទ្ធិ និងការធ្វើសេចក្តី សម្រេចចិត្តបាន ស្ថិតក្រោមអំណាចផ្តាច់មុខដោយមនុស្សមួយក្តាប់តូច។ ការប្រមូលផ្តុំអំណាចបែបនេះ បាននាំឱ្យ ឬរួមចំណែក ធ្វើឱ្យមានភាពក្រីក្រ ភាពទន់ខ្សោយ និងអំពើហឹង្សា ជាទូទៅលើសិទ្ធិមនុស្សរបស់ សហគមន៍ជាក់លាក់ដែលរួមទាំងសហគមន៍ដែលពឹងផ្អែកលើព្រៃឈើផងដែរ។ ប្រការសំខាន់គឺត្រូវបង្វែង និន្នាការបែបនេះ និងនាំយកក្រុម និងបុគ្គលនានាដែលគេផាត់ចោលមកក្នុងវេទិកានៃការធ្វើសេចក្តី សម្រេចចិត្តទន្ទឹមនឹងបម្លែងទស្សនៈ និងការប្រើប្រាស់អំណាចផងដែរ។

នេះជាប្រការដែលពាក់ព័ន្ធនៅក្នុងបរិបទនៃរបៀបវារៈ REDD+ ជាពិសេស នៅក្នុងការធានាថា ក្រុមមនុស្សដែលមិនសូវមានតំណាង និងអ្នកដែលពឹងផ្អែកលើធនធានព្រៃឈើសម្រាប់របរចិញ្ចឹមជីវិត របស់ខ្លួន ត្រូវបានទទួលស្គាល់ និងរួមបញ្ចូលយ៉ាងសមស្របទៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តជា ពិសេស ដែលទាក់ទងនឹងរបរចិញ្ចឹមជីវិត និងការចែកផល។

គឺប្រយោគអំពីអំណាចទាំងបីខាងក្រោយ (ក្នុងចំណោមបួន) ដែលអ្នកសម្របសម្រួលនៅថ្នាក់ មូលដ្ឋានអាចកៀងគរបាន។ ប្រសិនបើ អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានបានកំណត់អត្តសញ្ញាណ អ្នកពាក់ព័ន្ធជាក់លាក់ ដែលនៅពុំទាន់បានពាក់ព័ន្ធយ៉ាងមានអត្ថន័យ នៅក្នុងដំណើរការ REDD+

និងជាអ្នកដែលសមធម៌ បានក្លាយជាកង្វល់ដែលទាក់ទងនឹងសិទ្ធិ អត្ថប្រយោជន៍ និងការចូលរួម ដូច្នេះ ការប្រើប្រាស់យុទ្ធសាស្រ្តនានា ដើម្បីកៀងគរអំណាច "នៅក្នុង" និង "ជាមួយ" មានសារៈសំខាន់ណាស់។ ដំណើរការនៃការពាក់ព័ន្ធបែបច្នៃប្រឌិត មានគោលដៅកសាងអំណាចនៅក្នុងក្រុមអ្នកទន់ខ្សោយតាមរយៈបច្ចេកទេសខុសៗគ្នា។

### ការប្រើប្រាស់ការវិភាគអំណាចអាចជួយអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានដើម្បី៖

- ស្វែងយល់ពីយុទ្ធសាស្រ្តពង្រឹងសិទ្ធិអំណាច និងវិធីថ្មីៗនៃការធ្វើការជាមួយមណ្ឌលអ្នកគាំទ្រ
- មានការវិភាគកាន់តែស៊ីជម្រៅអំពីបញ្ហានេះ ដែលអង្គការនេះកំពុងដោះស្រាយ និងសាកល្បងការសន្មតអំពីថា តើការកែប្រែនឹងអាចសម្រេចបានដោយរបៀបណា និង
- ស្វែងយល់ពីយុទ្ធសាស្រ្តថ្មីៗសម្រាប់ការកែប្រែ។

### ទម្រង់នៃអំណាច

នេះជាធាតុផ្សំ**ដំបូង**ដែលត្រូវពិចារណា ទាក់ទងនឹងក្រុមអ្នកពាក់ព័ន្ធរបស់អ្នក។

**អំណាចដែលមើលឃើញ** រួមបញ្ចូលទិដ្ឋភាពនានានៃអំណាចនយោបាយដែលយើង "ឃើញ" - បទបញ្ញាផ្លូវការ រចនាសម្ព័ន្ធ គ្រឹះស្ថាន និងនីតិវិធី ដែលជូនដំណឹងដល់ដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ ក្រុមអ្នកទន់ខ្សោយខ្លះៗនៅក្នុងសង្គម ពុំដែល "មើលឃើញ" ទម្រង់នេះនៃអំណាចឡើយ។

**អំណាចបង្កប់**ត្រូវបានអនុវត្តតាមរយៈអ្នកមានអំណាច និងស្ថាប័នដែលមានអំណាច ដើម្បីរក្សាឥទ្ធិពលរបស់ខ្លួន ដោយបង្កើត និងកែប្រែរបៀបវារៈ និងមើលរម្លងកង្វល់ និងទស្សនៈនានារបស់ក្រុមអ្នកមិនសូវមានអំណាច។ វាក៏អាចពាក់ព័ន្ធនឹងសម្លេងរបស់អ្នកទន់ខ្សោយ ដែលពុំមានអ្នកឮ ឬពិចារណាឡើយ នៅក្នុងការរៀបចំគម្រោងស្តីពីព្រៃឈើ ឬ REDD+។

**អំណាចមើលមិនឃើញ** ប្រតិបត្តិការតាមវិធីនានាដែលក្នុងនោះ ប្រជាជនប្រកាន់យកទម្លាប់អនុវត្តតាមប្រពៃណី ដែលត្រូវបានបង្កើតឡើងដោយអ្នកដែលមានអំណាចច្រើនជាង។ មនុស្សទាំងឡាយអាចពុំដឹងអំពីសិទ្ធិរបស់ខ្លួន និងសមត្ថភាពរបស់ខ្លួន ក្នុងការនិយាយ និងអាចមើលឃើញទម្រង់ខុសៗគ្នានៃអំណាច ឬការគ្របសង្កត់មកលើពួកគាត់តាម "ធម្មជាតិ" ឬយ៉ាងហោចណាស់ មិនអាចកែប្រែបាន និងមិនអាចជៀសវាងបាន។

### លំហអំណាច

អំណាចត្រូវបានអនុវត្តតាមរយៈប្រជាជន តាមវិធីខុសៗ គ្នានៅក្នុងបរិបទណាមួយ។ ការយល់អំពីសំណុំលក្ខណៈនៃវេទិកាដែលក្នុងនោះមនុស្សខុសៗគ្នាអនុវត្តអំណាចរបស់ខ្លួន មានសារៈសំខាន់ណាស់

ដោយសារវាជួយ ក្នុងការកំណត់អត្តសញ្ញាណចំណុចចាប់ផ្តើម សម្រាប់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ដើម្បីផ្តួចផ្តើមដំណើរការកែប្រែ។ "លំហ" ត្រូវបានប្រើប្រាស់នៅទីនេះ ដើម្បីពន្យល់អំពីឱកាសសម្រាប់អន្តរអំពើជាផ្លូវការ និងមិនផ្លូវការ ដើម្បីជួយមនុស្សទាំងឡាយឱ្យមានឥទ្ធិពលមកលើសេចក្តីសម្រេចចិត្ត និងបទបញ្ញានានា ដែលមានឥទ្ធិពល ឬ ប៉ះពាល់មកលើជីវិតរបស់ពួកគាត់។

លំហបិទ គឺជាលំហដែលក្នុងនោះ ការសម្រេចចិត្តនានា បានធ្វើឡើងនៅក្នុងទីកន្លែងបិទទ្វារ - ជាញឹកញាប់ដោយគ្មានផ្តល់ឱកាសសម្រាប់ការរួមបញ្ចូល។ នេះអាចរាប់បញ្ចូលលំហផ្លូវការដែលបើកចំហសម្រាប់តែអ្នកនៅក្នុងតំណែងផ្លូវការ ឬ តំណាងផ្លូវការប៉ុណ្ណោះ។

### រូបទី ១០៖ គូបអំណាច សម្រាប់វិភាគជាតុផ្សំនានានៃអំណាច




**លំហអញ្ជើញ** គឺជាលំហដែលក្នុងនោះអាជ្ញាធរខុសៗគ្នា ស្នើឱ្យប្រជាជនចូលរួមនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ក្នុងនាមជាពលរដ្ឋ អ្នកទទួលផល ឬ អ្នកប្រើប្រាស់។ ទោះបីលំហទាំងនេះអាចក្លាយជាឱកាសសម្រាប់កិច្ចសហការពិតប្រាកដក៏ដោយ របៀបវារៈនានាច្រើនត្រូវបានសម្រេចជាមុន។

**លំហបង្កើត ឬ ទាមទារ** គឺលំហនានាដែលក្នុងនោះមនុស្សមានអំណាចតិចតួចមកជួបជុំគ្នា ដើម្បីបង្កើតលំហផ្ទាល់របស់ខ្លួន និងកំណត់របៀបវារៈរបស់ខ្លួន។ នេះរាប់បញ្ចូលឧទាហរណ៍នានានៃចលនាសង្គម និងយុទ្ធនាការរបស់អ្នកមូលដ្ឋាន។

### កម្រិតអំណាច

ការផ្លាស់ប្តូរអំណាចនៅតាមលំដាប់ខ្សែឈរ - ពិភពលោក តំបន់ជាតិ មូលដ្ឋាន សហគមន៍ លំនៅស្ថាន និងគ្រួសារ។ ឋាមវន្ត និងទំនាក់ទំនងមានភាពខុសគ្នា សម្រាប់កម្រិតនីមួយៗ។ វាជួយដល់អ្នក

សម្របសម្រួលនៅថ្នាក់មូលដ្ឋាន ដើម្បីយល់ដឹងអំពីថា តើអំណាចប្រែប្រួលបែបណារវាងលំដាប់ថ្នាក់ខុសៗគ្នា។

### តារាងទី ៥៖ ក្របខ័ណ្ឌមួយសម្រាប់ការពង្រឹងសិទ្ធិអំណាច

| | |
|---|---|
| **ទម្រង់នៃអំណាច** | លើកឡើងអំពីទម្រង់អំណាចបង្កើត និងមិនអាចមើលឃើញនៅគ្រប់លំដាប់ថ្នាក់ និងលំហ។ ចូរអ្នកធ្វើឱ្យអំណាចទាំងនោះអាចមើលឃើញបានតាមរយៈ ការបញ្ចុះបញ្ចូល និងការតស៊ូមតិ។ |
| **លំហនៃអំណាច** | ពង្រឹងស្ថាប័ន (មិន) ផ្លូវការ។ ចូរតភ្ជាប់ខ្សែដេកដោយកសាងខ្សែចង្វាក់គណនេយ្យភាព។ |
| **លំដាប់ថ្នាក់នៃអំណាច** | កៀងគរសមត្ថភាពនៅគ្រប់លំដាប់ថ្នាក់។ តភ្ជាប់តាមខ្សែឈរដោយកសាងសម្ព័ន្ធភាព និងបណ្តាញ។ |

# ឃ. ការបើកចំហប្រអប់ឧបករណ៍សម្រាប់ បង្កើតការពាក់ព័ន្ធ

គោលបំណងនៃការរៀនសូត្រ

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹង៖

- អាចពន្យល់អំពីមុខងារនៃឧបករណ៍ខុសៗគ្នា នៅក្នុងដំណើរការនៃការពាក់ព័ន្ធ ដើម្បីលើកកម្ពស់សមធម៌។
- កត់ត្រា ឧ ប ករណ៍ទាំងអស់ ដែលពួកគាត់បានប្រើប្រាស់នៅក្នុងដំណើរការធ្វើឱ្យពាក់ព័ន្ធរបស់ពួកគាត់ផ្ទាល់ និងអត្ថប្រយោជន៍នៃការប្រើប្រាស់ឧបករណ៍ទាំងនោះ
- វិភាគ ថា តើឧបករណ៍ណាខ្លះ ដែលអ្នកសម្របសម្រួលថ្នាក់មូលដ្ឋានបានប្រើប្រាស់ច្រើន ឬ តិចជាងគេ និង
- កំ ណត់ថា តើឧបករណ៍ណាខ្លះ មានប្រសិទ្ធភាពបំផុតនៅក្នុងការការធ្វើឱ្យពាក់ព័ន្ធតាមបែបច្នៃប្រឌិត ដើម្បីលើកកម្ពស់សមធម៌។

សម្ភារៈ

ក្រដាសផ្ទាំងធំ ហ្វឺត ប៊ិច បណ្ណក្រដាស Post-it ស្កុត និងរូបត្រីកោណ នៅលើក្រដាសផ្ទាំងធំសម្រាប់ក្រុមនីមួយៗ




រយៈពេល

៦០នាទី

---

## ជំហានអនុវត្ត

១. បង្ហាញមេរៀននេះ ដោយពន្យល់ថា ការយកចិត្តទុកដាក់ គឺទៅលើឧបករណ៍នានាដែលអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានអាចប្រើប្រាស់សម្រាប់ធ្វើឱ្យមានការពាក់ព័ន្ធបានប្រសើរជាងមុន នៃអ្នកពាក់ព័ន្ធនៅមូលដ្ឋាន។

២. សួរសិក្ខាកាមថា តើពួកគាត់យល់ថាពាក្យ "ឧបករណ៍" មានន័យបែបណា និងស្នើឱ្យពួកគាត់ផ្តល់ឧទាហរណ៍ (ញញួរ ម៉ាឡេត)។ សូមស្នើពួកគាត់ឱ្យផ្តល់ឧទាហរណ៍អំពីឧបករណ៍សម្របសម្រួល ដែលបានប្រើប្រាស់រួចមក ហើយនៅក្នុងវគ្គបណ្តុះបណ្តាលនេះ។



៣. បែងចែកសិក្ខាកាមជាក្រុម។ ស្នើក្រុមនីមួយៗចំណាយពេល ១០នាទី ដើម្បីវាយតម្លៃដោយរហ័ស ដើម្បីកំណត់រកឧបករណ៍នៃការធ្វើឱ្យមានការពាក់ព័ន្ធខុសៗគ្នា ដែលពួកគាត់ធ្លាប់បានប្រើប្រាស់ពីមុនមកក្នុងនាមជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន។ ស្នើឱ្យពួកគាត់សរសេរឧបករណ៍ទាំងនោះនៅលើប័ណ្ណដោយសរសេរឧបករណ៍មួយលើប័ណ្ណមួយសន្លឹក។

៤. ១០នាទី ក្រោយមក សូមឱ្យពួកគាត់ពិភាក្សាអំពីឧបករណ៍ទាំងនោះជាមួយគ្នា។

៥. ផ្តល់ក្រដាសផ្ទាំងធំមួយសន្លឹកដល់ក្រុមនីមួយៗ ដែលមានរូបត្រីកោណធំមួយដែលបានគូសរួចជាស្រេច។

៦. ស្នើឱ្យក្រុមនីមួយៗប្រើប្រាស់រូបត្រីកោណ ដើម្បីដាក់ឧបករណ៍របស់ខ្លួនទៅតាមកម្រិតដែលបានប្រើប្រាស់ញឹកញាប់។ ចូរពន្យល់ថា ការដែលបានបញ្ជាក់អំពីឧបករណ៍នានា និងរបៀបដែលប្រើប្រាស់ឧបករណ៍ទាំងនោះជាមួយក្រុមរបស់ពួកគាត់ សិក្ខាកាមគួរតែពិភាក្សា និងឯកភាពអំពីថាតើឧបករណ៍ណាខ្លះ ដែលបានប្រើប្រាស់ញឹកញាប់ជាងគេ និងដាក់ឧបករណ៍ទាំងនោះនៅបាតត្រីកោណ។ សូមណែនាំពួកគាត់ឱ្យដាក់ឧបករណ៍នានា ដែលប្រើប្រាស់តិចជាងគេនៅកំពូលត្រីកោណ។

៧. ក្រោយពេលដែលពួកគាត់បានបិទភ្ជាប់ប័ណ្ណទាំងនេះហើយចូរស្នើឱ្យក្រុមនីមួយៗបិទភ្ជាប់ក្រដាសផ្ទាំងធំនីមួយៗ ជាមួយគំនិតរបស់ពួកគាត់ដែលបានរៀបចំឡើងជិតគ្នានៅលើជញ្ជាំង។

៨. ទុកពេល ៥នាទី សម្រាប់សិក្ខាកាម ដើម្បីអានក្រដាសផ្ទាំងធំរបស់ក្រុមដទៃ ស្នើឱ្យមានការឆ្លុះបញ្ចាំងតាមសំណួរដូចតទៅ៖

- *តើឧបករណ៍ទាំងនេះដូចគ្នា ឬខុសគ្នា?*
- *តើឧបករណ៍ណាខ្លះដែលបានកត់សំគាល់នៅក្នុងគ្រប់ក្រុមទាំងអស់?*
- *តើឧបករណ៍ណាខ្លះមានលក្ខណៈដោយឡែក? ហេតុអ្វីទើបអ្នកគិតថា មានលក្ខណៈដោយឡែកពីគេ?*
- *ហេតុអ្វីឧបករណ៍ខ្លះត្រូវបានប្រើប្រាស់ញឹកញាប់ជាឧបករណ៍ដទៃទៀត?*
- *តើអ្នកគិតថា ឧបករណ៍នានាត្រូវបានប្រើប្រាស់ញឹកញាប់ ដោយសារវាមានប្រសិទ្ធភាពឬអ្វី? ហេតុអ្វីទើបអ្នកគិតបែបនេះ?*
- *តើឧបករណ៍ណាខ្លះដែលប្រើប្រាស់តិចជាងគេ និងហេតុអ្វី?*
- *តើអ្នកបានរៀនអ្វីខ្លះអំពីឧបករណ៍នានា ក្នុងនាមជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន?*
- *តើអ្នកធ្លាប់បានបង្កើតឧបករណ៍នានាដោយខ្លួនឯងឬទេ?*

- *តើជម្រើសឧបករណ៍របស់មានឥទ្ធិពលបែបណាលើគុណភាពនៃដំណើរការពាក់ព័ន្ធ និងការចូលរួមរបស់អ្នក?*

៩. ចូរបូកសរុបវគ្គនេះ ដោយពន្យល់ថា អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានជាច្រើនពុំប្រើប្រាស់ឧបករណ៍នានាដោយច្នៃប្រឌិតតាមតែពួកគាត់អាចធ្វើបាននោះឡើយ។ ចូរបញ្ជាក់ថាឧបករណ៍ថ្មីៗគួរតែបានបង្កើត និងសាកល្បង ដើម្បីជំរុញក្រុមនានា ជាពិសេសសហគមន៍មូលដ្ឋានដែលអាចជាអ្នកទន់ខ្សោយ ឬដែលទស្សនៈរបស់ពួកគាត់អាចមិនទាន់មានអ្នកយកចិត្តទុកដាក់ស្តាប់ទៅរកកម្រិតមួយនៃការពាក់ព័ន្ធដែលអាចធ្វើឱ្យមានភាពខុសគ្នា និងផ្តល់ទំនុកចិត្តសម្រាប់ការសំដែងអំពីខ្លួនឯង និងភាពតជាប់គ្នា។ ចូរបញ្ចប់ដោយពន្យល់ថា មេរៀននេះមានគោលដៅពិនិត្យមើលបទពិសោធន៍កន្លងមករបស់សិក្ខាកាមនៅក្នុងការប្រើប្រាស់ឧបករណ៍នានា ប៉ុន្តែនឹងមានមេរៀនបន្តបន្ទាប់ទៀតដែលនឹងផ្តោតលើរបៀបបង្កើតដំណើរការនៃការពាក់ព័ន្ធ និងការដាក់ឱ្យប្រើប្រាស់ឧបរណ៍ថ្មីៗមួយចំនួន។

---

## កំណត់សំគាល់របស់គ្រូបង្វាត់

សិក្ខាកាមច្រើនតែមានការច្របូកច្របល់អំពីឧបករណ៍ វិធី និងវិធាន។ ចូរជៀសវាងការកំណត់និយមន័យ ឬ កំហិតលើវិសាលភាពនៃការយល់ដឹងរបស់ពួកគាត់ អំពីឧបករណ៍ និងគ្រាន់តែលើកទឹកចិត្តពួកគាត់ឱ្យគិតអំពីគ្រប់ទម្រង់ដែលពួកគាត់បានប្រើប្រាស់ នៅក្នុងដំណើរការបង្កើតការពាក់ព័ន្ធរបស់ពួកគាត់ប៉ុណ្ណោះ បើទោះជាវាជាឧបករណ៍ វិធី ឬវិធានក៏ដោយ សម្រាប់ពួកគាត់។

គ្មានឯកសារអំណានសម្រាប់ផ្តល់ឱ្យពួកគាត់ឡើយនៅក្នុងមេរៀននេះ ដោយសារវាជាមេរៀនឆ្លុះបញ្ចាំងមួយប៉ុណ្ណោះ។ មេរៀននេះអាចរួមបញ្ចូល ឬ ផ្សារភ្ជាប់យ៉ាងជិតស្និទ្ធនៅក្នុងលំដាប់លំដោយមួយជាមួយមេរៀនស្តីពីការរៀបចំដំណើរការនៃការពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព។ គ្រូបង្ហាត់គួរតែបង្កើតចំណងទាក់ទងនេះឱ្យបានច្បាស់នៅក្នុងមេរៀននេះ។

# ខ. ការរៀបចំដំណើរការនៃការពាក់ព័ន្ធមួយ ឱ្យមានប្រសិទ្ធភាព

**គោលបំណងនៃការរៀនសូត្រ**

នៅចុងបញ្ចប់នៃមេរៀននេះសិក្ខាកាមនឹង៖

- ពន្យល់អំពីគុណតម្លៃនៃភាពច្នៃប្រឌិត នៅក្នុងការរៀបចំដំណើរការនៃការចូលរួមមួយ សម្រាប់អ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន
- អាចពន្យល់អំពីគុណតម្លៃនៃគោលគំនិត អំពីរចនាបថនៅពេលរៀបចំផែនការ សម្រាប់ដំណើរការចូលរួមសម្រាប់អ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន
- អាចឆ្លុះបញ្ចាំងអំពី ភាពច្នៃប្រឌិតផ្ទាល់ខ្លួន ក្នុងនាមជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន នៅពេលដែលរៀបចំ និងសម្របសម្រួល ដំណើរការនៃការពាក់ព័ន្ធមួយ និង
- អនុវត្តការរៀបចំដំណើរការនៃការពាក់ព័ន្ធ ដែលរួមទាំងការបង្កើតគោលបំណង លំហ ឬ នៃដំណើរការ និងការជ្រើសរើស ឧបករណ៍ដែលមានប្រសិទ្ធភាព សម្រាប់ដំណើរការនោះ និងបានទទួលយោបល់តបអំពីការរៀបចំដំណើរការ នៃការ ពាក់ព័ន្ធនោះ។

**សម្ភារៈ**

ក្រដាសផ្ទាំងធំ ហ្វឺត ប័ណ្ណ ក្រដាស Post-it ស្កុត ឧបករណ៍សម្រាប់ការចូលរួម ដែលបានបោះពុម្ពនៅលើបំណែកនៃសន្លឹកក្រដាស និងដាក់ក្នុងស្រោមសំបុត្រ វីដេអូ ពីBobby McFerrin (ចំពោះគន្លឹះភ្ជាប់ទៅវេបសាយ សូមអានកំណត់សំគាល់របស់គ្រូបង្ហាត់) និងឯកសារអំណាន។

**រយៈពេល**

១៨០ នាទី

---

## ជំហានអនុវត្ត

**១.** បង្ហាញវគ្គនេះដោយពន្យល់ថា ការយកចិត្តទុកដាក់គឺផ្តោតលើការរៀបចំដំណើរការនៃការចូលរួមបែបច្នៃប្រឌិត។

**២.** សួរសិក្ខាកាមថា តើពួកគាត់យល់ពាក្យ "ច្នៃប្រឌិត" ថាមានន័យយ៉ាងណា និងហេតុអ្វីការពាក់ព័ន្ធតម្រូវឱ្យមានការច្នៃប្រឌិត។ ចូរសរសេរចម្លើយរបស់ពួកគាត់នៅលើផ្ទាំងក្រដាស។

៣. បង្ហាញដល់សិក្ខាកាមវីដូអប្ញ Bobby McFerrin ។ ក្រោយទស្សនាវីដេអូ សូមផ្តល់ឱ្យសិក្ខាកាមនូវសំណួរឆ្លុះបញ្ចាំងដូចទៅ៖

- *តើអ្នកគិតថា មនុស្សទាំងនេះកំពុងប្រាប់យើងអំពីការធ្វើឱ្យមានការពាក់ព័ន្ធឬអ្វី?*
- *តើពួកគាត់ធ្វើបែបណា ដើម្បីភ្ជាប់ទំនាក់ទំនងនៃអ្វីដែលពួកគាត់និយាយជាមួយការលើកកម្ពស់សមធម៌?*
- *តើអ្នកយល់ថា ភាពច្នៃប្រឌិតអាចជួយបែបណាដែរដល់ដំណើរការនៃការចូលរួម?*
- *តើអ្នកធ្វើយ៉ាងណាដើម្បីឱ្យប្រាកដថា អ្នកបានធ្វើឱ្យ "បុគ្គលទាំងអស់" ពាក់ព័ន្ធនៅក្នុងដំណើរការចូលរួមរបស់អ្នក?*
- *ការឆ្លុះបញ្ចាំងអំពីឧបករណ៍ដែលអ្នកប្រើប្រាស់ជាញឹកញាប់ ដែលបានគូសបញ្ជាក់នៅក្នុងមេរៀននេះស្តីពី ប្រអប់ឧបករណ៍ពាក់ព័ន្ធ តើឧបករណ៍ណាខ្លះ ដែលធ្វើឱ្យបុគ្គលទាំងមូលពាក់ព័ន្ធ?*
- *តើអ្នកអាចធ្វើបែបណា ដើម្បីរួមបញ្ចូលឧបករណ៍នានានៅក្នុងដំណើរការដើម្បីធ្វើឱ្យមនុស្សទាំងឡាយពាក់ព័ន្ធកាន់តែមានប្រសិទ្ធភាព?*
- *ហេតុអ្វីអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន ជួនកាលមិនទទួលយកដំណើរការបែបច្នៃប្រឌិត?*
- *តើធ្វើអាចដាក់ពិន្ទុប៉ុន្មានសម្រាប់ដំណើរការច្នៃប្រឌិតរបស់អ្នក ក្នុងនាមជាអ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន នៅលើមាត្រដ្ឋាន ពី ១ ដល់ ១០?*

៤. ចូរពន្យល់ថា មេរៀននេះនឹងផ្តល់ឱ្យសិក្ខាកាមនូវឱកាសដើម្បីគ្រោង និងរៀបចំដំណើរការនៃការពាក់ព័ន្ធដែលសមហេតុផលជាមួយក្រុមរបស់ខ្លួន ដើម្បីពិចារណាថា តើពួកគាត់អាចរួមបញ្ចូលភាពច្នៃប្រឌិតបានដោយរបៀបណា និងដើម្បីធ្វើឱ្យបុគ្គលនានាចូលរួមពេញលេញ (ពេលគឺពាក់ព័ន្ធទាំងខាងគំនិត បេះដូង និងការរំជួលចិត្ត ជំនាញ ។ល។) នៅក្នុងដំណើរការនេះ។ ចូរពន្យល់ថា ការធ្វើឱ្យបុគ្គលពាក់ព័ន្ធទាំងមូល គឺត្រូវជានាថា ការចូលរួមបានផ្អែកលើគុណតម្លៃស្នូលចំនួនបួន (ការចូលរួមពេញលេញ ការយោគយល់គ្នា ដំណោះស្រាយជាបរិយាប័ន្ន/ គោលដៅដែលបានឯកភាពគ្នាជាបរិយាប័ន្ន និងការទទួលខុសត្រូវរួម)។

៥. ប្រសិនបើចាំបាច់ ចូររំលឹកអំពីធាតុផ្សំនានាដែលបានសិក្សារួចមកហើយ ក្នុងមេរៀនមុនៗនៃវគ្គបណ្តុះបណ្តាលនេះ ដែលទាក់ទងនឹងការសម្របសម្រួល និងការពាក់ព័ន្ធ (ឧបសគ្គ និងគុណតម្លៃនៃការចូលរួម នៅក្នុងក្រុមមេរៀនទី១) តួនាទី និងជំនាញរបស់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន (ក្នុងក្រុមមេរៀនទី២) ប្រអប់នៃការពាក់ព័ន្ធ ដែលបានបង្ហាញរបៀប ដែលធាតុផ្សំនានាជួយបង្កើតការ



ពាក់ព័ន្ធបែបច្នៃប្រឌិត និងប្រអប់ឧបករណ៍នៃការពាក់ព័ន្ធ ដែលផ្សំដោយឧបករណ៍ និងវិធីនានា ដែលអាចជួយនៅក្នុងការរៀបចំដំណើរការប្រកបដោយប្រសិទ្ធភាព (ក្រុមមេរៀនទី ៣)។

៦. ចែកសិក្ខាកាមជាបីក្រុម។ ចូរផ្តល់ឱ្យក្រុមនីមួយៗនូវគោលដៅរួមខុសគ្នាសម្រាប់ដំណើរការនៃការពាក់ព័ន្ធ ដើម្បីលើកកម្ពស់សមធម៌ ដែលពួកគាត់នឹងត្រូវបង្កើត។ ចូរពន្យល់សេចក្តីណែនាំនានាដូចដែលមាននៅក្នុងសន្លឹកលំហាត់ ជូនដំណឹងដល់សិក្ខាកាមថាមានការផ្តល់ឧបករណ៍មួយចំនួនដល់ពួកគាត់ (នៅក្នុងប្រអប់ឧបកណ៍សម្រាប់ធ្វើឱ្យមានការពាក់ព័ន្ធ) នៅក្នុងស្រោមសំបុត្រ។ ប៉ុន្តែពួកគាត់អាចប្រើប្រាស់ឧបករណ៍ផ្សេងតាមការចាំបាច់ ដោយសារពួកគាត់មានគំនិតផ្ទាល់ខ្លួនរួចហើយ។ ពួកគាត់ពុំចាំបាច់ប្រើប្រាស់ឧបករណ៍ទាំងអស់នៅក្នុងស្រោមសំបុត្រឡើយ។ ទោះជាយ៉ាងណាក៏ដោយ ចូរកត់សំគាល់ថា អ្នកចង់ឃើញដំណើរការមួយដែលមានភាពប្រាកដប្រជា ប៉ុន្តែមានលក្ខណៈខុសគ្នា និងបែបច្នៃប្រឌិត។ ក្នុងករណីខ្លះ គេអាចត្រូវការឱ្យមានការពន្យល់បំភ្លឺបន្ថែមទៀត។




៧. មុននឹងផ្តល់ឱ្យក្រុមនីមួយៗ ស្រោមសំបុត្ររបស់ពួកគាត់ ចូរពន្យល់ថា អ្នកចង់ផ្តល់ឱ្យពួកគាត់នូវគន្លឹះមួយចំនួន អំពីរបៀបរៀបចំដំណើរការនៃការពាក់ព័ន្ធមួយដែលមានប្រសិទ្ធភាព។ សូមសួរសិក្ខាកាមថា តើពួកគាត់យល់ដឹងអ្វីខ្លះ អំពីពាក្យ"ដំណើរការ"និងហេតុអ្វីអ្នកប្រើប្រាស់ពាក្យនេះ។ សួរសិក្ខាកាម ហេតុអ្វីអ្នកប្រើប្រាស់ពាក្យ "រៀបចំដំណើរការ" និងមិនប្រើពាក្យ "ផែនការ/គ្រោង"។ ក្រោយពួកគាត់បានផ្តល់ចម្លើយចូរពន្យល់ថា ពាក្យ "រៀបចំ" ក្នុងន័យនេះត្រូវបានប្រើប្រាស់ដើម្បីបញ្ជូនដំណើរការប្រកបដោយការយល់ដឹង (ជំហានតាមលំដាប់លំដោយសមហេតុផល) អំពីការរៀបចំផែនការបែបច្នៃប្រឌិតដែលមានមុខងារ និងគោលដៅច្បាស់លាស់។ វាមានន័យថា ជំហាននានាត្រូវតែចាត់ចែងឡើងតាមលំដាប់លំដោយ ហើយឧបករណ៍ជាក់លាក់ត្រូវតែជ្រើសយកសម្រាប់សម្រេចគោលដៅនៃដំណើរការរបស់អ្នក។

៨. ចូរពន្យល់ថា អ្នករៀបចំដំណើរការណាមួយ ត្រូវទទួលស្គាល់អំពីជំហានដូចខាងក្រោមនេះ នៅក្នុងការពិចារណាអំពីដំណើរការមួយ៖ កំណត់អំពីបរិបទ ផ្តល់គំនិតប្លែកៗគ្នា បង្កើតការយោគយល់គ្នា និងការគិតគូរបញ្ចូលគ្នាឆ្ពោះទៅកំណត់សកម្មភាព។ចូរពន្យល់ថានេះជា "សសរទ្រូង" នៃរចនាបថដំណើរការនានា ហើយពួកគាត់គួរតែពិចារណាសសរទ្រូងនេះនៅក្នុងរចនាបថនៃដំណើរការរបស់ពួកគាត់។

៩. ចូរផ្តល់ឱ្យក្រុមនីមួយៗនូវស្រោមសំបុត្រ ដែលក្នុងនោះមានឧបករណ៍នានា និងពន្យល់ថាពួកគាត់មានពេល ៤៥នាទី ដើម្បីរៀបចំដំណើរការរបស់ពួកគាត់ និងបង្កើតជាផែនទីដែលអាចមើលឃើញអំពីដំណើរការនេះ។ ពួកគាត់ត្រូវបង្ហាញជូនដំណើរការនេះដល់ក្រុមដទៃ។ សូមលើកទឹកចិត្តដល់ក្រុមនានាដើម្បីធ្វើការដកស្រង់ពិសោធន៍ និងប្រើប្រាស់ប័ណ្ណ និងក្រដាស Post-it ដើម្បីបង្កើតដំណើរការរបស់ពួកគាត់ ជាជាងសរសេរនៅលើក្រដាសផ្ទាំងធំដោយផ្ទាល់។ ចូរពន្យល់ថា នេះគឺជាផ្នែកមួយនៃដំណើរការរៀបចំដែលនឹងអនុញ្ញាតឱ្យមានការពិចារណានិងកែសម្រួលលំដាប់លំដោយនានា។

១០. ក្រោយរយៈពេល ៤៥នាទី សូមស្នើក្រុមនីមួយៗបិទភ្ជាប់ក្រាហ្វិកលំហូររចនាបថនៃដំណើរការរបស់ពួកគាត់លើជញ្ជាំង។ សូមផ្តល់ពេល ១០នាទី ដើម្បីពិនិត្យមើលលំហូរនៃរចនាបថរបស់គ្នាទៅវិញទៅមក។ ត្រូវបញ្ជាក់ច្បាស់ថា ក្រុមនីមួយៗត្រូវបានផ្តល់ឱកាសដើម្បីរៀបចំដំណើរការនៃការពាក់ព័ន្ធនេះ សម្រាប់គោលដៅខុសៗគ្នា ដែលមានន័យថា ពួកគាត់ទំនងជាប្រើប្រាស់ឧបករណ៍ដូចគ្នាតាមវិធីខុសគ្នា។

១១. ស្នើឱ្យក្រុមនីមួយៗបង្ហាញលំហូរដំណើរការរបស់ពួកគាត់សម្រាប់រយៈពេល ២-៣នាទី ដោយក្រុមនីមួយៗត្រូវផ្តោតលើហេតុផលសម្រាប់រចនាបថនៃដំណើរការនេះ និងការបញ្ជាក់ពីមូលហេតុនៃការជ្រើសយកឧបករណ៍ទាំងនេះ តែមិនពន្យល់ពិស្តារអំពីប្រធានបទនេះ ឬ បរិបទនៃក្រុមនានាដែលជាគោលដៅនៃការរៀបចំដំណើរការនេះឡើយ។

១២. សូមផ្តល់ឱ្យសិក្ខាកាមម្នាក់ៗនូវឱកាស ដើម្បីលើកសំណួរអំពីលំហូរនៃដំណើរការរបស់គ្នាទៅវិញទៅមក។ សូមរំលឹកពួកគេឱ្យផ្តោតលើក្រាហ្វិកនៃលំហូរ និងឧបករណ៍តែប៉ុណ្ណោះ។ ក្នុងពេលស្តាប់បទបង្ហាញនីមួយៗ សូមផ្តោតលើថា តើគោលបំណង និងជំហាននានាត្រូវបានរៀបចំតាមលំដាប់លំដោយ និងបែបច្នៃប្រឌិតឬទេ។

១៣. ក្រោយពេលដែលក្រុមទាំងអស់បានធ្វើបទបង្ហាញរបស់ខ្លួនរួចហើយ សូមធ្វើការឆ្លុះបញ្ចាំងតាមសំណួរដូចតទៅ៖

- *តើអ្នកមានអារម្មណ៍បែបណាក្នុងការធ្វើលំហាត់នេះ ?*
- *តើអ្នកយល់ថាមានអ្វីខ្លះដែលលំបាកឬងាយស្រួលសម្រាប់អ្នក និងហេតុអ្វី ?*
- *តើដំណើរការនេះ ខុសគ្នាពីរបៀបដែលអ្នករៀបចំដំណើរការនៃការពាក់ព័ន្ធ តាមបែបធម្មតាដែរ ឬ ទេ ?*
- *តើអ្នកដាក់ពិន្ទុបែបណា ចំពោះក្រុមរបស់អ្នកទៅលើភាពច្នៃប្រឌិតគិតតាមមាត្រាដ្ឋានពី ១ ដល់ ១០ ?*

- *តើអ្នកចាត់ចែងការរៀបចំ និងការដាក់ដាលំដាប់លំដោយបែបណានូវដំហាន និងគោលបំណងនានា ?*
- *តើគោលបំណងនានាបានជួយអ្នកបែបណា ក្នុងការជ្រើសរើសឧបករណ៍នានា ?*
- *តើអ្នកជ្រើសយកឧបករណ៍អ្វីខ្លះ និងហេតុអ្វី ?*
- *តើវាបានជួយដល់ការរៀបចំជារចនាសម្ព័ន្ធជាក់លាក់ សម្រាប់រចនាបថនៃដំណើរការរបស់អ្នក ឬ ទេ ?*
- *តើអ្នកគិតថាអ្នកអាចប្រើប្រាស់បច្ចេកទេសបែបនេះ ដើម្បីបង្កើតដំណើរការនៃការធ្វើឱ្យពាក់ព័ន្ធសម្រាប់បរិបទរបស់អ្នកឬទេ (ដូចជាក្នុងគម្រោងរបស់អ្នក) ?*
- *តើដំណើរការបង្កើតការពាក់ព័ន្ធ ដែលអ្នកបានរៀបចំឡើងមានភាពប្រាកដប្រជាកម្រិតណា ? តើអ្នកនឹងប្រើប្រាស់ឧបករណ៍នេះនៅក្នុងបរិបទ REDD+ ឬទេ ? ទោះប្រើឬ មិនប្រើ ហេតុអ្វី ?*
- *តើអាចមានឧបសគ្គអ្វីខ្លះ ក្នុងការប្រើប្រាស់ឧបករណ៍ទាំងនេះខ្លះ ?*
- *តើអ្វីខ្លះ ជាភាពខុសគ្នារវាងលំហូរនៃរចនាបថនេះ នៅក្នុងសកម្មភាពនេះ និងរបៀបវារៈសម្រាប់ការប្រជុំ ? តើរចនាបថបែបនេះ អាចជួយអ្នកបែបណា ក្នុងនាមជាអ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន ? ហេតុអ្វីដំណើរការនៃការបង្កើតការពាក់ព័ន្ធ និងការប្រជុំភាគច្រើនពុំមានលំហូរនៃរចនាបថ ?*

**១៤.** ក្រោយបានឆ្លុះបញ្ចាំងអំពីលំហាត់នេះ ចូរពន្យល់ដល់សិក្ខាកាមថា មេរៀននេះគឺសម្រាប់ពួកគាត់ដើម្បីស្វែងយល់អំពីគុណតម្លៃនៃការរៀបចំប្រកបដោយការយល់ដឹង នូវដំណើរការមួយជាជាងត្រឹមតែរបៀបវារៈ។ ចូរពន្យល់ថា គេត្រូវតែយល់ច្បាស់ថា ការរៀបចំរចនាបថ មិនមែនជាការជ្រើសរើសឧបករណ៍ដោយច្នៃប្រឌិតនោះទេ ប៉ុន្តែជាការធានាផងដែរថា ដំណើរការមួយនឹងសម្រេចគោលបំណងនានារបស់ខ្លួន និងរៀបចំចេញជាគោលបំណងច្បាស់លាស់ ដែលអាចងាយស្រួលយល់សម្រាប់សំណាក់អ្នកពាក់ព័ន្ធទាំងអស់។

**១៥.** ចូរពន្យល់ថា ជាញឹកញាប់ដំណើរការបែបនេះ មិនទាំងមានគោលបំណងច្បាស់លាស់ផង ហើយគេមិនអាចរៀបចំដំណើរការមួយដោយគ្មានគោលបំណងបានឡើយ។ ចូរបញ្ជាក់ថាឧបករណ៍ភាគច្រើនអាចប្រើប្រាស់បានតាមវិធីខុសៗគ្នា នៅក្នុងដំណើរការណាមួយអាស្រ័យលើគោលបំណងជាក់លាក់នៃដំណើរការនោះ(ដូចជាតើត្រូវសម្រេចអ្វីឱ្យបាន)។ការកែប្រែនិងបង្កើតឧបករណ៍ជាក់លាក់ដោយច្នៃប្រឌិតអាចពង្រឹងរាល់ដំណើរការនៃពាក់ព័ន្ធ។ ការជឿជាក់លើដំណើរការនេះគឺជាវិធីមួយសម្រាប់លើកទឹកចិត្តឱ្យមានការពាក់ព័ន្ធ និងការចូលរួមជាមួយគ្នាទៅវិញទៅមកពីសំណាក់អ្នកពាក់ព័ន្ធនានា។ ប្រការសំខាន់គឺ ការប្រើប្រាស់ឧបករណ៍នានាមិនត្រូវធ្វើឡើងដោយដាច់ដោយឡែកពីគ្នាឡើយ ហើយដំណើរការទាំងមូលចាប់តាំងពីដើមដំបូងជំរុញដល់ភាពច្នៃប្រឌិត និងជាកត្តាកំណត់អំពីរបៀបនិយាយសម្រាប់ការពាក់ព័ន្ធ។ វាមិនអាចជាមេរៀនដាច់ដោយឡែកដើម្បីបំពេញម៉ោងឬអនុវត្តល្បែងនិងល្បែងថាមពលឡើយ។

## គំណាត់ត្រារបស់គ្រូបង្ហាត់

សូមទុកពេលឱ្យគ្រប់គ្រាន់សម្រាប់ការឆ្លុះបញ្ចាំងលើលំហូរនៃរចនាបថ ដោយសារនេះជាពេលដែលភាគច្រើននៃការរៀនសូត្រកើតឡើង សម្រាប់មេរៀននេះ។ ត្រូវឱ្យប្រាកដថា ក្រុមនីមួយៗធ្វើបទបង្ហាញអំពី លំហូររចនាបថរបស់ខ្លួន ដែលអ្នកអាចពិនិត្យមើលថា តើជំហាននានាបានលើកតាមលំដាប់លំដោយសមហេតុផល និងមានគោលបំណងដែលទាក់ទងនឹងគោលដៅរួមដែរឬទេ។ សូមផ្តល់យោបល់ដល់គ្រប់ក្រុមអំពីភាពច្នៃប្រឌិតជារួមដែលពាក់ព័ន្ធនឹងរចនាបថនៃដំណើរការនេះ។

វីដេអូពី Bobby McFerrin អាចចូលមើលបានតាម៖ www.youtube.com/watch?v=Wo_dODxpTbpA។ ផ្នែកដែលអ្នកអាចប្រើប្រាស់ ដើម្បីបង្ហាញពីភាពច្នៃប្រឌិតគឺនៅចន្លោះនាទី 21.02 និង 24.44។ អ្នកអាចប្រើប្រាស់សំណៅដែលបានទទួលការអនុញ្ញាតនេះសម្រាប់បង្ហាញពីសាច់ភ្លេង៖ www.youtube.com/watch?v=ne6tB2KiZuk។ ដើម្បីបង្ហាញថា អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានត្រូវការភាពច្នៃប្រឌិតនៅក្នុងដំណើរការនៃការពាក់ព័ន្ធ អ្នកអាចប្រើប្រាស់វីដេអូនេះពី Bobby McFerrin ដែលបង្ហាញជាបទភ្លេង blues song ៖ www.youtube.comjwatch?v=rYg5CCwwNO។

អ្នកក៏អាចប្រើប្រាស់ Tina Seelig's TED talk ស្តីពីភាពច្នៃប្រឌិតផងដែរ ដើម្បីបង្ហាញថា តើអ្នកសម្របសម្រួលថ្នាក់មូលដ្ឋានអាចប្រើប្រាស់បទពិសោធន៍របស់ខ្លួន ឧបករណ៍បង្កើតការពាក់ព័ន្ធ និងរចនាបថនៃដំណើរការ ក៏ដូចជាប្រពៃណី និងចំណេះដឹងរបស់សហគមន៍ដែលពួកគាត់ធ្វើការជាមួយ ដើម្បីរៀបចំ និងអនុវត្តដំណើរការពាក់ព័ន្ធបែបច្នៃប្រឌិត។ វីដេអូនេះអាចចូលមើលក្នុង៖www. youtube.comjwatch?v=gyM6rx69iqg។

អ្នកក៏អាចស្វែងរកសម្ភារៈនានាដែលពាក់ព័ន្ធជាភាសាជាតិរបស់អ្នកផងដែរ ប៉ុន្តែត្រូវប្រាកដថា វីដេអូបែបនោះ ពិតជាពេញដោយគោលគំនិតនានាអំពីអ្វីដែលអាចធ្វើបាន នៅក្នុងការចូលរួមបែបច្នៃប្រឌិត។ សូមជៀសវាងការប្រើប្រាស់ឧបករណ៍បែបចូលរួមតាមធម្មតា។

សិក្ខាកាមអាចគិតតាមធម្មតាអំពីឧបករណ៍ខ្លះដែលអាចប្រើប្រាស់ ជាមួយក្រុមអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន ដោយសារការសន្មតខ្លះៗរបស់ពួកគាត់ និងសញ្ញាណដែលមានការកំណត់ទុកជាមុនអំពីចំណេះដឹង សមត្ថភាព ឬលទ្ធភាពរបស់ក្រុមនានាដែលពួកគាត់ធ្វើការជាមួយ។ ចូរសង្កត់ធ្ងន់ថា ឧបករណ៍ភាគច្រើនអាចយកមកប្រើប្រាស់ជាមួយក្រុមណាក៏បាន ក្នុងករណីដែលដំណើរការនោះត្រូវបានបង្កើតឡើង និងរៀបចំបានសមស្រប ជាមួយគោលដៅច្បាស់លាស់ និងគិតគូរផងដែរអំពីបរិបទមូលដ្ឋាន និងគុណតម្លៃនៃវប្បធម៌។

ដំណើរការផ្សេងមួយទៀតនៃការរៀបចំដំណើរការដែលមានប្រយោជន៍ គឺវដ្តនៃការសាកសួរបែបសរសើរ។ ឧបករណ៍នេះអាចយកមកប្រើប្រាស់ ប្រសិនបើក្រុមនេះមានចំណាប់អារម្មណ៍។ នេះជាដំណើរ

ការដែលមានបួនជំហាននៅក្នុងការស្វែងរក (គំនិតខុសៗគ្នា) សុបិន (គំនិតខុសគ្នា/ការស្រមៃ) ការរៀបចំ (គំនិតចុះសម្រុងគ្នា) និងគោលដៅ (ការប្តេជ្ញាដោយឡែកជាលក្ខណៈបុគ្គល និងសកម្មភាពជាក់លាក់ដែលត្រូវអនុវត្តទៅអនាគតដើម្បីបំពេញការប្តេជ្ញាដែលបានអនុវត្ត)។ អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានខ្លះ បានប្រើប្រាស់ដោយជោគជ័យនូវឧបករណ៍នេះសម្រាប់ជាសរសរទ្រូងនៃដំណើការរបស់ពួកគេ។ អ្នកអាចដាក់ឱ្យប្រើប្រាស់ឧបករណ៍នេះជាមួយឧទាហរណ៍នានា ដើម្បីបង្ហាញថា តើការសួរបែបលើកសរសើរ ត្រូវបានប្រើប្រាស់។

ប្រសិនបើសិក្ខាកាមស្នើសុំព័ត៌មានបន្ថែមអំពី ឧបករណ៍នានា អ្នកអាចថតចម្លងឯកសារស្តីពីឧបករណ៍មួយឈុតសម្រាប់ពួកគាត់ បន្ថែមលើឯកសារសម្រាប់អំណាន ឬ យោងទៅឯកសារដទៃទៀត ដូចជា Gamestorming by Dave Gray, Sunni Brown and James Macanufo ដែលមានយោងនៅក្នុងឯកសារសម្រាប់អំណាន។

ប្រសិនបើអ្នកអនុវត្តការបណ្តុះបណ្តាលនៅក្នុងស្ថានភាពតាមមូលដ្ឋាន ដូចក្នុងសេណារីយ៉ូនៃវគ្គបណ្តុះបណ្តាលខ្លះ អ្នកអាចផ្អែកលើល្បែងបង្កើតរចនាបថដែលមាននៅក្នុងមេរៀននេះស្តីពីគោលបំណងនៅក្នុងអំឡុងពេលនៃការវិភាគតាមមូលដ្ឋានអំពី បញ្ហាសមធម៌ និងឧបសគ្គនានាចំពោះការចូលរួមសម្រាប់ក្រុមជាក់លាក់។

# ល្បែងបង្កើតរចនាបថ

សកម្មភាពនេះមានគោលដៅផ្តល់ឱកាសដើម្បីរៀបចំដំណើរការនៃការពាក់ព័ន្ធបែបច្នៃប្រឌិត និងអនុវត្តគុណតម្លៃស្នូលទាំងបួននៃការចូលរួម។ គោលដៅរួមនៃដំណើរការនេះមានផ្តល់ជូន។ ដំណើរការនៃការពាក់ព័ន្ធត្រូវមានគោលដៅសម្រេចគោលដៅនេះ ដោយប្រើប្រាស់ចំណេះដឹង ជំនាញ និងឧបករណ៍នានាដែលបានពិភាក្សានៅក្នុងមេរៀនមុនៗ។ ក្រុមនេះនឹងត្រូវអនុវត្តកិច្ចការដូចខាងក្រោមនេះ ដើម្បីរៀបចំដំណើរការនៃការពាក់ព័ន្ធ៖

- កំណត់អត្តសញ្ញាណ**ជំហាន**នានា និង**ស្ទើរពេលវេលា** (គិតអំពីវិធីដែលជំហាននានា នឹងសម្រេចបានគោលដៅរួម)។
- កំណត់ **គោលបំណងជាក់លាក់ សម្រាប់ជំហាននីមួយៗ** និងសរសេរជំហានទាំងនោះ។
- កំណត់អត្តសញ្ញាណ**អ្នកណា** ដែលនឹងពាក់ព័ន្ធនៅក្នុង**ជំហាននីមួយៗ**។
- ជ្រើសរើស**ឧបករណ៍នានា** ដែលនឹងត្រូវប្រើប្រាស់នៅក្នុងជំហាននីមួយៗដោយផ្តល់ហេតុផលសម្រាប់ការជ្រើសរើសនីមួយៗ។ ប្រសិនបើប្រើប្រាស់ឧបករណ៍ខុសគ្នាណាមួយពីអ្វី ដែលបានផ្តល់សូមពន្យល់ពីមូលហេតុនិងរបៀបប្រើប្រាស់។




ចូររៀបចំផែនទីដែលអាចមើលឃើញអំពីរចនាបថនៃដំណើរការ (លំហូរនៃដំណើរការសម្រាប់ការពាក់ព័ន្ធ) និងបង្ហាញជូនមកក្រុម។ ត្រូវមានភាពច្នៃប្រឌិត និងផ្តល់ហេតុផលសមស្របសម្រាប់រចនាបថ។ ក្រុមនីមួយៗគួរធ្វើការជាមួយគ្នាទៅវិញទៅមកលើគោលដៅរួមនានា។

**ក្រុម ១៖ គោលដៅរួមនៃការពាក់ព័ន្ធដើម្បីលើកកម្ពស់សមធម៌៖**

ជូនដំណឹងដល់ស្ត្រី និងសហគមន៍ទន់ខ្សោយអំពីសិទ្ធិរបស់ពួកគាត់ក្នុងការឯកភាពដោយគ្មានការបង្ខិតបង្ខំ និងការទទួលព័ត៌មានជាមុន និងកំណត់អត្តសញ្ញាណតួនាទីនៅក្នុងដំណើរការនោះ។

**ក្រុម ២៖ គោលដៅរួមនៃការពាក់ព័ន្ធដើម្បីលើកកម្ពស់សមធម៌៖**

បង្កើតប្រព័ន្ធការពារសុវត្ថិភាពសម្រាប់ REDD+

**ក្រុមទី ៣៖ គោលដៅរួមនៃការពាក់ព័ន្ធដើម្បីលើកកម្ពស់សមធម៌៖**

សម្រេចពីនីតិវិធីសម្រាប់ការចែកផលប្រយោជន៍ នៅក្នុងគោលនយោបាយ REDD+

ច្បាប់ចម្លងនៃទំព័រដូចខាងក្រោមនេះ និងសន្លឹកដែលមានសេចក្តីអធិប្បាយអំពីឧបករណ៍នានាដែលអាចប្រើប្រាស់នៅក្នុងរចនាបថនៃដំណើរការពាក់ព័ន្ធនេះ។ សូមដាក់គោលដៅនៃការពាក់ព័ន្ធ និងឧបករណ៍មួយឈុតទៅក្នុងស្រោមសំបុត្រ។ សូមរៀបចំស្រោមសំបុត្រ ដោយផ្អែកលើចំនួនក្រុមដែលមាននៅក្នុងមេរៀននៃវគ្គបណ្តុះបណ្តាល។

**ការស្ទង់មតិ**

- ការអង្កេតខ្លីមួយ ឬ ការសម្ភាសដែលមានសង្គតិភាពជាមួយសំណាកនៃសាធារណជន ឬក្រុមគោលដៅ
- វាស់អ្វីដែលសាធារណជនអាចគិតថា តើពួកគាត់បានទទួលដំណឹង និងបានពាក់ព័ន្ធជុំវិញបញ្ហាជាក់លាក់
- មិនចាំបាច់តែតាមរយៈការកត់ត្រាលើក្រដាសឡើយ

**បញ្ជីសំណួរ**

- តាមធម្មតា គឺជាតារាងមួយលើក្រដាសដែលជាសំណួរបិទ ដើម្បីប្រមូលព័ត៌មានជាក់លាក់

**ការពិភាក្សាក្នុងក្រុមគោលដៅ**

- ការពិភាក្សាតែមួយលើកអំពីប្រធានបទជាក់លាក់មួយ ជាមួយមនុស្ស ៦-១២នាក់ ដែលត្រូវបានជ្រើសរើសទៅតាមលក្ខណៈវិនិច្ឆ័យជាក់លាក់ ដើម្បីធ្វើជាតំណាងនៃក្រុមណាមួយ ឬ ក្រុមអ្នកពាក់ព័ន្ធ

**ការប្រជុំ ឬ សិក្ខាសាលា**

- បុគ្គលមួយក្រុមដែលមានសាវតាខុសៗគ្នា ដែលជួបពិភាក្សាប្រធានបទ ឬ បញ្ហានានា ដើម្បីលើក អនុសាសន៍ ឬ ផែនការជាក់លាក់មួយ

**ព្រឹត្តបត្រព័ត៌មាន ឬ ព័ត៌មាន**

- ផ្តល់ព័ត៌មានដែលអាចមើលឃើញ និងសរសេរអំពីប្រធានបទ ឬ បញ្ហាជាក់លាក់ ឬ ជូនដំណឹងដល់ សាធារណជន អំពីសេចក្តីសម្រេចចិត្ត ឬ គោលនយោបាយថ្មីមួយ

**ការពិភាក្សាតាមវិធីសាស្ត្រពពុះមាត់ត្រី**

- ទម្រង់នៃការចូលរួមមួយដែលមានការកំហិតលើខ្លួនឯង ដែលអាចប្រើប្រាស់ជាមួយមនុស្ស ៨-៣០០នាក់ ដើម្បីផ្លាស់ប្តូរ ទស្សនៈ និង/ ឬ ឈានដល់ការឯកភាពគ្នានៃគំនិត (ការយោគយល់គ្នា)

**ពិធីប្រគុំតន្ត្រី ឬ ពិធីបុណ្យពិភាក្សា**

- វេទិកាមួយដើម្បីផ្លាស់ប្តូរគំនិត និងទស្សនៈ ដោយបង្កើតសារ ដោយប្រើប្រាស់តន្ត្រី (រេប ប្លឺ រ៉ក់ ផប់) អំពីបញ្ហាជាក់លាក់។

**ពិភពកាហ្វេ**

- បច្ចេកទេសនៃការពិភាក្សាតុមូលពាក់កណ្តាលផ្លូវការ ដើម្បីបង្កើតឱ្យមានការសន្ទនា និងការផ្លោះប្តូរ គំនិត នៅក្នុងក្រុមធំមួយ ដោយប្រើប្រាស់សំណួរ "ធំ" បើកចំហ និងការរួមបញ្ចូលគំនិតខុសៗគ្នា

**ជញ្ជាំងក្រាហ្វិទី (គំនូរតាមទីសាធារណៈ)**

- វិធីមួយដើម្បីប្រមូលគំនិតសម្រាប់ប្រតិកម្មដែលអាចមើលឃើញ និងចម្លើយតបអំពីបញ្ហា និងការ ពិភាក្សាជាក់លាក់
- ផ្តល់សេរីភាពដើម្បីសំដែងគំនិត ប្រតិកម្មតប និងយោបល់តប តាមទម្រង់ណាមួយ និងក្នុងពេល ណាមួយ

**សម្លេងរូបថត**

- ឧបករណ៍ដែលផ្តល់រូបភាព ដើម្បីជួយប្រជាជនក្នុងការសំដែងគំនិត ឬ ការឆ្លើយតបរបស់ពួកគាត់ ទៅនឹងសំណួរ ឬ កិច្ចការជាក់លាក់ ដោយបង្កើតជាខ្សែរឿងតាមរយៈរូបថត និងការចែករំលែករូបថត

**ក្រុមអ្នកផ្តល់ចក្ខុវិស័យ**

- វិធីមួយសម្រាប់អ្នកពាក់ព័ន្ធ ឬក្រុមនានា ដើម្បីបង្កើតសុបិន ឬ រូបភាពរួមគ្នាមួយ (ចក្ខុវិស័យអំពីអ្វីដែលពួកគាត់ចង់ឃើញទៅអនាគត តាមរយៈរូបភាពមួយ

**ការសាកល្បង ១០០ដុល្លារអាមេរិក**

- ឧបករណ៍ចាត់ជាអាទិភាពមួយ ដែលក្នុងនោះ ក្រុមមួយត្រូវបានផ្តល់រូបភាព ១០០ដុល្លារអាមេរិក ដើម្បីចាត់តាំង និងធ្វើសមិទ្ធកម្ម (ពន្យល់ពីមូលហេតុ) សកម្មភាព ឬ វត្ថុខុសៗគ្នា ដែលគួរតែចាត់ជាលំដាប់ថ្នាក់ ឬ ជ្រើសយក ពាក់ព័ន្ធនឹងសារៈសំខាន់សម្រាប់ក្រុមនោះ

**រូបភាព**

- ដំណើរការបំផុសគំនិតដែលអាចមើលឃើញ តាមរយៈការជ្រើសរើសចោះៗ និងបង្ហាញរូបភាពនានា ពីទស្សនាវដ្តី ឬ សម្ភារៈដទៃទៀត ដែលបន្ទាប់មកផ្សារភ្ជាប់ជាមួយប្រធានបទនាមួយជាក់លាក់
- លើកទឹកចិត្តឱ្យប្រើប្រាស់ការគិតបែបច្នៃប្រឌិត ការស្រមៃ និងការបង្កើតថ្មី និងអាចប្រើប្រាស់សម្រាប់ស្វែងយល់ និងបង្កើតជម្រើស ឬ គំនិតដែលគួរឱ្យចាប់អារម្មណ៍ ឬ ថ្មី

**កសាងពិភពលោកយើងនេះជា 3D**

- វិធីបង្កើតចក្ខុវិស័យ និងរៀបចំផែនការសម្រាប់ម៉ូដែល3D នៃអ្វីដែលប្រជាជនចង់ឃើញទៅអនាគត និង តើពួកគាត់អាចឈានដល់ស្ថានភាពនោះដោយរបៀបណា (ត្រូវការក្រដាសដែលមានជ័រការ ឬប្រើម្សៅពោត ជ័រការ ដែលអាចសមស្របជាមួយវត្ថុដែលពាក់ព័ន្ធជាក់លាក់)

**តារាងម៉ាទ្រីស "ឱ្យ និងយក"**

- តារាងម៉ាទ្រីសសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តមួយដែលបង្ហាញពីសកម្មភាពនានាអាចធ្វើទៅបានដោយផ្អែកដោយផ្អែកលើកិច្ចប្រឹងប្រែងដែលចាំបាច់ ដើម្បីអនុវត្ត និងផលប៉ះពាល់សំខាន់ៗចេញពីកិច្ចប្រឹងប្រែងទាំងនោះ

**ការបង្កើតផែនទីភាពខ្លាំង ឬ កងចក្រផ្ទាល់ខ្លួន**

- ឧបករណ៍មួយដែលជួយនៅក្នុងការបង្កើតផែនទី (កំណត់អត្តសញ្ញាណតាមវិធីដែលមើលឃើញ) អំពីអ្នកពាក់ព័ន្ធខុសៗគ្នា និងលក្ខណៈសម្បត្តិរបស់ពួកគាត់ (ភាពខ្លាំង និងកត្តារួមផ្សំវិជ្ជមាន)

**ការគូររូបរួមគ្នា**

- ការបង្កើតរូបមួយ ដោយផ្អែកលើខ្លឹមសាររួម ឬ អាទិភាពរួមគ្នា ឬ ការយល់ដឹងអំពីបញ្ហាមួយ ឬរឿងមួយ

**ប្រអប់**

- វត្ថុដែលបានពីការបង្កើតរូបភាពរួមគ្នា ដែលអាចប្រើប្រាស់សម្រាប់ពិភាក្សា រុករក និងស្វែងយល់អំពី គោលគំនិត សម្បត្តិ គំនិត និងចក្ខុវិស័យ

**គណៈការប្រជាពលរដ្ឋ**

- ក្រុមប្រជាពលរដ្ឋដែលជ្រើសរើសដោយចោះៗ ដែលជួបប្រជុំគ្នារយៈពេលប៉ុន្មានថ្ងៃ ដើម្បីតំណាងឱ្យសហគមន៍របស់ពួកគាត់ ដើម្បីពិចារណាអំពីបញ្ហាគោលនយោបាយ ដែលក្នុងនោះអាចមានការបង្ហាញពីភស្តុតាងមកពីសាក្សី និងអាចមានការពិនិត្យផ្ទៀងផ្ទាត់

**ការសម្ភាស**

- ការសម្ភាសមួយទល់មួយ ដើម្បីទទួលបានចំណាប់អារម្មណ៍អំពីបញ្ហា អារម្មណ៍ និងការយល់ឃើញណាមួយ

**តារាងម៉ាទ្រីសផលប៉ះពាល់ និងកិច្ចប្រឹងប្រែង**

- ឧបករណ៍អាចមើលឃើញមួយ ដែលគូសផែនទីអំពីសន្ទុះចិត្ត និងអន្តរអំពើក្នុងចំណោមបុគ្គល ឬភ្នាក់ងារដាក់លាក់ នៅក្នុងប្រព័ន្ធមួយ
- ឧបករណ៍វិភាគដ៏មានប្រយោជន៍មួយ ដែលជួយកំណត់និយមន័យ ពន្យល់ និងបង្កប់ខ្លឹមសារគុណតម្លៃនានានៅក្នុងក្រុមមួយ

**តារាងម៉ាទ្រីស** 4Cs ( **សមាសភាគ សំណុំលក្ខណៈ បញ្ហាប្រឈម និង ចរិតលក្ខណៈ** )

- វិធីសាស្ត្រមួយសម្រាប់វិភាគប្រធានបទ និងការប្រមូល និងចាត់ចែងឱ្យមានការយល់ដឹងមួយអំពីប្រធានបទនោះ តាមវិធីខុសៗគ្នា
- មានប្រយោជន៍នៅក្នុងការដេញដោល និងការកែប្រែវិធីតាមធម្មតានៃការគិត ដែលក្នុងនោះប្រធានបទមួយ ច្រើនតែត្រូវបានពិភាក្សាផ្ទាល់មាត់

**វីដេអូបែបចូលរួម**

- ឧបករណ៍និទានរឿងមួយដែលអាចមើលឃើញ សម្រាប់ចែករំលែកទស្សនវិស័យជាក់ស្តែង
- សិក្ខាកាមអាចផលិតវីដេអូមួយអំពីទស្សនៈរបស់ពួកគាត់សម្រាប់ដោះស្រាយបញ្ហាជាក់លាក់

**ការសំដែងតួ**

- វិធីមួយដែលអាចប្រើប្រាស់ដើម្បីបញ្ជូនអារម្មណ៍ និងទស្សនវិស័យសម្រាប់តួនាទីខុសៗគ្នា របស់អ្នកពាក់ព័ន្ធ ឬសិក្ខាកាមជាក់លាក់នៃដំណើរការនេះនៅក្នុងស្ថានភាពណាមួយ
- មានប្រយោជន៍សម្រាប់បង្ហាញ និងរុករកទស្សនវិស័យ គុណតម្លៃ អារម្មណ៍ និង យោបល់

**ទម្រង់នៃកម្មវិធីជជែក**

- វិធីធ្វើត្រាប់មួយដើម្បីបង្ហាញទស្សនៈខុសៗគ្នាអំពីប្រធានបទដូចគ្នាជាមួយ ″អ្នកជំនាញ″ ដែលត្រូវការឱ្យមានសំណួរច្បាស់លាស់ បែបប្រជែង និងយន្តការមួយសម្រាប់ការជជែកផ្ទាល់ជាមួយអ្នកស្តាប់

**តើមានអ្វីកើតឡើង ប្រសិនបើ**...

- វិធីចក្ខុវិស័យមួយ ដើម្បីបង្កើតការគិត "នៅក្រៅប្រអប់ ឬក្របខ័ណ្ឌ″ ដែលក្នុងនោះអ្វីៗទាំងអស់អាចកើតឡើងបាន

**ការវិភាគដែនកម្លាំង/ស្វត**( SWOT )

- វិធីនៃការវិភាគតាមបែបចូលរួមដែលអាចមើលឃើញ សម្រាប់ពិនិត្យមើលស្ថានភាពបច្ចុប្បន្ន និងអនាគត ដែលអាចប្រើប្រាស់ដើម្បីវិភាគអំពីអ្វីដែលត្រូវកែលម្អ និងអ្វីដែលអាចជំរុញឱ្យមានការកែប្រែ

**តារាងម៉ាទ្រីសអ្នកណាខ្លះ/អ្វីខ្លះ/ពេលណា**

- ឧបករណ៍រៀបចំផែនការសកម្មភាពដែលអាចមើលឃើញសម្រាប់វាយតម្លៃអ្នកណាដែលមានគណនេយ្យភាពលើកិច្ចការខុសៗគ្នា និងការទទួលខុសត្រូវ ដោយផ្អែកលើគោលដៅរួមគ្នា

# ការរៀបចំដំណើរការដោះពាក់ព័ន្ធបែបច្នៃប្រឌិត

## ហេតុអ្វីអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានចាំបាច់ត្រៀមរៀបចំរចនាបថនៃដំណើរការ?

ការរៀបចំដំណើរការនៃការពាក់ព័ន្ធមានលក្ខណៈខុសគ្នាពីការរៀបចំផែនការ សម្រាប់របៀបវារៈ។ របៀបវារៈច្រើនតែជាតារាងមួយដែលមានចំណងជើង និងពេលវេលាដែលមានលំហូរជាក់លាក់ ឬគោលបំណងច្បាស់លាស់អំពីអ្វីដែលត្រូវសម្រេចឱ្យបាន។ ដើម្បីរៀបចំដំណើរការនៃការពាក់ព័ន្ធដែលមានប្រសិទ្ធភាព អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានត្រូវពិចារណាអំពីលំហូរ និងលំដាប់លំដោយនៃជំហានជាក់លាក់ ជាមួយគោលបំណងច្បាស់លាស់។




អ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន គួរប្រើប្រាស់គុណតម្លៃស្នូលនៃការចូលរួម នៅក្នុងជំហាននីមួយៗ នៃដំណើរការនេះទន្ទឹមនឹងពិចារណាអំពីរបៀប ដើម្បីធ្វើឱ្យអ្នកពាក់ព័ន្ធចូលរួមជាមួយបញ្ហា និងជាមួយគ្នាទៅវិញទៅមក។




ជំហាននីមួយៗនៃដំណើរការនេះ ផ្សារភ្ជាប់ទៅនឹងជំហានដទៃទៀត តាមទម្រង់ខុសៗគ្នា។ លក្ខណៈសមហេតុផលនៃដំណើរការនេះ ត្រូវតែអាចបង្ហាញជាកស្តុតាងដល់អ្នកពាក់ព័ន្ធទាំងអស់ ឬសិក្ខាកាមទាំងអស់អំពីដំណើរការនៃការពាក់ព័ន្ធនេះ។ ប្រសិនបើសិក្ខាកាមណាម្នាក់ចាប់អារម្មណ៍ថាខ្លួនជាផ្នែកមួយនៃដំណើរការនេះ ពួកគាត់ទំនងជាចូលរួមកាន់តែច្រើនចាប់តាំងពីដើមដំបូង។

ដំណើរការនៃការពាក់ព័ន្ធបែបច្នៃប្រឌិតដែលត្រូវបានយោងថាជា "រចនាបថនៃការគិត" មានការពាក់ព័ន្ធជាមួយការរកមើលវិធីនានាដើម្បីកែលម្អស្ថានភាពមួយ និងបង្កើតបរិយាកាសមួយដែលក្នុងនោះមនុស្សទាំងឡាយអាចគិតដោយគ្មានការបង្ខិតបង្ខំ ដោយការស្រមៃ និងជាលក្ខណៈច្នៃប្រឌិត ដើម្បីស្វែងរកដំណោះស្រាយនានា ឬ បង្កើតគំនិតថ្មីៗ។ ឧបករណ៍ ល្បែង និងការបង្កើតរូបភាពអាចផ្សារភ្ជាប់ច្បាស់លាស់នៅក្នុងរចនាបថនៃដំណើរការ។ មុខងាររបស់ពួកគាត់នឹងពុំគួរស្ថិតនៅដាច់ដោយឡែកឡើយ។

អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានខ្លះគិតថា ការរៀបចំដំណើរការបែបច្នៃប្រឌិតមួយទាមទារឱ្យមានការបន្ថែមលំហាត់ថាមពលមួយចំនួនតូចទៅក្នុងទម្រង់ ឬ របៀបវារៈធម្មតា។ នេះមិនមែនជារចនាបថនៃដំណើរការទេ។ ការអនុវត្តគុណតម្លៃស្នូលទាំងបួននៃការចូលរួមនៅក្នុងរចនាបថនៃដំណើរការមានន័យថា អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានត្រូវតែរៀបចំឡើងវិញអំពី របៀបដែលសិក្ខាកាម និងអ្នកចាត់ចែងការប្រជុំយល់អំពីដំណើរការនៃការពាក់ព័ន្ធ។ និយាយម្យ៉ាងទៀតថា អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានត្រូវដេញដោលការយល់ឃើញអំពីទម្រង់នៃការចូលរួម ជាពិសេសគំរូនៃការចូលរួមដែលអាចពុំមានប្រសិទ្ធភាព និងទន់ខ្សោយ។

> “ចូរធ្វើឱ្យវាក្លាយជាទម្លាប់អនុវត្តមួយ ក្នុងការសាកល្បងយ៉ាងហោចណាស់រឿងថ្មីមួយ រៀងរាល់លើកដែលរូបអ្នកធ្វើការសម្របសម្រួលការបំផុសគំនិត។ ការធ្វើបែបនេះនឹងជួយឱ្យអ្នកមានភាពស្មោះត្រង់ បង្ខំអ្នកឱ្យបន្តបង្កើត និងកែលម្អ ព្រមទាំងរក្សាអ្វីៗឱ្យនៅមានជីវិត និងមានលក្ខណៈស្រស់ស្រាយសម្រាប់អ្នក។ អ្នកមិនលើកសរសើរអ្នកដទៃទេឡើយ លើកលែងតែអ្នកអាចបង្កើនថាមពលរបស់ខ្លួនឯង។”
>
> Gray, Brown and Macanufo in Gamestorming

## តើក្លាយជាអ្នកមានការច្នៃប្រឌិត មានន័យបែបណា និងហេតុអ្វីបានជាចាំបាច់បែបនេះ?

ភាពច្នៃប្រឌិត ក្នុងនាមជាអ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន គឺជាការសាកល្បងអ្វីថ្មី សម្រាប់បុគ្គលគ្រប់រូប ដែលពាក់ព័ន្ធនៅក្នុងដំណើរការនេះ៖ អ្នកសម្របសម្រួល ឬ បុគ្គលណាម្នាក់ដែលពាក់ព័ន្ធនៅក្នុងបរិបទណាមួយ (ដូចជា និស្សិត សិក្ខាកាម និងសហសេវិក)។ គេចាំបាច់ត្រូវតែមានភាពស្មោះត្រង់នៅក្នុងដំណើរការនេះ - គំនិតថ្មីៗ របកគំហើញ ឬ ការច្នៃប្រឌិត នឹងមិនអាចកើតឡើងបានឡើយ លើកលែងតែបុគ្គលនានាមានឆន្ទៈក្នុងការប្រថុយខ្លះៗ និងសាកល្បងរឿងថ្មីៗជាទៀងទាត់។

ការច្នៃប្រឌិតគួរតែបានពិចារណា ទាក់ទងនឹង លំហ លំហូរនៃរចនាបថ ឧបករណ៍ និងការចងក្រងជាឯកសារ។ ការកៀងគរភាពច្នៃប្រឌិតរបស់អ្នកពាក់ព័ន្ធនានា និងការគិតស្រមៃ មានសារៈសំខាន់ណាស់ជាការច្នៃប្រឌិត និងការស្រមើស្រមៃរបស់អ្នកសម្របសម្រួលនៅមូលដ្ឋាន។ ប្រការនេះនឹងកសាង និងបង្កើតថាមពលនៅក្នុងដំណើរការ និងនៅក្នុងក្រុម។

## ហេតុអ្វីអ្នកសម្របសម្រួលថ្នាក់មូលដ្ឋានខ្លះប្រកាន់យករបៀបវារៈ និងឧបករណ៍តាមធម្មតា?

ជាទូទៅ ការប្រជុំជាច្រើន និងដំណើរការនៃការពាក់ព័ន្ធ ត្រូវបានរៀបចំឡើងមានលក្ខណៈទន់ខ្សោយ និងបន្តប្រើប្រាស់ទម្រង់ និងរបៀបវារៈធម្មតា។ ការជួយដល់អ្នកកោះប្រជុំ ឬ ក្រុមមួយ

ដើម្បីរៀបចំដំណើរការនោះឡើងវិញ ដើម្បីធានាថា ប្រជាពលរដ្ឋអាចសំដែង "ឆន្ទៈពិតប្រាកដរបស់ខ្លួន" និងពាក់ព័ន្ធព្រមទាំងប្ដេជ្ញាចំពោះដំណើរការ និងបញ្ហា នៅចំពោះមុខមិនមែនជារឿងងាយស្រួលឡើយ។ ប្រការនេះនឹងពាក់ព័ន្ធជាមួយការដេញដោលចំពោះការយល់ឃើញរបស់ប្រជាជន។ ដំណើរការនៃការពាក់ព័ន្ធភាគច្រើន ត្រូវបានចាត់ចែងឡើងជាមួយការកំណត់ជាមុនអំពីលទ្ធផល។ ប្រការនេះកំហិតលើថា តើអ្នកចាត់ចែងរៀបចំនឹងមានការបើកចំហកម្រិតណា ដើម្បីទទួលគំនិតថ្មីៗ។




ជាសំណាងមិនល្អ ប្រសិនបើអ្នកណាម្នាក់ពីខាងក្រៅសហគមន៍ ឬ ក្រៅក្រុមណាមួយ សម្រេចយកសកម្មភាព ឬ លទ្ធផលមួយ សម្រាប់សហគមន៍ ឬ ក្រុមនោះ តាមធម្មតា ពួកគាត់ពុំមានស្មារតីម្ចាស់ការឡើយ ហើយវានឹងទទួលបរាជ័យ។ អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានត្រូវជឿលើគុណតម្លៃស្នូលទាំងបួននៃការចូលរួម និងជឿជាក់លើដំណើរការនៃការពាក់ព័ន្ធ។ អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានណាម្នាក់ត្រូវជឿថា គុណតម្លៃ និងដំណើរការទាំងនេះ អាចនាំមកនូវការរួមប្រសព្វគ្នានៅក្នុងការឈានទៅសម្រេចគោលដៅជាក់លាក់។

សហគមន៍ ឬ ក្រុមនានានឹងរកឃើញថា លំនាំផ្លូវរបស់ពួកគាត់សម្រាប់ការពាក់ព័ន្ធ និងចំណុចចាប់ផ្ដើមសម្រាប់លើកកម្ពស់សមធម៌ ប្រសិនបើពួកគាត់បានទទួលឱកាស ដើម្បីចូលរួមពិតប្រាកដ និងកំណត់លទ្ធផលរបស់ពួកគាត់ តាមរយៈដំណើរការមួយដែលបានរៀបចំយ៉ាងល្អ និងប្រកបដោយការបើកចំហ។

## ធ្វើបែបណាដើម្បីជំនះបានឧបសគ្គរបស់អ្នកក្នុងការបង្កើតភាពច្នៃប្រឌិត ក្នុងនាមជាអ្នកសម្របសម្រួល

ការជាប់គាំងនៅក្នុងវិធីនៃការសាកល្បងលើការបង្កើតដំណើរការនៃការពាក់ព័ន្ធមួយ ងាយនឹងកើតឡើង។ ជួនកាល ចំណុចនេះអាចនាំទៅរក "ឧបសគ្គចំពោះភាពច្នៃប្រឌិត" ក្នុងនាមជាអ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន។ រូបទី ១១ ផ្ដល់គន្លឹះខ្លះៗពីអ្នកជំនាញការសម្រាប់ជំនះឧបសគ្គចំពោះការច្នៃប្រឌិត។

ចូរចងចាំថា ភាពច្នៃប្រឌិត សុទ្ធតែជាឱកាសដោយចៃដន្យ ការបង្វែរគ្រឡប់ស្ថានការណ៍ និងការកែទម្រង់ឡើងវិញ។ ការធ្វើអ្វីមួយដែលគ្មានការរំពឹងទុកជាមុន អាចសម្រួលឱ្យមានភាពច្នៃប្រឌិត និងអាចឱ្យប្រជាជនមានសេរីភាពក្នុងការគិតតាមវិធីថ្មីៗ និងមិនមែនជាវិធីដូចមានពីមុនឡើយ។

## **រូបទី ១១៖** ដំបូន្មានរបស់អ្នកជំនាញសម្រាប់ជំនះឧបសគ្គខាងការច្នៃប្រឌិត

# គន្លឹះនៃភាពច្នៃប្រឌិត

រៀបចំឡើងសម្រាប់ករណីដែលអ្នកមានអារម្មណ៍ថាជាប់គាំងមិនអាចច្នៃប្រឌិតបានបាន

UNSTUCK
Live better every day

## ចាប់ផ្តើម



### ចាប់ផ្តើមដោយធ្វើអ្វីមួយផ្សេង

អ្នកកំពុងស្ថិតក្នុងស្ថានភាពចាប់ផ្តើមកំដៅសាច់ដុំ៖ ពោលគឺពុំទាន់ត្រៀមខ្លួនជាស្រេច ដើម្បីដោះស្រាយគម្រោងច្នៃប្រឌិតរបស់អ្នកនៅឡើយទេ។ ត្រូវជ្រើសយកបច្ចេកទេសណាមួយ - ក្រដាស mache ក្រដាស Post-it, Powerpoint - និងបង្កើតអ្វីមួយដែលមិនទាក់ទងទាល់តែសោះ។ អារម្មណ៍របស់អ្នកនឹងចាប់ផ្តើមឈានចូលទៅក្នុងលំហច្នៃប្រឌិត។

"បញ្ហានានា កម្រមានមុខមុតស្រួចណាស់ ហើយជាញឹកញាប់ ក្នុងពិភពលោកនេះគ្មានចម្លើយត្រូវគ្នាទេ។ អ្នកត្រូវការភាពច្នៃ ប្រឌិត ដើម្បីពន្យល់បញ្ហាមួយតាមបែបច្នៃប្រឌិត និងត្រូវពង្រីកចំនួន និងលទ្ធភាពនៃរបៀបដែលអាចដោះស្រាយបញ្ហានោះ"។
Keith Yamashita, ប្រធាន SYPartners

### ទស្សនមិនជាប់គាំង (UNSTUCK)

ការដោះស្រាយបញ្ហា គឺជាបេះដូងនៃភាពច្នៃប្រឌិត។ វាជាដំណើរការនៃការស្វែងរក ភាពតជាប់គ្នា ដែលនៅពុំទាន់មាននៅឡើយទេ ពោលគឺសមត្ថភាព— ដែលស្ថិត នៅក្នុងខ្លួនយើងគ្រប់គ្នា។



## ស្វែងរកគំនិតថ្មី

### ធ្វើបែបណាដើម្បីឲ្យ មានអារម្មណ៍បើកចំហ

១. កុំរារាំងរូបកជាអ្នកចេះ ដើម្បីអាចរៀនកិច្ចការថ្មីៗ
២. ស្តាប់ច្រើនជាងនិយាយដើម្បីទទួលបានគំនិតថ្មីៗ
៣. សួរ "ចុះបើ..." ដើម្បីបើកកកាយលទ្ធភាពថ្មីៗ

### ស្វែងរកគំនិតថ្មីនៅក្នុងកន្លែងមិនច្បាស់លាស់

| | |
|---|---|
| ហាងលក់គ្រឿងដែក | ដើរក្នុងបរិវេណក្បែរផ្ទះ |
| ជជែកជាមួយម្តាយ | អានសៀវភៅកូនក្មេង |
| ផ្សារក្រមួន | មើលមនុស្សម្នានៅផ្សារទំនើប |
| លេងល្បែងជិះក្ការ | នៅក្នុងព្រៃ |
| ជិះរថយន្តក្រុង | សួត្រកំណាព្យ |
| វិចិត្រសាល | ហាងលក់ថាសចម្រៀង |
| ពពក | សៀវភៅផែនទី |
| ជិះកង់ | ហាងលក់វត្ថុបូរាណ |
| ហាងលក់ចំណីប្លែកៗ | កន្លែងលក់ស្ករគ្រាប់ |
| ល្បែងបាល់ | សួនសត្វ |
| | រោងភាពយន្ត |

"គំនិតថ្មីៗមិនមែនជាគោលដៅឡើយ"។ វាត្រូវបានបើកចំហដើម្បីឲ្យឃើញអ្វីដែល ធ្វើឲ្យមានភាពខុសគ្នា។"
Vanessa Holden
Creative Director
West Elm

ទស្សនៈអំពីការមិនជាប់គាំងគំនិតថ្មីលេចឡើងនៅពេលយើងមានឆន្ទៈ ដើម្បីពិចារណាអំពីអ្វីដែលយើងជឿថាអាចមិនពិត។

## រុញច្រានទស្សនៈអំពីការរក្សាស្ថានភាពដដែល



### ធ្វើបែបណាដើម្បីបើកចំហគំនិតសំខាន់ៗ

( លំហាត់មួយសម្រាប់មនុស្សម្នាក់ ឬ ច្រើន )

១. កំណត់អំពីសេចក្តីពិតជាសាកល។ នេះជាគោលបំណង ឬ គោលដៅរបស់អ្នក។ ឧទាហរណ៍៖ ចំណាយពេលកាន់តែច្រើនជាមួយគ្នា ដើម្បីបង្កើនទំនាក់ទំនងរបស់យើង។
២. ស្វែងរក ប្រមូលយក និងរៀបចំវត្ថុបូរាណ ដែលទាក់ទងនឹង - ប៉ុន្តែជម្រុញ - សេចក្តីពិតទៅក្នុងកន្លែងថ្មីមួយ។ បូរាណវត្ថុអាចជារូបភាព វត្ថុពិត អត្ថបទ សម្រង់សំដី វេបសាយ ពោលគឺអ្វី ដែលជម្រុញលើកទឹកចិត្តអ្នក។
៣. ស្វែងរក និងបោះបង់ចោលបូរាណវត្ថុជាក់ស្តែង។
៤. អនុវត្តជំហានទី ២ឡើងវិញ។
៥. សិក្សាវត្ថុដែលអ្នកប្រមូលទុកដើម្បីស្វែងរកជុំមាស។

### ទស្សនៈរបស់មិនជាប់គាំង

អ្វីដែលមើលទៅដូចជាប្រាជ្ញាភ្លឺថ្លាដោយភាពច្នៃប្រឌិត ដែលលេចឡើងភ្លាមៗតាមពិតទៅកើតចេញពីការអនុវត្តជាប់ជាប្រចាំនៃការមើល គិត និងការធ្វើសកម្មភាពដោយច្នៃប្រឌិត.

ប្រសិនបើអ្នកចង់មានភាពច្នៃប្រិត អ្នកត្រូវតែជ្រើសរើសយកការកែទម្លាប់បច្ចុប្បន្ន និងធ្វើការកែប្រែវា។
Scott SlavinCreativity Coach and Director of "Naked in Alaska"

## ការទម្លុះទម្លាយភាពទ័លច្រក

### ជួយផង! ខ្ញុំជាប់គាំងហើយ

- បិទភ្នែករបស់អ្នក និងប្រាប់អ្នកណាម្នាក់នូវអ្វីដែលអ្នកឃើញ
- ស្វែងរកអ្វីម៉្យាងដើម្បីដោះស្រាយ
- ជួយអ្នកណាម្នាក់
- កំហិតខ្លួនឯងត្រឹមវិធីមួយ ឬច្រើន៖ ពេលវេលាបច្ចេកទេស ពាក្យសំដី ពណ៌ ប្រាក់ សម្ភារៈ
- ធ្វើអ្វីម៉្យាងជាក់ស្តែងដែលត្រូវការឲ្យមានការ គិតបន្តិចបន្តួច ឬ មិនត្រូវការ
- មើលបញ្ហានោះតាមទស្សនទានរបស់អ្នកដទៃ

"ត្រូវតែសាកល្បងវត្ថុ ១០យ៉ាងខុសពីមុន តាមវិធីនេះ មុននឹងស្វែងរកអ្វីមួយដែលមានដំណើរការបានល្អសម្រាប់អ្នក។"
- Linda Zacks Brookliyn -based Artist and Designer



ទស្សនមិនជាប់គាំង ឧបសគ្គបែបច្នៃប្រឌិតមួយ គឺជាសញ្ញាងាយមួយដែលបង្ហាញថា ដល់ពេលត្រូវសាកល្បងវិធានខុសពីមុនហើយ។

### ភាពមិនជាប់គាំង( UNSTUCK ) អាចជួយបាន

ទាញយកឱកាសពីឧបករណ៍ឥតគិតថ្លៃដែលបានពី Unstuck app's ដើម្បីជួយអ្នកដោះស្រាយប្រកបដោយការច្នៃប្រឌិត ដែលរួមទាំង៖

- "ប្រាប់ខ្ញុំមកហេតុអ្វី" ចាំបាច់ឈានដល់ស្នូលនៃអ្វី ដែលរាំងស្ទះអ្នក
- "បង្កើតរូបភាពនៃបញ្ហានោះ ដើម្បីស្វែងរកនិងចាត់ ចែងការលើកទឹកចិត្ត និង គំនិតនានា
- "ឥឡូវនេះ ឬ គ្មានពេលណាទាំងអស់" ដើម្បីដោះ ស្រាយបញ្ហានៃការពន្យាពេល
- "កែប្រែរបៀបធម្មតារបស់អ្នក" ដើម្បីងាកចេញ ពីទម្លាប់ចាស់
- គាំទ្រ ទល់នឹងគាំទ្រ" ដើម្បីធ្វើសេចក្តីសម្រេចចិត្ត
- មើលបញ្ហានោះតាមទស្សនទានរបស់អ្នកដទៃ

អ្នកអាចចម្លងយកដោយឥតគិតថ្លៃ
UNSTUCK IPAD APP At
HTTP://BIT.LY/UNSTUCKGIFT

www.UNSTUCK.com

# ច. ការតាមដានសមធម៌បែបនីតិវិធី

**គោលបំណងនៃការរៀនសូត្រ** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹង៖

- អាចពន្យល់ សមធម៌នីតិវិធី និង
- កំណត់បានអត្តសញ្ញាណ និងបង្ហាញហេតុផលនៃលការណ៍ និង ធាតុផ្សំសំខាន់ៗដែលត្រូវតាមដាន ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ និងសូចនាករមួយឈុត ដើម្បីវាយតម្លៃថាតើសម្រេចបានសមធម៌ នីតិវិធីហើយ ឬ នៅ។

**សម្ភារៈ** ក្រដាសផ្ទាំងធំ ហ្វឺត ប័ណ្ណ ក្រដាស Post-it ស្កុត និង ឯកសារអំណាន




**រយៈពេល** ៩០នាទី

---

## ជំហាននានា

**១.** បង្ហាញមេរៀននេះ ដោយពន្យល់ថា ប្រសិនបើគោលដៅចុងក្រោយជាសមធម៌បែបនីតិវិធីនៅក្នុង កិច្ចផ្តួចផ្តើម REDD+ ឬទិដ្ឋភាពដទៃទៀតនៃព្រៃឈើ និងការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ យើងត្រូវពិចារណាអំពីរបៀបតាមដានថា តើការប្រែប្រួលបានកើតឡើងនៅកម្រិតខុសៗគ្នានៃការ ពាក់ព័ន្ធដែរឬទេ។

**២.** ពិនិត្យឡើងវិញក្របខ័ណ្ឌសមធម៌ដោយរំលឹកសិក្ខាកាមថា នៅទូទាំងវគ្គបណ្តុះបណ្តាលនេះការ យកចិត្តទុកដាក់បានផ្តោតលើការពាក់ព័ន្ធ និងតួនាទីរបស់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន។ ទោះជាយ៉ាងណាក៏ដោយ ... គោលដៅគឺ សម្រាប់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានដើម្បីមាន ឥទ្ធិពលមកលើសមធម៌បែបនីតិវិធី ដើម្បីធានាថា គុណតម្លៃតាមបែបចូលរួមត្រូវបានអនុវត្តនៅ ទូទាំងដំណើរការពាក់ព័ន្ធ។ ប្រការនេះរាប់បញ្ចូលការចូលរួមយ៉ាងសកម្ម និងប្រកបដោយខ្លឹមសារ របស់ក្រុមជនទន់ខ្សោយដូចជាស្ត្រីជនជាតិដើមភាគតិច និងសហគមន៍ដែលផ្អែកលើព្រៃឈើ។

**៣.** បែងចែកសិក្ខាកាមជាក្រុមដែលមានគ្នាបួន ឬ ប្រាំនាក់។ ស្នើឱ្យពួកគាត់ស្រមៃថា ពួកគាត់ត្រូវបាន ជ្រើសរើសជាក្រុមការងារនៅក្នុងក្រុមការងារពិសេសថ្នាក់ជាតិ សម្រាប់តាមដានសមធម៌នីតិវិធីនៅ ក្នុងការអភិវឌ្ឍនៃយុទ្ធសាស្ត្រជាតិ REDD+ និងបន្ទាប់មក គឺការអនុវត្ត។ ចូរពន្យល់ថា អ្នកចង់ឱ្យ ពួកគាត់កំណត់អត្តសញ្ញាណអ្វីដែលពួកគាត់គិតថា ជាគោលការណ៍ ឬ ធាតុផ្សំសំខាន់ៗដែលអាច ជានាសមធម៌នីតិវិធី។ នៅពេលនោះ ពួកគាត់គួរតែបង្កើតលក្ខណៈវិនិច្ឆ័យ និងសូចនាករដែលជា ផ្នែកមួយនៃដំណើរការនោះ។ ចូរកត់សំគាល់ថា ពួកគាត់គួរតែផ្តោតលើអ្វីដែលពួកគាត់ត្រូវតាមដាន

និងរបៀបដែលពួកគេរស់ និងគួរតែមានលក្ខណៈងាយតាមតែអាចធ្វើបាន ដើម្បីអាចឱ្យអ្នកពាក់ព័ន្ធទាំងអស់យល់បាន។

៤. ចូរពន្យល់ថា ក្រុមការងារនេះនឹងត្រូវគេស្នើឱ្យបង្ហាញក្របខ័ណ្ឌតាមដានរបស់ខ្លួន ទៅក្រុមការងារពិសេសថ្នាក់ជាតិក្រោយរយៈពេល ៦០នាទី ។ ពួកគាត់នឹងមានរយៈពេល ៥នាទី សម្រាប់ធ្វើការបង្ហាញ។ ចូរពន្យល់ថា ក្រុមការងារពិសេសនេះរំពឹងចង់ឃើញបទបង្ហាញច្បាស់លាស់តាមវិជ្ជាជីវៈសម្រាប់ក្រុមនីមួយៗ។ ចូរលើកទឹកចិត្តដល់ក្រុមនានាឱ្យសរសេរឱ្យបានច្បាស់លាស់លើក្រដាសផ្ទាំងធំ និងប្រើប្រាស់ប័ណ្ណ ដើម្បីពួកគេអាចមានភាពបត់បែនក្នុងការសាកល្បង និងពិនិត្យមើលគំនិតខុសៗគ្នា និងយោបល់នានា។ ក្រោយរយៈពេល ៦០នាទី ស្នើសិក្ខាកាមឱ្យមកជុំគ្នាដើម្បីធ្វើការបង្ហាញលទ្ធផលរបស់ខ្លួន។ ត្រូវហ្មត់ចត់ចំពោះពេលវេលា និងត្រូវលើកសំណួរ ដើម្បីឱ្យប្រាកដថា ក្រុមនីមួយៗផ្តល់ហេតុផលសម្រាប់ក្របខ័ណ្ឌរបស់ខ្លួន។

៥. ក្រោយពីក្រុមទាំងអស់បានធ្វើការបង្ហាញរួចហើយ ត្រូវស្នើសិក្ខាកាមធ្វើការឆ្លុះបញ្ចាំង ដោយប្រើប្រាស់សំណួរដូចតទៅ៖

- *ផ្អែកតាមបទបង្ហាញ តើក្រុមណាខ្លះ ដែលអ្នកគិតថានឹងអាចតាមដានសមធម៌បែបនីតិវិធីដោយប្រសិទ្ធភាព?*
- *តើមានអ្វីខ្លះខុសគ្នាក្នុងចំណោមបទបង្ហាញទាំងអស់?*
- *តើមានគោលការណ៍ ឬ ធាតុផ្សំអ្វីខ្លះដែលដូចគ្នាក្នុងក្របខ័ណ្ឌតាមដានទាំងអស់?*
- *តើនៅខ្វះអ្វីខ្លះក្នុងក្របខ័ណ្ឌសម្រាប់ការតាមដានសមធម៌បែបនីតិវិធីប្រកបដោយប្រសិទ្ធភាព?*
- *តើអាចតាមដានឥទ្ធិពលនៃសមធម៌បែបនីតិវិធីមកលើបញ្ហាសមធម៌ដោយរបៀបណា?*
- *តើមានភាពខុសគ្នាឬទេ រវាងការតាមដានដំណើរការ និងលទ្ធផល?*
- *អ្នកណាខ្លះកំពុងតាមដានសមធម៌បែបនីតិវិធីនៅក្នុងបរិបទនៃ REDD+ របស់អ្នក?*
- *តើអ្នកសម្របសម្រួលថ្នាក់មូលដ្ឋានមានតួនាទីអ្វីខ្លះនៅក្នុងសមធម៌បែបនីតិវិធី?*

៦. ក្រោយពីការឆ្លុះបញ្ចាំង ចូរបង្ហាញគោលការណ៍ ឬ ធាតុផ្សំនៃសមធម៌បែបនីតិវិធី (សូមអានឯកសារអំណាន ប៉ុន្តែពុំទាន់ចែកជូនពេលនេះទេ) ដែលនៅត្រូវរៀបចំលក្ខណៈវិនិច្ឆ័យ និងសូចនាករ។ ដូចដែលអ្នកធ្វើការបង្ហាញ ចូរព្យាយាមបង្ហាញភាពពាក់ព័ន្ធគ្នាជាមួយក្របខ័ណ្ឌនានារបស់សិក្ខាកាម ដោយផ្តល់ឧទាហរណ៍អំពីលក្ខណៈវិនិច្ឆ័យ ឬ សូចនាករ សម្រាប់ក្របខ័ណ្ឌទាំងនោះដែលត្រូវគ្នាជាមួយគោលការណ៍ខុសៗគ្នា ឬ ធាតុផ្សំនានា។ ក្រោយពីបានបង្ហាញក្របខ័ណ្ឌទាំងនោះរួចហើយ ចូរធ្វើការឆ្លុះបញ្ចាំងជាមួយក្រុមនេះអំពីគោលការណ៍ និងធាតុផ្សំនានា។ សួរពួកគាត់ថា តើក្របខ័ណ្ឌរបស់ពួកគេសង្កត់ធ្ងន់លើអ្វីខ្លះ និងមួយណា ដែលពួកគាត់ភ្លេច។

**៧.** ក្រោយពីបានឆ្លុះបញ្ចាំង ត្រូវសួរសិក្ខាកាមថា តើពួកគាត់គិតថាមានសមធម៌បែបនីតិវិធីនៅក្នុងដំណើរការ REDD+ របស់ខ្លួននៅថ្នាក់ជាតិ និង/ឬថ្នាក់មូលដ្ឋានឬទេ។ សួរពួកគាត់ថា តើពួកគាត់គិតថាអ្វីខ្លះដែលនៅខ្វះឬទេ។

**៨.** ចូរបញ្ជាក់ឱ្យបានច្បាស់ដល់សិក្ខាកាមថា មានភាពខុសគ្នារវាងការតាមដាន**ដំណើរការ** និងការតាមដានលទ្ធផល។ សមធម៌បែបនីតិវិធីគឺអំពីការតាមដាននីតិវិធី និងដំណើរការនានាដែលមាននៅនឹងកន្លែង ដើម្បីតាមមើលប្រសិទ្ធភាពនៃការចូលរួម។ ចូរពន្យល់ថា ប្រសិនបើបានចងក្រងដំណើរការនេះជាឯកសារ ក្នុងករណីនោះ គេអាចផ្សារភ្ជាប់ជាមួយផលប៉ះពាល់នានាសម្រាប់ឥទ្ធិពលដែលមានមកលើការបែងចែកសមធម៌ និងបរិបទសមធម៌។

**៩.** ចូរបូកសរុបមេរៀននេះ ដោយពន្យល់ថា ជាការមានប្រយោជន៍ក្នុងការណែនាំគោលគំនិតនៃការតាមដានសមធម៌បែបនីតិវិធី ក្នុងនាមជាអ្នកសម្របសម្រួលថ្នាក់មូលដ្ឋាននៅក្នុងក្រុមអ្នកពាក់ព័ន្ធខុសៗគ្នាជាច្រើន ដោយសារវាអាចអនុញ្ញាតឱ្យមានការសង្កេតដោយប្រុងប្រយ័ត្នអំពីថា តើក្រុមណាខ្លះដែលមិនបានចូលរួមសកម្ម និងលទ្ធផលផ្ទាល់ ឬ ប្រយោលនៃសកម្មភាពនោះ។

---

## កំណត់សំគាល់របស់គ្រូបង្ហាត់

សិក្ខាកាមទំនងជាជួបការលំបាកក្នុងការកំណត់គោលការណ៍ និងធាតុផ្សំសំខាន់ៗ។ ទោះជាយ៉ាងណាក៏ដោយជាការល្អគឺ ត្រូវទុកឱ្យពួកគាត់ពិភាក្សាបំផុសគំនិតជាដំបូង និងបន្ទាប់មកឆ្លុះបញ្ចាំងអំពីគោលការណ៍នានា និងធាតុផ្សំនៅពេលដែលអ្នកណែនាំអំពីគោលការណ៍ទាំងនោះ។

# ការតាមដានសមធម៌បែបនីតិវិធី

## ការបង្កើតក្របខ័ណ្ឌតាមដានសមធម៌បែបនីតិវិធី

ដ្យាក្រាមខាងក្រោមអធិប្បាយអំពីគោលការណ៍នានា ឬ ធាតុផ្សំសំខាន់ៗដែលត្រូវការតាមដាន នៅពេលបង្កើតសមធម៌បែបនីតិវិធី។ វាផ្តល់ការពន្យល់បន្ថែមអំពីបញ្ហានានាដែលត្រូវតែ ឬ បានទទួលការពិចារណា។ លក្ខណៈវិនិច្ឆ័យ និងសូចនាករជាក់លាក់នៅពុំបានកំណត់នៅឡើយ ដោយសារវាអាស្រ័យលើបរិបទលក្ខខណ្ឌ ឬស្ថានភាពជាក់លាក់ ដែលកំពុងស្ថិតក្នុងការតាមដាន។



| គោលការណ៍ និងធាតុផ្សំសំខាន់ៗ | បញ្ហាដែលត្រូវពិចារណា |
|---|---|
| ការត្រៀមខ្លួននៅមុនពេលធ្វើការពាក់ព័ន្ធ | ការវិភាគអ្នកពាក់ព័ន្ធ ការកំណត់អត្តសញ្ញាណនៃ បញ្ហាសមធម៌ និងការលើកទឹកចិត្តនានា និងឧបសគ្គចំពោះការចូលរួមសម្រាប់ក្រុមនីមួយៗ។ |
| ឧបករណ៍ប្រាស្រ័យទាក់ទង និងរចនាបថនៃដំណើរការពាក់ព័ន្ធដែលមានប្រសិទ្ធភាព | ដំណើរការមួយដើម្បីឱ្យអ្នកទាំងអស់គ្នាពាក់ព័ន្ធ, ឧបករណ៍មានការពាក់ព័ន្ធសម្រាប់គោលបំណង។ ឱកាសសម្រាប់ទាំងអស់គ្នាដើម្បីចូលរួមដោយពិតគូរផងដែរអំពីក្រុមអ្នកទន់ខ្សោយអាចប្រើប្រាស់ឧបករណ៍នេះ |
| យន្តការបណ្តឹងសារទុក្ខ និងការគ្រប់គ្រងទំនាស់ | យន្តការបណ្តឹងសារទុក្ខដាក់ឱ្យប្រើប្រាស់ក្រុមនានាបានដឹងអំពីយន្តការបណ្តឹងសារទុក្ខមានការណែនាំអព្យាក្រឹត្យសម្រាប់ជនជាតិដើមភាគតិច |
| តម្លាភាព និងការទទួលបានព័ត៌មាន | ទម្រង់ និងវត្តមាននៃព័ត៌មានសម្រាប់គ្រប់ក្រុម នីតិវិធីមានតម្លាភាព និងប៉ារ៉ាម៉ែត្រច្បាស់លាស់អំពីការទទួលបានព័ត៌មាន។ |
| ការរួមបញ្ចូល និងការធ្វើជាតំណាង | ក្រុម/ក្រុមរងទាំងអស់មានវត្តមាននៅថ្នាក់ខុសៗគ្នាដែលរួមទាំងស្ត្រី និងជនជាតិដើមភាគតិច ក្រុមដែលមានឋានៈពិសេស បានពេញចិត្តចំពោះស្ថានភាពរបស់ក្រុម និងតំណាងពីក្រុមជនជាតិដើមខុសៗគ្នា។ |
| កំណត់ត្រា របាយការណ៍ និងឯកសារអំពីដំណើរការ | របាយការណ៍អំពីអ្នកចូលរួម និងទស្សនៈ ដែលរួមទាំង ការចងក្រងជាឯកសារមិនតាមធម្មតានៃទស្សនទានពីដើមដំបូង ដូចជា របាយការណ៍តាមការផលិតវីដេអូតាមបែបចូលរួម |
| លទ្ធផលសមធម៌ទៅតាមបរិបទ និងការបែងចែក | គូសផែនទីអំពីបញ្ហាសមធម៌ និងការកែប្រែជាបន្តបន្ទាប់សាច់រឿងអំពីការប្រែប្រួលដែលកើតមាន ធៀបនឹងសិទ្ធិ និងផលប្រយោជន៍។ |

# ៤ ម៉ូឌុលទី៤



# ពង្រឹងការរៀនសូត្រនៅក្នុងវគ្គ បណ្តុះបណ្តាលរបស់អ្នក ( ជម្រើស )

# ក. សមធម៌ ធៀបនឹងសមភាព
## (រំលឹកឡើងវិញអំពីការរៀនសូត្រ)

**គោលបំណងនៃការរៀនសូត្រ** នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹង ៖

- រំលឹកឡើងវិញពីភាពខុសគ្នារវាងសមធម៌ និងសមភាពដូចដែលបានពន្យល់នៅក្នុងមេរៀនមុនៗ និង
- ពន្យល់អំពីការយល់ដឹងរបស់ពួកគាត់ អំពីខ្លឹមសារនៃពាក្យចំនួនពីរដែលអាចមើលឃើញ។

**សម្ភារៈ** ហ្វឺត ក្រដាសពណ៌ទំហំ A4 ក្រដាសពណ៌ទំហំ A3 ឬ ក្រដាសពណ៌ធំៗជាងនេះ

**រយៈពេល** ៦០ នាទី

---

### ជំហានអនុវត្ត

១. បង្ហាញមេរៀននេះជាការរំលឹកឡើងវិញ។ ត្រូវឱ្យប្រាកដថា សិក្ខាកាមអង្គុយជាក្រុមដែលមានចំនួនសមាជិកស្មើគ្នា។ ចូរចែកសន្លឹកក្រដាសពណ៌ដល់សិក្ខាកាមម្នាក់ៗ និងស្នើឱ្យពួកគាត់គូរខ្សែបន្ទាត់ចុះក្រោមនៅចំកណ្តាល។

២. ស្នើឱ្យពួកគាត់ស្រង់យករូបភាពពីអ្វីដែលពួកគាត់គិតថា ជាសមធម៌មកដាក់នៅផ្នែកម្ខាង និងសមភាព ដាក់នៅផ្នែកម្ខាងទៀតនៃក្រដាស។ ពួកគាត់គួរតែឆ្លុះបញ្ចាំងត្រឡប់ទៅការរៀនសូត្ររបស់ពួកគាត់ពីមេរៀនមុនៗ។ ចូរពន្យល់ថា ពួកគាត់គួរតែគូរឱ្យជិតខ្លាំង និងបំពេញប្រឡោះនៅលើក្រដាស ដើម្បីអ្នកដទៃទៀតអាចមើលឃើញរូបរបស់ពួកគាត់ពីចម្ងាយ។

៣. ផ្តល់ឱ្យពួកគាត់រយៈពេល ៥នាទីដើម្បីគូរ។ សុំពួកគាត់ឱ្យចែករំលែករឿងរ៉ាវតាមរយៈរូបភាពរបស់ខ្លួន ជាមួយសមាជិកផ្សេងទៀតអំពីក្រុមនានារបស់ខ្លួន។

៤. ក្រោយពេលដែលសមាជិកនៃក្រុមនីមួយៗបានពន្យល់រូបភាពរបស់ខ្លួន និងការយល់ឃើញអំពីពាក្យទាំងពីរនេះហើយ ចូរប្រាប់ក្រុមទាំងនេះដើម្បីឱ្យគូររូបធំមួយ ដែលតំណាងឱ្យការយល់ឃើញរបស់ពួកគាត់អំពីពាក្យទាំងពីរនេះ។ ផ្តល់ឱ្យក្រុមនីមួយៗនូវក្រដាសពណ៌ទំហំ A3 ឬធំជាងនេះ។ ចូរផ្តល់ឱ្យក្រុមទាំងនេះរយៈពេល ៥នាទី ដើម្បីគូររូប។ ចូរសង្កត់ធ្ងន់ថានេះមិនមែនជាបញ្ហាអំពីការជ្រើសរើសរូបល្អទេ ប៉ុន្តែជាការបង្កើតរូបមួយដែលនឹងពន្យល់អំពីការយល់ដឹងរួមគ្នារបស់ពួកគាត់ និងភាពខុសគ្នានៃពាក្យទាំងពីរនេះ។

**៥.** នៅក្រោយពេលដែលក្រុមនីមួយៗ បានបង្កើតរូបមួយហើយ ចូរឱ្យពេលពួកគាត់ពីរ ឬ បីនាទី ដើម្បីក្រោកឈរឡើង និងបង្ហាញរូបភាពនោះ ឱ្យបានច្បាស់លាស់ដល់ក្រុមទាំងមូល។ ចូរលើកទឹកចិត្តដល់សមាជិកទាំងអស់នៃក្រុមនេះបានចូលរួម។

**៦.** បន្ទាប់ពីបានបង្ហាញរូបទាំងអស់រួចហើយ ត្រូវសួរសិក្ខាកាមនូវសំណួរឆ្លុះបញ្ចាំងអំពីលំហាត់ និងលទ្ធផលដូចតទៅ៖

- តើអ្នកមានអារម្មណ៍បែបណាពេលអនុវត្តលំហាត់នេះ?
- តើអ្នកធ្វើបែបណាក្នុងការសម្រេចថាតើត្រូវគូររូបអ្វី?
- តើលំហាត់នេះជួយគូសបញ្ជាក់អំពីការយល់ដឹងរួមគ្នារបស់អ្នក ឬទេអំពីសមធម៌ និងសមភាព? ហេតុអ្វី?
- តើអ្នកគិតថាមួយណាសំខាន់ជាងរវាងសមធម៌ និងសមភាព និងហេតុអ្វី?
- តើលំហាត់នេះប្រាប់យើងអំពីអ្វីខ្លះរវាង សមធម៌ និងសមភាព?

**៧.** ចូរបូកសរុបលំហាត់នេះ ដោយធ្វើការរំលឹកឡើងវិញអំពីការរៀនសូត្រនេះ ដោយយោងទៅមេរៀនស្តីពីសមធម៌ និងបទពិសោធន៍របស់សិក្ខាកាមអំពីការកាត់ផ្លែឪឡឹក (ឬផ្លែឈើណាមួយដែលបានប្រើប្រាស់)។ ចូរពន្យល់ថានេះ គឺជាការប្រឈមមួយ ដើម្បីសម្រេច ឬ ឈានដល់លទ្ធផលដែលមានសមធម៌ប្រសិនបើអ្នកពាក់ព័ន្ធ ឬសហគមន៍ពុំបានផ្តល់ឱកាសដូចគ្នាសម្រាប់ការចូលរួម។ ដោយធានាឱ្យមានសមធម៌ យេនឌ័រ នៅក្នុង REDD+ កាត់កាត់បន្ថយការប្រែប្រួលអាកាសធាតុ ឬការគ្រប់គ្រងព្រៃឈើ គឺជាឧទាហរណ៍មួយនៃចំណុចនេះ។ ប្រសិនបើមិនអាចធានាបានគុណភាពនៃយេនឌ័រនៅក្នុងបរិបទ ឬស្ថានភាពណាមួយទេនោះ (ដូចជានៅក្នុងវិសាលភាពនៃគម្រោង REDD+) ក្នុងករណីនោះលទ្ធផលមិនអាចចាត់ទុកថាមានសមធម៌ឡើយ។

---

## កំណត់សំគាល់របស់គ្រូបង្គោល

ដូចក្នុងករណីនៃការបង្កើតរូបភាព ឬ លំហាត់គូររូបដែរសិក្ខាកាមជាច្រើនអាចនៅតែមានៈថា ខ្លួនមិនអាចគូររូបបានឡើយ។ ចូរព្យាយាមលើកទឹកចិត្តពួកគាត់ឱ្យជំនះឧបសគ្គនេះ និងគូរអ្វីមួយងាយៗដែលអាចបញ្ជូនសារអំពីការយល់ដឹងរបស់ពួកគាត់ដោយពុំចាំបាច់សរសេរ។ នៅក្នុងស្ថានភាពនេះជាការប្រសើរដែលអ្នកពុំចាំបាច់ផ្តល់ឧទាហរណ៍ឡើយ បើពុំនោះទេសិក្ខាកាមទាំងអស់អាចចម្លងយកគំនិតនោះទាំងអស់គ្នា។

# ការបង្កើតរូបភាពអំពីសមភាព ធៀបនឹងសមធម៌

សូរស្នើសិក្ខាកាមយកក្រដាស A4 មួយសន្លឹក និងបែងចែកជាពាក់កណ្តាលតាមខ្សែកណ្តាលត្រង់ចុះក្រោម។ ស្នើពួកគាត់ឱ្យស្រង់យកនៅក្នុងទម្រង់ជារូបភាពមួយដែលពួកគាត់គិតថា ជាសមធម៌នៅផ្នែកម្ខាង និងសមភាពនៅផ្នែកម្ខាងទៀត។ នៅក្រោយពួកគាត់បានចែករំលែករូបរបស់ពួកគាត់រៀងៗខ្លួន ហើយចូរស្នើឱ្យពួកគាត់គូររូបមួយជាក្រុមដែលបង្ហាញពីការយល់ដឹងរបស់ពួកគាត់ អំពីភាពខុសគ្នារវាងសមធម៌ និងសមភាព។

ខាងក្រោមនេះជាឧទាហរណ៍មួយអំពីការយល់ដឹងតាមរូបភាព ដូចមានបង្ហាញដោយក្រុមមួយនៃសិក្ខាកាមនៅក្នុងការសាកល្បងឯកសារបណ្តុះបណ្តាលនេះនៅក្នុង ខែកញ្ញា ឆ្នាំ២០១៣។ ស្រោមដៃ និងដៃ គឺជាតំណាងឱ្យគុណភាពដែលអាចមើលឃើញបាន ដោយសារដៃទាំងអស់ទទួលស្រោមដៃមួយគូដូចគ្នា ទោះបីដៃរបស់ពួកគាត់មានទំហំប៉ុណ្ណាក៏ដោយ។ ស្រោមដៃមានទំហំប៉ុនគ្នា និងមានរាងដូចគ្នា ដើម្បីឱ្យត្រូវជាមួយដៃ ហើយនេះតំណាងឱ្យសមធម៌។



# ខ. តើអ្នកសម្របសម្រួលថ្នាក់មូលដ្ឋានអាចដោះស្រាយសមធម៌ដោយរបៀបណា? (រំលឹកឡើងវិញអំពីការរៀនសូត្រ)

**គោលបំណងនៃការរៀនសូត្រ**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹងៈ

- សំយោគអំពីថា តើអ្នកសម្របសម្រួលនៅក្នុងថ្នាក់មូលដ្ឋានអាចដោះស្រាយសមធម៌ដោយរបៀបណា ដោយផ្អែកលើការរៀនសូត្រពីមេរៀនមុនៗ និង
- ពង្រឹងចំណេះដឹងរបស់ខ្លួន និងកែសម្រួលគំនិតរបស់ខ្លួន ជាមួយអ្នកដទៃទៀតនៅក្នុងទម្រង់ជាចម្រៀងរបេ។

**សម្ភារៈ**

ក្រដាសផ្ទាំងធំ ហ្វឺត ប័ណ្ណ ក្រដាស Post-it ឧបករណ៍ភ្លេងរបេ ឬឧបករណ៍ សម្រាប់ស្ទូតកំណាព្យ និងមីក្រូហ្វូន




**រយៈពេល**

៦០នាទី

---

## ជំហានអនុវត្ត

១. សូមបង្ហាញមេរៀននេះ ជាការបូកសរុបមេរៀនឡើងវិញ ក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងមក។ មេរៀននេះគួរតែបានអនុវត្តនៅពាក់កណ្តាលនៃរយៈពេលប្រាំថ្ងៃនៃវគ្គបណ្តុះបណ្តាលនេះ។ ចូរពន្យល់ថា នេះគឺជាឱកាសដើម្បីវិភាគពិចារណា និងបង្កើតគំនិតអំពីថា តើក្នុងនាមជាអ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន សិក្ខាកាមអាចមានឥទ្ធិពលបែបណាមកលើដំណើរការនានាដែលអាចលើកកម្ពស់សមធម៌។ ដោយយោងទៅលទ្ធផលដែលបានពីមេរៀនខុសៗគ្នា ចូររំលឹកដល់សិក្ខាកាមអំពីអ្វីដែលអ្នកបានពិនិត្យមើលរួចមកហើយដោយពុំចាំបាច់ពិភាក្សាឡើងវិញដោយលម្អិតឡើយ។ អ្នកអាចទាញចំណាប់អារម្មណ៍របស់ពួកគាត់មករកក្រដាសផ្ទាំងធំដែលមានដ្យាក្រាម និងលទ្ធផលនានាដែលបិទភ្ជាប់នឹងជញ្ជាំង ឬក្តារខៀនក្នុងបន្ទប់បណ្តុះបណ្តាលនេះ។

២. ជ្រើសរើសសិក្ខាកាមដោយចោះៗ ដើម្បីបែងចែកជាក្រុម ដោយត្រូវប្រាកដថា ក្នុងក្រុមនីមួយៗមានចំនួនសិក្ខាកាមដូចគ្នា ដែលបានធ្វើការជាមួយគ្នាជាបន្តបន្ទាប់នៅក្នុងមេរៀនមុនៗឱ្យនៅក្នុងក្រុមជាមួយគ្នា។

៣. ចូរស្នើសិក្ខាកាមគ្រប់គ្នាឱ្យគិតពីវិធីខុសៗគ្នាជាច្រើន តាមតែអាចធ្វើបានអំពីថា តើអ្នកសម្របសម្រួលនៅមូលដ្ឋានអាចដោះស្រាយ និងលើកកម្ពស់សមធម៌ នៅក្នុងបរិបទរបស់ពួកគាត់ដោយរបៀបណា? ចូរផ្តល់ពេល ១០នាទី ដល់ពួកគាត់សម្រាប់សកម្មភាពនេះ។ ចូរប្រាប់ឱ្យពួកគាត់សរសេរគំនិតមួយលើប័ណ្ណមួយសន្លឹក។ ចូរគោរពឱ្យបានតាមម៉ោងពេល។ ប្រសិនបើចាំបាច់ត្រូវជំរុញឱ្យពួកគាត់ធ្វើការបានរហ័សបន្តិច។

៤. រយៈពេល ១០នាទីក្រោយមក ចូរពន្យល់ថា ឥឡូវនេះ ពួកគាត់នឹងមានពេល ១០នាទី ដើម្បីពិភាក្សាអំពីគំនិតរបស់ខ្លួន ដោយធ្វើឱ្យប្រាកដថា ពួកគាត់យល់ច្បាស់អំពី ទស្សនៈគ្នាទៅវិញទៅមក។ ដូចគ្នានេះដែរ ត្រូវគោរពតាមម៉ោងពេលកំណត់។

៥. រយៈពេល ១០នាទី ក្រោយមកត្រូវពន្យល់ថា ជំហានបន្ទាប់គឺ ក្រុមនីមួយៗត្រូវបង្កើតទំនុកច្រៀងរេបមួយ អំពីរបៀបដែលអ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន អាចដោះស្រាយបញ្ហាសមធម៌។ ត្រូវឱ្យប្រាកដថា សិក្ខាកាមទាំងអស់យល់តបទចម្រៀងរេបជាអ្វី។ ចូរពិចារណាអំពីការផ្តល់ឧទាហរណ៍ខ្លះៗ អំពីចម្រៀងរេប នៅពីខាងក្រោយ ដើម្បីសម្រួលដល់ដំណើរការគិតរបស់ក្រុមនេះ។ ប្រសិនបើចាំបាច់អាចស្នើសិក្ខាកាមណាម្នាក់ឱ្យផ្តល់ជាឧទាហរណ៍។

៦. ប្រសិនបើក្រុមនេះមានការលំបាកក្នុងការអនុវត្តកិច្ចការនេះ អ្នកអាចផ្តល់ឱ្យពួកគាត់នូវវិធីអនុវត្តតាមផ្លូវកាត់។ ពួកគាត់អាចប្តូរទំនុកច្រៀង នៅក្នុងបទចម្រៀងមួយដែលបានមកពីចម្រៀងដែលមានការពេញនិយម និងដែលមនុស្សគ្រប់គ្នាចេះច្រៀង។ ពួកគាត់អាចជំនួសទំនុកច្រៀងនៅក្នុងចម្រៀងនោះ ដោយទំនុកច្រៀងរបស់ពួកគាត់។ នៅក្នុងវគ្គនីមួយៗ ពួកគាត់អាចបង្កើតបទចម្រៀងពីគំនិតដែលពួកគាត់បានសរសេរនៅលើប័ណ្ណមុននេះ។ ចូរពន្យល់ថា អ្នកនឹងផ្តល់ឱ្យពួកគាត់រយៈពេលមិនច្រើនជាង ១៥នាទី ឡើយ ដើម្បីរៀបចំទំនុកច្រៀងនេះ។

៧. ក្រោយរយៈពេល ១៥នាទី ត្រូវបញ្ឈប់លំហាត់នេះ និងពន្យល់ថា ពួកគាត់ត្រូវច្រៀងចម្រៀងរបស់ខ្លួននៅក្នុងពិធីមហោស្រពចម្រៀងរេប ដើម្បីលើកកម្ពស់សមធម៌។ ចូរផ្តល់ឱ្យពួកគាត់ ៥នាទី ដើម្បីត្រៀមច្រៀង។

៨. ក្រោយ ៥នាទី ស្នើឱ្យក្រុមនីមួយៗឡើងច្រៀង។ ចូរព្យាយាមបង្កើតបរិយាកាសដែលក្នុងនោះក្រុមទាំងអស់មានទំនុកចិត្ត ដើម្បីច្រៀង។ ចូរផ្តល់ការលើកទឹកចិត្ត និងចុះឈ្មោះអ្នកដែលមានទំនុកចិត្ត និងដែលមានវោហារ ក្នុងចំណោមសិក្ខាកាមដើម្បីឡើងច្រៀង។

៩. ក្រោយពេលដែលក្រុមទាំងអស់បានច្រៀងហើយ សូមសួរសំណួរឆ្លុះបញ្ចាំងដូចតទៅ៖

- *តើពួកគាត់មានអារម្មណ៍បែបណាក្នុងពេលច្រៀងបទចម្រៀងរេប និងហេតុអ្វី?*
- *តើគំនិតសំខាន់ៗអ្វីខ្លះ ដែលលេចចេញពីបទចម្រៀងរេបនេះ?*
- *តើមានគំនិតដោយឡែកអ្វីខ្លះ នៅក្នុងបទចម្រៀងរេបនេះ?*

- *តើអ្នកចូលចិត្តបទចម្រៀងណាមួយជាងគេ និងហេតុអ្វី?*
- *តើសកម្មភាពនេះបានជួយផ្សារភ្ជាប់គំនិតខុសៗគ្នា បែបណាដែរ?*

១០. ចូរបូកសរុបមេរៀននេះ។ សូមបិទភ្ជាប់ទំនុកច្រៀងទាំងនេះនៅជាប់នឹងសន្លឹកក្រដាសផ្ទាំងធំដែលបង្ហាញពីតួនាទីរបស់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន។ ចូរពន្យល់ថា លំហាត់នេះត្រូវបានរៀបចំឡើង ដើម្បីសម្រួលដល់ការយល់ដឹងរបស់សិក្ខាកាមអំពីសមធម៌ និងរួមបញ្ចូលវិធីនានា ដែលអ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន អាចមានឥទ្ធិពលមកលើដំណើរការនានា ដែលអាចលើកកម្ពស់សមធម៌ ដែលបានពិភាក្សារួចមកហើយនៅក្នុងវគ្គបណ្តុះបណ្តាលនេះ។

# មហោស្រពចម្រៀងរេប (Rap) អំពីសមធម៌

ស្នើឱ្យក្រុមនេះសរសេរទំនុកច្រៀងសម្រាប់បទចម្រៀងរេបមួយដែលពន្យល់អំពីថា តើអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានអាចលើកកម្ពស់សមធម៌បែបណា។ ចូរបង្កើតឱ្យមានឱកាសបែបច្នៃប្រឌិតបើកចំហ និងមានសុវត្ថិភាព ដែលបង្កើតឱ្យមានអារម្មណ៍ដូចជាក្នុងមហោស្រពរេបមួយ ដោយប្រើប្រាស់ឧបករណ៍ដែលអាចមើលឃើញតាមរូបភាព សម្លេងភ្លេងបន្តិចៗ និងឆាកដែលមានមីក្រូហ្វូន ប្រសិនបើអាចធ្វើបាន។ ការផ្តល់ស្គរ និងឧបករណ៍ភ្លេងដទៃទៀត ក៏អាចបង្កើនដំណើរការគិតរបស់ក្រុមនេះផងដែរ នៅពេលរៀបចំទំនុកច្រៀងរបស់ខ្លួន។



**ការរៀបចំគឺជាគន្លឹះ បើអ្នកចង់ធ្វើឱ្យបានត្រឹមត្រូវ មនុស្សកាន់តែច្រើននឹងចូលរួម ហើយអ្នកនឹងបានឃើញ។**

**បើអ្នកចូលរួមអ្នកនឹងមិនមានអារម្មណ៍ថា គំនិតរបស់អ្នកដូចនៅក្នុងទ្រុងមួយឡើយសមធម៌គឺជាភាពចាំបាច់ ចូរលើកទឹកចិត្តឱ្យមានការចូលរួមឱ្យបានត្រឹមត្រូវ ចាប់ពីដើមដំបូងនៃដំណើរការ។**

**បើកឆាកជួយចូលរួមនៅក្នុងក្រុមចែករំលែករំលែកព័ត៌មាន លើកកម្ពស់កម្ពស់សមធម៌យេនឌ័រ។ មិនត្រឹមតែដឹងពីយេនឌ័រនោះទេ អ្នកគួរតែធ្វើឱ្យបានច្រើនជាងត្រឹមការយកចិត្តទុកដាក់ ភាពប្រឬកប្រឬបល់ពីការណ៍ពិត យោបល់ និងជំនឿអាចបង្កើនថាមពលដើម្បីស្លាបនានៅក្រៅបន្ទប់ដូចជាចោរ។**

**ដូច្នេះត្រូវប្រើគំរូសួរសំណួរជួយពន្យល់ពីដំណើរការនៃការចូលរួម លើកទឹកចិត្តអ្នកពាក់ព័ន្ធទាំងអស់ ក្រោយពីនោះអ្នកអាចបញ្ចុះបញ្ចូលអ្នកកសាងគោលនយោបាយ។**

**សមធម៌ពីការរៀបចំ ដើម្បីលើកកម្ពស់កម្ពស់ការចូលរួមកែលម្អដំណើរការ និងទំនាក់ទំនងសង្គម។**

ឧទាហរណ៍មួយអំពីបទចម្រៀងរ៉ាប់ស្តីពីការលើកកម្ពស់សមធម៌ ដែលនិពន្ធដោយសិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាលសាកល្បងឯកសារនេះ៖ Emily Etue, Luis Barquin, Kinnalone, Bishnu Pouydal, 2013.

# គ. តើអ្នកឃើញ មានអារម្មណ៍ ឮ និងរៀនសូត្រ អ្វីខ្លះសម្រាប់លើកកម្ពស់សមធម៌?

| | |
|---|---|
| គោលបំណងនៃការរៀនសូត្រ | នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹង៖<br>• ពិភាក្សាពីបទពិសោធន៍នៃការរៀនសូត្ររបស់ខ្លួនស្ដីពី ការលើកកម្ពស់សមធម៌ និង<br>• ពិភាក្សាសំណួរនានា សម្រាប់គ្រូបង្គាត់ ដើម្បីឆ្លើយតបនៅក្នុងដំណើរការដែលនៅសល់ ក្នុងវគ្គរៀនសូត្រនេះ។ |
| សម្ភារៈ | ក្រដាសផ្ទាំងធំ ជាមួយក្របខ័ណ្ឌ ដែលមើលឃើញសម្រាប់ក្រុមនីមួយៗ ហ្វឺត និងប័ណ្ណ ឬ ក្រដាស Post-it (បួនពណ៌) |
| រយៈពេល | ៤០នាទី |

## ជំហានអនុវត្ត



១. សូមពន្យល់ថាសកម្មភាពនេះនឹងជួយសិក្ខាកាមឆ្លុះបញ្ចាំងអំពីការរៀនសូត្ររបស់ពួកគាត់ជាបុគ្គល និងជាក្រុមស្ដីពី ការលើកកម្ពស់សមធម៌ តាមរយៈការរៀបចំ និងការអនុវត្តដំណើរការពាក់ព័ន្ធបែបច្នៃប្រឌិត។

២. ចែកក្រដាសផ្ទាំងធំ ជាបួនផ្នែក (ដោយគូរបន្ទាត់ខ្វែងជាសញ្ញាលេខបូក)។ បន្ទាប់មក គូររូបសញ្ញាសម្រាប់មើល (ភ្នែកមួយ) ស្ដាប់ (ត្រចៀកមួយ) អារម្មណ៍ (បេះដូងមួយ) និងការរៀនសូត្រ (ដៃមួយ) នៅក្នុងជ្រុងនីមួយៗនៃផ្ទៃក្រដាសផ្ទាំងធំនោះ។

៣. បែងចែកសិក្ខាកាមជាក្រុមដែលមានគ្នា បួន ឬ ប្រាំនាក់។ ចូរផ្ដល់ឱ្យពួកគាត់នូវក្រដាសផ្ទាំងធំមួយដែលបានរៀបចំ ដោយក្រុមនីមួយៗមានរូបដូចគ្នា ដែលបានប្រើប្រាស់នៅក្នុងឧទាហរណ៍នេះ។

៤. ចូរពន្យល់ថា អ្នកចង់ឱ្យសិក្ខាកាមគិតដោយស្ងាត់ៗអំពីអ្វីដែលខ្លួនបានឃើញ ឮចាប់អារម្មណ៍ និងបានរៀនសូត្រនៅក្នុងវគ្គបណ្តុះបណ្តាលនេះ រហូតមកទល់ពេលនេះ ស្តីពីការលើកកម្ពស់សមធម៌។

៥. ចូរពន្យល់ថា ពួកគាត់គួរតែគូររូបដើម្បីជាតំណាងនូវអ្វីដែលពួកគាត់បានឃើញ ឮចាប់អារម្មណ៍ និងរៀនសូត្រ នៅលើក្រដាស Post-it។ ត្រូវបញ្ជាក់ និងរំលឹកពួកគាត់ថា ពួកគាត់មិនត្រូវសរសេរពាក្យអ្វីមួយឡើយ។ ចូរពន្យល់ថា បុគ្គលម្នាក់ៗគួរគូររូបយ៉ាងហោចណាស់មួយនៅលើជ្រុងនីមួយៗ ។ ប្រសិនបើ ពួកគាត់មានពេលច្រើនថែមទៀត ពួកគាត់អាចបន្ថែមរូប។ ចូរផ្តល់ពេល ១៥ នាទី ដើម្បីពួកគាត់គិត និងគូរ។ ចូរពន្យល់ថា ពួកគាត់អាចប្រើរូបសញ្ញាប្រសិនបើពួកគាត់មិនចង់គូររូប។

៦. ក្រោយរយៈពេល ១៥នាទី សូមឱ្យពួកគាត់បិទភ្ជាប់គំនូររបស់ខ្លួននៅតាមជ្រុងនីមួយៗនៃក្រដាសផ្ទាំងធំរបស់ខ្លួន និងទុកពេល ១០នាទី ដើម្បីពួកគាត់វិភាគគំនូររបស់ខ្លួន និងគិតអំពីថាតើពួកគាត់នឹងបង្ហាញគំនូរនេះដល់ក្រុមទាំងមូលបែបណា។

៧. ស្នើក្រុមនីមួយៗបង្ហាញដំណើរនៃការរៀនសូត្រដោយរូបគំនូររបស់ពួកគាត់។ ក្រោយពីបានបញ្ចប់ សូមចង្អុលបង្ហាញបញ្ហាគន្លឹះនានា ឬ សំណួរដែលលេចឡើង។ ប្រសិនបើអ្នកមានពេល អ្នកក៏អាចគូសបញ្ជាក់ពីភាពដូចគ្នា និងភាពខុសគ្នារវាងមេរៀននានារបស់ក្រុមខុសៗគ្នាផងដែរ។

៨. ចូរតាំងបង្ហាញដំណើរនៃការរៀនសូត្រដោយរូបភាព ដែលមាននៅលើក្រដាសផ្ទាំងធំ នៅជាប់នឹងជញ្ជាំងក្នុងបន្ទប់រៀន និងអាចប្រើប្រាស់ជាសម្ភារៈយោងនៅក្នុងពេលឆ្លើយតបនឹងសំណួរថ្មីៗ ឬ ប្រសិនបើសិក្ខាកាមនៅមានសំណួរ។

## កំណត់សំគាល់របស់គ្រូបង្ហាត់

សិក្ខាកាមអាចជំទាស់ ថាពួកគាត់មិនអាចគូររូបអំពីអ្វីដែលពួកគាត់បានឮឡើយ។ ចូរផ្តល់ឧទាហរណ៍ និងលើកទឹកចិត្ត ឱ្យមានទំនុកចិត្តលើវិធីសាស្ត្រនេះ។ ប្រសិនបើការអនុវត្តបានហ្មត់ចត់ល្អិតល្អន់នេះតាមធម្មតាអាចបង្ហាញគំនិតស៊ីជម្រៅអំពីការរៀនសូត្រជាលក្ខណៈបុគ្គល ជាងការចែករំលែករំលែកតាមពាក្យសំដីទៅទៀត។

# ឃ. ការជំរុញឱ្យមានមានច្នៃប្រឌិត និង កែសម្រួលរចនាបថនៃដំណើរការ

**គោលបំណងនៃការរៀនសូត្រ**

នៅចុងបញ្ចប់នៃមេរៀននេះ សិក្ខាកាមនឹង៖

- អនុវត្តការកែប្រែលើការប្រើប្រាស់វត្ថុណាមួយសម្រាប់គោលបំណងខុសៗគ្នា និង
- អាចពន្យល់ អំពីធាតុផ្សំសំខាន់ៗនៃភាពច្នៃប្រឌិត និងការកែសម្រួល និងថាតើវាទាក់ទងគ្នាបែបណា ជាមួយដំណើរការនៃការរៀបចំដំណើរការពាក់ព័ន្ធបែបច្នៃប្រឌិត ដែលអាចលើកកម្ពស់សមធម៌។

**សម្ភារៈ**

វត្ថុដែលអ្នកស្គាល់ច្បាស់ (ដូចជាកៅអីឆ័ត្រកន្ទេល ធុងទឹក ឬ អ្វីផ្សេងទៀត ដែលមាន ដែលមានទំហំធំគ្រប់គ្រាន់សម្រាប់ក្រុមទាំងមូលមើលឃើញពីចម្ងាយ។



**រយៈពេល**

៣០នាទី

---

### ជំហានអនុវត្ត

១. ចូរបង្ហាញមេរៀននេះ ជាលំហាត់អំពីភាពច្នៃប្រឌិត និងការកែសម្រួលជំនាញ។ ចូរផ្សារភ្ជាប់ចំណុចនេះទៅផ្ទះជំនាញជំរុញការចូលរួមដោយច្នៃប្រឌិត និងការប្រើប្រាស់ភាពច្នៃប្រឌិតនៅក្នុងការរៀបចំដំណើរការពាក់ព័ន្ធបែបច្នៃប្រឌិត។

២. សុំឱ្យសិក្ខាកាមឈរជិតគ្នាជារង្វង់ និងដាក់វត្ថុមួយនៅចំកណ្ដាល។ ត្រូវឱ្យប្រាកដថា អ្នកជ្រើសរើសយកវត្ថុដែលមានប្រើប្រាស់ទូទៅតាមលំនៅស្ថាន ដែលមនុស្សគ្រប់រូបស្គាល់ និងប្រើប្រាស់រាល់ថ្ងៃ និងដែលអាចមើលឃើញពីចម្ងាយ។

៣. ចូរស្នើសិក្ខាកាមប្ដូរវេនគ្នា ដើម្បីបង្ហាញពីរបៀបប្រើប្រាស់វត្ថុនោះខុសពីអ្វីដែលធ្លាប់ប្រើប្រាស់។ ឧទាហរណ៍ ប្រសិនបើវត្ថុនោះជាធុងទឹកមួយ ដូច្នេះគេអាចប្រើប្រាស់វាដូចជាឆ័ត្រ ឬជាឧបករណ៍ណាមួយ។ សូមផ្ដល់ជាឧទាហរណ៍តែមួយ បន្ទាប់មកសូមឱ្យសិក្ខាកាមបង្ហាញជាកាយវិការ (ដោយមិននិយាយ)។ អ្នកក្រៅពីនេះត្រូវធ្វើការទស្សន៍ទាយអំពីគោលបំណងនៃការប្រើប្រាស់។

៤. ចូរបន្តលំនាំនៃការអនុវត្តលំហាត់នេះ។ ប្រសិនបើសិក្ខាកាមណាម្នាក់ជួបការលំបាក សូមបន្តទៅសិក្ខាកាមម្នាក់ទៀត ប៉ុន្តែចូរពន្យល់ថា អ្នកទាំងនោះនឹងមានឱកាសម្តងទៀតនៅជុំក្រោយ។

៥. ចូរបន្តរបៀបនេះ ជារង្វង់យ៉ាងហោចណាស់រហូតបានពីរ ឬបីជុំ។ មិនត្រូវរំលឹកសិក្ខាកាមនៅជុំទីបីជាជុំចុងក្រោយឡើយ។ គ្រាន់តែបន្តយ៉ាងឆាប់រហ័ស រហូតដល់អ្នកដែលមានគំនិតច្រើនអំពីរបៀបប្រើប្រាស់ធុងទឹក (ឬវត្ថុណាមួយដែលបានជ្រើសយក)។ អ្នកត្រូវបន្តរហូត យ៉ាងហោចណាស់បីជុំ បើពុំនោះទេជាតុផ្សំសំខាន់ៗនៃភាពច្នៃប្រឌិតនឹងមិនអាចរកឃើញបានឡើយ ដូចជាការរួមផ្សំកម្លាំងជាមួយគ្នា ដើម្បីធ្វើឱ្យការប្រើប្រាស់វត្ថុនេះជាក្រុម ឬការរួមផ្សំវត្ថុនេះជាមួយវត្ថុដទៃទៀតនៅក្នុងបន្ទប់នេះ។

៦. បន្ទាប់ពីអ្នកបានបញ្ចប់លំហាត់នេះមក ចូរធ្វើការឆ្លុះបញ្ចាំងជាមួយក្រុមនេះតាមសំណួរដូចតទៅ៖

- *តើអ្នកមានអារម្មណ៍បែបណាក្នុងពេលអនុវត្តលំហាត់នេះ? តើអ្វីដែលធ្វើឱ្យលំបាក និងអ្វីធ្វើឱ្យងាយស្រួល?*
- *តើអ្នកធ្វើបែបណាដើម្បីបានគំនិតថ្មីៗ? តើអ្វីខ្លះជាប្រភពនៃការលើកទឹកចិត្តដល់អ្នក?*
- *តើគំនិតអ្វីខ្លះដែលល្អជាងគេនៅផ្នែកខាងដើមនៃលំហាត់នេះ ឬនៅខាងចុងលំហាត់នេះ និងហេតុអ្វី?*
- *អ្វីខ្លះដែលបានជួយអ្នកកែប្រែរបៀបប្រើប្រាស់វត្ថុនោះ និងអ្វីខ្លះដែលរារាំងអ្នក?*
- *តាមធម្មតា តើអ្នកធ្វើបែបណាដើម្បីស្វែងរកគំនិតថ្មីៗ ក្នុងនាមជាអ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន?*
- *តើលំហាត់នេះទាក់ទងបែបណាជាមួយតួនាទីរបស់អ្នក ជាអ្នកសម្របសម្រួលថ្នាក់មូលដ្ឋាននៅពេលរៀបចំដំណើរការមួយសម្រាប់ក្រុម?*
- *ហេតុអ្វីអ្នកសម្របសម្រួលថ្នាក់មូលដ្ឋានត្រូវមានភាពច្នៃប្រឌិត និងកែប្រែជំនាញ?*
- *តើអ្វីខ្លះដែលអ្នកអាចធ្វើបាន ក្នុងនាមជាអ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន ប្រសិនបើអ្នកជាប់គាំង និងត្រូវការស្វែងរកគំនិតថ្មីៗ ដើម្បីកែសម្រួលកិច្ចការនានាជាផ្នែក មួយនៃដំណើរការជាក្រុម?*

៧. ក្រោយពីបានបញ្ចប់ការឆ្លុះបញ្ចាំងហើយ ចូរសង្ខេបសកម្មភាពនេះ ដោយសង្កត់ធ្ងន់លើតម្រូវការសម្រាប់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន ដើម្បីស្វែងរកវិធីថ្មីៗ និងដំណើរការនានាសម្រាប់ក្រុមនានា ដើម្បីពិនិត្យបញ្ហា ឬ កិច្ចការនៃដំណើរការនានា។ ការកែសម្រួលដំណើរការ និងបញ្ហានេះអាចជួយឱ្យក្រុមមើលឃើញបញ្ហាខុសៗគ្នា។ ចូរផ្សារភ្ជាប់សកម្មភាពនេះជាមួយសន្លឹកព័ត៌មានអំពីគន្លឹះនៃភាពច្នៃប្រឌិត នៅក្នុងមេរៀនស្តីពីការរៀបចំ ដំណើរការពាក់ព័ន្ធដែលមានប្រសិទ្ធភាព។

## កំណត់ត្រារបស់គ្រូបង្ហាត់

គន្លឹះសម្រាប់លំហាត់នេះគឺបន្តដំណើរការរហូត។ នៅពេលដែលអ្នកបន្តជារង្វង់ សូមដាក់សម្ពាធមកលើក្រុមនេះ ដើម្បីធ្វើឱ្យពួកគាត់បន្តមានគំនិតថ្មីៗ និងត្រូវប្រាកដថា អ្នកតែងតែវិលត្រឡប់មករកអ្នកដែលពុំទាន់បានបញ្ចេញគំនិត។

# ឧបសម្ព័ន្ធ ១៖ សេណារីយ៉ូនៃការរៀបចំវគ្គបណ្តុះបណ្តាលទៅតាមមេរៀន

សេណារីយ៉ូនៃការបណ្តុះបណ្តាល ១៖ វគ្គបណ្តុះបណ្តាលក្នុងថ្នាក់មួយលើកមានរយៈពេលប្រាំថ្ងៃ សម្រាប់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន (សម្រាប់គ្រប់ក្រុមមេរៀន)

| ពេល | ថ្ងៃទី ១ | ថ្ងៃទី ២ | ថ្ងៃទី ៣ | ថ្ងៃទី ៤ | ថ្ងៃទី ៥ |
|---|---|---|---|---|---|
| ព្រឹក | បេកគំហើញដោយខ្លួនឯងតាមរយៈការគិតដោយផ្អែកលើសម្បត្តិ<br><br>ការបង្ហាញពីវគ្គបណ្តុះបណ្តាល<br><br>តើសមធម៌ជាអ្វី? | ការបូកសរុបការរៀនសូត្រ<br><br>អ្នកណាខ្លះជាអ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋាន?<br><br>ការផ្សារភ្ជាប់សមធម៌ និងការចូលរួម | ការវិភាគជំនាញរបស់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានសម្រាប់ការពាក់ព័ន្ធដោយប្រសិទ្ធភាព<br><br>ការអនុវត្តជំនាញសួរសំណួរ | ការបូកសរុបការរៀនសូត្រ<br><br>ស្វែងរកអំណាចនិងសមធម៌ | ការអនុវត្តជំនាញពន្យល់<br><br>ការរៀបចំដំណើរការនៃការ |
| រសៀល | ហេតុអ្វីសមធម៌សំខាន់នៅក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលផ្អែកលើព្រៃឈើ ដែលរួមទាំង REDD+<br><br>ការវិភាគក្របខ័ណ្ឌសមធម៌ក្នុងតថភាព | តួនាទីរបស់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានសម្រាប់លើកកម្ពស់សមធម៌នៅថ្នាក់មូលដ្ឋាន<br><br>តើការពាក់ព័ន្ធដោយប្រសិទ្ធភាពជាអ្វី? | ការអនុវត្តជំនាញបង្កើតរូបភាព<br><br>ការរៀបចំដំណើរការពាក់ព័ន្ធដោយប្រសិទ្ធភាព | ការអនុវត្តជំនាញនិទានរឿង<br><br>ប្រអប់ឧបករណ៍ពាក់ព័ន្ធ | ការតាមដានសមធម៌នីតិវិធី<br><br>ទីចំហ និងគ្លីនិក<br><br>ការបូកសរុបវគ្គ |

## សេណារីយ៉ូបណ្តុះបណ្តាល ២៖ សិក្ខាសាលាបណ្តុះបណ្តាលមួយលើករយៈពេលមួយថ្ងៃស្តីពីទិដ្ឋភាពរួម សម្រាប់អ្នកធ្វើសេចក្តីសម្រេច និងអ្នករៀបចំផែនការ

| ពេល | មេរៀន (ថ្ងៃទី ១) |
|---|---|
| ព្រឹក | • ការបង្ហាញជូនអំពីវគ្គបណ្តុះបណ្តាលនេះ (កែសម្រួល)<br>• អ្នកណាខ្លះជាអ្នកពាក់ព័ន្ធនៅក្នុងថ្នាក់មូលដ្ឋាន?<br>• តើសមធម៌ជាអ្វី?<br>• ហេតុអ្វីសមធម៌សំខាន់ ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលផ្អែកលើព្រៃឈើ ដែលរួមទាំង REDD+ |
| រសៀល | • ការប្រើប្រាស់ក្របខ័ណ្ឌសមធម៌នៅក្នុងស្ថានភាពជាក់ស្តែង<br>• ការផ្សារភ្ជាប់ សមធម៌ និងការចូលរួម<br>• ការបូកសរុបការឆ្លុះបញ្ចាំងផ្ទាល់ខ្លួនអំពីសកម្មភាព |

## សេណារីយ៉ូបណ្តុះបណ្តាល ៣៖ សិក្ខាសាលាបណ្តុះបណ្តាលតាមមូលដ្ឋានតែមួយលើករយៈពេលតែមួយថ្ងៃ សម្រាប់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន និងមេដឹកនាំសហគមន៍

| ពេល | ថ្ងៃទី ១ | ថ្ងៃទី ២ (តាមភូមិសាស្ត្រ) | ថ្ងៃទី ៣ |
|---|---|---|---|
| ព្រឹក | • បេកគំហើញផ្ទាល់ខ្លួនតាមរយៈការគិតដែលផ្អែកលើសម្បត្តិ<br>• តើសមធម៌ជាអ្វី? | • បេកគំហើញផ្ទាល់ខ្លួនតាមរយៈការគិតដែលផ្អែកលើសម្បត្តិ<br>• តើសមធម៌ជាអ្វី? | • បេកគំហើញផ្ទាល់ខ្លួនតាមរយៈការគិតដែលផ្អែកលើសម្បត្តិ<br>• តើសមធម៌ជាអ្វី? |
| រសៀល | • ហេតុអ្វីសមធម៌សំខាន់នៅក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលផ្អែក លើព្រៃឈើ ដែលរួមទាំង REDD+<br>• ការផ្សារភ្ជាប់សមធម៌ និងការចូលរួម | •ករណីសិក្សាអំពីដំណើរការពាក់ព័ន្ធនិងកត្តាជោគជ័យ (ប្រើប្រាស់ករណីស្តែងពីមូលដ្ឋាន) | • តើការពាក់ព័ន្ធដោយប្រសិទ្ធភាពជាអ្វី?<br>• ការរៀបចំដំណើរការពាក់ព័ន្ធដោយប្រសិទ្ធភាព (ផ្តោតលើបេកគំហើញពីករណីជាក់ស្តែងនៅមូលដ្ឋាន ដើម្បីរៀបចំដំណើរទៅអនាគត) |

## សេណារីយ៉ូបណ្ដុះបណ្ដាល ៤៖ សិក្ខាសាលាសហគមន៍មួយលើករយៈពេលពីរថ្ងៃ

| ពេល | ថ្ងៃទី ១ | ថ្ងៃទី ២ |
| --- | --- | --- |
| ព្រឹក | • របកគំហើញដោយខ្លួនឯង តាមរយៈ ការគិតដោយផ្អែកលើសម្បត្តិ<br>• តើសមធម៌ជាអ្វី? | • តើការពាក់ព័ន្ធដោយប្រសិទ្ធភាពជាអ្វី?<br>• ប្រអប់ឧបករណ៍ពាក់ព័ន្ធ |
| រសៀល | • ការកំណត់បញ្ហាសមធម៌នៅកម្រិតសហគមន៍<br>• ការផ្សារភ្ជាប់សមធម៌និងការចូលរួម (កែសម្រួល) - ការកំណត់អត្តសញ្ញាណឧបសគ្គចំពោះការចូលរួមសម្រាប់ក្រុមជាក់លាក់ | • ការរៀបចំដំណើរការពាក់ព័ន្ធដែលមានប្រសិទ្ធភាព (កែសម្រួលសម្រាប់ការពាក់ព័ន្ធនៅក្នុងសហគមន៍ តាមក្រុមអ្នកពាក់ព័ន្ធនីមួយៗ)<br>• ផែនការសកម្មភាពសម្រាប់អនាគត |

## សេណារីយ៉ូបណ្តុះបណ្តាល ៥៖ សិក្ខាសាលារៀនសូត្ររយៈពេលបួនថ្ងៃផ្សារភ្ជាប់នឹងការចុះតាមមូលដ្ឋាន

| ពេល | ថ្ងៃទី ១ | ថ្ងៃទី ២ | ចុះមូលដ្ឋាន(សប្តាហ៍ទី ២ មកបន្តវិញ)[១៥] | ថ្ងៃទី ៣ | ថ្ងៃទី ៤ |
|---|---|---|---|---|---|
| ព្រឹក | • របេកគំហើញផ្ទាល់ខ្លួនតាមរយៈការគិតដែលផ្អែកលើសម្បត្តិ<br>• តើសមធម៌ជាអ្វី | • អ្នកណាខ្លះជាអ្នកសម្របសម្រួលថ្នាក់មូលដ្ឋាន<br>• ការផ្សារភ្ជាប់សមធម៌ និងការចូលរួម | | • ឆ្លុះបញ្ចាំង និងចែករំលែក<br>• របេកគំហើញពីមូលដ្ឋានដើម្បីវិភាគបញ្ហាសមធម៌ និងភាពខ្លាំង និងភាពខ្សោយនៃការពាក់ព័ន្ធ និងឧបសគ្គចំពោះការចូលរួមរវាងក្រុមនានានៅមូលដ្ឋាន<br>• តើអ្វីជាការពាក់ព័ន្ធដោយមានប្រសិទ្ធភាព? (ផ្សារភ្ជាប់នឹងរបេកគំហើញពីមូលដ្ឋាន) | • ការអនុវត្តជំនាញបង្កើតរូបភាព ឬជំនាញដឹកនាំខាងយេនឌ័រ<br>• ប្រអប់ឧបករណ៍ពាក់ព័ន្ធ |
| រសៀល | • ហេតុអ្វីសមធម៌សំខាន់នៅក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលផ្អែកលើព្រៃឈើ ដែលរួមទាំង REDD+<br>• ការផ្សារភ្ជាប់សមធម៌ និងការចូលរួម | • តួនាទីរបស់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានដើម្បីបង្កើនសមធម៌នៅមូលដ្ឋាន<br>• អនុវត្តជំនាញសួរសំណួររៀបចំវិធីសាស្ត្រធ្វើការតាមមូលដ្ឋានដើម្បីកំណត់ក្របខ័ណ្ឌសមធម៌ និងឧបសគ្គចំពោះការចូលរួម | | • ការស្វែងយល់ពីអំណាច និងសមធម៌<br>• ជំនាញរបស់អ្នកសម្របសម្រួលថ្នាក់មូលដ្ឋានសម្រាប់ការពាក់ព័ន្ធដោយប្រសិទ្ធភាព | • ការរៀបចំដំណើរការពាក់ព័ន្ធដោយប្រសិទ្ធភាព (កែសម្រួលសម្រាប់ដំណើរការទៅអនាគត សម្រាប់ចុះតាមមូលដ្ឋាន)<br>• ការតាមដានសមធម៌នីតិក្រមក្នុងទីតាំងតាមមូលដ្ឋាន(កែសម្រួល) |

១៥ ការរៀបចំវគ្គនេះសន្មត់ថា ការចុះមូលដ្ឋានគឺធ្វើឡើងដោយគ្មានគ្រូបង្គាត់ទៅជាមួយ ហើយសិក្ខាកាមត្រូវបានផ្តល់ឱ្យនូវក្របខ័ណ្ឌមួយដើម្បីរៀបចំដំណើរការ និងបង្ហាញលទ្ធផលរបស់ពួកគាត់មុនពេលចាប់ផ្តើមផ្នែកទី២នៃវគ្គ ។ គ្រូបង្គាត់អាចរកជួបបានសម្រាប់ការផ្តល់យោបល់លើការវិភាគលទ្ធផល នៅពេលរសៀលមុនពេលផ្នែកទី២នៃវគ្គចាប់ផ្តើម ។

# ឧបសម្ព័ន្ធ ២៖ ឯកសារយោង និងឯកសារ អំណានបន្ថែម

បន្ថែមលើឯកសារដែលបានយោងនៅក្នុងឯកសារបណ្តុះបណ្តាលនេះ តារាងខាងក្រោមរួមបញ្ចូលវេបសាយដែលមានប្រយោជន៍ និងឯកសារអំណាន ដែលអ្នកអាចធ្វើសេចក្តីយោងក្នុងនាមជាគ្រូបង្គាត់។ ឯកសារអំណាននេះត្រូវបានចាត់បញ្ចូលជាមេរៀនចំនួនបីក្រុម ដើម្បីងាយស្រួលសម្រាប់ជាជំនួយក្នុងការយោង។

| | ចំណងជើង/តំណភ្ជាប់ | អ្នកនិពន្ធ/ប្រភពឯកសារ និងតំណភ្ជាប់ក្នុងវេបសាយ | ចំណងជើង/តំណភ្ជាប់ |
|---|---|---|---|
| **មេរៀនក្នុងក្រុម ១៖ គោលការណ៍គ្រឹះនៃសមធម៌ និងការចូលរួមនៅក្នុងបរិបទព្រៃឈើ និងការប្រែប្រួលអាកាសធាតុ** | | | |
| ១ | A framework for defining equity: a policy brief | Marhajan, M, 2011. មាននៅក្នុង៖ <www.espa.ac.utk/files/espa/ Schreckenberg-poster.pdf> | ឯកសារអនុសាសន៍គោលនយោបាយនេះបានផ្អែកលើឯកសារដែលមានចំណងជើងថា Defining equity : a framework f or evaluating equity in the context of ecosystem services, McDermot t, M., Sango Mahanty, S. and Schreckenberg, K., 2011.ឯកសារអនុសាសន៍គោលនយោបាយដ៏មានប្រយោជន៍មួយដែលផ្តល់ទិដ្ឋភាពរួមនៃការពន្យល់ និងការគិតគូរ អំពីក្របខ័ណ្ឌសមធម៌ដែលប្រើប្រាស់នៅក្នុងឯកសារណែនាំនេះ។ |
| ២ | Equity issues in REDD+ | Peskett, L., Vickers, B. and Graham, K., 2011. មាននៅក្នុង៖ <theredddesk. org/sites/default/files/resources/.../ equity_issues_in_redd.pdf > | បទបង្ហាញមួយអំពីបញ្ហាសមធម៌ក្នុង REDD+ ដែលផ្អែកលើការវិភាគក្របខ័ណ្ឌ។ |
| ៣ | How does free, prior, informed consent impact social equity ? lessons from mining, forestry and their implications for REDD+ | Mahanty, S. and Dermott, M., 2013. មាននៅក្នុង៖ <http://www.sciencedi_ rect.com/science/ article/pii/S0264837713001294> | ឯកសារនេះពិនិត្យមើលតួនាទីនៃការឯកភាពមតិដោយគ្មានការបង្ខិតបង្ខំដោយបានទទួលព័ត៌មានជាមុន សម្រាប់ឥទ្ធិពលមកលើសមធម៌សង្គម និងភាពមិនច្បាស់លាស់ និងតម្លៃក្នុងកម្រិតកំណត់នៃវិធានបែបនេះក្នុងស្ថានភាពនានាដែលក្នុងនោះសិទ្ធិនៅពុំទាន់ចែងច្បាស់។ |

| | | | |
|---|---|---|---|
| ៤ | Introducing equity in REDD | REDD-Net Asia-Pacific bulletin #1, 2011. មាននៅក្នុង៖ <http://www.recoftc.org/site/resources/REDD-Net-Asia-Pacific-Bulletin-1-Introducing-Equity-in-REDD.php> | សេចក្ដីសង្ខេបដ៏មានប្រយោជន៍មួយអំពីក្របខ័ណ្ឌសមធម៌ ជាមួយឧទាហរណ៍អំពីទិដ្ឋភាពខុសៗគ្នា។ |
| ៥ | From research to action, leaf by leaf: Getting gender right in REDD+ social and environmental standards: Lessons from action research [books 1 & 2] | The Women's Environment and Development Organization and the REDD+ Social and Environmental Standards Secretariat, 2013. មាននៅក្នុង៖<http://www.wedo.org/library/wedo-launches-from-research-to-action-leaf-byleaf-getting-gender-right-in-redd-ses> | ទិដ្ឋភាពរួមនិងគោលការណ៍ណែនាំជាក់លាក់អំពី របៀបស្រង់យកទិដ្ឋភាពនានានៃយេនឌ័រនៅក្នុងកម្មវិធី REDD+ |
| ៦ | Is equitable REDD+ possible? The role of social safeguards, standards, and impact assessment in reducing risks and enhancing outcomes | Forest Trends, 2012. មាននៅក្នុង៖ <http://www.forest-trends.org/documents/files/doc_3232.pdf> | ទស្សនៈវិស័យដែលមានប្រយោជន៍មួយអំពីផលប៉ះពាល់នៃ REDD+ មកលើសមធម៌ និងបញ្ហាសង្គម និងការបង្ហាញពីមូលហេតុដែល REDD+ នឹងមិនសុទ្ធតែអាចដំណើរការបានល្អឡើយបើគ្មានការគិតគូរអំពីសមធម៌សង្គម |
| ៧ | The Nature of Sustainable Development, 2nd edition | Beder, S., Scribe, N., Vic., 1996. មាននៅក្នុង៖<http://www.uow.edu.au/~sharonb/STS300/equity/meaning/index.html> | |
| **មេរៀនក្នុងក្រុម ២៖ តួនាទី និងជំនាញរបស់អ្នកសម្របសម្រួលនៅថ្នាក់មូលដ្ឋានសម្រាប់លើកកម្ពស់សមធម៌នៅសហគមន៍មូលដ្ឋាន** | | | |
| ៨ | The world café: Shaping our futures through conversations that matter | Brown, J., with Isaacs, D. and The World Café Community, 2005. San Francisco, CA: Berrett - Koehler Publishers, Inc | ឯកសារយោងគួរឱ្យចាប់អារម្មណ៍មួយ អំពីវិធីសម្របសម្រួលសម្រាប់ការចូលរួមនៅក្នុងការសន្ទនាជាមួយសំណួរដែលមានអានុភាព។ |
| ៩ | The art of explanation: Making your ideas, products, andservices easier to understand | Lefever, L., 2013. Hoboken, NJ: John Wiley & Sons, Inc. | ទិដ្ឋភាពរួមនៃវិធីកែលម្អជំនាញពន្យល់ជាមួយឧបករណ៍ គន្លឹះ និងបច្ចេកទេសដែលអាចមានប្រយោជន៍នៅក្នុងការធ្វើឱ្យងាយស្រួលយល់នូវគោលគំនិតអំពីអាកាសធាតុ។ |

| | | | |
|---|---|---|---|
| ១០ | Gamestorming: A playbook for innovators, rulebreakers, and changemakers | Gray, D., Brown, S. and Macanufo, J., 2010. Sebastopol, CA: O'Reilly Media, Inc. | សៀវភៅដ៏ល្អមួយសម្រាប់បំផុសគំនិតថ្មីៗ និងវិធីនានាដើម្បីធ្វើឱ្យមានការចូលរួមតាមវិធីខុសៗគ្នា សម្រាប់ការបំបែកគំនិត ការយោគយល់គ្នា និងការប្រមូលផ្តុំគំនិត។ |
| ១១ | Resonate: Present visual stories that transform audiences | Duarte, N., 2010. Hoboken, NJ: John Wiley & Sons, Inc. | ការពន្យល់ច្បាស់លាស់មួយអំពីវិធីប្រើប្រាស់ និងនិទានរឿង នៅក្នុងបរិបទនៃបទបង្ហាញនានាដែលអាចកែសម្រួលសម្រាប់គ្រប់បរិបទ និងកែសម្រួលវិធីដែលអ្នកគិតនៅក្នុងការនិទានរឿង។ |
| ១២ | The sketchnote handbook: The illustrated guide to visual note taking | Rhode, M., 2013. San Francisco, CA: Peachpit Press. | សៀវភៅនេះអាចណែនាំអ្នកនៅក្នុងការអនុវត្តជំនាញបង្កើតរូបភាពងាយៗរបស់អ្នក និងបញ្ចុះបញ្ចូលអ្នកថាការបង្កើតរូបភាពគឺជាភាសាមួយដែលមនុស្សគ្រប់រូបអាចរៀនបាន។ |
| **មេរៀនក្នុងក្រុម ៣៖<br>ការរៀបចំ និងតាមដានដំណើរការនៃការពាក់ព័ន្ធនៅថ្នាក់មូលដ្ឋានឱ្យមានប្រសិទ្ធភាពដើម្បីលើកកម្ពស់សមធម៌** | | | |
| ១៣ | Change the way you see everything through asset-based thinking. | Cramer, K. and Wasiak, H., 2006. Philadelphia, PA: Running Press. | ទិដ្ឋភាពរួមមួយដែលមានប្រយោជន៍នៃតម្លៃក្នុងការគិតដែលផ្អែកលើសម្បត្តិ ដែលអ្នកអាចជំរុញតាមរយៈរចនាបថនៃដំណើរការរបស់អ្នក។ |
| ១៤ | The power of appreciative enquiry: A practical guide to positive change | Whitney, D. and Trosten-Bloom, A., 2010. 2nd ed. San Francisco, CA: Berrett-Koehler Publishers, Inc. | ផ្តល់ការពិនិត្យពិស្តារមួយអំពីមូលហេតុដែលការងារលើកសំណួរបែបលើកសរសើរ និងរបៀបដែលវិធីនេះអាចក្លាយជាវិធានបែបស្ថាបនា ដើម្បីប្រើប្រាស់ជាសរសរស្តម្ភសម្រាប់រចនាបថនៃដំណើរការដែលមានការចូលរួម។ |
| ១៥ | Appreciative enquiry for collaborative solutions: 21 strength-based workshops | Stratton-Berkessel, R., 2010. San Francisco, CA: Pfeiffer. | ផ្តល់គំនិតខ្លះៗអំពីគំរូនៃសិក្ខាសាលា និងដំណើរការនានាសម្រាប់ការពាក់ព័ន្ធ ដែលរួមបញ្ចូលគុណតម្លៃនៃការសួរបែបលើកសរសើរ។ |

| | | | |
|---|---|---|---|
| ១៦ | Power: a practical guide for facilitating social change | Hunjan,R. and Pettit,J., 2011 . | |
| ១៧ | The art of engagement: Bridging the gap between people and possibilities | Haudan, J., 2008. New York: Mc-Graw-Hill Professional Publishing. | |

THE CENTER FOR PEOPLE AND FORESTS

បេសកកម្មរបស់ RECOFTC គឺពង្រឹងសមត្ថភាពរបស់ប្រជាជនមូលដ្ឋាន ដើម្បីទទួលបានសិទ្ធិរឹងមាំលើកកម្ពស់អភិបាលកិច្ច និងការទទួលបានផលប្រយោជន៍ដោយសមធម៌ពីការគ្រប់គ្រង ប្រកបដោយនិរន្តរភាពនូវតំបន់ទេសភាពព្រៃឈើ នៅអាស៊ីប៉ាស៊ីហ្វិក។

RECOFTC មានតួនាទីសំខាន់នៅក្នុងវិស័យព្រៃឈើ។ RECOFTC ជាអង្គការអន្តរជាតិមិនស្វែងរកប្រាក់ចំណេញតែមួយគត់ដែល មានជំនាញក្នុងការអភិវឌ្ឍសមត្ថភាពសម្រាប់សហគមន៍ព្រៃឈើ។ RECOFTC ធ្វើការងាររបស់ខ្លួនតាមរយៈយុទ្ធសាស្ត្រភ្ជាប់បណ្ដាញការងារ និងការកសាងភាពជាដៃគូជាមួយស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន ប្រជាជនមូលដ្ឋាន និងគ្រឹះស្ថានអប់រំ និងស្រាវជ្រាវ នៅក្នុងតំបន់ អាស៊ីប៉ាស៊ីហ្វិក និងតំបន់ដទៃទៀត។ រយៈពេលជាង ២៥ឆ្នាំ នៃបទពិសោធន៍ថ្នាក់អន្តរជាតិរបស់ខ្លួន RECOFTC បានរួមចំណែកស្វែងរកដំណោះស្រាយនូវរាល់បញ្ហារវាងមនុស្ស និងព្រៃឈើ ប្រកបដោយមានប្រសិទ្ធភាព តាមរយៈការកសាងសមត្ថភាព ដោយរួមមានការសិក្សាស្រាវជ្រាវ និងការវិភាគ ការអនុវត្តសាកល្បងសហគមន៍ព្រៃឈើ និងតាមរយៈការបណ្ដុះបណ្ដាល។

RECOFTC—The Center for People and Forests
P.O. Box 1111 Kasetsart Post Office
Bangkok, Thailand 10903
Tel ( 66-2 ) 940-5700
Fax ( 66-2 ) 561-4880
info@recoftc.org

ISBN: 978-616-91154-7-2

Printed on recycled paper